ថ្ងៃនេះ ជាថ្ងៃសុទ្ធតែឫក្សល្អ ចាំនួនពេលវេលាក៏ជាមង្គលដ៏ប្រសើរពន់ពេកណាស់, ដែលក្នុងទីន្ទេះលោកគ្រូចៅអធិការ អ៊ិត-ហេង ជាសិស្សច្បងរបស់ព្រះសព, ទីន័លោកគ្រូចៅអធិការ ដូ-ប៊ុល វត្តខ្នងក្តាម (សៀមរាប) ជាតួនាទីមិសំណាប់នៃព្រះសពសុខ-ន្ធន ទីន័លោកគ្រូសូត្រស្តាំព្រះនាម ស្រ-សូរ ទីន័ឧកញ៉ាមេឃុំ អ្នកអ៊ុក-សម

ព្រមទាំងសូត្រ ជាតវិយា, អ្នកដំរង់ព្រំ-លឿន ទាំងកា យឿន, អ្នកដំរង់ច្រក-ជាត់ ទាំងដំរោម។ អ្នកដំរង់ដួងធុយ ទាំងកា គួន ទីឯអ្នកដង្ហើ ទួ-ស្ងៀ ទាំងពាក្យ ប៉ិន, ក្រមុំឃុំថាម់-ហ៊ុយ ទាំងសំឃ តំ, អ្នកដង្ហើ ផាប់-ធាយ ទាំងពាក្យ ប៉ិន, អ្នកដង្ហើ ង៉ាន់ ទាំងកា អ៊ិន, អ្នកដង្ហើ លុយ ទាំងកា ត័ម, អ្នកដង្ហើ សរ ទាំងកា ម៉ែ, អ្នកដង្ហើ ឃ៉ង ទាំងកា ហ៊ិ, អ្នកដង្ហើ ង៉ាំន ទាំងកា ទ៊ុត, អ្នកដង្ហើ ហេង ទាំងកា ម៉ី, អ្នកដង្ហើ ដួង ទាំងកា លី, អ្នកដង្ហើ ចាំត ទាំងកា ហែម ជាដើម ព្រមទាំងក្រុមសិស្សានុសិស្សតួច-ធំទៅកន្លែងជីជាត-ឆ្ងាយ មកច្រមុំគ្នាធ្វើបុណ្យនេះ ដោយមានថ្លៃធ្វើប្រវត្តិរឿងកំព្រៃសពសុខ-ខួនខ្ញុំ បន្តិចបន្តួចជាកិច្ចខាងដើម ចែកជូនដល់លោកអ្នកជាក្រុមសប្បុរសទាំងឡាយស្តាប់ជួបមានសេចក្តីតទៅនេះ

លោក-អ្នកក្រុមពុទ្ធបរិស័ទទាំងឡាយ! ព្រះគេជព្រះគុណព្រះសពសុខ-ខួននេះ មានាឈ្មោះថែម ចំការឈ្មោះសុខ លោកកើតថ្ងៃសុក្រ ទី២ពិសាខ ឆ្នាំចចញ្ចស័ក (ក្នុង ព.ស. ២៤១៩ ន.ស. ១៨៧៦) លុះអាយុ ១៨ ឆ្នាំ បានទៅវត្តសិក្សាគម្ពីរសោស្តែក្នុងសំណាក់លោកគ្រូវស់ អាយុ ២១ ឆ្នាំ បួសជាសាមណេរក្នុងសំណាក់លោកគ្រូវស់ អាយុ ២៤ ឆ្នាំ ទើបមកជាតិក្នុងកាវ៉ែកក្នុងសំណាក់លោកគ្រូវស់ អាយុ ២៤ ឆ្នាំ បួសបាន ៧ វស្សា បានធ្វើជាគ្រូសូត្រ ហើយលោកបានតស៊ូជំ

ធំ ១ ខ្នងកន្លះវត្ត សាងសាលាសំណាក់ ១ ខ្នងនៅភូមិបង្គោល លុះដល់មកគាល់ ៣១ ឆ្នាំ វស្សាចាន ៤ វស្សា បានឡើងជាចៅអធិការ ហើយលោងតសាងរឿនវិហាររៀបថ្ម ១ ជុំ សាងកុដិធំ ១ ខ្នង សាលាធម្មសំភាច់ធ្វើបុណ្យ ១ ខ្នង សាលាឆាន់ ១ ខ្នង សាលាសំភាច់ធ្វើចង្ហាន់ ១ ខ្នង សាងជង្គង់ចាត់ស៊ុមដ៏ត ១ ភ្លូ ទីធំបុណ្យជាច្រើន មានហែកមិន ៥ វត្តជាដើម ។

លុះដល់មកព្រះជន្ម ៧០ ឆ្នាំ វស្សាចាន ៤៨ វស្សា កំចាប់មានគាងជាយកេតជាង ពួកសិស្សានុសិស្សចាំងឡាយ ក៏ទំព្យាចាលពេញតំលាំង ពេលនោះក៏មិនជាសោះឡើយ លោងក៏ខួលអនិច្ចធម្មនៅនៅថ្ងៃសុក្រ ១០ កើត ខែមាឃ ឆ្នាំមមែ ឆស័ក (ព. ស. ២៤៨៤) ហើយពួកសិស្សានុសិស្សដំណល់សពទុក ១ ឆ្នាំ ទើបនាំគ្នាធ្វើបុណ្យ ឃាបនកិច្ចសពលោង ។

លុះដល់មកឆ្នាំជូតស័ក ព. ស. ២៤៩១ ត្រីនំ.លើខែកត្តិក ៦ កេច ថ្ងៃចន្ទ ពេលម៉ោង ៧ ព្រឹក ពួកសិស្សានុសិស្សនាំគ្នាធ្វើបុណ្យជាទន្លាកអស់ ៦ ថ្ងៃ ទើបលៅព្រះអដ្ឋិធាតុលោងបញ្ចុះក្នុងស្រុកក្នុងសាងថ្មាងតម្បូងព្រះវិហារវត្តនោះ ។

ដោយអំណាចពាក្យទិសទី្ឋ ដែលយើងខ្ញុំជាក្រុមសិស្សានុសិស្ស
តួច-ធំបានធ្វើនេះ សូមទទួលនូវគ្រប់ផលប្រគេនចំពោះដល់ដួងវិញ្ញាណក្ខន្ធ
ព្រះតេជព្រះគុណ ព្រះសង្ឃសុខ - ទុក្ខ ជាគ្រូចចង្ក្រាយដ៏ធំនៃយើងខ្ញុំ ។

សូមឲ្យលោកបានទទួលអនុមោទនាយកផលនេះ សោយសេចក្តី
សុខ សេចក្តីចំរើន តាមប្រាថ្នារបស់លោកចុះ ។

ហើយសូមលោកឲ្យសំពះសាធុការមកយើងខ្ញុំគ្រប់ៗ គ្នា ឲ្យបាន
ប្រកបដោយសម្បត្តិ ៣ ប្រការ គឺសម្បត្តិមនុស្ស ១ ទេពតា ១ និង
ព្រះនិព្វាន ១ ជាទីបំផុតជិតកុំបីឃ្លាតឡើយ ។

ប្លងនិងឥន្ទ្រីញ៉ាក - ថែម ប្រែរៀបរៀង

(ត)

លុះអំណើះពេលតមក - នាងលោះសេចក្តីត្រាស់ដឹងរបស់ព្រះអង្គ បានផ្សាយចេញទៅហើយ ហានេតគ្រាបទូលសួរព្រះពុទ្ធជាម្ចាស់អំពីរឿងពាន់នោះ នេតគ្រាបទូលសួរព្រះអង្គថា ព្រោះហេតុអ្វី បានជាព្រះនាងយសោធរ ទ្រង់សែ្នទៅនឹងមាស ហើយទ្រង់ព្រះដំណើរយ៉ាងយាសល្អមើលណាស់, ទើបព្រះអង្គដែលចក្រាត់ឡតែងនោះពេ ទ្រង់ឆ្លើយថា: «ក្រៅអំពីតថាគតគ្មាននរណាដឹងរឿងនេះទេ ចើទុនជាមានគេចេះដឹងខ្លះ ក៏មិនបានជាពេញលេញល្អទេ ក្នុងពេលដែលវដ្តនៃការលែកើតលែស្លាប់តំពុងនៅមាន រាល់តាំងឡាយនឹងតំនិតតាំងឡាយ នឹងជីវិតដែលនៅខ្លួនក៏ត្រឡប់កើតមានទៀនវិញទៀត ។ ឥឡូវនេះ តថាគតនៅលើតនឹកឃើញ ដល់បើគិតដេញទៀនក៏ត្រឡប់ដោយលាននោះដែរ នៅវេលាដែលតថាគតត្រូចង្អើតនៅក្នុងក្តុង ដ៏ដេរដោសដោយពែព្រឹក្សនៅដងក្តុងហិមាលយ" តថាគតជាសត្វភ្ញាមួយមានសេចក្តីស្រែងឃ្មាន សែ្នតមានឡាយឆ្នូតៗ ដេកនៅក្នុងតុម្ពស្សវាភ្លាំង យើងចាំគន់មើលដោយភ្នែកត្រឡែតមើលតែត្រឹមៗ ចំពោះហ្វូងសត្វដែលតំពុងត្រឹវស្មៅ ចូលមកជាន់ដែជិតខ្លើងៗ ជាន់មរណៈ ចំពោះសំណាក់របស់យើង ឬមួយនៅ

ត្រៃមាតាពន្ធរាំងឆ្ងាយ យើងដើរតែបន្តិចទៅក្នុងព្រៃដោយសេចក្តីស្រែកឃ្នានស្ងែនរនំភ្លារ ដោយស្រងាតាមក្លិនមនុស្សប្តីម ។ ទៅតណ្តាលព្រៃស្រែនស្រងាដែលជាលំនៅនៃពួកព្រៃឆ្ងាយ តារាណាះ ទៅក្នុងព្រៃញឹក ឬព្រៃរនាមដ៏ចំបូណាដោយប្រឡាយទឹក ជាជ្រោះដែលដ៏ងអូរ មានព្រៃឆ្ងាយ ។ មានបូបនោមធើតណាស់នោះក្នុងព្រៃជាហេតុឲ្យពួកព្រៃឆ្ងាយធ្វើចំបាំងនឹងគ្នា ស្បែកខាងព្រៃឆ្ងាយមានភណិមាសក្រឡាខ្លា ដូចជាស្បែតបម្រាដែលខាងយសោធរក្រែង ក្នុងកាលឥឡូវនេះដែរ, ការតស៊ូគ្នាក្នុងព្រៃនោះខ្លាំងក្លាណាស់ ឆ្នេញនឹងត្រូចអាជាអាវុធ ខណៈនោះ ខាងព្រៃឆ្ងាយបែរើតក្រសែកមើលមកយើង ដែលស្រែចស្រែបដោយសេចក្តីត្រាស ខាងបួសជាខ្មាន់ ។ ហើយនៅតិចជុត ខាងព្រៃឆ្ងាយនោះដើរបួលមកយ៉ាងអង់អាចតាត់មុខស្តេចព្រៃឯទៀត ។ សឹងមានតែស្មាមបួសស្រែចទូន ដែលយើងបានតស៊ូឲ្យបាជ័យទៅ ខាងព្រៃឆ្ងាយឃុតខាត់លិទ្ធយ៉ាងថ្លឹមៗ ចំពោះឆ្នើចំនីរបស់យើង រួចខាងតាមមកនៅរួមរស្មេហាជាមួយនឹងយើងក្នុងព្រៃនោះទៅ ។ រដ្ឋនៃការវិលកើតវិលស្លាប់ត្រឡប់ពីហានពុមមកតាន់ហានខ្ពស់ដូច្នេះឯង ។ ។

ហេតុដូច្នេះ ព្រះពុទ្ធកុមារីត្រូវបានទៅព្រះសិទ្ធត្ថកុមារដោយវេតនាសន្ទិសុទ្ធ ហើយនាគាលង្ការដោយឫទ្ធានដំណើរប្រពៃ (តិច្ចកុរាវេលាល្អ) បុណ្យអភិសេកសម្រេចក៏បានចាត់ធ្វើឡើង ឲ្យត្រឹមត្រូវតាម

ចំនៀមពួកសាកិយៈ អាស្រមនេះមាសគេបានរៀបគាំងហើយ ត្រកំបានគ្រាលរៀបចំហើយ គេបានព្យួរទង្វែងផ្កាអណ្តាហ៍ពិភាហ៍ គេបានបង្អាំបោះខ្លួរព្រះហស្តរបស់ក្សត្រាក្សត្រី ហើយគេបានកាច់ខំផ្តែមជាពីរកំណាត់ គេបានបាចសាចអង្ករ ខឹងខឹងអប់បណ្តែតសរសៃចំបើងពីរសរសៃលើខឹងដោះគ្រហមហើយអណ្តែតទៅជិតគ្នា ជាប្រផ្នូលល្អសម្រាប់ឃើញសេចក្តីស្នេហា ថាខំងមានរហូតដល់ទៅស្លាប់ រួចក្សត្រាក្សត្រីស្ថាមីភរិយាគាំងគូនាំគ្នាដើរប្រទក្សិណ ៧ ជំហាន ជុំវិញព្រះភ្លើង ៣ ជុំ (តាមច្បាប់រៀបការរបស់ព្រាហ្មណ៍) គ្រឿងទេយ្យទាន ក៏ចាត់ចែងប្រគេនដល់ពួកអ្នកបួសនិងពួកសូម្ប គ្រឿងសំណែនផ្សេងៗ គេក៏បានឱាយទាយទៅបូជាតាមព្រះវិហារគាំងខ្លាយ នៅទីបំផុត គេបានធ្វើពិធីសូត្រមន្ត រួចគេបង្គំព្រះពុទ្ធរបស់ក្សត្រាក្សត្រីជាមួយគ្នា ។ កាលណោះព្រះវរពុទ្ធបិតារបស់ព្រះពុទ្ធកុមារមានព្រះឧទ្ធារថា « ព្រះពុទ្ធកុមារ ដ៏ប្រសើរ! បុត្រនេះពីដើមមកជារបស់យើង តាំងពីឥឡូវទៅ ត្រូវបានជារបស់អ្នកតែម្នាក់ឯង សុំឱ្យអ្នកមានមេត្តាដល់កុមារ ដែលបានផ្ញើជីវិតខ្លួនទៅនឹងអ្នក » ។ តទំពីនោះ គេបានដើរហែព្រះនាងយសោធរ ដ៏ឆើតឆោមទៅតំណាក់ព្រះស្វាមី ព្រមទាំងភ្ញៀវភ្ញាក់ក្សត្រាន្តិ្ត គេបានប្រគល់ព្រះនាងដល់ព្រះហស្តព្រះសិទ្ធត្ថពុទ្ធកុមារ ហើយគូស្នេហាទាំងពីរអង្គមានតែសេចក្តីស្នេហាទៅវិញទៅមកយ៉ាងវៃក្រៃលែងតទៅ » ។

ប៉ុន្តែសម្តេចព្រះវេរៈតាមនាទ់សព្វព្រះទ័យ តែមានសេចក្តី
ស្នេហាប៉ុណ្ណោះទេ ទ្រង់ចាន់ឲ្យជាដ៏តសាងកំណើយ៉ាងធើនតួរឲ្យចាប់ចិត្ត
ស្នេហាថែមទៀត មិនមានអ្នកប្រៀបផ្ទឹមចាន់លើតាសុជា ជាកំណសព្រាប់
ជាទីក្សេមក្សាន្តព្រះទ័យនៃព្រះពជកុមារ ; នៅជុំវិញកំណត្រង់តណ្តាលទី
លានដ៏ធំទូលាយនោះ មានកុំពុងទៀវស្រែងាត់ ដែលជាកំណោលស្ទឹង
ពេជាទី ខាងក្នុងទីចង្អាក់ចុះមកតំណើងកុំហិមាលយ៉ា ដើម្បីនាំទឹកចង្អរ
ចូលទៅកន្លែងខ្ទេតង្គា ធ្វើឲ្យទេតង្គាមានលេចធំ ៗ ឡើង ។ នៅទិស
ខាងត្បូង មានព្រៃអំពិលទំនិះព្រៃកំងកុំ ដ៏ដេរជាសទៅដោយផ្កាមាន
ពណ៌ស្រែអាប់ចិចចាំងព្រះពជកំង តែតែងមានសូរសំឡេងខ្យល់ដែលបក់
មកត្អូសូរតែកេះដូចសូរឃ្លើងសាន្តក្នុងស៊ុំទ្រូមតូមឈើ , នៅទិសខាងជើង
មានកំពូលកុំធំ ៗ ច្រកច្រាងសំបុរសក្សុះ ក្នុងត្រូមកុំហិមាលយ៉ា ហាក់
ដូចជាគេលើកដីតទៅកុកពន្ធន្លាងដល់ផ្ទៃមេឃ គួរឲ្យអស្ចារ្យ ហើយ
ចក្រវាឡនេះត្រដែងត្រដឹមដោយកំពូល ទឹងជុំសិលាស្រួច ៗ ចួនមូល
ចួនសំប៉ែត ចួនចោតសន្ធឹម ចួនជាដុំខ្ចីតកច្រកច្រាង ចួនជាជ្រោះ
ជ្រៃ ហើយមានទឹកឈូរហូរបុះទៅក៏មាន ធ្វើឲ្យកើតតំនិតន្តដ៏ខ្ពស់
ឡើងត្រដែង ដល់ទៅផ្ទៃមេឃ ហាក់ដូចជាបានសន្ធនាការជាមួយនឹង
ពួកទេព្តា ។ នៅតាមដងព្រៃតាមហិមៈនោះ ដេរជាសទៅដោយព្រៃ
ព្រឹក្សាលំតាវល្លិ ដែលបន្លែឲ្យស្ទើក្តីរម្ងែដោយទឹកឈូរ ហើយបិទចាំង

ស្រែចំណេះដោយទឹកពពក, ភា រែក្រែមបុះមកខៀន មានតុម្ពដើមស្រល់ក្តុំធំ ៗ ផ្សេង ៗ ដាលំនៅនៃខ្លារខិន ចៀមវៃព្រៃ ហើយលាន់ឮសូរសត្វខ្លែងយំរន់ ក្នុងវៃព្រៃ, បុះក្រែមបងខៀត ជាទំព័លស្មៅមានពណ៌ថ្លៃក ៗ ដូចដាព្រៃ ដែលគេក្រាលនៅដើរគាសនះព្រះ សម្រាប់តង្គីយសូត្រធម៌ថ្វាយបង្គំ ព្រះ ។ នៅចំពីខាងមុខ ពួកជាងវិស្វកម៌ាំស្នាសាន់ក្រាសាទ ឲ យ៉ាងធើត លើដីខ្ពស់ ប្លុះគេសង់ថ្ពក្ប មានកំពែងសសរព័ទ្ធជុំវិញ, មានរូប ចម្លាក់ជារឿងពីរពីត្រែងនាយ ដូចជារូបរនេះគ្រឹស្ណៈ រូបទេពអប្សរ នាងសីតា ហាណុមាន នាងព្រៃថបទី ហើយនៅលើស៊ុមក្លោងទ្វារគេ ឆ្លាក់រូបព្រះគនេស ទ្រង់វែលទឹងកង្វែរ ដើម្បីសំដែងសេចក្តីចេះដឹង ទឹងសេចក្តីចំរើន អង្គុយមួរប្រមោយ ។ ឈរចើរើរទៅតាមផ្លូវចត់ចែន នៃសួនឧទ្យានទឹងទីក្លា ចូលទៅដល់ទ្វារមានក្នងជាទ្វារថ្មកែវសក្រឡា ផ្កាកុលាប ហោជាងធ្វើពីឈើខ្ទឹមចំនួន ឯរណីទ្វារធ្វើពីថ្មកែវស្រែមោល ហើយទ្វារខ្ទឹមចំនួនមានសង្ខឹកទ្វារប្រដាប់ដោយគំនូរផ្សេង ។ ដើរលេងសួរ ឲ្យសប្បាយចិត្តក្នុងមន្ទប់ល្ងែងផ្សេង ។ យ៉ាងល្អធើត ទឹងចន្ទប់មានម្ចប់ ឆឹងឆឹង កាលខ្ញើងជណ្តើរយ៉ាងល្អទៅ ហើយដើរតាត់រចៀងជាថ្នាក់ ទៅ ទើបមើលឃើញល្ងែងចន្ទប់ផ្សេង ។ ដែលមានពណ៌លាចថ្នាំ ហើយ សសរដាពួក ។ មានទឹកឈូរផ្កាឈូកវៀងជុំគ្នា ទឹងក្រចាប់ដែលផុះ ផុតពីទឹកឡើងមក មានមច្ចជាតិតូចធ្វេចស្បូនា ទៅក្នុងគាងនៃទេចវែល

មានសំបុរមាសសំបុរឥឡៅ មានក្តីគេហៈឧណ្ហាលាស់ លាងក្តាន់ក្តែងធំ
តែបង្កាកុលាបដែលមានកូនតែអូប ហ្វូងបក្សីសំបុរផ្លូវជួប ហើរវេចនា
កណ្តាលដើមត្នោត បក្សីព្រាបសំបុរឥឡៅ សំបុរត្រែវេះ ធ្វើសំបុកខៅ
លើកក្បាលសសរពណ៌មាសនៅលើវែងសិលាថ្មដ៏ធ្ងន់ស្រមោល មាន
ហ្វូងបក្សីក្អែងរំកាយមានខ្មុយយ៉ាងល្អ ឯបក្សីត្រសាសំបុរសដូចទឹកដោះ
ទឹងទីខុយតូច។ ក៏រមិលមើលបក្សីក្អែងជាប្អូនអាយុស្ទាប់ស្ទឹម បក្សី
សេកត្រហាមក៏លោតផ្លោះចោះស៊ីផ្លែឈើតាផ្លែ១ ទៅផ្លែ១ បក្សីច្រៀងហើរ
ទៅចំលើផ្កា១ ទៅផ្កា ១ ភ្លូងជីងចក់តុកកែពួនសំងំរតក់ខ្លាចត្រយបារម្ភ
សត្វកំប្រុកនាំគ្នាចុះមកស៊ីគោជនាហារនៅទឹងដែង ពីព្រោះត្រចង់តិចចង់
មានតែសេចក្តីសប្បាយក្សេមក្សាន្ត ឯពស់ខ្មៅជាប្រផ្នូលស្មុគមង្គលសម្រាប់
តែកូល ក៏ដេកកំរើលជាប្អូននៅកណ្តាលថ្ងៃខាងក្រោមផ្កាចន្ទន៍ ក្បែរខាង
ទីខោះ មានពួកពានរធ្លើឫកពាឡកឡៅកហ្ងឹងក្អែក ។ ហើយនៅ
តំណាក់ជាទីស្នេហាតាំងមូល ពេញទៅដោយពួកបក្សីដែលស្មោះត្រង់
គ្នាន់តែឲ្យសញ្ញាបន្តិច កំមានពួកមនុស្សមុខមាត់ស្រស់បស់តែមន
ខ្លួលបម្រើយ៉ាងរួសរាន់ តាំងនិយាយសំដីពាក្យ អ្នកបម្រើម្នាក់ ។ សឹង
នាំគ្នាបង់ធ្វើឲ្យកើតសប្បាយកែកឃ តាំងចិត្តស្តាប់បង្គាប់ដោយសេចក្តី
គោរព ដើម្បីនាំជីវិតហ្ងឹងទៅកសេចក្តីក្សេមក្សាន្ត ដូចជាខន្ធក្តាមាន

ក្នុងដីពាំដោរជាន់ខ្ពស់ ហើយព្រះនាងយសោធរា ជាព្រះពន្ធុនាថ្លៃឲ្យកាន់សំណាត់នេះ ប្រកបដោយសេចក្តីគ្រែកគ្រកាលយ៉ាងវែលែង ។

ប៉ុន្តែគ្រែកំពីលើងបន្ទប់ពប់រយដ៏ផ្ទុតផ្ទង់ នៅមានបន្ទប់សំងាត់ ១ ទៀត ដែលប្រកបដោយរចនាយ៉ាងវិចិត្រប្រណិត ដើម្បីជាទីសម្រាកអធ្យាស្រ័យ កាលនឹងដើរចូលទៅកាន់បន្ទប់នេះ គោងដើរកាត់ទីលានសំងាត់ដែលនៅខាងក្នុងប្រាសាទនោះឯង តែជាទីលានស្មៅ ត្រង់កណ្តាលធ្វើជាថ្នែរសំបុះស្អាតដូចខ្នើងដោះ មានជណ្តើរឡើងទៅលើជាថ្មីមថ្ម មានបង្អាន់ដៃទាន់រចនាជាក្បាច់ក្បូរប្រដាប់ប្រដាដោយថ្មកែវពណិផ្សេងៗ យ៉ាងល្អ គួរឲ្យសប្បាយអ្វីម្ល៉េះ កាលបើបានឈប់សម្រាកពាល់អស់ចិត្តក្នុងពាដស្ថានោះ ហាក់ដូចបានដើរលើទឹកនកក្នុងរដូវក្តៅ ស្មើនៃសុរិយោដ្ឋះពន្លឺច្រាលផ្លេ ចូលទៅតាមទ្វារនឹងបន្ទោះពន្លឺស្រទន់ៗ មានពណ៌ស្ដួចជាប្រាក់ សន្សឹមៗបាត់ពន្លឺទៅជាស្រអាប់ ហាក់ដូចពន្លឺថ្ងៃបានឈប់លែងវែប្រែប្រួលភ្លាមទៅជាពន្លឺស្នេហាទៅវិញ ព្រោះខាងក្នុងទ្វារនេះ មានបន្ទប់ធំស្រឡះ ល្អត្រគាលវិសេសជាងទីដទៃ ។ មានពន្លឺបង្គឿង នោមព្រឹមៗក្នុងត្រអូប ឆ្លុះពន្លឺទៅតាមបង្អួចត្បូងមុក្តា ហើយព្រះសន្ធិយាភ្លាកយភ្លាយចរាប់តាស ព្រះរៃនបន្ទំសុទ្ធតែទន់ឆ្ងាស ផ្ទៃតផ្ទង់ថ្លៃថ្នូ ដែលនឹងបើតបិទបានតែស្ទើរណាដែលមានរូបនោមឆើតប៉ុណ្ណោះទៅមុខទៀតនោះ ឥតមានអ្នកណាមួយសាចដឹងបានថា ជាវេលាយប់

ថ្ងៃសៅរ៍ ត្រែះថ្ងៃខ័ណ្ឌ ជាមានពន្ធឹកភ្លៀងធ្លាតជាខ្លះ ស៊ីន
ក្តីបញ្ជាស់ជាធំរៀលថ្ងៃអាទិត្យទៅមុខ តែសែងពន្ធឹ តែកាលជាធំពន្ធឹមាស
នៃអាទិត្យ ទ្រង់យ. ឲ្យលំបាកមកពីកើយរហើយសប្បាយជាធំរៀលព្រឹក
តែត្រជាក់ជាងក្នុងយោមយប់ សំឡេងពិណបន្ទេរលានឮឡើងពាំងយប់
ពាំងថ្ងៃ. តោជនាហារដ៏មានទុជារសរមែងមានមកជាខ្លះ មិនថាយប់
មិនថាថ្ងៃ ពាំងឆ្កែឈើស្រស់ដោយឆ្កែកសន្សើម ត្រឿងផឹកផ្សំដោយ
ហឹម:នៃភ្នំហិមាលយ៉ា មេឃដ៏មានទុជារស ហើយជាក់ឆ្កែកុំក្នុងកាជន:
ដែលធ្វើពីកូតដំរី ពាំងយប់ពាំងថ្ងៃ សឹងមានឱជារថ្កុំដែលបានរើស
សម្រាំង ចាក់ថ្នាយពាំងយប់ពាំងថ្ងៃជាខ្លះ ព្រមពាំងសូរតន្ត្រី, លួងលោម
ប្រទេាមឲ្យកើតសេចក្តីស្នេហា ជារឿងជាស់ព្រះទ័យព្រះសិទ្ធត្ថកាជ-
កុមារឲ្យភ្លាក់រលឹកពីតារម្មណ៍សន្តិសុខ ហើយដឹកនាំព្រះវិញ្ញាណឲ្យភ្ជាប់
ទៅនៅក្នុងកាមស្នេហាទៀនវិញ ដោយតន្ត្រីដែលឮល្វែងល្វើយ នៅ
កណ្តាលប្តូច្ចា ឬដោយសូរសៀងចំរៀងដែលគួរឲ្យកើតឈមតណ្ហា
ហើយតារាំរែកជាខ្លាតម្រែត ធ្វើតាមបង្ហាក់ ព្រមពាំងតន្ត្រីតាំងនឹងកូន
ចន្ទ្រដ៏ចតរនៅតដើងនាងរថ្កុំ ចូតពាក់ធ្លៀវដៃ-ដើង ខ្ទិងសូរសៀភ្លូសំឡេង
ពិណវៃឬក្រែកុំ ឯប្រែងឈ្មស់ខ្ទឹងបម្រាក់ខ្ទឹងវៃឬតពណ៌ាវៀវដុតអប់
តែឲ្យប៉ក់ក្លិនផ្សាយពាំដោះខ្លួនខ្លាយទៅ ពាំឲ្យវិញ្ញាណរបស់ព្រះអង្គក្លើន

ហើយអាញ្ជើញស្តេចឲ្យផ្ទំលើព្រះហត្ថព្រះនាងយសោធរា ព្រះសង្ឃ-
ពជកុមារខ្ញុំសម្តែងព្រះឥរិយាបថដូច្នេះ តែងខ្ញុំភ្ញាក់ឡើងមិ្ញ ទាំង
អស់ ក្នុងលោកនេះ ។

មួយវិញទៀត ព្រះមហាសត្វក៏ខ្ញុំបញ្ជាក់ថា នៅភាគក្នុងកំពែង
ព្រះពជវាំងនោះ មិនឲ្យអ្នកណាមួយនិយាយពាក្យស្ងាប់ឲ្យសោះ ព្រម
ទាំងចាស់ជរា, សេចក្តីទុក្ខសោកសេចក្តីថប្បង្គិតចិត្តឬឈឺចាប់, ក្នុងព្រះ
ពជស្ថាននោះ បើមានឧបាសិកាណាមួយឈឺឬយំតបុះ កំពូលវាំងមិនអាច
លោតកំចាត់ទេ ឧបាសិកាណាមានអាការដូច្នេះ ចើទុកជាឥតទោសភ័យខ្លាំសោះ
ក៏ត្រូវតែចរណ្តៅញ៉ឲ្យឆាយចេញអំពីព្រះពជវាំងហានស្ងួតនោះដែរ ដោយ
ខ្ញុំវែកឆែងលែងខ្លាចព្រះពជកុមារ ខ្ញុំខ្ចងដល់សេចក្តីទុក្ខក្រៃក្រ
ឋេរបស់ឧបាសិកានោះ។ ហើយមានពួកញាតិវង្សចាំតាកក្បាលោសយ៉ាងមុឺងម៉ាត់
ចំពោះអ្នកដែលនិយាយអំពីទុក្ខសោកក្នុងលោកនេះ ដែលពេញទៅ
ដោយលំបាកវេទនា យ៉ាងសោកសង្រែងសង្រៃសេចក្តីភិតភ័យជាដើម
ច្រើនបើមានសត់ស (ស្លាប់) តែ ១ សារសៃទៅលើក្នុងសត់ឋេរបស់ឧបាសិកា
ឬឧបាសិកាស្លេខណា ត្រូវកាយញ្ជឹងក្នុងជម្ងឺមានទោសក្បត់ចោទដល់វេលា
ព្រឹកព្រហាម ផ្តាកុលាឋដែលរៀរកេរហើយ ត្រូវរើសច្រមូលយក
ទៅចោលឲ្យឆ្ងាស់ ស្ទឹងឈើឆាប់កំត្រូវបោះបង់ឲ្យឆ្ងាស់មិនឲ្យមានខ្ញុំ បណ្តា
រូបតំណូរដែលធ្វើឲ្យកើតមុខក្តួយ ត្រូវយកចេញឲ្យឆ្ងាស់ពីព្រះពជស្ថាន

នេះ ព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់គាស់ថា «ប្រសិនបើគេ (ព្រះពុទ្ធនេះ) តាំងនៅក្នុងបឋមវ័យ ឃ្លាតឆ្ងាយអំពីបុស្តវៃលដឹកនាំឲ្យកើតសេចក្តីសង្វេគ មិនចំរើនឲ្យឆាប់ក្នុងញាណគតិវៃលមិនខាន់ច្បាស់ដូច្នោះហើយ ស្រមោលនៃដង្កូតជ័យ គឺព្រះពោធិញ្ញាណក៏មិនទន់ខ្យាយចុះទៅហើយយើងនឹងបានឃើញគេជាពៅហ្មាយជាមានអាទុកាពជាក្រៃលែងគ្រប់គ្រងនូវគ្រួគ្រាទៅគ្រប់ៗ ប្រទេស (បក្រពន្ធពុទ្ធ) ប្រសិនបើគេត្រូវការ ហើយគេនឹងជាម្ចាស់នៃក្សត្រចាំនឹងឡាយ វៃលជាកិត្តិយសដ៏ធំធ្ងន់ក្នុងរជ្ជសម័យរបស់គេ» ។

ហេតុនេះ នៅជុំវិញនៃតំណាក់ស្នេហាដ៏ល្អវិចិត្រ វៃលមានសុទ្ធតែកន្ត្រកណ្ហាជាគ្រឿងយុទ្ធាវុធ ទឹងសារក្សេមក្សាន្តជាប់រឹងការពារ ប៉ុន្តែឆ្ងាយពីការវៃលគេបានឃើញនោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ចាត់ឲ្យសាងកំពែងយ៉ាងគ្រាស់ មានទ្វារស៊ាំរឹង្គ មានសន្ទឹងទ្វារពីរ ក្នុងភូវនៈមួយៗ ត្រូវប្រើមនុស្សក្រាប់រយនាក់សម្រាប់ចេក ហើយខណៈវៃលចេក មានឮស្នូរសំឡេងគងរំពងទៅឆ្ងាយ ប្រមាណកន្លះយោជន៍ ទាំងគ្រាយទ្វារនេះក៏មានទ្វារទើរទើបចន្លាប់ៗ គ្នាទៅទៀត គឺថាកាលដើនីងចេញពីព្រះបរមស្ថានដ៏សុខសម្រាន្តនោះទៅ ត្រូវដើរលងទ្វារចាំង ៣ នោះមកជាមុន ទើបចេញទៅរួច ជាទ្វារដ៏ធំសំបើមមហិមាជាក់ស្តែង (មានត)

ឃុនណារីមេធីស្រី - អ្នកប្រមាំដុំព្រះត្រៃបិដក

ក្បៀតក្បៀរ (ឆន្ទៈ - ចប់)

មានសាវកសន្និបាត ៤ លើក គឺ ១ មានព្រះខីណាស្រព ១០០ កោដិ ទី២ មានព្រះខីណាស្រព ៩០ កោដិ ទី ៣ មានព្រះខីណាស្រព ៨០ កោដិ ព្រះជន្មាយុ ១ សែនឆ្នាំទើបបរិនិព្វាន ។

សម័យនោះ ព្រះលោកនាំគ្នាបបួលយើងខ្ញុំកើតជាតាបសឈោះមន្តស មានតេជៈដ៏ខ្លាំងក្លា ប្រកបដោយឥតកិញ្ចាតាល បានឃើញផ្លែព្រីងថ្វាយព្រះពុទ្ធព្រះនាមសិទ្ធត្ថព្រះអង្គនាយថា តាបសទេវធីបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

ពាក្យ - ព្រះពុទ្ធតិស្សៈ

ព្រះមាតានាមព្រះនាងមហាមា ព្រះបិតាជាក្សត្រិយ៍ព្រះនាមជនសន្ធ អគ្គមហេសីនាមព្រះនាងសុភទ្ទា ព្រះពោធិព្រឹក្សព្រះនាមអានន្ទ ភូមិនគរឈ្មោះរេមកៈ ព្រះជន្មាយុ ៧ សែនឆ្នាំ ទើបចេញបព្វជ្ជាដោយសេះ ធ្វើទុក្ករកិរិយាតែ ៦ ខែ ដើម្បីងាយនាំព្រឹក្ស អគ្គសាវក ២ រូប គឺត្រាហ្មខេៈ ១ ឧទយៈ ១ ឧបដ្ឋាក ១ រូប ឈ្មោះសមនៈ អគ្គសាវិកា ២ រូប គឺ ផុស្សា ១ សុខុត្តា ១ មានសាវកសន្និបាត ៣ លើក គឺ ១ មានព្រះ

ទីណាស្រេច ១ សែនអង្គ ទី ២ មានព្រះទីណាស្រេច ៨០ សែនអង្គ ទី ៣ មានព្រះទីណាស្រេច ៨០ សែនអង្គ ព្រះជន្មាយុ ១ សែនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះមហាមុនីវេស្សន្តរយើង ទ្រង់កើតជាស្ដេចព្រះនាម សុជាត ។ ឃានលះបង់គោតសម្បីដ៏ច្រើន ហើយទៅបួសជាឥសី ៧ឆ្នាំ លុះវែលទ្រង់ព្រះផ្នួសហើយ ឃានឮថា ព្រះពុទ្ធព្រះនាមតិស្សត្រាស់ទ្បើងក្នុងលោក ក៏ត្រេកអរឥតឧបមា ឃានយកផ្កាមន្ទារពីព្រឹក្ស ផ្កាឈូនទឹងផ្កាចាប៉ែតព្រឹក្សជាទិព្យបន់ថ្វាយ ហើយឈរចាំងផ្កាពីខាងលើ ព្រះពុទ្ធតិស្សទ្រង់ទាយថា ឥសីនេះ នឹងឃានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

១៨-. ព្រះពុទ្ធបុស្ស

ព្រះមាតានាមព្រះនាងសិរិមា ព្រះបិតាជាក្សត្រព្រះនាមជយសេន អគ្គមហេសីនាមព្រះនាងឥសាគោតមី ព្រះពុទ្ធបុត្រព្រះនាមអានន្ទ ក្នុងកាសិនគរ ព្រះជន្មាយុ ៩ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយយានដំរី ធ្វើទុក្ករកិរិយា ៧ ថ្ងៃ ដើមពន្លឺតត្រៃជាគោធិព្រឹក្ស អគ្គសាវក ២ រូប គឺ សុក្កិត្ត ឧបសេន ១ ឧបដ្ឋាក ១ រូប ឈ្មោះសកិយ្យ អគ្គសាវិកា ២ រូប គឺចាលា ១ ឧបចាលា ១ មានសាវកសន្និបាត ៣ លើក ទី ១ មានព្រះទីណាស្រេច ៦០ សែនអង្គ ទី ២ មានព្រះទីណាស្រេច ៥០ សែនអង្គ

ទី ៣ មានព្រះវិណាស្រេច ៤០ សែនអង្គុ ព្រះជន្មាយុ ៩ ហ្មឺនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះអរហំសម្ពុទ្ធវេស់យើង ទ្រង់កើតជាក្សត្រិយ៍ព្រះនាមវិជិត ទ្រង់លះពជ្យាចោល ហើយចេញទៅទ្រង់ព្រះផ្នួសក្នុងសំណាក់ព្រះពុទ្ធបុស្សនោះ ព្រះអង្គភាយមាំ តិកុនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

១៩ – ព្រះពុទ្ធវិបស្សី

ព្រះមាតានាមព្រះនាងពន្ធុមតី ព្រះបិតាជាក្សត្រិយ៍ព្រះនាមពន្ធុមអគ្គរាជវេស៍ នាមព្រះនាងសុទស្សនា ព្រះរោជបុត្រព្រះនាមសមវដ្តក្ខន្ធកុនគេះពន្ធុមតី ព្រះជន្មាយុ ៨ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយយានរថផ្ចើទុក្ខកេរិយា ៨ ខែ ដើមព្រឹក្សត្រាស់ជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺ ខន្ធ ១ តិស្សនាម ១ ឧបដ្ឋាក ១ រូប ឈ្មោះអសោក អគ្គសាវិកា ២ រូប គឺ បន្ទូ ១ បន្ទូមិត្តា ១ មានសាវកសន្និបាត ៣ លើក ទី ១ មានព្រះវិណាស្រេច ៦៨ សែនអង្គុ ទី ២ មានភិក្ខុ ១ សែនអង្គុ ទី ៣ មានភិក្ខុ ៨ ហ្មឺនអង្គុ ព្រះជន្មាយុ ៨ ហ្មឺនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះលោកនាថវេស់យើងទ្រង់កើតជាស្តេចនាគឈ្មោះអតុល មានរិទ្ធិច្រើនមានបុណ្យវុឌ្ឍិរឿង មានឱនាគបរិវារច្រើនសែនចូលទៅគាល់ព្រះពុទ្ធវិបស្សី ហើយប្រគំដោយតូរ្យដន្ត្រីទិព្វថ្វាយ

ហើយប្រគេនតាំងមាសដល់ព្រះពុទ្ធអគ្គនោះ ព្រះអគ្គទ្រទំនាយថា ស្តេចនាគនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

๒๐ – ព្រះពុទ្ធសិខី

ព្រះមាតានាមព្រះនាងបភាវតី ព្រះបិតាជាក្សត្រព្រះនាមអរុណ អគ្គមហេសីនាមព្រះនាងសព្វកាមា ព្រះរាជបុត្រព្រះនាមអតុល ក្នុងទសអរុណវតី ព្រះជន្មាយុ ៧ ពាន់ឆ្នាំ ទើបទេវភូតាភាវ ដោយយានដ៏ឆ្មើងក្តកវិយោ ៨ វេ ដើមស្វាយសម្លាកោងដ៏ព្រឹក្ស អគ្គសាវក ២ រូប គឺ អភិភូ ๑ សម្ភវៈ ๑ ឧបដ្ឋាក ๑ រូបឈ្មោះខេមង្ករ អគ្គសាវិកា ๒ រូប គឺ មនិលា ๑ បទុមា ๑ មានសាវកសន្និបាត ๓ លើក គឺ ๑ មានកោដិឆ្នាំ ទ្វាទសស្រព ๑សែនអគ្គ ទី ๒ មានកោដិ ๘ ហ្មឺនអគ្គ ទី ๓ មានកោដិ ๗ ហ្មឺនអគ្គ ព្រះជន្មាយុប្រមាណ ๗ ហ្មឺនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះជិនស្រីរបស់យើងទ្រង់កើតជាស្តេចព្រះនាមអរិន្ទមៈ បានប្រគេនបង្អាន់ដល់សង្ឃមានព្រះពុទ្ធជាប្រធាន ហើយតាក់តែងយានដ៏វិចិត្រប្រគេនដល់ព្រះសម្ពុទ្ធព្រះនាមសិខី ព្រះអគ្គទាយកថា ព្រះជាអគ្គនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

๒๑ – ព្រះពុទ្ធវេស្សភូ

ព្រះមាតានាមព្រះនាងយសវតី ព្រះបិតាជាក្សត្រព្រះនាមសុប្បតិតៈ អគ្គមហេសីនាមព្រះនាងសុចិត្តា ព្រះរាជបុត្រព្រះនាមសុប្បពុទ្ធ

ក្នុងនគរឈ្មោះអនោមៈ ព្រះជន្មាយុ ៦ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយ
ព្រះសង្វាគា ធ្វើទុក្ករកិរិយា ៦ វស្សា ដើមពោធិព្រឹក្ស នគ្គសាវក ២
រូប គឺ សោណៈ ១ ឧត្តរៈ ១ ឧបដ្ឋាក ១ រូប ឈ្មោះឧបសន្តៈ អគ្គសាវិកា
២ រូប គឺ ភគា ១ សមាលា ១ មានសាវកសន្និបាត ៣ លើក គឺ ១
មានព្រះខីណាស្រព ៨០ ពាន់ដងដំ គឺ ២ មានភិក្ខុ ៧០ ពាន់រូប គឺ
៣ មានភិក្ខុ ៦០ ពាន់រូប ព្រះជន្មាយុប្រមាណ ៦០ ពាន់ឆ្នាំ ទើប
បរិនិព្វាន ។

សម័យនោះ ព្រះសុគតរបស់យើងខ្ញុំតែងសោយព្រះនាម
សុទស្សនៈ ជានិច្ចគ្រប់ទីឆ្ងាយសំពត់ដល់ព្រះសង្ឃមានព្រះពុទ្ធជា
ប្រធាន ហើយបួសក្នុងសំណាក់ព្រះជិនស្រីអង្គនោះ ព្រះពុទ្ធវេស្ស-
ភូទ្រង់ទាយថា ស្តេចនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតសាសនា
មិនខាន ។

២២— ព្រះពុទ្ធកកុសន្ធៈ

មាតាឈ្មោះនាងវិសាខា បិតាឈ្មោះអគ្គិទត្តព្រាហ្មណ៍ ភរិយា
ឈ្មោះនាងកេចិនី បុត្រឈ្មោះឧត្តរ ក្នុងនគរឈ្មោះខេមវតី ព្រះជន្មាយុ
៤ ពាន់ឆ្នាំ ទើបចេញបព្វជ្ជាដោយយានរថ ធ្វើទុក្ករកិរិយា ៨ វស្សា ដើម
ទ្រែសជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺវិធុរៈ ១ សញ្ជីវនាម ១ ឧបដ្ឋាក
១ រូប ឈ្មោះពុទ្ធិជ អគ្គសាវិកា ២ រូប គឺសាមា ១ ឧត្តរានាមា ១ មាន

សាវ័កសន្និបាតតែ ១ លើក មានព្រះទីឃាស្រែ ៤០ ពាន់អង្គ ព្រះជន្មាយុប្រមាណ ៤០ ពាន់ឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះសុតនវបស់យើងខ្ញុំកើតជាក្សត្រ ព្រះនាមខេមៈ បានប្រគេនទានដ៏ប្រើន មានជាតិ ចីវរ ថ្នាំជន្លក់ ឈើតែមជាដើម ដល់ព្រះពុទ្ធកកុសន្ធ ព្រមទាំងព្រះសង្ឃ ព្រះពុទ្ធកកុសន្ធទ្រង់ឆាយថា ព្រះរាជានេះនឹងបានត្រាស់ជា ព្រះពុទ្ធកកីអនាគតកាលមិនខាន ។

២៣ – ព្រះពុទ្ធកោនាគមនៈ

មាតាឈ្មោះនាងឧត្តរា បិតាឈ្មោះយញ្ញទត្តព្រាហ្មណ៍ ភរិយាឈ្មោះនាងវុឌ្ឍគត្តា បុត្រឈ្មោះសត្តឥសិ កន្លងនូវសោកតែ ព្រះជន្មាយុ ៣ ពាន់ឆ្នាំ ទើបបេញ្ចញពួជ្ឈានដោយយានដំរី ធ្វើទុក្ករកិរិយា ៦ ខែ ដើមពុទ្ធវរ ជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺកិច្ចាសៈ ១ ឧត្តរៈ ១ ឧបដ្ឋាន ១ រូប ឈ្មោះសោត្ថិជ អគ្គសាវិកា ២ រូប គឺនាងសមុទ្ទ ១ នាងឧត្តរា ១ មានសាវ័កសន្និបាតតែ ១ លើក មានកំពស់ព្រះកាយ ៣ ហ្មឺនអង្គ ព្រះជន្មាយុប្រមាណ ៣ ហ្មឺនឆ្នាំ ទើបបរិនិព្វាន ។

សម័យនោះ ព្រះគោតមសម្ពុទ្ធបស់យើងខ្ញុំកើតជាក្សត្រ ព្រះនាមបព្វតៈ បានយាងទៅបួបព្រះសម្ពុទ្ធ ហើយស្តាប់ធម៌ទេសនាដ៏ប្រសើរ បានប្រគេនទានដ៏ប្រើនគឺជាតិ សំពត់ភេទសូត្រសំពត់ឧម្ពលជាដើម

ដល់ព្រះសង្ឃព្រមទាំងព្រះពុទ្ធ ។ ព្រះពុទ្ធគោតមនេះទ្រង់ទាយថា ព្រះកស្សបអង្គនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

២៤—. ព្រះពុទ្ធកស្សប

មាតាឈ្មោះធនវតី បិតាជាព្រាហ្មណ៍ឈ្មោះព្រហ្មទត្ត តំរិយាឈ្មោះសុនន្ទា ប៉ុន្តែឈ្មោះវិជិតសេន ក្នុងនគរោរណសី ព្រះជន្មាយុ ២ ពាន់ឆ្នាំ ទើបចេញចាកផ្ទាជាយច្បាសាទ ធ្វើទុក្ករតំរិយា ៧ ថ្ងៃ ដើមពៃជាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺតិស្ស ១ ភារទ្វាជ ១ ឧបដ្ឋាក ១ រូប ឈ្មោះសព្ភមិត្ត អគ្គសាវិកា ២ រូប គឺនាងអនុលា ១ រុវេលា ១ មានសាវកសន្និបាតតែ ១ លើក មានព្រះទំណាស្រេច ២ ពាន់អង្គ ព្រះជន្មាយុ ២ ហ៊ឺនឆ្នាំ ទើបជាទិព្វគត ។

ឯលោះ ព្រះសក្យមុនីបរមសាស្តាយើងទ្រង់កើតជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្តខេះចប់ត្រៃវេទ ស្គាល់ផែនដីនឹងអាកាសខេះជីជាតោរោគ ។ គ្រានោះ ឃើញរោងឧបដ្ឋានរបស់ព្រះពុទ្ធកស្សប បានទាំងជោតិបាលមាណព ក៏ចូលទៅគាល់ព្រះជិនស្រីព្រះនាមកស្សប ហើយក៏ចូលកន្លែងសំណាក់ព្រះជិនស្រីនោះ ជាអ្នកមានឫទ្ធិឈ្លាសក្នុងវត្តភូមិ បានបំពេញកិច្ចក្នុងសាសនាព្រះពុទ្ធកស្សបនោះ ព្រះអង្គទ្រង់ឃើញសេចក្តីអស្ចារ្យខ្លាំង ទើបទ្រង់ព្យាករណ៍ថា ជោតិបាលកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលមិនខាន ។

២៥- ព្រះពុទ្ធគោតម

ព្រះមាតានាមព្រះនាងមហាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ អគ្គមហេសីនាមព្រះនាងយសោធរា ព្រះពជបុត្រព្រះនាមរាហុល ក្នុងនគរកបិលវត្ថុ ព្រះជន្មាយុ ២៩ ឆ្នាំ ទើបចេញបព្វជ្ជា ដោយយានសេះឈ្មោះកណ្ឋកៈ ៦ ឆ្នាំ ដើមពោធិដាពោធិព្រឹក្ស អគ្គសាវក ២ រូប គឺ កោលិត ១ ឧបតិស្ស ១ ឧបដ្ឋាក ១ រូប ឈ្មោះអានន្ទ អគ្គសាវិកា ២ រូប គឺនាងខេមា ១ ឧប្បលវណ្ណា ១ មានសាវកសន្និបាតតែ ១ លើក មានព្រះខីណាស្រព ១៦៥០ អង្គ ព្រះជន្មាយុប្រមាណ ១០០ ឆ្នាំ ទើបបរិនិព្វាន ។

ក្នុងសៀវភៅពុទ្ធប្បវត្តិសង្គ្រាយថា ព្រះហស្តាបេសំយើងខ្ញុំបរិនិព្វានក្នុងព្រះជន្មាយុ ៨១ ឆ្នាំ គឺព្រះជន្ម ៦៩ ឆ្នាំចេញបព្វជ្ជា ធ្វើទុក្ករកិរិយា ៦ ឆ្នាំ ចូលត្រាស់អនុត្តរសម្មោធិ ហើយចំពេញភ្នំ ៤៥ ឆ្នាំ ទើបបរិនិព្វាន ប៉ុន្តែមកវិញព្រះជន្ម ៨០ ឆ្នាំតត់ តែក្នុងសុត្តន្តបិដកខ្លះនិកាយពុទ្ធវង្ស ព្រះពុទ្ធទាំង ៦ ៨ ព្រះអង្គខ្ញុំពុំឃើញមានព្រះសូត្រណាមួយ ព្រះលោកនាថបេសំយើងមានព្រះជន្ម ១ ០០ ឆ្នាំ ។

អំពីការតាំងចៅអធិការថ្មី

(គពីឆ្នាំ ១៩៦៨)

សញ្ញាប័ត្រលេខ ១៩ ចុះថ្ងៃ ៥ រោច ខែចេត្រ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ មាស - ឃុន នាមឆាយា សុវណ្ណគ្គោ កើតឆ្នាំថោះ អាយុ ៣៤ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តព្រៃតឡូមាក ឃុំព្រៃតឡូមាក ស្រុកឧដុង្គចំកណ្តាល កណ្តាល ។

សញ្ញាប័ត្រលេខ ២៧ ចុះថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ជួត - លាន នាមឆាយា ព្រហ្មជោតគ្គោ កើតឆ្នាំថោះអាយុ ៣៤ ឆ្នាំ វស្សា ១៧ ជាចៅអធិការវត្តព្រៃស្តា ឃុំព្រៃញ្ញ ស្រុកពាមរ៉ង ព្រៃវែង ។

សញ្ញាប័ត្រលេខ ២៨ ចុះថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ចក់ - មៅ នាមឆាយា កាលគ្គោ កើតឆ្នាំថោះអាយុ ៣៤ ឆ្នាំ វស្សា ១៨ ជាចៅអធិការវត្តសម៉ ឃុំព្រៃតញ្ញ ស្រុកពាមរ៉ង ព្រៃវែង ។

សញ្ញាប័ត្រលេខ ២៩ ចុះថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ គួច - យន់ នាមឆាយា ពុទ្ធជោត កើតឆ្នាំច្រូវ អាយុ ៤៨ ឆ្នាំ វស្សា ២៧ ជាចៅអធិការវត្តព្រៃជ ឃុំព្រៃស្រឡិត ស្រុកពាមរ៉ង ព្រៃវែង ។

សញ្ញាប័ត្រលេខ ៣០ ចុះថ្ងៃ ១១ កើត ខែពិសាខ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ប៊ូ . ភ័ន នាមឆាយាឥន្ទ្រោត កើតឆ្នាំមមីឯកុ ៣១ ឆ្នាំ វស្សា ១០ ជាចៅអធិការវត្តតាពាំង ឃុំកប ស្រុកពាំង ខៃត្រពែង ។

សញ្ញាប័ត្រលេខ ៣១ ចុះថ្ងៃ ១១ កើតវ៉ែពិសាខ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូជា - ទុះ នាមឆាយា មុត្តាបញ្ញោ កើតឆ្នាំរកាឯកុ ៤៩ ឆ្នាំ វស្សា ១៨ ជាចៅអធិការវត្តមន្ទីរធំត្រែ ឃុំត្រែពត្រែ ស្រុកត្រែពត្រែ ខៃត្រពែង ។

សញ្ញាប័ត្រលេខ ៣២ ចុះថ្ងៃ ១៦ ខ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូ តឹម-ស៊ីយ នាមឆាយា មង្គលបញ្ញោ កើតឆ្នាំថោះ អាឯកុ ៤៦ ឆ្នាំ វស្សា ២៤ ជាចៅអធិការវត្តត្រែពទំមូង ឃុំតង្កុំ ស្រុកពាំង ខៃត្រពែង ។

សញ្ញាប័ត្រលេខ ៣៣ ចុះថ្ងៃ ១៦ ខ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូ សួរ-ខុយ នាមឆាយា សុវណ្ណត្ថេរ កើតឆ្នាំថោះឯកុ ៣៤ ឆ្នាំ វស្សា ១៣ ជាចៅអធិការវត្តតាមិញ ឃុំស្មោង ស្រុកតំបែរមារ ខៃត្រពែង ។

សញ្ញាប័ត្រលេខ ៣៤ ចុះថ្ងៃ ១៦ ខ ឆ្នាំជូតសម្រិទ្ធិស័ក តាំងលោកគ្រូ ងិន - ទិម នាមឆាយា កេសវវង្សោ កើតឆ្នាំកេងឯកុ ៥៧ ឆ្នាំ វស្សា ៣៥ ជាចៅអធិការវត្តមន្ទីរឆ្ងាយកម្ម ឃុំត្រែពត្រែ ស្រុកត្រែពត្រែង ខៃត្រពែង ។

សញ្ញាប័ត្រលេខ ៣៩ ចុះថ្ងៃ ១៦ ខែ ៦ ឆ្នាំជូរទេសម្រែទ្វីស័ក តាំងលោក ត្រួ អុត - តុប នាមឆាយា ឋញ្ញាជោត កើតឆ្នាំជូតអាឃុ ៧៣ ឆ្នាំ វស្សា ៥៦ ជាចៅអធិការវត្តសាកនេតេជោ ឃុំលេខ ៣ ក្រុងកំពត ។

សញ្ញាប័ត្រលេខ ៤០ ចុះថ្ងៃ ៧ ខែ ៦ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោក ត្រួ ម៉ម - មួង នាមឆាយាសុធម្មោ កើតឆ្នាំ ១៩០៧ អាឃុ ៣១ ឆ្នាំ វស្សា ១០ ជាចៅអធិការវត្តតៃត្រញ្ចៅ ឃុំតៃត្រញ្ចៅ ស្រុកកំពតកំង ខេត្តតៃត្រវែង ។

សញ្ញាប័ត្រលេខ ៤១ ចុះថ្ងៃ ៧ ខែ ៦ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោក ត្រួ យិម នាមឆាយាចន្ទសុវណ្ណមុនី កើតឆ្នាំរកាអាឃុ ៥៦ ឆ្នាំ វស្សា ៣១ ជាចៅអធិការវត្តតៃត្រសំឡាញ ឃុំរកា ស្រុកកាំង ខេត្តតៃត្រវែង ។

សញ្ញាប័ត្រលេខ ៤៧ ចុះថ្ងៃ ៧ ខែ ៦ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោក ត្រួ ម៉ុន - មូល នាមឆាយា សុវណ្ណឋញ្ញោ កើតឆ្នាំ ១៩៤៦ អាឃុ ៦២ ឆ្នាំ វស្សា ៤១ ជាចៅអធិការវត្តមន្ទ្រី ឃុំមន្ទ្រី ស្រុកមោសរៀក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៤៨ ចុះថ្ងៃ ៧ ខែ ៦ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោក ត្រួ តឹម-ពៅ នាមឆាយា ធម្មកេសរ កើតឆ្នាំ ១៩៤២ ពេឃុ ៤២ ឆ្នាំ វស្សា ៦ ជាចៅអធិការវត្តស្វាយជុំជ ឃុំមន្ទ្រី ស្រុកមោសរៀក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៨៩ ចុះថ្ងៃ ៧ ខែ ធ្នូ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោកគ្រូ ណុច - ឆុល នាមនាយាធម្មត្ថេរ កើតឆ្នាំមមែ អាយុ ៤២ ឆ្នាំ វស្សា ២០ ជាចៅអធិការវត្តត្រពាំងព្រីង ឃុំអន្លង្គព្រះស្រែ ស្រុកអមាសហេក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ៩០ ចុះថ្ងៃ ៧ ខែ ធ្នូ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោកគ្រូ ហែ - តុន នាមធាយ សិរិបញ្ញាវេរ កើតឆ្នាំមមី អាយុ ៤៣ ឆ្នាំ វស្សា ២១ ជាចៅអធិការវត្តជ្រោយ ឃុំព្រៃតដំបូង ស្រុកស្រីសុន្ទរ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ៩១ ចុះថ្ងៃ ៧ កេះខែពិសាខ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោកគ្រូ ខេត - ឃិន នាមធាយ ព្រហ្មវង្សោភា កើតឆ្នាំវក អាយុ ៦៩ ឆ្នាំ វស្សា ៣ ជាចៅអធិការវត្តមជ្ឈិមវន ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៩៦ ចុះថ្ងៃ ៨ កេះខែពិសាខ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោកគ្រូ ប៉ុល - ឆិន នាមធាយ ជោតត្ថេរ កើតឆ្នាំជូតអាយុ ៤៩ ឆ្នាំ វស្សា ២៧ ជាចៅអធិការវត្តកំពង់ធំ ឃុំកំពង់ធំ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៩៣ ចុះថ្ងៃ ៨ កេះខែពិសាខ ឆ្នាំជូតសម្រែទ្វីស័ក តាំងលោកគ្រូ ប៊ូ - ឈឿន នាមធាយ ធម្មសត្ថា កើតឆ្នាំថោះ អាយុ ៤៨ ឆ្នាំ វស្សា ២៦ ជាចៅអធិការវត្តសន់ឃ្លាំង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៤ ចុះថ្ងៃសៅរ៍ ទី ១៦ ខែមេសា ឆ្នាំជូតសំរឹទ្ធិស័ក តាំងឲ្យលោកគ្រូ ង៉ែត ឈាម ឈ្មោះ ធម្មធាយ បញ្ញាវិរិយៈ កើតឆ្នាំកុរ អាយុ ៣៣ វស្សា ១២ ជាគ្រូសូត្រស្តាំវត្តសង់ឃ្លាង ឃុំតាំងគ្រួសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៥៥ ចុះថ្ងៃសៅរ៍ ទី ១៦ ខែមេសា ឆ្នាំជូតសំរឹទ្ធិស័ក តាំងឲ្យលោកគ្រូ ង៉ែត ឈាម ឈ្មោះ ធម្មធាយ ធម្មសារគ្គោ កើតឆ្នាំកុរ អាយុ ៣៤ វស្សា ១១ ជាគ្រូសូត្រធ្លាប់ នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៥៦ ចុះថ្ងៃ ១០ កើត ខែចេត្រ ឆ្នាំជូតសំរឹទ្ធិស័ក តាំងឲ្យលោកគ្រូ អ៊ូ - ផង ឈ្មោះ ធម្មធាយ ឥន្ទបញ្ញោ កើតឆ្នាំជូត អាយុ ២៦ វស្សា ៣ ជាគ្រូសូត្រស្តាំ វត្តព្រៃព្នង ឃុំលាងផ្អែ ស្រុកកំពង់ត្រាញ ខេត្តពោធិសាត់ ។

សញ្ញាប័ត្រលេខ ៨៣ ចុះថ្ងៃព្រហស្បតិ៍ ២ កើត ខែជេស្ឋ ឆ្នាំជូត សំរឹទ្ធិស័ក តាំងឲ្យលោកគ្រូ ង៉ាយ - សឿង ឈ្មោះ ធម្មធាយ ព្រហ្មចរញ្ញោ កើតឆ្នាំថោះ អាយុ ៥៨ វស្សា ៣៧ ជាព្រះគ្រូវិបស្សនាញាណ វត្តពោធិគ-ឃ្លាង ឃុំលេខ ៧ ត្រពាំងកុងពេញ ។

សញ្ញាប័ត្រលេខ ៨៤ ចុះថ្ងៃចន្ទ ១ កើត ខែជេស្ឋ ឆ្នាំជូតសំរឹទ្ធិស័ក តាំងឲ្យលោកគ្រូ យិម - ឈួម ឈ្មោះ ធម្មធាយ សុវណ្ណោ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៣ ជាចៅអធិការវត្តបន្ទាយចុងស្រី ឃុំត្រពាំងធំ ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ៨៥ ចុះថ្ងៃសុក្រ ១១ រោច ខែជេស្ឋ ឆ្នាំជូតសំរឹទ្ធិស័ក តាំងឲ្យលោកគ្រូ ខៀង - ខ្លោក កើតឆ្នាំរកា អាយុ ៤៤ វស្សា ៣៧

ជាចៅអធិការវត្តតេនពោធិ៍ ឃុំត្រែង ជើងក្រោន ស្រុកស៊ីធរកណ្តាល ខេត្តត្បែងឆែង ។

សញ្ញាប័ត្រលេខ ៤៦ ចុះគោលបំរាច្ចេទដែល តាំងលោកគ្រូ ហ៊ុយ - ជុម នាមធាយាធម្មបិតា កើតឆ្នាំខាល អាយុ ៤៩ វស្សា ៧ ជាព្រះសង្ឃនៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៤៧ ចុះថ្ងៃ សុក្រ ៣ កើត ខែភាសាធ ឆ្នាំជូត សំរឹទ្ធិស័ក តាំងលោកគ្រូ ឈន់ - ខៃ នាមធាយាសរធម្មជោត កើតឆ្នាំកុរ អាយុ ៦៦ វស្សា ៤ ជាចៅអធិការ វត្តប្រជុំសាគរ ឃុំលេខ ៧ ស្រុកបាទី ក្រុងកំពុតតេញ ។

សញ្ញាប័ត្រលេខ ៤៨ ចុះថ្ងៃអង្គារ ៦ ភេទ ខែអាសាធ ឆ្នាំជូត សំរឹទ្ធិស័ក តាំងលោកគ្រូ វង់ - ហ៊ាន នាមធាយាសុវណ្ណជោត កើតឆ្នាំច អាយុ ៥១ វស្សា ៤៦ ជាចៅអធិការ វត្តទួលអណ្តាត ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ៤៩ ចុះគោលបំរាច្ចេទដែល តាំងលោកគ្រូ ខែវ - ទុក នាមធាយាព្រហ្មសិរី កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជាចៅអធិការ វត្តពោធិ៍ ឃុំត្រពះមេ ស្រុកជាំក្សាន្ត ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០២ ចុះឆ្នាំគោលបំរាច្ចេទដែលតាំងលោកគ្រូ មាស - សុខ នាមធាយា សសន្តម កើតឆ្នាំច អាយុ ៧៤ វស្សា ៥៣ ជាចៅអធិការវត្តព្រះឥន្ទ្រទេព ឃុំភូមិថ្មី ស្រុកតែម ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ចាន់-ព្រំ នាមនាយា ធម្មជោត កើតឆ្នាំវក អាយុ ៤១ វស្សា ២០ ជា
ចៅអធិការវត្តស្វាយណាត់ ឃុំ-ស្រែចបែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
សៅ-ស៊ូរ នាមនាយធម្មវង្ស កើតឆ្នាំថោះ អាយុ ៣៦ វស្សា ១៥ ជា
ចៅអធិការវត្តសិលាទិមិត្ត ឃុំកូមិថ្មី ស្រែចបែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ចាន់-ឈម នាមនាយធម្មវិនយ កើតឆ្នាំច អាយុ ២៧ វស្សា ៦ ជា
ចៅអធិការវត្តសំពៅតែវ ឃុំពោធិ ស្រែចបែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ព្រំ-ចិន នាមនាយធម្មវង្ស កើតឆ្នាំកុរ អាយុ ២៦ វស្សា ៤ ជា
ចៅអធិការវត្តខ្សាច ឃុំច្រាច ស្រែចបែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ
ជួន-ស៊ុល នាមនាយធម្មប្បញ្ញោ កើតឆ្នាំថោះ អាយុ ២៥ វស្សា ៦
ជាចៅអធិការវត្តខ្លួចទិមិត្ត ឃុំកូវៃ ស្រែចបែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ១០៨ ចុះថ្ងៃព្រហស្បតិ៍ ៨ កេីត ខែអាសាធ ឆ្នាំថោះ
សំរឹទ្ធិស័ក តាំងលោកគ្រូ ឆន-សុទ នាមនាយាវន្តប្បញ្ញោ កើតឆ្នាំថោះ
អាយុ ៤៦ វស្សា ១៤ ជាចៅអធិការវត្តគុន ឃុំផ្សារដែក ស្រែចពញាឮ
ខេត្តឧណ្ណាលុ ។

(មានត)

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុទ្ធផ្សាយ
អំពីពុទ្ធសាសនាបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនាបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសង្គា ស្រ - ហាយ
ក្រុមជំនុំព្រះវិន័យ នៅពុទ្ធសាសនាបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	បញ្ជីរឿង	ទំព័រ
អ្នកនាយ ឈិម - ក្រសេម	ព្រះរាជពង្សាវតារ ភាគទី ១ សម័យនគរភ្នំ (ហ្វូណាន)	៨១
ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌូ	១០០
លោក វ៉ាយ - ប៊ុក តាយបញ្ជី	សុភាសិតខ្មែរ (តមក - ចប់)	១១៦
លោកអាចារ្យ ទិញ - ក្រាញ	រឿងធ្វើស្រែខ្មែរ នៅកម្ពុជាក្រោម (ក្លស័ងស៊ុ) (តមក)	១២៤
អ្នកនាយព្រះឃ្លាំង ខង	រឿងភោគកុលកុមារ (តមក)	១៣២
ផ្នែកសាសនា		
ឃុន បណ្ណានុរក្ស ប៊ូ - ប៊ី	វិធ្លាការក្សាចិត្ត ក្នុងបច្ចុប្បន្ន	១៣៨
ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម	ពន្ធអាស៊ីទ្វីប (តមក)	១៤៤
ព្រះមហា កែវ - ណាត្រី	មង្គលកុណ្ឌលិនិទានខ្លះពីលេខ ១២ ឆ្នាំ ១៩៤៩)	១៥១
កំណាត់ដំណឹងប្រវត្តិការណ៍		
ក្រសួងធម្មការ	ការតាំងបៅអធិការថ្មី (តមក)	១៥៧

ឆ្នាំទី ២១ – លេខ ២ ខែកុម្ភៈ ឆ្នាំ ១៩៤៩ – ដំឡៃដាវ ១ ឆ្នាំ ៩៦ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Neak Oknha Chhim-Krasem Député	Histoire ancienne du Camdodge	81
Luong Nibandhamantrî Nhok-Thèm	Histoire sommaire de l'Inde	100
M. Ray-Buc chef comptable (I. B.)	Recueil de maximes des écrivains grecs (suite et fin).....	116
Monsieur Dinh-Prach	Travaux des champs chez les Cambodgiens de Cochinchine (suite).....	124
Feu Neak Oknha Brah khleang-Nong	Bhog Kul Kumâr (en vers) (suite)...	132

Partie religieuse:

Khun Pannânuraks Bou-Po (I.B.)	Entrainement spirituel (texte tiré du Sumanglavilâsinî).....	137
Luong Nibandhamantri Nhok-Trem	Lumière de l'Asie (suite).....	144
Brah Mahâ Keo-Nakri	Matthakundalinidân (suite du nº 12 de 1948)	150

Notes et chroniques

Ministère des Cultes	Nomination de nouveaux Chau Adhikâr (suite).....	157

21e Année: Nº 2 Février 1949 — Prix d'abonnement 96$00 par an.

ព្រះរាជពង្សាវតារកាកន៑ ១

សម័យនន្រក្ខ (ហ្វូណាន)

ក្រសែម ទេពពិទូរ

ម្ចាស់ប្រវត្តិសាស្ត្រ ប្រទេស - ប្រជាជាតិខ្មែរ អំតាំដើម

តាមដែលបានស្រាវជ្រាវតាមផ្លូវប្រវត្តិសាស្ត្រមកហើយ ប្រាកដថាខេត្តកន្ធារដែនដីណ្ហៀកតន្លង់ ដែលផុតអំពីមជ្ឈមប្រទេស ជាទឹកដីនៃប្រទេសដ៏ច្រើន ទៅតែនៅឆ្ងាយណាស់នៃប្រទេសទាំងនោះ គឺតែនដែលហៅថា ទក្ខិណាបថប្បទេក្ខិណាគ្គិគោល មានប្រទេស ១ ឈ្មោះ « កុមេរុ [1] » ជាប្រទេសធំ មានប្រជាជនកុះករច្រើន, ខ្មែរយើងដើមឡើយ (មុនដែលផ្សាយមកនៅក្នុងកម្ពុជរដ្ឋ) គេស័យនៅក្នុងកុមេរុរដ្ឋនោះ ។ ជាប្រទេសបុរាំខ្មែរអំពីបុព្វណសម័យមក ។

ដោយហេតុប្រជាជាតិឈ្មោះ « កុមេរុ » ប្រទេសដែលប្រជាជាតិនោះគេស័យនៅ ក៏គេនាំមានឈ្មោះថា « កុមេរុ » ឬដោយហេតុថាប្រទេសឈ្មោះថា « កុមេរុ » ប្រជាជាតិដែលនៅក្នុងប្រទេសនោះ ក៏គេនាំមានឈ្មោះថា « កុមេរុ » ដែរ ។ ឈ្មោះជាតិខ្មែរហៅត្រឹមត្រូវតាមរូប

---

១ ក្នុងសៀវភៅ (ភាសាខ្មែរ) របស់លោកអៀរ-កើសថាស័ព្ទនេះជាឈ្មោះហិនឌូ ។ តាមសេចក្តីទំនៃរបស់ពួកហិណ្ឌូជាឈ្មោះដែលមានស្រែះទៅខាងដើមខាងបុរាំ ដូចយ៉ាង សុមេរុ កុមេរុ ជាដើមជាឈ្មោះ ទន្លេ ។

ស័ព្ទដើមថា កុមេរ ដូច្នេះ តែតាមសំឡេងនិយាយជាធម្មតាថា កុមេរ៍ ខ្ញុំនឹងដូចឈ្មោះភ្នំសុមេរុ គេហៅទៅត្រឹមសុមេរ៍ ។ លុះយូរមកឈ្មោះនេះបានក្លាយទៅជាខ្មែរ ក្រោកដោយសារលោកចាត់ទុកថាជាខ្មែរថា «ក្មេរ» ទៅជាសំឡេងផ្សំ, ក្រែយសម័យចាស់លោកចាត់មកហៅថាប្រែជា «ខ្មែរ» ក៏ល្អ ត្រូវការប្រែតាមជាភាសាតន្ត្រៈគេសរសេរជា ខេមរៈ ពាក្យនេះដោយហេតុនេះក្លាយរូបស័ព្ទដើមបន្តិចមកយូរហើយ ។

លុះមកដល់ក្រោយពុទ្ធកាលជាច្រើនរយឆ្នាំ ខ្មែរយើងទើបផ្លាស់មកតាំងនៅក្នុងដែនសុវណ្ណភូមិនេះ ។

សុវណ្ណភូមិនឹងប្រជាជាតិ

ដែនដីដែលតាំងនៅក្នុងរវាងប្រទេសឥណ្ឌា និងប្រទេសចិន ហៅថា «សុវណ្ណភូមិ» (ដែលយើងស) ត្រូវនឹងពាក្យក្នុងបច្ចុប្បន្ននេះថា ឥណ្ឌូចិន តែក្នុងសិលាចារឹកកាលណាចេះមិន ឃើញតម្រូវចំពោះប្រទេសមួយ ជាសុវណ្ណភូមិ ។ មុនដែលខ្មែរចុះមកតាំងនៅមិនយូរប៉ុន្មាន ដែនសុវណ្ណភូមិបានមកទុកជាតំតាំងនៅហើយ ៥ គណៈ គឺ:

១ - អាណាចក្រភ័ញ្ញ ជារាជធានីដំបូងនៅស្រុកខេមរៈសៀមសព្វថ្ងៃនេះ តាំងពីជាន់ដំបូងនៅសុវណ្ណគីរ (សាខ្ពើម) តម្បែរនេះក្លាក់ទៅជារាជធានីភូមា ។

៦ - អាណាចក្រមាល័យ ជារបស់ជាតិជ្វាមាំលយូ តាំងពីជាន់ជំបូងទៅសិន្ធុបុរៈ (សិន្ធុប៊ូរ) ។

៧ - អាណាចក្រលង់ ជារបស់ជាតិលង់ ម្នាលៗដើម ទៅក្នុងដែនសៀមសព្វថ្ងៃនេះ តែអាណាចក្រនេះត្រូវបំបែកចេញជា ៣ រដ្ឋ ហៅឈ្មោះតាមដែលវែរហៅក្នុងជាន់ក្រោយថា

ក - រដ្ឋឆ្វាងវ៉ាត់ តាំងពីជាន់ទៅស្រុតដែលហៅក្នុងកាលឥឡូវនេះថា ខនរបម ។

ខ - រដ្ឋយោនកប្បយាង ទៅក្នុងមណ្ឌលតាយ៉ាង្យរបស់សៀមសព្វថ្ងៃនេះតាំងពីជាន់ទៅស្រុងដិនយ៉ាង ភាងលុចស្រុងជៀនសែន ។

គ រដ្ឋនគ្រប្បុរ ទៅក្នុងមណ្ឌលកាំគល្លិសានរបស់សៀមក្នុងបច្ចុប្បន្នតាំងពីជាន់ទៅខនកុំសព្វថ្ងៃនេះ ។

ជាតិលង់ឆ្លែងគ្នាជា ៣ ពួកត្រង់ត្រង់រដ្ឋទាំង ៣ នេះ ទំនៃពីគ្នាតែទៅក្នុងហាន:ជាភាគរភាពផងគ្នា ។

៨ អាណាចក្រកុំ (កម្ពុជរដ្ឋ) ជារបស់ជាតិ ១ សិងជាអំបូរក្លា (១) តាំងពីជាន់ជំបូងទៅរកង៍ចាក្កំ ខំងចាណាម ។

---

១ ជាតិក្លាឆ្លែងគ្នាទៅបាយតាមកោះតាមឈូងសមុទ្រ ដូចជា ស៊ីហ្វក តាំងពីកោះផ្ការកោះសូមាត្រាកោះបន៍អូ កោះតិណាង សិន្ធុប៊ូរ ខំងត្រង់ប្រទេសកម្ពុជាសព្វថ្ងៃនេះតែឆ្លែងជាអាណាចក្រផ្សេងៗគ្នា ។

៥ - អាណាចក្រចេម្ប៉ា ជារបស់ជាតិចាម្ប៉ា នៅខាងកើតតម្កល់ជួ
តីប្រទេសយៀងណាមសព្វថ្ងៃនេះ គាំងកផ្ទាំងដ៏ថ្កុំថ្កើងនៅឥន្ទ្រប្បុរៈ ។

ក្រៅអំពីជាតិចាំងនេះ ក៏មានមនុស្សសន្តិមជាសន្តិមតូចៗរួបរួមនៅ
ក្នុងចំណូលមនុស្សព្រៃគឺ ព័ណ សម្រែ លណែ ភ្នង ជាដើម គ្មានព្រះកជា
រដ្ឋាភិបាលត្រួតត្រង ដូចប្រទេសចាំងឡាយដែលពោលមកខាងលើទេ ។

ខ្មែរធ្វើយមកសុវណ្ណភូមិ

ក្រោយពុទ្ធកាល ប្រមាណឆ្នាំពុទ្ធសតវត្សទី ២ ដល់ទី ៦
ប្រជាជាតិខ្មែរបានមករកស៊ីលក់ដូរនឹងមកតាំស្រុយៅក្នុងដែនសុវណ្ណភូមិ
ជាហូរហែមក ចំនួនដូចជាតិចិនដែលធ្វើយក្នុងកម្ពុជរដ្ឋក្នុងបច្ចុប្បន្ន ។

ពាក្យដែលថា «ខ្មែរធើងធ្វើយមកតំបន់សុវណ្ណ» ដូច្នេះ តើមានអ្វីខ្លះជា
សមគាង ? ។ តបថា ក្រៅពីជាតិនឹងឈ្មោះប្រទេសដូចបានពោល
ហើយ នៅមានពាក្យគាងយ៉ាងជាខ្មែរគ្រប់ជាងយ៉ាងជាសមគាង គឺ ៖

ក - លក្ខណៈអក្សរ នឹង ភាសា

ខ - លក្ខិប្រពៃណី នឹង សាសនា

គ - ពង្សាវតារ នឹង សេចក្តីពន់ហេតុ ។

លក្ខណៈអក្សរនឹងភាសា — យើងត្រូវដឹងជាមុនថា អក្សរ
ជាវណ្ណៈនឹងអក្សរខ្មែរយើង មានដើមកំណើតមកពីអក្សរព្រាហ្មណ៍នៅ
ឥណ្ឌាជាមួយគ្នា ក្នុងជាដំដើមមានលក្ខណៈដូចគ្នា តែយូរមកៗ

ជួរទៅ ហើយថែមចំនឹងចន្លោះទៅទៀប ទេសជ្វាយពីគ្នា លក្ខណៈអក្សរ
ក៏សន្សឹម ។ ល្អៀងគ្នាចេញទៅជាយលំជាប់ ដោះបីជួរខ្លះក៏នៅមាន
ស្នាមល្មមឲ្យយើងដឹងថាជាអំបូរជាមួយគ្នា ។ ការនឹងបញ្ជាក់ពី
លក្ខណៈអក្សរ យើងត្រូវពិនិត្យតាមសិលាចារឹង ដែលជាគំរូធំដែលគេ
បានចារឹកខុសគ្នាឆ្ងាយពីសម័យនោះ ។ ចាំងកន្ត ប្រទេសឥណ្ឌា ចាំងកន្ត
ប្រទេសកម្ពុជា ។ សិលាចារឹកក្នុងប្រទេសចាំងពីរនេះ គួរចាត់តាម
សម័យមុន-ក្រោយជា ២ ចែក គឺចែកជាន់ដើម និងចែកជាន់ក្រោយ ។

ចែកជាន់ដើមក្នុងឥណ្ឌា កំណត់ត្រឹមសិលាចារឹកបង្ហូត្រយ៉ាវង្ស
កទម្ព: និងវង្ស បល្លវៈ ដែលមានចារឹកខុនៅចេតិយ នៅខេត្តស្ថាន
ផ្សេង ។ ក្នុងដែន សលុវង្កប្ប: កិញ្ចិបុរ និងមត្រាស ។ សិលាចារឹក
ចែកជាន់ក្រោយគេឃើញមាន៣ឯង ជាប្រើនអន្លើ តាំងពីវេងពាក់
កណ្តាលដែនខោះចុះមកដល់ចុងដែនខាងត្បូងនឹងខាងកើត ។

សិលាចារឹកខ្មែរចែកជាន់ដើម កំណត់រួមកាប់ពីសម័យបន្តកន្ទុលដល់
ខាងដើមសម័យបន្តរង ត្រឹមរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័ទី ១ (ព. ស.
១៨២០-១៨៣៥) នៅហរិហរាល័យ ។ ចែកជាន់ក្រោយ កំណត់ពី
ត្រឹមរជ្ជកាលព្រះបាទយសោវរ្ម័ទី ១ (ព. ស. ១៨៣៦-១៨៧៤)
ដល់ចុងសម័យបន្តរង ។

អក្សរថែបជាន់ដើមចាំងខាងអណ្តូង ចាំងខាងខ្មែរ មានលក្ខណៈ
ខ្ចង់មូល ។ ថែបចន្លង់ត្រូវនឹងថែបដែលយើងហៅថា អក្សរមូល ។
អក្សរថែបជាន់ក្រោយមានលក្ខណៈខ្ចង់ជ្រួនជ្រុង មានខ្ចង់ខ្នុងស្រួច ។
ត្រូវនឹងថែបដែលយើងហៅថាអក្សរទម ។

អក្សរចារឹកចាំង ២ ថែបនេះ អាចជាគោលដ៏សំខាន់សម្រាប់ប្រៀប
ធៀបប្រវត្តិសាស្ត្រចាស់ណាស់ ។ អ្នកជ្រាជ្រុតណាតតែមានហោក
ឋាថាជាតិជាក់ជាមែន ចានពិនិត្យនឹងឲ្យសេចក្តីយល់ឃុតថា អក្សរ
អណ្តូងនឹងអក្សរខ្មែរមានលក្ខណៈប្រហែលគ្នាទៅតាមសម័យ គឺថែបជាន់
ដើមអណ្តូងប្រហែលគ្នានឹងថែបជាន់ដើមខ្មែរ , ថែបជាន់ក្រោយអណ្តូង
ប្រហែលគ្នានឹងថែបជាន់ក្រោយខ្មែរ ; ទោះបីមានល្អៀងគ្នាខ្លះ ក៏ចំពោះ
អាយុនៃតួអក្សរនោះ ។ ដែលគេចេញឲ្យឆ្ងាយ តាមសេចក្តីយោម ។

ឯភាសានោះ ក្រុងដនៅសិលាចារឹកខ្មែរ មាន ២ ភាសា គឺភាសា
សំស្ក្រឹតនឹងភាសាខ្មែរ ។ ខ្លះយើងអាចដឹងបានថា ភាសាសំស្ក្រឹត
មានដើមកំណើតនៅអណ្តូង ខ្មែរយើងឆ្លាតណាស់ ឆ្លាប់ប្រើមកចោយ,
កាលពុះមកនៅកន្លែងដែនដីអាយនេះ ក៏នាំយកភាសាសំស្ក្រឹតមកប្រើក្នុង
ផ្លូវការផង ភាសាសំស្ក្រឹតទើបឃើញក្រុងដនៅសិលាចារឹកខ្មែរសឹងមាន
សេចក្តីជាផ្លូវការ ។ ឯភាសាខ្មែរនោះសោត គេឃើញលាយចន្លែះ
នៅដោយភាសាសំស្ក្រឹត, ចាំងនេះជាសម្គាល់ ១ យ៉ាង ។

លទ្ធិប្រពៃណីនិងសាសនា – លទ្ធិប្រពៃណីផ្សេងៗ មានពាក្យ
បូជាភេទ: (ពាក្យគោរកំបាយភ្លេង), ពាក្យតាហារ៉ាហាមដ្ឋល, ពាក្យទូ-
ទេសមាស, នឹងរបៀបទាស្រ (កំ) ជាដើម ដែលខ្មែរយើងនិយម
ធ្វើនៅក្នុងប្រទេសនេះ (ខ្ញុំទេពតាវូរ - ក្រសែម) ឃើញដូចគ្នាពាក់ព័ន្ធឈ្មោះ ពាក្យរបៀបដែលគេនិយមធ្វើ
នៅឥណ្ឌា គោះមានឈ្មោះខ្លះ ក៏ចំពោះតាន ៗ ជាឯទេសប៉ុណ្ណោះ
នៅមានគោលដំលូមឲ្យយើងសង្កេតដឹងដើមជាន់ចាន់ថា ពាក្យពាក់ព័ន្ធនេះ
ផ្សាយមកពីឥណ្ឌាដោយខ្មែរយើងជាអ្នកនាំមកដោយខ្លួនឯង ។

ឯសាសនានោះ គឺសាសនាព្រាហ្មណ៍ ទឹងស្លាសនាពុទ្ធ, សាសនា
ពាក់ព័ន្ធនេះមានដើមកំណើតនៅក្នុងឥណ្ឌា តាលខ្មែរយើងផ្សាយមកនៅ
ក្នុងដែនដីនេះ ក៏នាំយកមកប្រតិស្ថានក្នុងប្រទេសរបស់ខ្លួន សម្រាប់
ប្រព្រឹត្តប្រតិបត្តិ តាំងពីដំបូងមក សិង្ហមានបុព្វណស្ថាន ដូចយ៉ាង
ប្រាសាទ - ប្រាង្គទេវស្ថាន ពុទ្ធវិហារ ទឹងបុព្វណវត្ត ដូចយ៉ាងទេវរូប
ព្រះពុទ្ធរូបជាដើម ដែលខ្មែរយើងសាងឡើងដោយឋ - ឥដ្ឋ ទឹងដោយ
សម្រិទ្ធ សិង្ហមានពាក្យសាសនាក្នុងព្រះពាជអាណាចក្រដល់សព្វថ្ងៃនេះ ។
ខ្ញុំនេះសូមដោយសេចក្តីដែលប្រាជ្ញនៅក្នុងពាក្យវគ្គចិន្តនៃឈ្មោះណ័ន្តរ-
ជូ ទឹងលាងជូ ថា «គាត្រូវធម្មិកលិង្គផ្សាយមកក្នុងឥណ្ឌាចិន មានរឿងផ្សេងៗ

ហូលមកគ្រែបលើវិញ្ញាស្រែងគាយជារួចរយឆ្នាំ នឹវិញ្ញាគស្សរសាស្ត្រ, គាសាសំស្ក្រឹត, សាសនា, រឹងប្រជ្ញា, ទំនៀមចនា ។ល។ ។ ខ្ញុំនេះ យើងគាចកំណែងយ៉ាងពេញចិត្តថា អ្នកដែលមានគារ្យធម៌ពីឥណ្ឌៀមកផ្សាយក្នុងដែនជីគាយនេះ តែខ្មែរគេស្រែយជាតិខ្មែរជាអ្នកមានគារ្យធម៌ខ្ពង់ខ្ពស់ ចាំងមានឥទ្ធិពល ទើបគាចផ្សាយគារ្យធម៌បេស់ខ្លួនទៅលើជាតិចាំងឡាយដែលនៅក្រោមអំណាច ទំនឹងជាតិចាំងឡាយដែលនៅឆ្ងាយទៀតផង, ដោយហេតុនេះ ទើបមានឆាយាថា «ខ្មែរជាឥណ្ឌៀចិន៉ នៅក្នុងដែនសុវណ្ណភូមិ ឬឥណ្ឌូចិន ជាដែនឧណ្ណាលនៃគារ្យធម៌ ចំនឹងដូចប្រមដីជាដែនឧណ្ណាលនៃគារ្យធម៌ក្រិក ។ ចាំងនេះ ជាសមគាន ១ យ៉ាង ។

ពង្សាវតារនឹងសេចក្តីកត់ហេតុ — ក្នុងព្រះកមពង្សាវតារក្រុងកម្ពុជាថា «ព្រះហោង អង្គគាងជាមកអំពីឥណ្ឌៀខាងត្បូង» ។ ពង្សាវតារភូមា[1] «ថាមនទឹងខ្មែរជាបងប្អូនឥងគ្នា ចុះមកអំពីឥណ្ឌៀខាងត្បូងចាំងពីរភ្លេងតែភ្លេកមនផ្សាយមកមុនបង្អិច មនទឹងខ្មែរសុទ្ធតែមានច្បាប់ដំណាលអំពីគារសាងជបមមហានគរបេស់ខ្លួន, ខ្មែរនោះឆ្លាប់មានអំណាចផ្សាយទៅក្នុងដែនសុវណ្ណភូមិចាំងមួល ជំរៀកលែងមកហើយក្នុងសម័យមួយ» ។ ពង្សាវតារចិនថា «អ្នកដែលតាំងច្បាប់ទេសខ្មែរដំបូង គាមហួនទៀមមកពីឥណ្ឌៀ ចូលមកគាត់ច្បាប់ទេសនេះពីទិសខាងត្បូង» ។ ច្បាប់ត្តិសាស្ត្រ

• ឬក៏ចំនែលក្រុមព្រៃនេរាធិបច្រើនពួកដូរ ច្រើបេញជាភាសាសៀម ។

សាកលថា[1] «ពួកឥណ្ឌៀដែលចូលមកនោះ ដោយច្រើនមកអំពីនៃត្រកាណ៌ត សំដីជាពួកដែលមានសោហិតត្រាច្ចាណ៌ទឹងក្បត្រិយ៍ល្អយ៉ាងដូចដែរដោយច្រើន ជាអ្នកកាន់ខ្លួនថាមានវណ្ណៈខ្ពស់» ។ ដំណនេះជាសមគាន ១ យ៉ាង ។

ហេតុដែលខ្មែរផ្លាយមក

តាំងតាំងក្រោយពុទ្ធសាលប្រមាណ ២០០ ឆ្នាំជាដើមមក ជនជាតិខ្មែរបានផ្តើមផ្លាយមកក្នុងដែនសុវណ្ណភូមិ តែសន្សឹមផ្លាយរៀយ ។ មកជាច្រើនលើក-ច្រើនឆ្នាំ ទើបបានតាំងឥស្សរភាពឡើងបាន ។ ហេតុដែលខ្មែរផ្លាយមកនោះមាន ២ យ៉ាង គឺ ពួក១ះ មកដោយចង់ដើម្បីនេះស៊ីលាភ់ផ្លូវតាមធម្មតា ពួកនេះមកហើយត្រឡប់ទៅវិញក៏មាន ះនៅជាប់តែម្តងក៏មាន ។ ពួក១ះមកដោយវេត់ស៊ីត ក្នុងពេលដែលមានសង្គ្រាមក្នុងប្រទេស ពួកនេះមកម្តង ។ ច្រើនខាក់ជាប់តាន់ក៏ជាប់ហ្នឹងតែម្តង ។ ការវេត់សឹងចាប់មានឡើងពីក្នុងរជ្ជកាលព្រះបាទពិន្ទុសារ ព្រះកំណាមគឺ (សោយរាជ្យក្នុងឆ្នាំ ព.ស. ២៥២) ដោយឯង់បានលើងទ័ពធំមកវាយឥណ្ឌៀតាមទាងគ្រប់ទិស រហូតចុះមកដល់ដែនមគ្រាស ។ តមក ក្នុងរជ្ជកាលព្រះបាទជម្មាសោក នុះសព្រះបាទពិន្ទុសារ (សោយរាជ្យ ព. ស. ២៧៤) បានស្តេចលើងទ័ពហ្លួងមកវាយឥណ្ឌៀតាមទាងគ្រប់

---

១ របស់លោកហ្ស៊ីងវិចត្រិតាទការ ; មើលត្រង់ភាគ ៩ ។

ខ្មែរ ក៏ឃើញចូលមកដល់តំបន់ក្រុង ។ សង្គ្រាមចាប់តាំងពីរលើកនេះ បានបំពាល់មកលើប្រទេសកម្ពុជាយ៉ាងខ្លាំង ។ សង្គ្រាមលើកក្រោយនេះធំណាស់ ព្រោះជនក្នុងសំណាក់ព្រះបាទធម្មាសោកថា អ្នកស្មុគស្មាញព្រះបាទធម្មាសោកសម្លាប់ជាច្រើន ។ ដែលត្រូវចាប់ជាឈ្លើយក៏ច្រើនណាស់ ។ ប្រទេសនោះ ។ បានតស៊ូពេញទំហឹង តែពុំអាចនឹងទប់ទល់នឹងសេនាទុកាពនៃព្រះបាទធម្មាសោកបាន ក៏គោងញ៉ីមចុះចាញ់ គ្រានោះ ប្រជាជនស្ត្រីៗភាំងៗពុំបាន ក៏រត់ចេញអំពីមុខសឹកឆ្លងទន្លេចន្លីលមកកន្លែងសុវណ្ណភូមិ ។ ក្នុងគ្រាសង្គ្រាមទាំងពីរលើកនេះ ប្រជាជនជាតិខ្មែរបានដោះខ្លួនចេញអំពីមុខសឹកជាច្រើន តែពុំបានមកពាំនាំសន្តិភាពទេ នៅសល់ក្នុងប្រទេសដើមជាច្រើនភាគ ។

ក្រោយមកទៀត ប្រមាណក្នុងឆ្នាំ ព.ស. ២១០ ប្រទេសសុភស្ត្រនឹងប្រទេសអង្គរដែលនៅកន្លែងសុវណ្ណភូមិតាគខាងត្បូងជាមួយគ្នា កើតច្បាំងគ្នាឡើង សាហេតុសង្គ្រាមមកពីរឿងសាសនា ហើយឆេលជាលដល់ប្រទេសជិតខាង ។ ចំពោះតែបដិបក្ខ ដំបូងខាងអង្គរមានប្រៀបជាង តមកបុរីក្រោយ ខាងសុភស្ត្រត្រូវចាញ់មានជ័យជំនះ ។ សង្គ្រាមគ្រានេះក៏មានមនុស្សភាគរត់ចៀសមុខសឹកឆ្លងមកនៅក្នុងដែនសុវណ្ណភូមិជាច្រើនដូចមុន ។ ។

ផ្លូវដែលផ្សាយមកកន្លងស្រុកណាក្នុមានតែ ៦ ផ្លូវ គឺពួកខ្ញុំដើរផ្លូវកាត់ដោយធ្វើចន្លោះចន្លឹល មកឡើងត្រង់ឆ្នាវពីរប៊ែរសមន ។ កន្លងពួកនេះ ពួកខ្ញុំកើតាំងទីលំនៅកន្លងប៊ែរសមន ក៏មាន ពួកខ្ញុំសន្សឹមដើរសែនប៊ែរសមនមកខាងកើត រស្មីនរកដីនខ្ញុំដែលតាំងទីលំនៅ នៅដោយអន្លើ ។ រៀងពីយមកដល់នគរកុំ (កម្ពុជា) នេះ ក៏មាន ។ ពួកខ្ញុំបើកសំពៅចេញទៅទិសខាងត្បូង សំដៅមកឆោះសួនាត្រា កោះជ្រាបូលតាមច្រកមលូកា ហើយចេញពីច្រកក្រៅជ្រោយមាំលយូ បែរមុខឆ្ពើង មកទិសឦសាន សំដៅចូលមកកាណាចត្រកុំពីខាងត្បូង ជាន មកឡើងត្រង់ឈូងចន្លោះក្តីនេះច្រើន ជាងឡើងទៅទីដទៃ ។

លុះមកនៅច្រើនឡើង ។ ប្រមាណក្នុងតុខសនត្រូវខែ ៧ ទើបជាន ឧកញ៉ាស្តេចខាងសយ្រកោតឡើងកន្លងអាណាចត្រកុំ សង្កត់លើសយ្រកោតនគរកុំជាដំបូង ត្រូវយកអំពីនោះមកក៏សន្សឹមៗ ផ្សាយតទ្វីតលេចញ្រៅទៀន ពាល់តែជាន់ជាមហាប្រទេស នៅកន្លងដែនស្រុកណាក្នុមិ ដូចមានប្រាកដក្នុងប្រវត្តិសាស្ត្រតទៅ ។

ព្រះរាជដំណាក់ក្រុងវត្តភូ ភាគទី ១

សម័យឥណ្ឌាភ្នំ

គ. ស. ៦៩៣ - ១៣៤៣

ស្ថាបនាឥស្សរភាព

ព្រះបាទកុមារ

ប្រមាណ គ. ស. ៦៩៣ - ៧៤២ ឆ. ស. ១៥០ - ១៩៩

ផែនដីដ៏ជាក្រឡេសកម្ពុជានេះ មុនដែលខ្មែរតាំងឥស្សរភាព ខោះជាចេស់ជាតិជ្រា បានតាំងឥស្សរភាពមកហើយ ប្រមាណ ១០០ ឆ្នាំ តាំងពីជជាន៍នៅរៀងច្បាស់ធំធំជាណាម ហៅតាមភាសាខ្មែរថា ខនរកុំ មានក្សត្រិយ៍គ្រប់គ្រងមក ៥ អង្គ, អង្គទី ៥ ជាក្សត្រីក្រមុំ ព្រះនាមហៅតាមសំដីចិនថា លីវយើ, ជាព្រះពជនីនៃខនរនេះគ្រាយចប់ផុត ។

ក្នុងរជ្ជសម័យនៃព្រះពជនីនេះ មានរឿបុរសខ្មែរ ១ នាក់ ជាតិជាព្រាហ្មណ៍ខ្មែរនាមកោណ្ឌញ្ញៈ ឬ កោណ្ឌណ្យៈ ជាមហាបក្ខិតស្វាមី នៅអង្គកុម្ភរាជក្នុងដែនដណ្តៅតាន់ក្សិណ ព្រមដោយបក្ខពួកជាច្រើនខាក់ សុទ្ធសឹងតែជាអ្នកមានសិល្បវិជ្ជាការគ្រប់ផ្នែក ជានរួបរួមស្បៀងអាហារនិងគ្រឿងសស្ត្រាវុធពាល់ខ្លួន ចុះសំពៅចេញចាកច្រកទេសចេស់ខ្លួន បើកសំដៅកោះសុមាត្រា ហើយចត់ចែរសំដៅមកខ្សឹងខនរកុំពីខាងត្បូង ចូលតាមឈូងទន្លេចាស់កុំ ខ្សឹងមកដល់ខនរកុំ ។

តារមណ្ឌនៃពួកនេះឃើញថាពាក់ខន់ដោយប្រុងប្រៀបប្រដាប់ហាលជាមាន
បំណងនឹងមនក្រញោចយកខនតកុំ ទើបមានអារុងជាម៉ាន់ដែរ ។

ឯលោកបាលខនតកុំ សង្កេតឃើញតាឈរតំរៀបក្បាហានប្លែកអំពី
ពួកបរទេសដែលខ្ជាប់ខ្ជួលមកសព្វដង ដូច្នេះទើបបញ្ជាការឲ្យ ឲ្យតាហាន
១ ក្រុមចេញទៅប្រណាម ដោយគ្រែងថា បើទ័ពបរណ្តាយឲ្យទៅ
ទៅ អាចនឹងមានកយន្តពួកឈដល់ព្រះខនតា តែពួកស្មេណ្ឌាញ:មិនត្រម
ថយចេញទៅតាមបញ្ជា ទើបកើតជាសាហេតុនស្ងួតឡើងដោយអារុង
នៃមិនយូរប៉ុន្មាន ផលក្នុងទីបំផុតនៃការតេស្ងូ កំតីពួកស្មេណ្ឌាញ:មាន
ជ័យ ព្រះពជនិនតកុំកំភោនចុះញ៉ាម ។

រីឯបុរសស្មេណ្ឌាញ:តាលង្គមាបន្ទាយតកុំសម្រេចហើយ កំត្រូវអ្នក
ខនតនេះនឹងពួកបេះខ្លួន អញ្ជើញឲ្យឡើងគ្រងពិភពខនតកុំនទៅ
ជាខន់ព្រះពជនិនតកុំជាអគ្គមហេស៊ីផង ថ្វាខនដព្រះបរមនាមតាមព្រះ
ឱគ្រងថា ស្មេណ្ឌាញ:តាមឈ្មោះប្រទេស ឬតាមឈ្មោះជាតិថា ភុមេរុ
ដែលភាក្យសាម៍ញ្ញថា ព្រះថេរ ។ ឯព្រះអគ្គមហេស៊ីនោះ មិនមានអ្ន
ណាស្គាល់ព្រះនាមជាជាក់លាក់ទេ ក្នុងព្រះពជនិព្រាវតារគ្រែងតម្កើងថា
ព្រះនាម «ជាកតៃ» តែថាព្រះនាងនេះជានាគ៍ មៅវិញ ។ ចំណែរមក
ទ្រង់មានព្រះរាជនុសេ ១ អង្គដែលថ្វាកដព្រះនាមថា «ព្រះវីរវ័ន»
ដែលក្នុងតង្គ្រាតារចេនហៅថា ប៉ុនប៉ុន ។

ការផែនដី: គ្រោយដែលចាន់តែងតាំងតាតហើយ ព្រះចាន់កុមារ អង្គនាំពាជ ចាន់ទ្រង់សាងព្រះពាជធានីជាថ្មី ដោយដូចគ្រួងចាស់នោះ ថ្វាយសាងគ្រប់លើគ្រួងចាស់នោះឯង មុនទ្រង់សាងចាន់ស្តេចយាងទៅទតដល់ចំណែនខ្លួន ដើម្បីទ្រង់រំសាកចិត្តយកភូមិ ទ្រង់ចាន់យកព្រះខ្មែរលំពែងជ័យអំពីដែនជប៉ុនហ៊ិត ឈ្មោះអស្សគ្គាមន (ជាបុត្រចៅស្តេចហ្នាណ៍ឈ្មោះគ្រាន:) មកទ្រង់អង្គាន់ផ្សង់ហើយ ទើបទ្រង់ពួយព្រះលំពែងទៅ ដោយគេញ្ញាំកើត ព្រះលំពែងជ័យទៅជាក់ដោតនៅទី ១ ទ្រង់ក៏កំណាត់យកចិនោះដាច់ជ័យភូមិ ជាថ្នូតក្រុង គ្រាស់ឲ្យជាង៏សាងព្រះនគរឡើង ឲ្យនាមថា «វ្យាធបុរៈ» ។

គ្រៅអំពីការសាងក្រុងនេះ ទ្រង់ចាន់ចាត់ការចំនុកចម្រុងប្រជាពលស្តុកដោយផ្សាយចំណេះវិជ្ជាតាមវិបជតណ្ឌ ទាំងថ្នូរលោតទាំងថ្នូរធម៌ ឲ្យផ្សាយទូទៅក្នុងទឹមណ្ឌលព្រះពាជអាណាចក្រ តាមហានៈនៃព្រះអង្គជាព្រះពាជាម្ចាស់នៃនជី ប្រជានិករជាតិស្រុកទាំយ កាលចាន់ទុកខ្លួលសេចក្តីតនុគ្រោះអំពីព្រះអង្គដោយនានាប្រការច្រើនហើយ ក៏ចាន់សេចក្តីសោមនស្ស ព្រមទាំងសំដែងសេចក្តីស្មោះត្រង់ទុំ ខ្លឹងសារសើរព្រះចារើខ្លួនៗ ។ ស្តេចស្ថិតនៅក្នុងពាជសម្បត្តិ ដល់ព្រះជន្ម ៨០ វស្សាក៏សោយទិវង្គត ។

សេចក្តីអធិប្បាយខ្លះក្នុងរជ្ជកាលទី ๑

ប្រវត្តិសាស្ត្រក្នុងរជ្ជកាលទី ๑ នេះ ១ខ្លះស្មុកស្មាញហើយគំហុំនឹងនិតរបស់អ្នកផងគឺមាន, ១ខ្លះបានគ្មាយទៅជារឿងព្រៃងយ៉ាងអណ្តែតអណ្តូង តែក៏នៅមានបុគ្គលជាច្រើនរូប ដឿយាងស៊ប់សួនថា ជារឿងប្រវត្តិសាស្ត្រពិតៗក៏មាន ។ រឿងពាំងនេះមិនបាន់ឃើញមានអ្នកណាវិនិច្ឆ័យខុសដោយត្រឹមត្រូវនោះឡើយ ។ ការដែលខ្ញុំរៀបរៀងព្រះរាជពង្សាវតារនេះ គឺបង្ហាញជាមុនថា បើនឹងខុសបណ្តោយឲ្យទៅដូច្នោះ ទៅឃើញថា ល្អរឿងតាំងពីសេចក្តីពិតពេកណាស់ ទើបសូមអធិប្បាយជំនោះ ១ខ្លះខុសក្នុងនេះដោយសង្ខេប ដើម្បីឲ្យអ្នកជ្រាបប្រវត្តិសាស្ត្រជួយពិភាក្សានឹងវិនិច្ឆ័យតទៅ :

ព្រះបរមនាមនៃព្រះមហាក្សត្រិយ៍អង្គទី ๑ ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជា[๑]ថា ព្រះមហាក្សត្រិយ៍អង្គទី ๑ នេះ មានព្រះជាតិជាក្សត្រិយ៍ព្រះនាម "ព្រះថោង" ជាពូជនៃសេព្រះចុងភៅទំព្រះរាជវង្សនៅនគរក្រុងច័ន្ទ ។ បន្ទាប់ខ្លះថា ព្រះបរមនាម កុមារ ដោយហៅតាមព្រះនាមព្រះរាជមាតា ។

សេចក្តីពិត ព្រះមហាក្សត្រិយ៍អង្គនេះពិតជាបរទេសនៅក្នុងប្រទេសនេះមានជ័រជាតិជា "ព្រាហ្មណ៍" ព្រះនាមហៅតាមព្រះនៅតែថា

---

๑ សំដៅយកពង្សាវតារស្តឹកកាត ឬក្រឹងដែលមានទៅសព្វថ្ងៃនេះ ។

គោណ្ឌញ្ញៈ ឬ គោណ្ឌណ្យៈ ហៅតាមឈ្មោះជាតិ ឬហៅតាមឈ្មោះប្រទេសដើមថា កុមេរុ ។ តង្វាយតែរចំនួនហៅព្រះនាមនៃព្រះមហាក្សត្រិយ៍អង្គនេះថា «ហួនខៀន» ។ ព្រះនាម ព្រះថោង ប្រែថាន សេចក្តីថា «ព្រះអង្គមាស» ជាពាក្យលើងដំកើងតាមទំនៀម ដោយអធិប្បាយថា ដែលមានព្រះនាមថាព្រះអង្គមាស ដោយទ្រង់ជាន់ក្នុងរជ្ជកាលមាស ។ ព្រះនាម ហួនខៀន ជាភាសាចិន ប្រែថាន សេចក្តីថា តែរលើមេឃ (អគ្គរាជ្ជ ឬ បុស្សរតន) ត្រូវនឹងពាក្យក្នុងបច្ចុប្បន្នថា ព្រះតែវហ្វ៎ នេះគឺជាសេចក្តីហៅលើងដំកើង ដូចគ្នានឹងពាក្យថា ព្រះថោងដែរ គេអាចហៅ ព្រះអង្គមាស ឬព្រះតែវហ្វ៎ ចំនួសព្រះបរមនាមបាន តែព្រះថោងអង្គនេះ មិនមែនជាក្សត្រិយ៍ដែលសាងនគរធំដូចមានពោលក្នុង ព. ក. តង្វាយតែរក្នុងតម្លៃជា នោះទេ ។

ព្រះនាមព្រះអគ្គមហេសី : ក្នុង ព. ក. ថា ព្រះអគ្គមហេសីព្រះថោង ព្រះនាម ឆាវតី ជាធីតាឧកជនៅឋានចុតាល ។

ព្រះថោងមានព្រះអគ្គមហេសីជានាងនាគមែនឬ ? យើងមិនចាប់ផ្តើមកឲ្យអ្នកប្រវត្តិសាស្ត្រជួយស្រាវជ្រាវទៀតទេ យើងគាបគាត់ថា អគ្គមហេសីព្រះថោងឬព្រះចុងកុមេរុនោះ មានសញ្ជាតិជាមនុស្ស ហើយមានវណ្ណៈជាក្សត្រិយ៍ស្មុគ្គ ដូចពោលមកខាងដើម មិនមែនជាសត្វនាគតាំងពីក្បាល ដូចមានពោលក្នុង ព. ក. នោះទេ ។ ព្រះនាមដូចម្តេច

កន ព. ក ថា ជាកវតី, កន ព. ច. (តន្ត្រវាគារចំនួន) ថា លាវយើ ឬហៅ
ខ្លីថា លាវ ។ ពាក្យនេះជាតាសាចំនួន ប្រែថាខ្មែរសេចក្តីថា ជាឈ្មោះដើម
ឈើ ១ យ៉ាង ឈ្មោះឈើនេះ ត្រូវនឹងពាក្យបារាំងថា Soule មាន
ប្រភេទដុះនៅតាមមាត់សមុទ្រ មានលក្ខណៈដើមទន់ស្តើងសំបុរខៀវ,
កន្ទេរដើមដូចជនិ្ធមនុស្ស ស្តើងគ្នាល្អិតហើយវែងប្រមាណជាង ១ ហត្ថ
ដូចសក់កន្ទិចដែលរំសោយចេញ. តាលត្រូវខ្យល់សូមរីខ្យល់ត្រសៀច ។
ក៏រំតើយទៅមក ទំនងសូរខ្យល់ក្រ ។ យ៉ាងអស្ចារ្យ ។ ឈើនេះបន្ទុះហៅ
ដូចម្តេច មិនឆ្លងដឹងបាន តែម៉ើនឹងហៅឲ្យសមតាមហេតុផល គួរហៅ-
ថា "ដើមសក់ក្រអូប" ព្រោះស្តើកដូចសក់មនុស្ស ។ ព្រះពជិនន្តរក្នុ
ប្រវេលជាមានព្រះនាមពិសេសថា "ព្រះនាងសក់ក្រអូប (សុគន្ធកេស-
គន្ធាវតី) ដូច្នេះ មិនមែនជាឆាតវតី ព្រោះសមដោយរឿងបុរាណ ១ ថា
មានស្តេចក្សត្រីក្រមុំ ១ អង្គ ព្រះនាម នាងសក់ក្រអូប នៅក្នុងវែតក្រ
ចាំង (តាកែវ) ព្រះនាងនេះចាញ់កលនាយឈ្មួញសំពៅ ដោយ
នាយសំពៅឲ្យលេងមហោស្រពលើសំពៅក្នុងក្រមួយ ព្រះនាងសក់ក្រ-
អូប ក៏ឡើងទៅគេលើសំពៅនោះ នាយសំពៅបានឲ្យគេជកយុថ្កា
សន្ធឹមៗចេញទៅ ពាលតែទៅដល់កណ្តាលសមុទ្រ គំយកព្រះនាង
បាន ។ រឿងនេះ គួរឲ្យសន្និដ្ឋានថាជារឿងព្រះបាទសោណ្ឌញ្ញៈនឹង
ព្រះនាងលាវយើតែម្តង ។

ជាភាសា – ភ្នំ ជាភាសាខ្មែរ ក្នុងសិលាចារឹកតែងសរសេរថា "ភ្នំ" ច្រើនសរសេរ ទើរហៅតាមសំឡេងនេះដែរ តែមិនច្បាស់ ក្នុងជាន់ដើមច្រើនសរសេរជា កំ-ឃុ-ណាំ តាលច្រើនតាមកក្លាយទៅជា ហ្គូណាន,[1] ឬកាំនហៅថា ហ្គូណង់, ជាឈ្មោះព្រះពុទ្ធជាន ឬជាំងជាឈ្មោះព្រះពុទ្ធអាណាចក្រខ្មែរក្នុងជាន់ដើម (នគរគោកឆ្នក) ក្រុងនគរធំ (នគរសៀមបច្ចុ) មិនមែនជាបច្ចុមនគរ ដូចក្នុង ព.ព. ឬដូចដែលអ្នកខ្លះយល់ទេ ។

ខ្មែរធំជាជ្វា – ក្រៅយដែលព្រះចាន់កុមេរុបានជាព្រះពុទ្ធម្ចាស់ផែនដីអាណាចក្រភ្នំហើយ ជាតិខ្មែរធំជាតិជ្វាម្ចាស់ស្រុកដើម បានរួមគ្នាទៅជាជាតិ ១ ហៅថា កុមេរុ គឺជាខ្មែរសព្វថ្ងៃនេះ ឯលក្ខណៈរូបកាន់ធំឯការប្រពន្ធមិនជាតិជាំង ២ នេះ ផ្សេងគ្នាខ្លះ គឺលក្ខណៈរូបកាន់ខ្មែរក្នុងជាន់ដើមឯណោះ មិនដូចជ្វាជាំងមិនដូចខ្មែរក្នុងសម័យនេះស្មោះទេ, ខ្មែរក្នុងជាន់ដើមរូបកាន់ច្រើនស្រួល ។ ច្រមុះស្រួច សំបុរកាយទៅស្រអែមយ៉ាងដែលហៅថា សំបុរជ្វាក្នុងបច្ចុប្បន្ន ។ ពួកប្រុស អ្នកដែលមានលោហិតជាព្រាហ្មណ៍ខ្មែរ ខ្លះសក់ប្លង់ អ្នកដែលជាខ្មែរសុទ្ធ ឆាត់សក់ស្មៅតសំពត់បង់ក្បាល ពួកស្រីជាំងអស់ ខ្លះសក់ប្លង់ ស្មៅតសំឡុយពាក់គាវខ្លីតខ្លួន មានស្បៃភាខាពីក្រៅ ប្លុសចង្កេះជាប់ដោយត្រឹងមាសត្រឹងក្បួនច្រើន ។ ។ និស្ស័យចិត្តថ្លើមជាអ្នកអង់អាច មុះមុត

---

[1] ហ្គូណាន មិនមែន ភ្នំតិ ដូចអ្នកខ្លះយល់ទេ ។

ក្នុងហានតុំសូវញៀមចុះចាញ់សេចក្តីខ្ជឿយហត់ ឬពួនបរបក្សជោគជ័យ ជាអ្នកមានអាវុធមិ ក្លៀវឆមិ ខ្លូវសិល្បវិជ្ជាឈ្លាសពាំងពួន ខ្ពស់ជាងនានាជាតិនៅដែនដីតាយនេះពាំងអស់ ។

ឯជាតិជ្វានោះ មានលក្ខណៈ រូបកាន់ជាយ"ងមធ្យម សំបុរគាយសដ្ឋិះ រូបច្រែនល្អ ។ រៈបៀបតែងកាយ ប្រុសគាត់សក់ ស្ងៀតសំឡួយ ។ ស្រីខុតសក់បូង ស្ងៀកសំឡួយ ត្រឹងច្រដាប់តែងកាយត្រូវតាមសំពត់អាវគ្នាអ្វីជាសំខាន់ ។ ទំនៀយចិត្តថ្នើមជាអ្នកអត់ធន់ គួរដល់ការងារពាំងពួន អាវុធមិនៅខ្លាន សិល្បវិជ្ជាការពាំងពួនមានបេះត្បាញសំពត់ច្រៃខ្លះដែរហើយ តែនៅជ្រាងជ្រាង ពុំបានជាល្អហ្មត់ចត់នៅឡើយ ទីលំនៅសង់ឡើងដោយត្រឹងឈើឫស្សីជាធម្មតា ជាខ្នុមដូច ។ ច្រែនបូលបិត្តអាស្រ័យនៅដោយខ្លួក ប៉ុនច្រែសម៉ក្នុងផ្លូវដើងទឹក បបរកស៊ីផ្ទៃស្រែចំការ ទឹងច្រែនច្រែត្រឹតក្នុងផ្លូវនេសាទត្រីជារបរគោជីវៈ ។ ការគាន់សាសនាក្នុងជាន់នោះពុំខាន់ខាន មានតែការពេចគាន់ទេពាក្យជាសារណៈច្រែចាំជីវិត ទើបមកបានទទួលនោរពបង់គាន់សាសនាព្រាហ្មណ៍ទឹងព្រះពុទ្ធសាសនាខ្លះ តាមខ្នែកនឹងវេលាដែលខ្នែផ្សាយមកនៅក្នុងច្រទេសនេះជាច្រែនហើយ ។ តែទោះបីយ៉ាងណាក៏ដោយ ជាតិជ្វាមែងមានអាវុធមិសមគួរមកហើយ ទើបអាចតាំងឥស្សរភាពជាច្រទេសជាតិមកបាន ។

(មានត)

វគ្គទី ១

អំពីសភាពនៃវៀតណាមសម័យបុរាណ

ផែនដីដ៏ធំធូលាយដែលជាទឹកដីនៃគណៈចារ្យទាំងឡាយ ជាដែនកើតនៃសាសនានានា មានសាសនាព្រាហ្មណ៍និងពុទ្ធសាសនាជាដើម ជាកំណើតនៃរឿងកម្មកុំពុងជាន់ដើមហៅថា «ការតវ៉ា» ។ ឯឈ្មោះដែលហៅថាវៀតណាម នេះ ដោយយល់ថា ប្រទេសនេះមានទន្លេសំខ្លួជាសំខាន់ ទើបមានឈ្មោះហៅម្យ៉ាងទៀតថា «សំខ្លួស្ថាន» តែសព្វថ្ងៃនេះយើងនិយមហៅថា វៀតណាម ជួស្រុកអាំងដ៏ តាមសំដីចាស់ ។ ឯលំអិតដើមមក ផែនដីចំណែងនេះយើងហៅថា ជម្ពូទ្វីប ដូចមានរឿងក៏វែកាជក្នុងតម្លៃដើការបស់យើងជាច្រើនអន្លើ ។

ឯសភាពរបស់ប្រទេសវៀតណាម យើងត្រូវតែពិនិត្យពិចារណាដោយម៉ត់ចត់ ព្រោះភូមិប្រទេសដែលមនុស្សគាស់យកនៅ រមែងជាគ្រឿងអប់រំចំណូចគំនិត ទឹងនិស្ស័យឲ្យមានសភាពផ្សេង ។ គ្នា ដូចជាពួកមនុស្សដែលនៅលើទីដីមានជ័ជាភ្នំក្តី តែងមានដំនៀថា មនុស្សយើងតែស្ងាប់នៅតែងនៅចាប់កំណើតថ្មីជាដរាប ។ ឯពួកមនុស្សដែលនៅកន្លែ

ក្រៀមក្រោះដូចមានដំណាំបុជសាជលអ៊ីចេ តែងតែមានគំនិតគិតឃើញ
ថា មនុស្សយើងស្លាប់ទៅសូន្យដូចគេតែពីរតេ ដូច្នេះជាដើម ។

ឥណ្ឌៀជាជាតិដែលមានលក្ខណៈទឹងអារ្យធម៌ទុំស្មគ្មាន់ជនជាតិ
ដទៃ។ មានប្រទេសអេម៉ូច្ចូជាដើម ដូចយើងបានរៀបរាលរួចមកហើយ ។
ទុកជាឥណ្ឌៀបានទទួលអារ្យធម៌ពីក្រិកទាំងនេះ ដោយហេតុព្រះបាទអា-
លេក្សង់ដ្រមហាជដ្ឋាជាំលុយចូលប្រទេសឥណ្ឌៀមុនហើយ តាមជនជាតិក្រិកនឹងជនជាតិឥណ្ឌៀមានការប្រសព្វគ្នាជារឿនក៏
ដោយ ឥណ្ឌៀក៏នៅតែមានអារ្យធម៌ទេសខ្លួនដោយឡែកជារឿន ដែល
បានមកពីជាតិដទៃនោះមានតិចតេ ព៌ាព្រោះប្រទេសឥណ្ឌៀ មានភ្នំមាន
សមុទ្រជាកំពែងព័ទ្ធខ្លាមចោមជុំវិញ ដូចជាភ្នំអាហ្វាន, ភ្នំហិណ្ឌូកូ-
ហិមាលយ៉ា, ជាភ្នំភូមានឹងមហាសមុទ្រឥណ្ឌៀ ។ល។ ធ្វើឲ្យ
ប្រទេសឥណ្ឌៀ ជាប្រទេសមួយនៅដោយឡែកដាច់ពីប្រទេសដទៃ ។

ចំណែកខាងក្នុងទេត្តដែនទៃប្រទេសឥណ្ឌៀនេះ គេបែងចែកជាពីរ
ចំណែក។ មួយហៅថា មជ្ឈិមប្រទេសនៅខាងជើង តែដំណាចខ្លួ
មេរង្គាឡើងដល់ទឹងជនភ្នំហិមាលយ៉ា, មួយចំណែកទៀតនៅខាង
ត្បូងហៅថាដេចឆាន់ ឬ ចច្ចន្តជនបទ តាំងពីកាតកណ្ដាលរបស់ឥណ្ឌៀ
ចុះមកដល់ឈេះលង្កា ។

ទឹកដីអាកាសរបស់ឥណ្ឌៀនោះ មិនស្មើមានប្រទេសណាដូចទេ តែនៅកន្លែងតំបន់តែមួយ នៅក្នុងប្រទេសតែមួយ អាចមានអាកាសធាតុជាច្រើនហើម: ភ្លាក់ ហើយវិលជាក្តៅចំផុតស្មើតែគ្រាំពុំបានក៏មាន ។ អ្នកដែលភ្លាក់ឡើងទៅដល់កំពូលភ្នំហិមាលយ៉ាហើយត្រឡប់ចុះមកវិញ រមែងមានអាការៈដ៏ខ្លួនហាក់ដូចទៅនៅក្នុងស៊ីបេរ៉ៃ ហើយចេញពីស៊ីបេរ៉ៃក៏ដល់តែហ៊ីកតែម្តង តែចេញពីរដាំចំផុតក៏ដល់ក្តៅចំផុត ។ ជនជាតិឥណ្ឌៀជាច្រើនមិនបានទៅនៅលើភ្នំហិមាលយ៉ា ប្រជាជននៅខាងត្រែកមស្មើតែគាំងអស់ ដែលមានអាកាសក្តៅ ទើបគួរពោលថា ឥណ្ឌៀជាប្រទេសក្តៅ ហើយក្តៅជាងប្រទេសឥណ្ឌូចិនយើងទៅទៀត ។

មនុស្សដែលនៅក្នុងប្រទេសក្តៅទំនងប្រទេសនោះ រមែងខុសគ្នាឆ្ងាយ គឺពួកជនដែលនៅក្នុងប្រទេសនោះ ជាមនុស្សទេស្យាចាំខ្ញុំឃ្លាតមានមាន: ព្យាយាមធ្វើការជាច្រើន ហើយចេះប្រើធម្មជាតិមកជាប្រយោជន៍ដល់ខ្លួន ប្រើធម្មជាតិជាត្រឿងសូរស្មើនឹងចំណេះចេះដឹងសេចក្តីសុខសប្បាយ ទំនងសេចក្តីស្ងួនស្តួមដល់ខ្លួនផង ដូចជាពួកអឺរុប អាមេរិក ចិនជាដើម តែងមានលក្ខណៈជាអ្នកមានមាន: ខ្ញុំឃ្លាតព្យាយាមតស៊ូទឹងទឹកដីអាកាស ជ័ត្តកាយរកវែធាតុក្នុងដែនដីមកប្រើជាប្រយោជន៍បាន ពុកជាមានហើម: នាំឲ្យត្រជាក់ងើយជាចំផុតក៏នៅតែមានតំនិតចេះប្រើធម្មជាតិជាត្រឿងតំសាន្តចិត្ត ដូចជាប្រណាំងតស៊ូសេចក្តីត្បាផ្សេងៗបាន ។

ឯពួកជនដែលនៅក្នុងប្រទេសស្កូ ច្រើនតែចៀសជាទាសានៃធម្មជាតិ
មានមានៈ ៣យ៉ាយមកតាម មិនស្ថិតមានតំនឹងតតិតឡើយឡានស្មើនឹងរកសេចក្តី
ចំរើនទេ ។

ទុកជាឥណ្ឌៀជាជាតិចរមបុរាណជំនាន់ស្មើនឹងជាតិឯទៀត ។ ដែល
បានពោលមកហើយកំដោយ ប្រវត្តិសាស្ត្រដែលស្រាវជ្រាវរកបានក្នុង
វេលានេះក៏មិនស្មើនឹងគ្រាកប្បាកមទេ ពោលគឺសេចក្តីចំរើនរបស់ឥណ្ឌៀ
កន្លងមក: វេលា ៣ - ៤ ពាន់ឆ្នាំ មានការចំរើនតិចជាងសេចក្តីចំរើនរបស់
គ្រាកនឹងកេម កន្លងមក: វេលាមិនដល់ ១ ពាន់ឆ្នាំ ។ តែទុកជាយ៉ាងណា
ក៏ដោយ នៅតែគួរពេញចិត្តថា ឥណ្ឌៀជាប្រទេសចំរើនយ៉ាងវៃក្រៃលែង ១ កន្ល
សម័យបុរាណ ហើយតនឹងខ្នង់រហូតមកដល់សព្វថ្ងៃនេះ មិនសោយជាតិ
សាបសូន្យទៅ ។ អារ្យធម៌របស់ឥណ្ឌៀជាមាតានៃអារ្យធម៌របស់ទ្វីប
អាស៊ីទាំងមូល ។ ជនជាតិក្រិតជាទីកើតនៃអារ្យធម៌របស់អឺរុបយ៉ាងណា
ឥណ្ឌៀក៏ជាទីកើតនៃអារ្យធម៌របស់អាស៊ីយ៉ាងនោះដែរ ។ ភាសាសំដី
របស់ឥណ្ឌៀផ្សាយចេញទៅហើយ ក្លាយជាភាសាសំដីរបស់នានា
ប្រទេស រីឯជាងរបស់ឥណ្ឌៀជាគំរូបែបដែនៃការជាងរបស់ជាតិដទៃ ។
ជាច្រើនជាតិ តែតែមានអ្នកប្រាជ្ញប្រវត្តិសាស្ត្រខ្លះ ហៅឥណ្ឌៀថាជា
« ក្រែងនៃអាស៊ី » ។

បើយើងពិនិត្យតាមប្រវត្តិសាស្ត្រ ទើបយើញថា ប្រទេសឥណ្ឌា
ច្រៀតត្តធ្វើកិច្ចការជាបុណ្យជាបាប ក៏ព្រោះមានចិត្តជាមុនជាមេជាមគ្គ-
នាយកបង្គាប់ច្រាប់ឲ្យធ្វើ » ។ អំពើជាសុចរិតនឹងពុំបុរិតនេះឯងរមែង
ជិតជាមភាមឲ្យផលជាសុខនឹងជាទុក្ខផល់ប្តូរលុ ដូចស្រមោលអនុលុ
តាមប្រាណជូរច្នោះឯង ។

ហេតុនេះ សាធុជនគួរកែប្រាកាវចិត្ត កុំឲ្យលិចចុះលង់ចូល
ចំណូលទៅក្នុងផ្លូវអាក្រក់តីកុំឲ្យចិត្តតិតចង់បានច្រៀត អ្នកជាខៃលើមកធ្វើ
ជាវេរស់ខ្លួន, កុំឲ្យចិត្តតិតរុកកួនញ៉ាំបានតេ, កុំឲ្យចិត្តតិតយល់ខុសថា
ជាត្រូវ ។ ក៏ចិត្តដែលប្រតិបដោយលោភ ទោស: មោហ: ទាំង ៣
យ៉ាងនេះណាមួយហើយឈ្មោះថាជាចិត្តមិនស្អាត ជាចិត្តគ្រោតគ្រាត ។
កាលបើចិត្តនៃបុគ្គលឯណាតវល្អក់មិនស្អាតផ្លូវផង់ ជាចិត្តសៅហ្មងហើយ
បុគ្គលនោះឈឺចាប់ឃ្លានខ្លួនទៅនឹងទៅកើតក្នុងពុតិតភពជាច្រើនជ កាល
បើចិត្តបរិសុទ្ធស្អាតជ្រះថ្លាពីញឹនឹងទៅកើតក្នុងសុគតិភព ដោយពិត ។

๔ - ព្រះមុនិន្ទជាម្ចាស់ទ្រង់បានត្រាស់ជំងឺអនុត្តរសម្មោធិញ្ញាណ
មានព្រះបញ្ញាចាក់ធ្លុះយល់វែងឆ្ងាយ ទ្រង់ជ្រាបច្បាស់ហេតុផលបាប
បុណ្យគុណទោសខុសត្រូវផ្លូវនរកសួគ៌និព្វាន មានច្បាស់ផង
ច្បាស់ជាន់ត្រង់ច្បាស់ឆាំង ។ អំពើណាអាក្រក់លាមកជៀកជាប ទ្រង់
លះបង់ដោយ ព្រះអង្គឯងព្រមទាំងសំដែងប្រាប់សត្វឲ្យលះបង់ផង អំពើ
ណាជាបុណ្យគុណសុចរិត ព្រះអង្គទ្រង់សន្សំឲ្យកើតមាន ព្រមទាំង

ទៀនប្រដៅសត្វឲ្យប្រតិបត្តិតាមផង ។ នេះជាគុណទី ๑ របស់ព្រះពុទ្ធ ហៅថា បញ្ញាគុណ ។

ព្រះសម្ពុទ្ធមិនមែនមានតែមួយបញ្ញាប៉ុណ្ណោះទេ ព្រះអង្គខ្ជាប់ខ្ជួនបញ្ញានោះមួយឯងគាត់បំបាត់អាសវក្កិលេសតណ្ហា ឲ្យអស់មិនមានសេសសល់សំណល់ក្នុងសន្តាន ខ្ជាប់មានព្រះហឫទ័យបរិសុទ្ធផុតមន្ទិលសៅហ្មង កន្ទងហួសសើយចិត្តរបស់សាមញ្ញសត្វក្នុងលៃតែកពព្រះអង្គមិនញាប់ញ័រមិនកក្រើករំភើបក្នុងព្រះហឫទ័យ ខ្ជាប់មានព្រះហឫទ័យនឹងធឹងឥតដោរនោច មិនឃ្លេងឃ្លោង មិនប្រាំងផត មិនខ្ពស់ទាប ដៅតាមលោភធម៌ឡើយ ព្រះអង្គដល់ខ្លួរការជាអ្នកប្រសើរក្រៃគួរប្រមាន ។ នេះជាគុណទី ๒ របស់ព្រះពុទ្ធ ហៅថា វិសុទ្ធិគុណ ។

ព្រះអនន្តញាណខ្ជាប់មានបញ្ញានឹងឧបវិសុទ្ធនេះ ឈ្មោះថា ព្រះអង្គមានព្រហ្មចរិយកិច្ច ធ្វើរួចស្រេចហើយ បើព្រះអង្គព្រងើយឥន្ទ្រីយមិនខ្វល់ខ្វាយធ្វើអ្វីទៀត ហេតុដល់ព្រះអង្គខ្ជាប់ចរិនិព្វានទៅវិញ ក៏ឯនដែរ តែព្រះអង្គនឹងធ្វើដូច្នោះមិនកើត ព្រោះព្រះអង្គមានព្រះមហាករុណាគុណដ៏ឥតលើសលុបដល់មនុស្សសត្វខ្លាំងពូកែ ដែលកំពុងនេះក្តៅដោយភ្លើងគឺលេសតិកៈ ទោសៈ មោហៈ ខឹងភ្លើងទុក្ខគឺជាតិជរាព្យាធិមរណៈជាប់ជំពាក់ខាក់ខិនជាប់រឹតរវៃរឹមរាមក្នុងភពវដ្តសង្សារតែជាប តែជួស ជ្រុលជ្រួស ផ្ទេមផ្ទឹម ផ្ទេលផ្ទោល កើតស្លាប់ៗកើត

ច្រែនកំណើតមិនកំណត់ក្នុងភពបី ។ ព្រះជិនស្រីច្រើនក៏ទំនងគ្នាយ ព្រហ្ម-
វិហារធម៌ដល់សព្វសត្វដោយឥតរើសមុខ ហើយច្រើនបំប្រាសសត្រាស់
ខ្លួនច្រៀនច្រដោសត្វ ដោយឥតគិតដល់ការខ្ជិលហត់ឡើយ តាំង
អំពីសម្ពោធិសម័យរហូតដល់ថ្ងៃបរិនិព្វានជាទីបំផុត នេះជាគុណទី ៣
នៃព្រះពុទ្ធហៅថា កតញ្ញូតាគុណ ។

ព្រះសម្មាសម្ពុទ្ធច្រើនបំប្រណាំដោយឋញ្ញាគុណ វិសុទ្ធិគុណនឹងករុណា
គុណជូចជាទពលិនាមគុណនេះ បើជនណាមានចិត្តជ្រះថ្លានឹងព្រះអង្គ
ហើយជននោះរមែងបានសេចក្តីក្សេមក្នុងលោកនេះនឹងលោកខាងមុខ
គួយាំងជូចមង្គលកុណ្ឌលីមាណព ដែលបានដំណាលក្រុមមកហើយនោះ
ឯង ។

នាមដើមខ្ញុំឈ្មោះអត្ថ "ណ" ស្រែអាខ្សល់ត្រង់ស្រែអ៊ុ
រួមនួចបូចគ្នាជា "ណាត្រី" បិតនោះគឺវត្តខ្លួលតាឯង ។
ខ្ញុំបានរៀបរៀងរឿងកំរនេះ សូមលើកអ្នកនេះគិមិត្តខែត
ត្រង់ណាភ្លាំងភ្លាត់ប្តូនសូផ្តក ខ្លួនខែចជូនញាតជាតិនេមរៈ ។
សូមព្រះសទ្ធម្មបិតតំមត់ សូមរដ្ឋធម្មញ្ញាវរៈ
សូមតម្កុជាវុឌ្ឍនៈ សមសក្តិរឿងរឿងអើយ ។

ឃុនបញ្ញាសុរក្ស ប៊ូ-ប៉ូ ពៀបរៀង

(តទៅទៀត)

ដោយឲ្យបេះដូងក្តី ដោយបង្ហាត់បង្រៀនចំណេះវិជ្ជាក្តី ហើយទទឹងដល់សេចក្តីល្អរបស់មនុស្សដែលខ្លួនស្រឡាញ់ចង់អាន មានមាតាបិតាគ្រូអាចារ្យជាដើមថា «លោកចាំងអស់នោះសុទ្ធតែបានធ្វើសេចក្តីល្អខុងមងពីមុនៗ ក្នុងម្នាក់ៗ មិនមែនតិចទេ» ក្នុងវេលាដែលទឹតនោះត្រូវឲ្យតាំងគិតដល់សេចក្តីល្អរបស់លោកចាំងអស់នោះឲ្យឃើញសព្វគ្រប់ជា។

២ - ឲ្យទទឹងដល់អំពើល្អដែលធ្វើឲ្យអ្នកដទៃបានល្អបានសុខថា «គេបានល្អបានសុខដោយគុណធម៌ណា គុណធម៌នោះយើងក៏មានដូចគេដែរ» ត្រង់ទីនេះបានសេចក្តីថា យើងទទឹងដល់អ្នកណាជាគួរយ៉ាងដើម្បីបណ្តុះចិត្តយើងឲ្យរីកឈ្ងៃ យើងត្រូវពិចារណាមើលសេចក្តីល្អរបស់អ្នកនោះ ជាមុនហ៊ានទើបពិចារណាមើលខ្លួនយើងថា «យើងគ្មានគុណធម៌បែបនោះដូចគេទេ» ឬមួយឃើញថា «យើងមានគុណធម៌បែបនោះដូចគេដែរ» ត្រូវឲ្យធ្វើចិត្តខ្លួនគេទទឹងខ្លួនយើងជាមិនត្រៃយ៍។

៣ - ឲ្យទទឹងដល់គុណរបស់ព្រះទំព្នាយថា «ព្រះទំព្នាយគ្មានសេចក្តីសោយសោក គ្មានសេចក្តីខ្វល់ខ្វាយ មានតែសេចក្តីសុខមួយយ៉ាង»

ប៉ុន្តែអ្នកដែលមិនភ្ញាក់ផ្អើលមិនភ្ញាក់ផ្អើលដដែលរឿងព្រះនិព្វាន ទើបឲ្យនឹកដូច្នោះមិនបានទេ គ្រាន់តែឲ្យគេនឹកដល់គុណនៃសេចក្តីវិនាសយសប្បាយចិត្តថា មានសេចក្តីសុខយ៉ាងណា ប៉ុណ្ណោះបានហើយ ព្រោះថាលុះបើគេនឹកយ៉ាងនេះហើយ គេតាំងតែនឹងដឹងថា « សេចក្តីវិនាសយសប្បាយចិត្តតែងធ្វើឲ្យបានសេចក្តីសុខជាច្រើន » ដូច្នេះគេភ្ញាក់ដឹងមកនឹងខ្លួនគេស្រាប់ហើយ ។

៤ - កុំឲ្យសេពគប់នឹងមនុស្សខូលខុក ឲ្យសេពគប់តែនឹងមនុស្សដែលមានចិត្តវិនាសយក្បៀក្បាជាដើម ព្រោះថានឹងធ្វើខ្លួនឲ្យវិនាសយទៅតាមគេផង ។

៥ ឲ្យនឹកតែគ្រង់រឿងដែលនាំឲ្យចិត្តសប្បាយវិនាសយ ដែលខ្លួនភ្ញាក់ផ្អើលបានឮបានស្តាប់មកអំពីក្បួនច្បាប់ឬអំពីអ្នកដទៃ ឬក៏រឿងដែលធ្លាប់ធ្វើខ្លួនឲ្យមានចិត្តសប្បាយវិនាសយខកគាប់ដើម ទោះជាឈរសេងសើចក្តីធ្វើការងារមែនទែនក្តី ពាក្យសំដីយ៉ាងណាក្តី ។

៦ - ឲ្យបញ្ឈប់ចិត្តទៅកន្លែងសេចក្តីវិនាសយ ពាល់តែចិត្តកើតសេចក្តីត្រែកត្រអាល គឺឲ្យហាត់ធ្វើជាអ្នកសប្បាយវិនាសយ កុំឲ្យហាត់ធ្វើជាអ្នកខូលខុក ។

ឈរធ្វើតាមគោលទាំង ៦ ប្រការនេះបានហើយ សេចក្តីសោយសោកឬក៏ចិត្ត, លើចិត្ត, អាក់អន់ចិត្តដែលកើតឡើងកន្លះវិនាទីក៏ចាប់

ប្តូរសំលាចាស់ក្រ, សំលាត្រាត់ប្រាស់ចាកមនុស្សដែលខ្លួនស្រឡាញ់ ប្តឹងគ្នាចាន់ដែលខៅទំនងបែស់ទ្រព្យជាដើម ចិត្តសៅសោយសោកសែងតូចចិត្តសៅបាន ចិត្តត្រឡប់ជាសប្បាយកែកយកត្រគត់ត្រអាលឡើងហើយបរិភោគអាហារក៏បាន ដេកក៏លក់ ធ្វើអ្វីក៏បានសម្រេចដូចប្រាថ្នា ។

๕ - វិជ្ជាកំចាត់សេចក្តីមិនសប្បាយចិត្ត គឺចិត្តអង្គុតមាន ๖ ប្រការគឺ:

๑ - ឲ្យបរិភោគតែអាហារដែលត្រូវនឹងកាលយើយបែស់ខ្លួន គឺអាហារដែលចរិភោគទៅហើយមិនធ្វើឲ្យហើមចាស់ ឬឲ្យស្ទឹតស្ទៃ, ឲ្យតឹងគោះផ្អែះ ។

๒ - ឲ្យរើសរកអាកាសជាទីត្រូវនឹងខ្លួនស្រួយចិត្តថ្លើមរបស់ខ្លួន គឺថាបើខ្លួនត្រូវនឹងអាកាសត្តៅខ្លាំងឬត្តៅអ៊ុន ។ ឬក៏ត្រជាក់ ក៏ឲ្យរកទីដែលមានអាកាសដូច្នោះជាទីស្រួចយកអាម្មណ៍ តែមានមនុស្សជាច្រើនត្រូវនឹងអាកាសត្រជាក់ ឬត្តៅអ៊ុន ។ ឯអាកាសត្តៅខ្លាំងខាលតែស្អុះស្អាប់នោះមានតែមនុស្សលោហិតតិចទើបត្រូវគ្នា ។

๓ - ឲ្យរើសនូវយោបថជាទីសប្បាយ គឺថាបើខ្លួនត្រូវនឹងឥរិយាបថណាច្រើន ក៏ឲ្យប្រកាន់យកឥរិយាបថនោះជាប្រមាណ (ពាក្យថាឥរិយាបថ បានដល់ការដេក, ដើរ, ឈរ, អង្គុយ) ។

៤ - ឲ្យធ្វើខ្លួនជាកណ្តាល។ កុំបណ្តោយចិត្តឲ្យតែកាយឬឲ្យអាក់អន់ក្នុងវេលាខ្លួនឯង ឬអ្នកដទៃមានទុក្ខភ័យអន្តរាយ ឬក៏ចាន់សេចក្តីសុខសេចក្តីចំរើន ការដែលនឹងធ្វើចិត្តឲ្យជាកណ្តាល។ ដូច្នោះបាន ត្រូវឲ្យនឹកពិចារណាជាញឹកញាប់ថា "ព្រោះតែកម្មជារបស់យើង, របស់គេ"។ ត្រង់ពាក្យថា «ឧត្ត» នេះជាពាក្យកណ្តាល។ សំដៅយកតាំងពីខាងល្អតាំងខាងអាក្រក់។

៥ - កុំឲ្យសេពគប់នឹងមនុស្សដែលខៅមិនសុខ។ គឺមនុស្សដែលបូលចិត្តតែបៀតបៀនអ្នកដទៃ បូលចិត្តតែធ្វើឲ្យគេក្តៅក្រហាយឲ្យគេតឹងតែង ត្រូវសេពគប់នឹងមនុស្សដែលបូលចិត្តតែខាងសេចក្តីស្ងប់ប៉ុណ្ណោះ។

៦ - ត្រូវធ្វើចិត្តឲ្យធ្ងន់ខៅក្នុងដំណើរស្ងប់កាយស្ងប់ចិត្ត ឥរិយាបថនឹងឲ្យតាល់តែកើតចិត្តស្ងប់ដែលចាត់ជាសេចក្តីសប្បាយ ឈឺសប្បាយចិត្ត។

កាលបើធ្វើតាមគោលចាំង ៦ ប្រការនេះបានហើយ មុខជាបានទទួលសេចក្តីសប្បាយកាយសប្បាយចិត្តជាប្រាកដ លែងក្តៅក្រហាយដោយរឿងដែលកើតក្នុងចិត្តទៀត។

៦ - វិធីកំចាត់បិត្តមិនឆឹង, មិនធ្ងន់ធ្ងរ មាន ៤ ប្រការគឺ ÷

១ ត្រូវរក្សាសេចក្តីស្អាតចាំងខាងក្នុងខាងក្រៅ គឺត្រូវសំអាត

ឯងកាយ , សំលៀងបំពាក់ ត្រូវរក្សាបរិស័ទ្ធឲ្យស្អាតបាត ជានិច្ច ។

២ - ត្រូវធ្វើតុណាធម៌ ៥ យ៉ាងគឺ សេចក្តីជឿ ១ សេចក្តីព្យាយាម ១ សេចក្តីព្រម ១ សេចក្តីតាំងចិត្ត ១ សេចក្តីត្រិះរិះ ១ ឲ្យមានស្មើៗគ្នា កុំឲ្យតិចច្រើនជាងគ្នា ។

៣ - ត្រូវឲ្យគ្រាតក្នុងការកំណត់ចាំត្រឿងសំគាល់បេស់ផ្សេង ។ ដែលយើងបានជួបប្រទះ គឺថាការបើបានឃើញបេស់អ្វី ត្រូវតែចាំបានណារកបេស់ជាត្រឿងសំគាល់ដែលអាចនឹងធ្វើឲ្យយើងសង្កេតចាំបានពិតប្រាកដកុំគ្រាន់តែមើលទេ ។

៤ - ត្រូវបេះបណ្តុះបណ្តាលចិត្តឲ្យរឹងប៉ឹងខ្លាំងណែន ឲ្យរាក់ឆន្ទៈនឹងត្រូវបេះប្រដៅចិត្តឲ្យល្អគឺកុំឲ្យចិត្តក្តាហានហួស កុំឲ្យចិត្តរាក់ឆន្ទៈហួស កុំឲ្យចិត្តអណ្តែតអណ្តូងរវើរវាយ ។ ឯវិធីដែលនឹងធ្វើចិត្តឲ្យបានល្អដូច្នោះ ត្រូវឲ្យនឹកពិចារណាដល់បេស់ដែលធ្វើចិត្តឲ្យខ្ជិនខ្ជាយ ឲ្យខុនឆ្គាំ គាលបើនឹកឃើញបេស់ដូច្នោះហើយ ត្រូវលះចោរបេស់នោះចោលចេញ ហើយឲ្យនឹកពិចារណាដល់បេស់ដែលធ្វើចិត្តឲ្យរឹងប៉ឹងខ្លាំងណែន ដែលធ្វើចិត្តឲ្យរាក់ឆន្ទៈសប្បាយ ដែលធ្វើចិត្តមិនឲ្យរវើរវាយវិញ ។

៥ - បើដឹងថាចិត្តខ្លួនបានធ្វើនូវអំពើបាបខ្លួនហើយ ត្រូវឲ្យឈប់ស្ងៀមត្រឹមណោះ កុំបន្ទាបចិត្តបុះ កុំដំកើងចិត្តឲ្យខ្ពស់ឡើងឲ្យតែ

ត្រូវចេះចិត្តឲ្យនៅនឹងនៃត្រឹមប៉ុណ្ណោះ តាល់តែចិត្តនោះជាប់ជាមិនស្ប័យ
របស់ខ្លួនបានពិតប្រាកដ ។

๖ កុំឲ្យសេពគប់នឹងមនុស្សចិត្តសាក, ចិត្តមិននឹងខ្លួនមិនឆ្ងល់
ត្រូវសេពគប់តែនឹងមនុស្សចិត្តខ្ជាប់ខ្ជួនឆ្ងល់ឆ្ង ជាអ្នកធ្វើអំពើអ្វីធ្វើមែនចែន
មិនលេះលោះ មិនសាក ។

๗ - ត្រូវទឹកតែរបស់ដែលខ្លួនបានតាំងចិត្តពុតរួចមកហើយថានឹង
ធ្វើហើយទំរាំធ្វើរបស់នោះឲ្យតាល់តែបានសម្រេចតាមបំណងនឹងត្រូវ
ធ្វើតែអំពើល្អ មិនត្រូវធ្វើអំពើអាក្រក់ឡើយ ។

๘ - ត្រូវធ្វើចិត្តឲ្យស្មើនៅកន្លែងដែលខ្លួនជាប់ខ្លួន ត្រូវស្រឡាញ់តែកន្លែង
ដែលខ្លួនជាប់ខ្លួនជានិច្ច ។

កាលបើធ្វើតាមគោលតាំង ๘ ប្រការនេះបានហើយ នឹងតែនឹង
បានជាមនុស្សមានចិត្តមាំមួនឆ្ងល់ឆ្ងមិនខាន ។

๓ - វិជ្ជាសម្រាប់កំចាត់ចិត្តមិនតាំងនៅជាកណ្តាល

មាន ๘ ប្រការគឺ :

๑ - កន្លះវេលាខ្លួនឯងដែលប្អូនកងនៃបានខុសក្តី បានសុខក្តី ត្រូវ
ទឹកថា ព្រោះតែនម្នាក់ក្រក់ម្ខាងម្ខាងរបស់ហើយនឹងនឹងរបស់គេ ឬមួយទឹក
ថាគ្មានអ្នកណាបានខុសបានសុខទេឡើយ មានតែជាគុ ๔ ប៉ុណ្ណោះបាន
ខុសបានសុខ ។

๒ - ត្រូវនឹកថា គ្មានអ្នកណាជាម្ចាស់បេស់អ្វីៗឡើយ បេស់ទាំងអស់គ្រាន់តែជាគ្រឿងអាស្រ័យ មួយដងមួយៗលប់ប៉ុណ្ណោះទេ ប្តមួយទឹកថា បណ្តាបេស់ទាំងអស់សុទ្ធតែជាបេស់មាននៅមួយសំណើរប៉ុណ្ណោះទេ មិនបាននៅបិតបេរយើនយូរឡើយ ។

๓ - កុំសេពនឹងមនុស្សដែលងប់ចិត្តនឹងអ្នកជាទៃឬបេស់ដទៃ ពាល់តែចេញអាការច្រែកជាមកទាំងគ្រែ ដូចជាចូលចិត្តស្រឡាញ់អ្នកណាក៏បេះតែវង្វេងទៅតាមអ្នកនោះដែរនាំលែងជាន់ខ្សត្រូវ ឬមួយស្រឡាញ់បេស់ណាកាត់ចិត្តពីបេស់នោះមិនជាប់ ។

๔ - ត្រូវសេពនឹងតែនឹងមនុស្សជាកណ្តាលៗក្នុងអ្នកជាទៃឬបេស់ដទៃ គឺជាមនុស្សមិនលំអៀងព្រោះសេចក្តីស្រឡាញ់ឬស្អប់ជាដើម ។

๕ - ត្រូវបញ្ជូនចិត្តឲ្យស្មើឲ្យធ្ងន់ទៅក្នុងផ្លូវកណ្តាលៗជាដរាប ត្រូវរំបង្ហាត់ចិត្ត ទាញចិត្តទៅកែតែងផ្លូវកណ្តាលជាដរាប ពាល់តែបានជាងប្បាស់ថាចិត្តរបស់ខ្លួនតាំងនៅសិប់ក្នុងផ្លូវកណ្តាលមែនទែនហើយ ។

កាលបើធ្វើតាមគោលទាំង ๕ ប្រការនេះបានហើយ មុខជានឹងកំចាត់ចិត្តលំអៀងឲ្យខ្ចាត់ចេញទៅបានជាមិនខាន ។

វិជ្ជាទាំង ๗ ប្រការដែលបានតណិនាមកហើយនេះ ជាវិជ្ជាមានគុណវិសេសដល់មនុស្សយ៉ាងធំក្រៃលែង ព្រោះថាបើអ្នកណាមិនវង្វេងភ្លាំងភ្លេច, មិនល្ងង់ខ្លៅ, មិនខ្ជិលច្រអូស, មិនតូចចិត្ត, មិនអផ្សុកចិត្ត,

ដំនាងឆាយលេះលោះ, ដំនលំអៀនជាឧក្កដ្ឋលហើយ អ្នកនោះនឹងធ្វើ
កិច្ចការអ្វីបន្តិចតិចហេតុអ្វី សូម្បីជាការកែលំបាកឬជាហេតុជ្រាលជ្រៅ
កំបាំងនឹងតិចត្រង់ជ្រាក៏អាចធ្វើឲ្យសម្រេចតាមគ្រាថ្មាបាន ហេតុនេះ ស្ទួ
តែអ្នកវង្វើងភ្លាំងភ្លេចច្រើន ។ល។ អ្នកមានចិត្តលំអៀន ទំព្រឹងព្រឺត្តូ
តាមវិស្សាចាំង ៧ ប្រការនេះឯង ។

វិស្សាវរឿង ៧ ប្រការ ចប់តែប៉ុណ្ណោះ

ប្រវត្តិបុព្វចរិយា

របស់ព្រះមហា មាស – យូ ចៅអធិការវត្តក្បាលកោះអន្ទង់ចិន

ព្រះគេជព្រះគុណ ព្រះមហា មាស - យូ មានានាមធម៌ បិតា
នាមមាស លោកកើតនៅភូមិចណ្តាលកោះ ឃុំកោះអន្ទង់ចិន ស្រុក
ស្អាង ខែត្រកណ្តាល ក្នុងពុទ្ធសករាជ ២៤២៣ ឆ្នាំម្សាញ់ ត្រីស័ក
ខែចេត្រ ថ្ងៃអង្គារ ។

កាលលោកនៅជាកុមារ អាយុបាន ៧ ឆ្នាំ មានបិតាបានទាំយក
ទៅឲ្យទៅសិក្សាអក្សរសោ ស្ត្រីក្នុងសំណាក់លោកគ្រូព្រំ វត្តកណ្តាលកោះ
ដោយដល់ចេះមើល ចេះសរសេរបានយ៉ាងស្អាត់ ។ លុះអាយុ ១២ ឆ្នាំ
បានបព្វជ្ជាជាសាមណេរ នៅវត្តនោះបាន ៣ វស្សា កំលោចាក
ស៊ីក្សាបន្ថែមជាយោងវាស ប្រែកបអាជីវកិច្ចតាមសម្ថានជីវៈ បណ្តាលយូ
មានកំរិយាសុភាពកបសារ មានវាចាទន់ភ្លន់ពីកេះផ្តែមល្អែមចេះគួរសម
ធ្វើញាតិសន្ថានត្រឹងលានចាស់ទុំព្រឹទ្ធាចារ្យណាស់ ពេញចិត្តតែធំធំ
ការស្អាតជាទំនួ ។

លុះអាយុបាន ២១ ឆ្នាំ ទើបកូលមកឧបសម្បទាជាភិក្ខុ ក្នុងវត្ត
ក្បាលកោះ លោកគ្រូសុវណ្ណបញ្ញោ នាមស៊ូ ជាព្រះឧបជ្ឈាយ៍ លោកគ្រូ
អន្ទង្គោ នាមតង់ ជាកម្មវាចា លោកគ្រូព្រហ្មជោតោ នាមអ៊ុំ ជាអនុសាវនៈ
បានឆ្លងឆ្លាយថា សុវណ្ណជោតោ ក្នុងឆ្នាំថ្លូវត្រីស័ក ព ស. ២៤២៤
ខែពុធយាសាធ ថ្ងៃព្រហស្បត៍ ៣ រោច ។

លុះចប់សម្បាវារៈហើយ ក្នុងវស្សាទី ១ ទី ២ បានរៀនជាដំបូងក្នុងបាលីនិងមគ្គាណាវៈ ចេះចាំយ៉ាងស្ទាត់ជំនាញក្នុងការសូត្រ, ឧស្សាហ៍ធ្វើវត្តប្រតិបត្តិចំពោះគ្រូបាធ្យាយដោយសេចក្តីគោរពយ៉ាងក្រៃលែង ។

វស្សាទី ៣ ក៏លាព្រះទេវជ្ឈាយ៍ចេញទៅសំណាក់ព្រះឧម្មដ្ឋានឯវត្តកៀនស្វាយក្រៅ ស្រុកកៀនស្វាយ ក្នុងសំណាក់លោកគ្រូនាមតង់ បាន ៣ វស្សា ក៏ត្រឡប់មកកាន់វត្តដើមវិញ ។

វស្សាទី ៤ បានចេញទៅគ្រូចារសកម្មឯវត្តសាត់សំរោ លុះរួចកិច្ចហើយ ទើបនិមន្តចង្ហុសទៅនៅរៀនព្រះវៃត្រចិងឯវត្តទ្រខនង់ (ខាងខ្ទុំធំ) នៅរៀនក្នុងទីនោះបានមួយវស្សា ។

វស្សាទី ៥ ដល់វស្សាទី ១៦ ត្រឡប់មកនៅសិក្សាឯវត្តកែវព្រះភ្លើងវិញ ក្នុងសំណាក់លោកគ្រូសាក្យវង្ស ឃួន បានប្រែតម្ពីរធម្មបទពីលោកគ្រូឈាចារ្យព្រំ-ភេត តាលនៅជាសង្ឃនៅឡើយ ហើយដែលទើបនិមន្តមកពីបាធិតថ្មី ។ ព្រះសពមានសេចក្តីព្យាយាមសង្ឃានរៀនសូត្រណាស់ តាំងមានសេចក្តីជ្ងន់ជ្ងមអត់ធន់ធ្ងន់ការក្រែលំបាកគ្រប់យ៉ាង ។ ដោយកំលាំងនៃការព្យាយាម ទើបសេចក្តីចង់ច្រើនេះហើយ ដែលធ្វើឲ្យលោកបានទៅជាអ្នកមានចំណេះវិជ្ជាដោយមុតមាំក្នុងផ្លូវពុទ្ធសាសនា ។ ក្នុងជំនាន់នោះព្រះកុណាជាម្ចាស់ជីវិតជាខុនសោដ្ឋ បានទ្រង់ព្រះពាធុញ្ញាតបើកឲ្យព្រះសង្ឃដែលចេះព្រះវៃត្រចិងជកចាំនិយាយបួលទៅប្រឡងដេញ

ប្រយោគទៅវិហារព្រះមែរមេន ។ ឯលោះព្រះសពគឺបានបុះឈ្មោះ
ចូលទៅប្រឡងជាមួយនឹងព្រះសង្ឃឯទៀត ។ ជារៀង កំបានជាប់ជ័
ជាមហា ៤ ប្រយោគ ក្នុងឆ្នាំជូត ចត្វាស័ក ព.ស. ២៤៥៥ ថ្ងៃគាត់ស
៣ កើតខែផល្គុន ។ ព្រះគុណាទ្រង់ព្រះកជាមធ្លុតមួយនឹងទេយ្យ-
វត្ថុជាច្រើនទៀតជាផ្លាន់ នឹងសេចក្តីសរសើរអំពីសារព្យាយាម ដែលលោក
ចំរើនរៀនសូត្រជាបដល់បានសម្រេចប្រយោជន៍ ។ រួចកំប្រឡង
ហើយ កំនិមន្តទ្រង់ព្រះមកនៅវត្តកាលកោះវិញ ។

តាំងពីសប្តាទី ១៣ ខែឆ្លងទៅ ព្រះសពចាប់ផ្តើមបង្ហាប់ចេញ
ជាលីព្រះកៃតែបង្ហូរជល់កំភ្លុ . សាមណេរដែលនិមន្តមកអំពីវិជ្ជនៅផ្សេង ។
ព្រមទាំងទេសនាដឹកនាំពន្យល់ទូជាសក . ទូជាសកា ឲ្យបានចេះដឹង
ស្គាល់កិច្ចប្រតិបត្តិដ៏ត្រឹមត្រូវតាមផ្លូវពុទ្ធសាសនា តាំងសំពះលោក
កំសួរសុខទុក្ខយ៉ាងសាយសុះខ្លួទៅកន្លងទីតាំងពួន ។

ដល់មកក្នុងឆ្នាំកៃតិស័ក ព.ស. ២៤៦៤ លោកត្រូវព្រហ្មជាតៃ
តាមអ៊ុំជាទៅអធិការវត្តកាលកោះមានតាមជាមុន ។ មិនយូរប៉ុន្មាន
ក៏ទទួលអនិច្ចធម្មទៅក្នុងថ្ងៃអង្គារ ១៤ កើតខែមិគសិរវេលាម៉ោង ១០ ព្រឹក ។
ឯសពលោកគេដាំកល់ទុកចំនួន ៤ ថ្ងៃ តាជាបមកដល់ថ្ងៃ ១៤ កើត
ខែនាយទើបបានធ្វើបុណ្យឈាបនកិច្ច ។

លំដាប់នោះ ព្រះតេជព្រះគុណ ព្រះមហាមាស - យូ បានទទួលភារៈជាចៅអធិការតរៀងមក លោកទំយកព្រះទ័យទុកដាក់កិច្ចការរៀបចំវត្តអារាម ឥតងាករកសាងសេនាសនៈផ្សេង ។ តែសាងព្រះវិហារកើងធំ កើងសំរិទ្ធិស័ក ព. ស. ២៤៧១ ព្រមទាំងសាលា ភូព-ជំ, កុដិភូព-ធំ ធម្មមន្ទីរហោត្រយ ឥតងព្រះចេតិយសំពះបញ្ចុះឆាកុន្ត្រែនចេស់លោក, បានបង្កើតឲ្យមានសាលាបាលីរៀន ចំនុកបំរុងឲ្យមានគាថារៀមកបង្រៀនកាល់ឆ្នាំ ក្នុងមួយឆ្នាំ ។ មានព្រះសង្ឃគាត់មកពីស្រុកជិតឆ្ងាយមករៀនសូត្រយ៉ាងតិចបំផុតត្រឹម ៩០ អង្គឡើងទៅ ; បានសុំពរជាឲ្យបង្កើតសាលា-បឋមវិជ្ជា ជាទីបណ្តុះបំណែះវិជ្ជាដល់ពួកកូនចៅអ្នកស្រុកឲ្យបានចេះដឹងគ្រប់ៗគ្នា ។

នៅថ្ងៃអង្គារ ៣ កើត ខែកត្តិក ឆ្នាំមមែចត្វាស័ក ព. ស. ២៤៨៦ ត្រូវនឹងថ្ងៃ ៦ ខែកញ្ញា ព្រះសពបានទទួលគ្រឿងឥស្សរិយយសមើរៃជយច្ចាក់ ដែលព្រះបាទសម្តេចព្រះនរោត្តម - សីហនុ រ៉ូយ៉ែន ទ្រង់មានព្រះហឫទ័យប្រោសព្រះរាជទានទុកជាព្រះកេរ្តិ៍ ដោយសេចក្តីបង់អាន ដ៏ស្មោះអស់ពីព្រះរាជហឫទ័យ ។

ព្រះតេជព្រះគុណ ព្រះសព លោកបួសជាសាមណេរបាន ៣ វស្សា, ជាភិក្ខុបាន ៤៧ វស្សា ។ ចាប់ដើមតាំងពីបួសមក លោកព្យាយាមធ្វើសេចក្តីប្រែតបត្តិជាប្រយោជន៍ដ៏ធំដល់ខ្លួនលោកផង ដល់ជនជាតិផង

ដល់ពុទ្ធសាសនាផង ។ គឺដោយអំណាចនៃបច្ចុប្បន្នភាពយ៉ាងនេះហើយ ដែលនាំឲ្យទីវត្តទាំងមូល ទទឹងមាតុភូមិរបស់លោកយ៉ាងមុខៗ ទៅនេះសេចក្តីចំរើនដោយការចេះដឹងនឹងសេចក្តីប្រតិបត្តិធម៌តាមគ្រប់ត្រាតាមផ្លូវពុទ្ធសាសនា ទឹងចំរើនដោយចិត្តសទ្ធា: កើតមានពាសពេញក្នុងវត្តសំរាប់ជាទីជ្រកកោននៃបព្វជិតទាំងឡាយ ដែលកាលពីដើមមាននៃកុដិស្បូវតូចៗ ហើយមានសុទ្ធតែស្បូវ ទឹងស្មៅស្បែងជុះច្រុះច្រែះ ស្ងាត់សូន្យឈប់ឡើងតេឮសូវនៃសត្វយំតូចៗស្រែងេះស្រែងោច ។ ស្រែពីច្រាជ្រាឈ្មោ សូវនៃទឹងសេចក្តីព្យាយាមពង្រឹងសាសនាឲ្យបានរុងរឿងនេះ លោកនៅមានព្រះទ័យសប្បុរសមួយយ៉ាងទៀតដែលមនុស្សទាំងអស់តម្រូវមាន ហើយដែលនាំឲ្យមានកិត្តិស័ព្ទថាជា «អ្នកច្បាប្ញ» នៃនៃច្បាប្ញដរឡើង ឯព្រះទ័យសប្បុរសនោះគឺលោកមានមេត្តាចិត្តផ្សាយទៅកាន់ចរិយាសីលវត្តរបស់មុខ ។ ទៅវិលាដែលមានពុទ្ធដីកាទៅនេអ្នកណាមួយលោកតែងមានវាចាយ៉ាងស្រទន់ផ្អែមល្ហែម ប្រកបដោយព្រះកត្តញ្ញញ្ញូញ៉ាងសុភាពសំឡីងមើលដោយព្រះនេត្រជ័ពេញទៅដោយមេត្តាទៅនេអ្នកនោះ មានចរិយាសណ្តាប់ធ្នាប់រៀបរយចុះសុតត់ស្រួលសមរម្យជាសមណៈ អ្នកមានសទ្ធានចិត្តស្ងប់រម្ងាប់ជាប់ជាប់ដោយឈរប្រតិត្តិត្រហ្មចរិយធម៌ ព្រោះហេតុនោះមើយ ចានជាពួនសប្បុរសទាំងឡាយ

គ្រាន់តែបានឃើញ - ជួបសន្ទនាជាមួយនឹងលោងតែម្តង ក៏កើតសេចក្តីជ្រះថ្លាឡើង ។

ចំណែរចេរកាលតមក ព្រះសពមានអាពាធក្តៅស្រៀវស្រាញអស់ចំនួនបួនដប់ថ្ងៃ ស្រាប់តែមកដល់ថ្ងៃ ៤ កើតខែពុតឆាសាធ ឆ្នាំកុរនព្វស័ក ព.ស. ២៤៩០ ត្រូវជាឆ្នាំឆុតំរប់ ៦៧ ឆ្នាំ ពេលនោះក៏បណ្តាលឲ្យពុះព្រះលោហិតចេញមកតាមព្រះនេត្តនូវស្បែមពន់ពេក ចាប់ពីនោះមក តាំងហើមខ្លាំងឡើងចន្លិចមួង ។ ជារឿយហូតដល់សតាំង្គឆាយ ចាំងមួល ។ ពួកគ្រូបាសាង - គ្រូបាសិកានឹងសិស្សានុសិស្ស នូវអស់ញោតមិត្តភក្តិតភ័ន្តច្រួលច្រាលមហិមា នាំគ្នាមកព្រហឹងអឺងកងពេញវត្តអារាម ។

គ្រានោះ ពេទ្យហ្គាយាំងចំណាន ។ ក៏បានមកព្យាបាលដោយម៉ឺងម៉ាត់ ប៉ុន្តែមិនអាចកំចាត់កេងនោះឆ្ងាយឡើយ ដរាបដល់ថ្ងៃពុធ ១១ កើតខែស្រាពណ៍ ឆ្នាំជវដែលទើបគេនាំគ្នាមន្តលោកចុះនាវាទៅឯមន្ទីរពេទ្យព្រះកេតុមាលា ព្យាបាលកេនោះអស់ ១ រសៀលតត់ ក៏បានស្រាកស្រាន្តម្ល៉ាប់ចេកអាពាធនោះ។ ហើយក៏គ្រឡប់មកវត្តវិញនៅថ្ងៃ ១៥ កើតខែកត្តិក ។

បណ្តាំដែលគ្រែពេទ្យបានផ្តាំឲ្យតមវៀរយ៉ាងដុំខ្លាន មានតមម្ហូបចំណែកប្រៃនឹងគ្រឿងហឹរក្តៅជាដើមនោះ លោកពុំដែលហ៊ានប្រតិក្ខេបន្ទ

សោះឡើយ ទោះបីមានចំណង់ចង់ធាន់យ៉ាងណាក៏ដោយ ក៏ស៊ូតែទំអត់សង្កត់ចំណង់ ព្រោះខ្លាចគេនោះមានកំឡាំងរឹតឡើងវិញជាន ប៉ុន្តែទុកណាជាប្រយ័ត្នដល់ម្ល៉ោះក៏ដោយ ពេលដែលមានឪកាសយ៉ាងអស្ចារ្យ នោះ គ្រាន់តែគ្រាបសម្លឹងទៅចំនួនជា ១ ឆ្នាំប៉ុណ្ណោះ ក៏គំរើនឡើងជាថ្មី ជាន់វិញ ព្រះសពក៏កោងតែនមន្តទៅឯមន្ទីរពេទ្យម្តងទៀត ។ ប៉ុន្តែ ម្តងនេះ ពុំមានធ្លាប់ថយសោះ អាការធន់ទុំក៏ឈានតែធ្ងន់ឡើងបន្តិចម្តងៗ ឥតស្រាកស្រាន្ត សូម្បីពេទ្យយ៉ាងចំណានមកពាបាលយ៉ាងណា ក៏តែមិនកើត ទីបំផុតលោកក៏សន្មតឃាត់ស្មារតីឥតដឹងខ្លួនត្រាណ សិស្សានុសិស្សដែលថែរក្សាអង្គឈោក ដឹងច្បាស់ថាលោកគ្មានក្តីសង្ឃឹមនឹងជាដែលមកពីដើមហើយ ទើបនាំលោកត្រឡប់មកកាន់វត្តវិញ ។ នៅវេលាយប់ម៉ោង ១១ ទឹក ១៥ នាទីក្នុងថ្ងៃពុធ ១៣ ចេតខែមិគសិរ ឆ្នាំជូតសំរឹទ្ធិស័ក ព.ស. ២៤៩១ ត្រូវនឹងថ្ងៃ ២៩ ខែធ្នូ ឆ្នាំ ១៩៤៧ គ្រង់ជន្មាយុបូលក្នុងវេលា ៦៩ ឆ្នាំ ព្រះសពក៏ទទួលអន្ទិច្ចធម្មចំពោះមុខសិស្សានុសិស្ស ពាំនគ្រហស្ថ ចាប្តូជនដែលមកចោមរោមជុំជិតដោយសេចក្តីសោកស្តាយយ៉ាងលើសលន់គ្មានប្រមាណ ស្ទើរជាខ្លួនមុខរក៏ក្រៀមក្រំដូចជាឆ្លើមធំៗក្រឡូលគ្រប់គ្នា ស្តាយអើយគ្រែលែងស្តាយ ។

នាវេលានោះ គេឮសូរតែស័ព្ទជមិលាន់ឡើងឆន៍ពេញពាំងមន្ទីរហោគ្រែយ ជាកិច្ចជូនដំណើរកន្លងពេលទីបំផុតនៃជីវិតសង្ខារបេះសំលោក

បន្ទាប់ពីនោះមកសំឡេងតន្ត្រីស្តាប់ឮឡើងតន្ត្រីកងគ្រែតន្ត្រីក្រឹស្ទាត់ ជាសញ្ញាឲ្យដំណឹងដល់ជនទាំងឡាយឲ្យបានជ្រាបអំពីព្រឹត្តិការណ៍នោះ ។ មរណសញ្ញានេះ ធ្វើឲ្យពួកសិស្សានុសិស្ស ខ្លាចអស់ញាតិមិត្តទាំងពួងកើតសេចក្តីរំភើបក្តុកក្តួលដួលក្នុងចិត្តដោយសេចក្តីសោកស្តាយយ៉ាងក្រៃលែង ហាក់ដូចជាមានបេះដូងថ្មីមួយទាត់ជ្រុះចាក់ពីក្នុងក្បាល ។

នៅថ្ងៃព្រហស្បតិ៍ ១៤ កេះ គឺជាថ្ងៃបន្ទាប់ពីថ្ងៃអនិច្ចធម្មនោះមក វេលាវេលាម៉ោង ៤ មានការជួបជុំធំ ដោយមហាជនទាំងពួងជិតគ្រហស្ថចាស់ក្មេងជារាប់ពាន់ ចូលមកគាល់ព្រះសពហើយនិមន្តឡើងកាន់ឡាន រួចផ្សាយយ៉ាងជិត ទើបជាក់ក្នុងមឈូសដែលប្រដាប់ដោយគ្រឿងជាន់ដ៏មានតម្លៃបំផុតគួរតាំងសម្រាលខ្នងនិងផ្ទៃល្អពន្លឹក ហែទៅជិតស្ថិតក្នុងសាលាធំយ៉ាងខ្ពស់ត្រដែត ។

ចាប់តាំងពីថ្ងៃនោះដរាបមក ពួកទាហាន - ប៉ូលិសទាំងឡាយក៏នាំគ្នាមកធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសផលប្រគេនលោកពលាលថ្ងៃតាមវេន ។ ពិធីបុណ្យនោះតាំងវេលាយប់និមន្តព្រះសង្ឃចំរើនបរិត្ត ជួនឈឺមានទេសនាផង ព្រឹកឡើងអគ្គិសពកត្តាហារអស់ចំនួន ២ ឬ ១៤ ថ្ងៃ ។ លុះដល់ថ្ងៃអាទិត្យ ១ កើតខែផល្គុន ឆ្នាំជូតស័ក ព.ស. ២៤៩១

ត្រូវនឹងថ្ងៃ ១៣ ខែមីនាឆ្នាំ ១៩៤៩ ទើបគេព្រមព្រៀងគ្នាធ្វើបុណ្យឈា-
បនកិច្ចបូជាសពលោក ដោយពិធីបុណ្យយ៉ាងធំ ក្នុងរាត្រីអធិកអធ័មអស់ ៣
ថ្ងៃ ២ យប់ ។

ចប់ច្បាប់ដោយសង្ខេប ។

ច្បាប់នេះ លោកគ្រូអាចារ្យដាម- ណាងហ៊ាន សុវណ្ណដោតោ មហាបរិយត្តិទត្តវិជ្ជា
នៅវត្តក្បាលកោះ ឃុំកោះអន្ទង់ចិន ស្រុកស្អាង ខែត្រកណ្តាល បានរៀបរៀង ។

រឿងបោះពុម្ពព្រះត្រៃបិដក នៃពុទ្ធសាសនបណ្ឌិត្យ

សាពត៌មានអាសាខ្មែរ ១ ឈ្មោះ «សំខ្មែនខ្មែរ» បេញផ្សាយលើងដំបូង បានចោទសួរពុទ្ធសាសនបណ្ឌិត្យ អំពីរឿងបោះពុម្ពព្រះត្រៃបិដក ។ តែពាក្យចោទសួរនេះ គេអាចឆ្លើយដោយងាយ ដោយគ្មានក្បាយឡើន ប្រសិនបើគេចង់ដឹងរឿងនេះបានអញ្ជើញទៅសួរដល់អធិបត៌ៃក្រុមដំទុំព្រះត្រៃបិដក ឬអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ។ ពាក្យចោទសួរនោះចង់ដឹងថា ៖

១ ១) - ហេតុអ្វី ទើបគេឈប់បោះពុម្ពព្រះត្រៃបិដក ?

១ ២) - ដល់កាលណា ទើបគេចាប់បោះពុម្ពឡើងវិញ ?

យើងតួយល់ថា ការបោះពុម្ពសៀវភៅនោះ ត្រូវមានក្រដាសស្តើង, ក្រដាសក្រាស់ តួអក្សរសៀមាប់បោះពុម្ព ខ្ចីឆ្នាក់កាសផង ។

ប្រសិនបើលោកណាមួយអ្នកធ្លាប់បានធ្វើការបោះពុម្ព នៅពេលដែលពុទ្ធសាសនបណ្ឌិត្យចង្អុំបោះពុម្ពព្រះត្រៃបិដកនោះ គង់ខ្លីដឹងថាក្នុងរយៈវេលា ៣ ឆ្នាំមកនេះ គេបានជួបប្រទះនឹងសេចក្តីលំបាកយ៉ាងសំបើម ក្នុងការបោះពុម្ពគ្រប់មុខ ព័ត្រោះគេឃើញមានតែក្រដាសយ៉ាងអាក្រក់ក្រៃលែង ហើយក្នុងពេលនោះ បើនៅស្តុកមានសល់វិញ គេអាចនឹងបានដោយងាយជាងរកក្រដាសក្រាស់ ។ (កាតុង) ។ ប្រសិន

ម៉ើលោកអ្នកណាមួយដែលចង់គ្រាបរឿងនេះ ចូរអញ្ជើញទៅកាន់ពុទ្ធសាសនចក្តីត្រជៃហើយយើងបានបង្ហាញគ្រជាស្រុកគាយ ដែលគ្រាតតន្រ្តែម មានសំបុរខ្មៅ ដែលយើងគ្រាំអត់មិនបានហើយនៅតែប្រែការសម្រាប់ចោះពុម្ពសៀវភៅលើ ទឹងទស្សនាផ្តើមពុជសុរិយោអស់រៀល ៣ ឆ្នាំមកហើយ ។

យើងមិនអាចប្រែគ្រជាស្រុងអាយនេះ សម្រាប់ចោះពុម្ពព្រៃវែងបានដែលសេសសល់មិនទាន់បានចោះពុម្ពនៅឡើយនេះទេ តែព្រៃវែងមាន ៣៥ ក្បាលដែលបានចោះពុម្ពរួចទៅហើយនោះ សុទ្ធតែប្រែគ្រជាសយ៉ាងប្រណិត ហើយជាគំរូបំផុត ។

យើងក្តាំបានសួរដោយចង់ដឹងថា តើអស់លោកអ្នកជាវ សុំចំណូលយកសៀវភៅដែលគេបានចោះពុម្ព ដោយគ្រជាសធុនអន់នេះបានទេ ។ គេឆ្លើយមកយើងថា ទេ ។

ដល់ឥឡូវនេះ យើងអាចរកគ្រជាសប្រណិតទំនើងគ្រជាសរឹងសម្រាប់ផ្តើគ្រែបាន ។

ប៉ុន្តែ យើងមានតែគ្រជាសមួយមុខសម្រាប់ចោះពុម្ពគ្រប់គ្រាន់ហើយឬ ?

យើងនៅត្រូវការគ្រាក់ទឹងអក្ខរក្រុងពុម្ពផង ។ ខ ! រឿងគ្រាក់នេះ យើងមានមិនគ្រប់គ្រាន់ទេ ប៉ុន្តែយើងទឹងរិះរកមធ្យោបាយណោ

មួយដើម្បីជួយចំពេញការខ្វះខានខ្លះតទៅ ។ ដូច្នេះ យើងសូមពន្យល់ដោយបញ្ជាស់លាស់អំពីរឿងនេះ :

មុនដំបូងយើងត្រូវដឹងថា ថវិការបស់ពុទ្ធសាសនបណ្ឌិត្យ មិនមានចំនួនច្រើនណាមួយ សម្រាប់ចោះពុម្ពព្រះត្រៃបិដកទេ ។ ការចោះពុម្ពសៀវភៅដែលរួបរួមជាឈុតៗ នេះ ត្រូវមានដើមទុនធនធាន ១ ដោយខ្លួនឯង ឬជាប់ច្រើន ១ ជាប់ដោយខ្លួន ដែលពួកអ្នកជាវត្រូវជួយចំនុកបំរុង ។ ប្រសិនបើ គេចេញសៀវភៅមិ ១ ដែលបានចោះពុម្ពលើកដំបូងនោះ គេនឹងបានយើញអក្សរនៅលើចំពាក់ខាងក្នុងជាភាសាចាក់ឯ លើចំពាក់ខាងក្រៅជាភាសាខ្មែរថា « ដើមទុនដែលបំណាយបោះពុម្ពសៀវភៅព្រះត្រៃបិដក ភាគទី ១ នេះ គឺលោកប៉ូល–រ៉ាយណូត៍ រដ្ឋមន្ត្រីអាណានិគម បានធ្វើអំណោយផ្តាល់ខ្លួន » ។

ដំណែ្បចោះពុម្ពព្រះត្រៃបិដក ៣៩ ក្បាលតមកគ្រាយក្រៅ សុទ្ធតែអ្នកជាវចេញថ្លៃចាំងអស់ ។ កន្លងមកដំបូងនោះគេចោះពុម្ព ១ លើក ៗ ចំនួនពីរពាន់ក្បាល ក្នុង ១ ក្បាល ។ ដំណែ្បដើមច្រើលែ ១ រៀលប៉ុណ្ណោះ ។ ដល់មកឥឡូវនេះ សម្រាប់ការចោះពុម្ពជួបគ្នានេះ ដំណែ្បចោះពុម្ពក្នុង ១ ក្បាល ។ ឡើងដល់ ១០០ រៀល អាញ្ចឹញាមើលចុះថ្លៃកន្លាយ៉ាំងណាទៅ ។ ដូច្នេះ យើងត្រូវមានច្រើនដល់ ២០០.០០០ រៀល

សម្រាប់ថ្លៃចុះពុម្ពព្រះត្រៃបិដក ១ ភាគ ក្នុងពេលនេះ ឥឡូវនេះយើងមានថ្លាក់សល់នៅក្នុងហិបត្រឹម ៧០.០០០ រៀលប៉ុណ្ណោះ ។ ហេតុនេះ ត្រូវរិះរកមធ្យោបាយណាមួយជួយបំពេញការខ្វះឆាតនេះ ដោយសុំឲ្យអ្នកជាវបន្ថែមថ្លាក់ថែម ឬសុំដំនួយពីវត្ថុតិចុល ។

ប៉ុន្តែនៅពេលនេះ យើងមិនមែនត្រូវការតែថ្លាក់មួយយ៉ាងទេ តែត្រូវមានកេងពុម្ពដែលអាចខ្ចីលធ្វើការនេះបានផង ។ ដកចេញមកដល់ថ្ងៃនេះ កេងពុម្ពតូចក្តី កេងពុម្ពព្រះពជ្រក្តី មិនមានអក្សរគ្រប់គ្រាន់សម្រាប់ច្រើការចុះពុម្ពព្រះត្រៃបិដកទេ ដែលមានអក្សរមួលនៅចំពីរម្ខាង អក្សរជ្រែងនៅចំពីរម្ខាង ។

កាលពីសម័យពាជការណាពាក្យចាស់ កេងពុម្ពព្រះពជ្រក្បាស្ទើរតែធ្វើការឲ្យពុទ្ធសាសនបណ្ឌិត្យទាំងស្រុង ប៉ុន្តែកាលពីពីរបីឆ្នាំមកនេះ កេងពុម្ពមានការងារច្រើន ដោយខ្ចីលធ្វើការឲ្យវង្សកិចុលខ្មែរ មិនអាចធ្វើការឲ្យពុទ្ធសាសនបណ្ឌិត្យតាមត្រូវការ ។ ស្មើរតែដែលយើងសុំឲ្យចុះពុម្ពកោងយីតយូរពន់ពេក គោងដេកផ្ទះដល់ពីឆ្នាំហើយក៏នៅតែមិនទាន់បានចេញពីកេងពុម្ពក៏មាន ។

ហេតុដូច្នេះ ប្រសិនបើយើងមានថ្លាក់ហើយនៅតែត្រូវយល់ថាកាលណាកេងពុម្ពព្រះពជ្រក្បាមានអក្សរ, ម៉ាស៊ូនទទឹងអ្នកធ្វើការឲ្យបានគ្រប់គ្រាន់ ទើបអាចបង្ហើយការចុះពុម្ពព្រះត្រៃបិដកនេះបាន ។

ដូចគេថាបានឃើញស្រាប់ ការចោះគុម្ពព្រៃវៃតែបំផុតក្នុងគ្រានេះ មិនមែនធ្វើបានដោយងាយស្រួលដូចកាលមុនមានវិបត្តិកងរលោកនោះទេ បើមានតែតឹមតែខ្លះល្អក៏ធ្វើការមិនកើត ។ យើងមានសង្ឃឹមថាប្រសិនបើលោកអ្នកណាមួយ ជាអ្នកស្នេហាជាតិ ជាអ្នកស្រឡាញ់ពុទ្ធសាសនា នឹងនៃធ្វើការឈ្លោះសាយាងតាប់ប្រើសេរីមួយ ដើម្បីជួយយើងយោងដ៏ខ្ជិលចិត្តខាងឲ្យកើតសង្ឃឹជាថ្មី ព្រមទាំងឲ្យកើតឆន្ទៈល្អនៃអ្នកខ្លួនធ្វើការចោះពាម ។

កម្ពុជសុរិយា

រស្មីនៃវប្បធម៌ ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចោះពុម្ពផ្សាយ
នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងធំពន្ធមន្ត្រី ញ៉ុក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសង្គា ស្ង - ហ្គាយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	បញ្ជីរឿង	ទំព័រ
ហ្លួងធំពន្ធមន្ត្រី ញ៉ុក - ថែម	ពាក្យថ្មីៗ ក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា	២៤
—	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសតំណៀ (តមក)..	២៥៥
អ្នកឧកញ៉ា ឈិម - ក្រែសេម	ព្រះរាជពង្សាវតារភាគទី ១ សម័យនគរភ្នំ (តមក).	២៦២
លោក វ៉ាយ - ប៊ុក ក្រមការ	សុភាសិតខ្មែរ ភាគទី ១ (តមក)	២៧១
—	ប្រជុំពាក្យព្រៃងនឹងថាវចនាថាវ៉ាង (តមក).....	២៧៥
លោកអាចារ្យ ឌិញ - ប្រាជ្ញ	រៀងធ្វើស្រែខ្មែរ នៅកម្ពុជាក្រោម (ក្លស័ងស៊ុខ) (តមក - ចប់)	២៧៩
អ្នកឧកញ៉ាព្រះឃ្លាំង ឧង	រៀងភាគកុលកុ (តមក)	២៨៦
ផ្នែកសាសនា		
ព្រះសតមហារស់ - ពេ	សាបគ្គីកថា	២៩៣
ហ្លួងធំពន្ធមន្ត្រី ញ៉ុក ថែម	ពន្ធអាស៊ីទ្បូប (តមក).....	៣០៦
កំណត់ទំនឹងប្រវត្តិការណ៍		
ភិក្ខុ សូន - សុរិន	បុណ្យឈាបនតំចូសពអ្នកអាចារ្យ ហ៊ុន - សុធិ .	៣១២
ក្រសួងធម្មការ	អំពីការតាំងចៅអធិការថ្មី (តមក)	៣១៨

ឆ្នាំទី ២១ – លេខ ៤ ខែមេសា ឆ្នាំ ១៩៨៩ – ដំឡៃជាវ ១ ឆ្នាំ ៩៦ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Saṭṭhā So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire

		page
Luong Nibandhamantrî Nhok-Thêm	Nouveaux terme de législation employé dans la Constitution	244
— d.—	Histoire sommaire de l'Inde (suite).	255
Neak Oknha Chhim-Krasem Député	Histoire ancienne du Camdodge (suite).	262
M.Ray-Buc kramakar (I. B.)	Proverbes et maximes tome I (suite).	271
—id—	Recueil de Dictons et devises français (suite).....	275
Monsieur Dinh-Prach	Travaux des champs chez les Cambodgiens de Cochinchine (suite et fin)..	279
Feu Neak Oknhā Brah khleang Nông	Bhog kul kumār (suite)	286

Partie religieuse:

Feu Vén. Ros-Ko	Sāmaggikathā.....	293
Luong Nibandhamantri Nhok-Thêm	Lumière de l'Asie (suite)	306

Notes et chroniques

Vén. Suon Surin	Compte-rendu des cérémonies de la crémation de l'Achar Hin-Such	312
Ministère des cultes	Nomination des nouveaux chau Adhikar (suite).....	318

...ée: No 4 Avril 1949 — Prix d'abonnement 96$00 par an.

ឈរនៅយនពាក្យថ្មីៗ ព្រមទាំងសេចក្ដីអធិប្បាយមនចុះផ្សាយក្នុងមជ្ឈិមសុរិយោនេះ យើងយល់ថា មានប្រយោជន៍ដល់អ្នកអានទស្សនាវដ្ដីរបស់យើងខ្ញុំ ព្រោះជាបច្ច័យឲ្យដំណើរទាន់ផ្នែកអក្សរសាស្ត្រកែចំរើនឡើងតាមសម័យ។ ក្នុងកាលនេះ យើងស្រង់យកពាក្យថ្មីៗខ្លះអំពីវដ្ដធម្មន្ដរកញ្ញ ប្រទេសកម្ពុជាដែលលោក អៀវ-កើស ប្រធានវដ្ដសភាបានបួមមកអធិប្បាយទុកនៅខាងក្នុងបញ្ចប់វដ្ដធម្មន្ដរកញ្ញយនមកចុះផ្សាយក្នុងទីនេះទៀត ត្រង់តែថ្វាស់ដែរៀបរៀងជាថ្មី តាមក្នុងទីនេះ ប្រើពាក្យច្រើនជាមេពាក្យ ហើយប្រែជាខ្មែរ ចន្លះសេចក្ដីពន្យល់ ឬសេចក្ដីអធិប្បាយទៅខាងក្នុង។

ការដែលយើងរៀបរៀងតាមវិធីនេះ ដើម្បីតម្រៃតាមពាក្យថ្មីផ្សេងៗទៀត ដែលគណកម្មការវប្បធម៌បានប្រែរួចហើយ យើងនឹងយកមនចុះផ្សាយក្នុងទស្សនាវដ្ដីនេះតាំងពីដំបូងកល់ៗរៀងទៅ។

អស់លោក-អ្នកដែលស្រឡាញ់ពេញចិត្តនឹងប្រទេសជាតិ តង់ជ្រាបជាក់ច្បាស់ថា ភាសានឹងអក្សរជាគ្រឿងឧបនរណ៍យ៉ាងសំខាន់ក្នុងនយោបាយរក្សាការពារប្រទេសជាតិមិនឲ្យរលាយសាបសូន្យ។ ហេតុនេះហើយបានជាអារ្យៈប្រទេសចាំងឡាយ ចាំងតូច ចាំងធំ ទំនុកបំរុងទំពន្លឹកភាសានឹងអក្សរសាស្ត្ររបស់ជាតិគេយ៉ាងម៉ឺងម៉ាត់ ដើម្បីជា

កំពុងយកវេទស្រែខេត្តជាតិគេផង ជានយោបាយផ្សាយឥទ្ធិពលរបស់ជាតិគេផង ។

* តាមដែលយើងបានសង្កេតស្ថានការណ៍កន្លងមកក្នុងប៉ុន្មានេះ យល់ថាជនជាតិខ្មែរយើងហាក់ដូចជាមិនសូវយកចិត្តទុកដាក់ទំនឹងអក្សរសាស្ត្ររបស់ជាតិទេ មានតាតិចណាស់ ដែលយកចិត្តទុកដាក់ជួយចំណុតបំរុងការសាទំនឹងអក្សរបស់ជាតិខ្លួន ។ ហេតុនេះ បានជាសៀវភៅចោះពុម្ពទំនឹងសាសនាផ្សេង ។ ជាភាសាខ្មែរចំរើនឡើងពុំដូច ។ សព្វថ្ងៃនេះការសែតទំនឹងសៀវភៅចោះពុម្ពជាភាសាខ្មែរមានចំនួនប្លែបស្តើងណាស់មិនសមទំនឹងហានៈរបស់ប្រទេស ទំនឹងចំនួនប្រជាជនខ្មែរ ។ ពិតមែនតែពេលវេលាឥឡូវនេះ យើងខ្វះអក្សរ ខ្វះម៉ាស៊ីនចោះពុម្ព ពីមុននេះបន្តិចខ្វះក្រដាសចោះពុម្ពថែមទៀតផង ។ តែដល់មកសព្វថ្ងៃនេះ បញ្ហាខ្វះក្រដាសចោះពុម្ពមិនសូវសំខាន់ទេ ព្រោះក្រដាសមានហៀរហូរចូលមកស្រុកយើងគ្រប់គ្រាន់ហើយ នៅខ្វះតែអក្សរនឹងម៉ាស៊ីនប៉ុណ្ណោះ ។ បញ្ហាខាងក្រោមនេះ បើយើងប្រឹងរៀនរកធ្យាយដោះស្រាយដោយខ្លួនម៉ាត់ក៏គង់តែសម្រេចដោយគាប់ពុំខាន ។ បញ្ហាការខ្វះខាតជាងដទៃទៀត ដូចសំតត់, អំបោះ, ស្ពាន់, ឈើនូសជាដើម ជុតលែតអស់ទៅហើយ ដោយគាស្រយ័សេចក្តីខ្វល់ខ្វាយនៃពួកឈ្មួញ ។ ឯរឿងអក្សរនឹងម៉ាស៊ីនចោះពុម្ពកំតង់មានទំនងដូចគ្នាដែរ ។

ទៅទីបំផុត យើងសូមរំលឹកបងប្អូនរួមជាតិ ដោយមេត្រីចិត្តសុបរិសុទ្ធថា «តែបណ្តាយឲ្យអក្សរធំជាសាសន៍ ជាតិយើងមុខជាវិលាយ» ។ ហេតុនេះ, យើងត្រូវព្រួតដៃគ្នាតស៊ូជាសាធារណៈអក្សរបេះដូងយើងឲ្យបានលូតលាស់ឡើងតាមកាលសម័យ ដើម្បីជាបច្ច័យឲ្យជាតិ-សាសនា-មហាក្សត្រ ទំនឹងដួងមនុស្សបេះដូងយើងតាំងនៅក្នុងខ្លួនតទៅ ។

ញ៉ុក-ថែម

ពាក្យប្រែនឹងពាក្យអធិប្បាយ

ស្រង់ពីវចនានុក្រម ប្រទេសកម្ពុជា

Accord កិច្ចព្រមព្រៀង គឺលិខិតសញ្ញាដែលមានសារៈសំខាន់តិចជាងសន្ធិសញ្ញា ទំនងអនុសញ្ញា ហៅថា កិច្ចព្រមព្រៀង ។ ឧ. តាំងពីជុតមហាសង្គ្រាមលើកគ្រោងនេះមក ប្រទេសកម្ពុជាបានធ្វើកិច្ចព្រមព្រៀងទំនងប្រទេសជាច្រើនអស់ ៨ កិច្ច ។

Assemblée Ordinaire ប្រជុំសាមញ្ញ: ប្រជុំតាមធម្មតា ។ ឧ. រដ្ឋសភាមានសម័យប្រជុំសាមញ្ញ ២ ក្នុងមួយឆ្នាំ ។ សម័យប្រជុំទីមួយ ។ មានកំណត់វេលាយ៉ាងតិច ៣ ខែ ។ ដល់ជុតសម័យប្រជុំទីមួយ ។ អ្នកតំណាងក្រុមឈប់សម្រាកមៅទីលំនៅវិញ ។ ។ន ។

Assemblée extraordinaire ប្រជុំវិសាមញ្ញ: ប្រជុំក្រៅតាមធម្មតា ។ ឧ. កាលណាជុតសម័យប្រជុំសាមញ្ញទីមួយ ។ អ្នកតំណាងក្រុមណែងបានឈប់សម្រាកតាមកំណត់ធម្មតា ។ ប៉ុន្តែពេលត្រូវឈប់សម្រាកនេះ ជួនជាមានឈាមចំខ្លួនតែតខ្លាំង ត្រូវហៅរដ្ឋសភាមកប្រជុំ សម័យប្រជុំបែបនេះ ហៅថា ប្រជុំវិសាមញ្ញ ។

Autonomie : ស្វ័យភាព: ការគ្រប់គ្រងប្រទេសដោយខ្លួនឯង ។ រដ្ឋស្វ័យភាព ជាប្រទេសដែលមានអំណាចគ្រប់គ្រងក្នុងប្រទេសដោយ

ខ្លួនឯង គឺថាមានតែចំណាយអធិបតេយ្យភាពក្នុងប្រទេស ឯចំណាយអធិបតេយ្យភាពក្រៅប្រទេស ត្រូវជាការចាំបាច់ជាមួយផ្សេងទៀត ។

Budget : ថវិកា ។ ពាក្យនេះ តើបែកមកពីពាក្យថា ថង់ (ថង់ធ្វើពីស្បាក់) ត្រូវនឹងភាសាបារាំង ប៊ុតសេ, សំដៅដល់ការគ្រោងចំណូល - ចំណាយ ។

Capacité : សមត្ថភាព គឺភាពនៃបុគ្គលដែលអាចធ្វើបាន ។ ឧ. ខ្ញុំមានចំណេះដឹងធ្វើខ្លួ, គុ, កៅអីបាន ហើយខ្ញុំមានកម្លាំងនឹងគ្រឿងប្រដាប់ល្អមនឹងធ្វើការនេះកើត នេះថាខ្ញុំមានសមត្ថភាពធ្វើប្រដាប់ប្រដានេះបាន ។ បើខ្ញុំធ្វើមិនកើត នេះថាខ្ញុំគ្មានសមត្ថភាពទេ ។

Cas : ករណី : ការដែលកើតឡើង: ហេតុដែលបណ្តាលឡើង, រឿងដែលមានឡើង ។

Citoyens : ពលរដ្ឋ គឺសមាជិករបស់រដ្ឋ គឺជនដែលមានសិទ្ធិគេញតាមច្បាប់សម្រាប់ស្រែក ។ ឧ. ក្នុងប្រទេសខ្មែរ ជនជាតិខ្មែរទាំងជនជាតិដែលកើតជាខ្មែរ ដូចជា ចាម កួយ ព្នង សំរែ.. ទាំងជនដែលចូលជាតិជាខ្មែរ ជាពលរដ្ឋខ្មែរ ។ ឯជនជាតិក្រៅអំពីនេះដូចជា យួន ភ្លីង្គជាដើម មិនមែនជាពលរដ្ឋខ្មែរទេ ។ ជនចំពូកក្រោយនេះខ្លះសិទ្ធិខ្លះដូចជាសិទ្ធិចោះឆ្នោតជ្រើសតាំងអ្នកតំណាងក្រុងជាដើម ។

Condition: លក្ខណសម្បត្តិ: សំដៅដល់លក្ខណៈបុគ្គលដែលត្រូវមាន ដើម្បីឲ្យមានសិទ្ធិជ្រើសតាំងឬដើម្បីឈរឈ្មោះជាបេក្ខជន ។ លក្ខណសម្បត្តិដែលត្រូវមានដើម្បីតាំងអ្នកតំណាងក្រុងភ្នំពេញ គឺជាពលរដ្ឋខ្មែរ ភេទប្រុស អាយុមិនតិចជាង ២០ ឆ្នាំបរិបូណ៌ ពុំមែនជាទាហានពុំមែនជាបព្វជិត ពុំមែនជាមនុស្សវង្កេរលេចរ័ត ឬមនុស្សមានទោសឧក្រិដ្ឋ ។ ល ។ (ពាក្យ Condition នេះកន្លងមកខ្មែរតែងប្រែថាលក្ខខ័ណ្ឌ ក៏បាន) ។

Conseil des Ministre: គណៈរដ្ឋមន្ត្រី: ក្រុមរដ្ឋមន្ត្រីទាំងអស់គ្នារួមបញ្ចូលរដ្ឋលេខាធិការផង ។

Conseil du Royaume: ក្រុមប្រឹក្សាព្រះពុទ្ធអាណាចក្រ គឺប្រជុំប្តូរសភាមួយ ចំនួនប្រហែលគ្នានឹងរដ្ឋសភាដែរ តែរដ្ឋសភាកាន់អំណាចនីតិបញ្ញត្តិ ។ ឯសភានេះមិនកាន់អំណាចនីតិបញ្ញត្តិទេ គ្រាន់តែពិនិត្យច្បាប់ដែលរដ្ឋសភាបានបញ្ជូនមកតាំងហើយ ឧទ្ធរណ៍ដែលរដ្ឋសភាបានបញ្ជូនមកឲ្យពិនិត្យ ។

Candidat: បេក្ខជន គឺអ្នកឈរឈ្មោះឲ្យគេជ្រើសតាំងខ្លួន ឧទាហរណ៍ មួយមានចំណងចង់ធ្វើជាតំណាងឯស្តុក ហើយបានឈរឈ្មោះឲ្យឯស្តុក ចោះឆ្នោតជ្រើសតាំងខ្លួនឡើង ។

Convention: អនុសញ្ញា : លិខិតសញ្ញាដែលមានសារៈសំខាន់ជាងគេ ពីសន្ធិសញ្ញា ។ ឧ. ប្រទេសកម្ពុជាបានធ្វើអនុសញ្ញាជាមួយនឹងប្រទេសជាច្រើន នៅ គ ស. ១៩៧៤ ។

Colonie: អាណានិគម ឬប្រទេសអាណានិគម គឺប្រទេសចំណុះ ឬប្រទេសដែលនៅក្រោមបង្គាប់ប្រទេសដទៃ ។ ឧ. ប្រទេសកូរ៉ង់ស៊ីនមុនពេលសង្គ្រាមលើកក្រោយនេះ មិនមែនជាវត្ថុយឺតណាមទេ ព្រោះគ្មានវត្ថាកិច្ចាល គឺជាប្រទេសអាណានិគមច្បាស់ ។

Cruauté : ការុណកម្ម គឺអំពើឃោរ, អំពើសាហាវ ឬអំពើអាក្រក់ ។ កង់ឌីនេះ ចាន់ជល់ការជាក់តំណៅយ៉ាងគឺនតែងឥតមេត្តា ។

Devoir : តារណីយកិច្ច ការអ្វី ។ ដែលយើងត្រូវធ្វើ ។ ឧ. សេចក្តីគោរព ជាតារណីយកិច្ចនៃបុត្រ ចំពោះមាតា-បិតា ។ ប្រសេចក្តីថាបុត្រត្រូវតែគោរពមាតា-បិតា ។ ការចង់ពន្ធជួនពជការ ជាតារណីយកិច្ចនៃពលរដ្ឋទាំងឡាយ ។

Discipline : វិន័យ គឺរបៀបប្តូចប្បាប់ទាំងពួង ដែលមនុស្សទាំងឡាយនៅកងក្រម ក្នុងពួកជាមួយគ្នាត្រូវប្រតិបត្តិតាម ។

Evénement: ព្រឹត្តិការណ៍ គឺហេតុដែលបណ្តាលកើតឡើងក្នុងលោក, ហេតុដែលឆ្លងសំគាល់ចាន់ ។

Etat : រដ្ឋ គឺប្រទេសឬដែន ដែលមានរដ្ឋាភិបាលឬរាជរដ្ឋាភិបាលគ្រប់គ្រង ។

Etat Associé : សមាគមរដ្ឋ គឺរដ្ឋដែលនៅក្នុងសហភាពជាំង ។ សហភាពជាំង ពុងដូចជាក្រុមហ៊ុនមួយ ឬសមាគមមួយ ។ រដ្ឋដែលនៅក្នុងសហភាពជាំង ពុកដូចអ្នកចូលហ៊ុនក្នុងសមាគម ទើបហៅថា សមាគមរដ្ឋ ។

Egalité : សមភាពគឺភាពស្មើគ្នា ។ ទេមវដនមានសមភាពដូចគ្នា ប្រែសេចក្តីថា ទេមវដនមានសិទ្ធិ គ្មាននរណាមានសិទ្ធិច្រើនជាងនរណាទេ ។

Gouvernement : រដ្ឋាភិបាល គឺនាយករដ្ឋមន្ត្រី ទីឆ្នាំរដ្ឋមន្ត្រីជាំង-ឡាយ ព្រមទាំងរដ្ឋលេខាធិការធំ រួមគ្នាទាំងអស់ជារដ្ឋាភិបាល ។

Grades: ហានន្តរស័ក្តិ គឺបណ្តាស័ក្តិតូច-ធំតាមមុខការ ។

Immunité (Parlementaire) អភ័យឯកសិទ្ធិ គឺសិទ្ធិដែលជនខ្លះមានចំពោះខ្លួនម្នាក់ៗ មិនឲ្យមានភ័យ មិនឲ្យមានទោសដល់ខ្លួន ដូចមិនឲ្យគេទោច គេចាប់ គេឃុំឃាំងជាដើម ដោយហេតុបានសំដែងយោបល់ឬមតិដូច្នេះ ដូចោះ ក្នុងមុខក្រសួងរបស់ខ្លួន ។ អភ័យឯកសិទ្ធិនេះ ជារបស់សមាជិករដ្ឋសភា ។

Journal Officiel ពាក្យថ្ម គឺជាសៃតពាក្យ ។ កន្លងទៅនេះ សំដៅ
ដល់ទស្សនាវដ្តី ដែលពាក្យចូលនៅចុះពុម្ព ចុះកិច្ចការផ្សេងៗដូច
ជាច្បាប់ ព្រះពាក្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា ។ល។
ដើម្បីផ្សាយដល់មហាជន ។

Législation : និតិកាល គឺរយៈពេលនៃរដ្ឋសភា ពីពេល
ប្រជុំដំបូង រហូតដល់ពេលដែលត្រូវរំលាយ ដើម្បីឲ្យប្រជាពលរដ្ឋ
ជ្រើសតាំងជាថ្មី ។ តាមធម្មតា និតិកាលនៃរដ្ឋសភាខ្មែរមានកំណត់ ៤ ឆ្នាំ ។

Majorité: និតិភាព គឺភាវៈនៃជនដែលមានអាយុពេញការតាមច្បាប់
ហើយ. សម្រាប់ជនជាតិខ្មែរ កំណត់អាយុដែលគប្រើសិទ្ធិបេះឆ្នោត
ដោយពេញបរិបូណ៌បាន គឺអាយុ ២០ ឆ្នាំ ។

Mandat អាណត្តិ: សេចក្តីបង្គាប់ ។ កន្លងទៅនេះសំដៅដល់សិទ្ធិដែល
ប្រជាពលរដ្ឋប្រគល់ទៅជនណាមួយឲ្យនិយាយការជួសខ្លួន ។

Membre: សមាជិក គឺអ្នកចូលក្នុងសមាគម ឬអ្នកកាប់បញ្ចូលក្នុងពួក
ក្រុមណាមួយ ។ ឧ. ក្នុងគ្រួសារមួយមានគ្នា ៧ នាក់ គឺជីតា ជីដូន,
ឪពុក, ម្តាយ និងកូន ៣ នាក់ ។ មនុស្សទាំង ៧ នាក់នេះ ជាសមាជិក
នៃគ្រួសារនោះ គឺជីតាជាសមាជិក ១ ជីដូនជាសមាជិក ១ ។ ល ។
អ្នកតំណាងពលរដ្ឋជាសមាជិកនៃរដ្ឋសភា ។

Ministre រដ្ឋមន្ត្រី: អ្នកគាន់អំណាចនិតិប្រតិបត្តិ, តាលពីសម័យមុននេះ គេហៅថា សេនាបតី ។

Minorité អនីតិភាព ឬភាវៈនៃក្មេងដែលមានអាយុមិនទាន់ពេញការតាមកំណត់ច្បាប់ ។ សន្តានជនជាតិខ្មែរ សំដៅដល់ក្មេងដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំចប់ចូលកិ ។

Motion ញត្តិ; តាក្យដែលសូត្រប្រកាសក្នុងសិក្ខាសាលាជុំ ។ សេចក្តីណែនាំដែលសមាជិករដ្ឋសភាចុងថ្ងៃក្នុងសិក្ខាសាលាជុំ ។

Nation: ប្រជាជាតិ: មនុស្សទាំងឡាយដែលនៅរួបរួមគ្រាមអំណាចជាតិតែមួយជួបគ្នា ហើយត្រូវប្រតិបត្តិតាមច្បាប់ខ្លួនៅជួបគ្នាហៅថា ប្រជាជាតិមួយ ។

Ordre Royal du Cambodge: ក្រមឥស្សរិយយសកម្ពុជា ។ ក្រមនេះគេបង្កើតឡើង ដើម្បីឲ្យចំណាប់ដល់ជនដែលបានប្រព្រឹត្តល្អ បានធ្វើប្រយោជន៍ដល់ពជការ ដល់ប្រទេសជាតិ មានប្រភេទផ្សេង ។ គឺក្រមឥស្សរិយយសសុវត្ថិភាព បំណាច់ទាន់ក្សេត្រាធិការ (Ordre du Mérite Agricole) ក្រមឥស្សរិយយសមុនីសារកិច្ច (Ordre du Mérite Historique, Littéraire et Seientifique) ក្រមឥស្សរិយយសព្រះករុណាទ្រង់ពជ្ឈ (Ordre du Règne) ក្រមឥស្សរិយយសស្ត្រីឧត្តមា (Ordre du Mérite Féminin) ក្រមឥស្សរិយយសកីឡាប្តូរ (Ordre du mérite Sportif)

ក្នុងក្រមឥស្សរិយយសទំនួយ។ មានថ្នាក់ផ្សេង។ ដូចជាអស្សរិទ្ធិ (chevalier) សេនា (Officier) ឥសិសេនា (Commandeur) វរសេនា (Grand Officier) មហាសិរីវន្ទ (grand Croix) ចាំងអស់ ៥ ថ្នាក់។ ក្រមឥស្សរិយយសខ្ទះ មានតែ ៤ ឬ ៣ ថ្នាក់។ មនុស្សក្នុងថ្នាក់ទំនួយ។ នៃក្រមឥស្សរិយយស មានត្រឿងឥស្សរិយោភរណ៍ពាក់ជាសំគាល់។ ត្រឿងឥស្សរិយោភរណ៍ ហៅតាមពាក្យសាមញ្ញថា «មេដែយ»។

Président : ប្រធាន : អ្នកដែលធំជាងគេក្នុងក្រុមប្រជុំ។ ជួនកាលហៅថា អធិបតី កំបាន។

Président du Conseil des ministres : នាយករដ្ឋមន្ត្រី : រដ្ឋមន្ត្រីដែលជាធំជាងរដ្ឋមន្ត្រីដទៃទៀត ដែលជានាយកនៃរដ្ឋមន្ត្រីដទៃទៀត។ ត្រូវនឹងពាក្យថា «អគ្គមហាសេនា» ដែលប្រើកន្លងសម័យមុននេះ។

Prince héritier : រដ្ឋទាយាទ គឺព្រះអង្គម្ចាស់ ដែលត្រូវទទួលរាជសម្បត្តិជាមតក, ក្សត្រដែលបំរុងរាជ្យជាតំណអំពីក្សត្រដែលនឹងក្នុងរាជសម្បត្តិ។

Personne morale : និតិបុគ្គល គឺបុគ្គលនេះគ្មានរូបគ្មានអង្គទេ។ និតិបុគ្គលនេះហើយដែលជារដ្ឋ (Etat)។

Obstacle : ឧបស័គ្គ គឺ ត្រឿងទើសទាក់, ត្រឿងជំពាស់, ត្រឿងពក់ព័ន។

Pouvoir judiciaire : អំណាចតុលាការគឺអំណាចដែលធ្វើវិនិច្ឆ័យក្តី ។

Pouvoir législatif : អំណាចនីតិបញ្ញត្តិ : អំណាចធ្វើច្បាប់ - តាំងច្បាប់ - រៀបចំធ្វើច្បាប់ ។

Pouvoir exécutif : អំណាចនីតិប្រតិបត្តិ : អំណាចប្រើច្បាប់ដែលតាំងឡើងមកហើយ, អំណាចយកច្បាប់ទៅដាក់ឲ្យប្រជាជនប្រតិបត្តិតាម ។

Profession : វិជ្ជាជីវៈ អាជីវៈគឺ ទេវម្មទានការកសុំ ។ វិជ្ជាជីវៈនឹងអាជីវៈ ដែលត្រូវប្រើវិជ្ជា ចាន់ដល់ទេវដែលត្រូវប្រើចំណេះដឹង ដូចពេទ្យ, ត្រូអាចារ្យ ជាដើម ។

Règlement : បទបញ្ជា : ឧទាហរណ៍ច្បាប់បញ្ជា ឬ សេចក្តីបង្គាប់បញ្ជា ។

Région : ភូមិភាគ : ចំណែកមួយនៃផែនដី ឬជាចំណែកនៃប្រទេស, មិនមែនប្រទេសទាំងមូលទេ ។

Règne : រជ្ជកាល : គឺរយៈ វេលាដែលព្រះមហាក្សត្រមានអំណាច ឆ្នាំសម្បត្តិ ។

Ratification : សច្ចាប័ន : ការបញ្ជាក់ត្រឹមត្រូវតាមរបៀបច្បាប់ខ្លួនរបស់ដែលបានធ្វើហើយ ឬដែលបានសន្យាទុកគ្នាហើយ ។

Régent : ពជាទុសិទ្ធ គឺអ្នកដែលទទួលព្រះពជការ: ត្រួតជជ្ឈ ជំនួសក្សត្រត្រួតជជ្ឈជាបណ្តោះអាសន្ន ។

Spécial : ពិសេស, ជោយឡែក ។

Secrétaire d'Etat : ផ្នែលេខាធិការ មានមុខក្រសួងជួយរដ្ឋមន្ត្រីដែរតែគាន់តែមានសារៈសំខាន់តិចជាង ។

Suffrage restreint: អសាធារណៈ មិនមែនចាំងអស់ មិនមែនចាំងមូល ឆ្នោះឆ្នោតអសាធារណៈ គឺឆ្នោះឆ្នោតមិនចាំងអស់គ្នា ជនខ្លះមានសិទ្ធិឆ្នោះឆ្នោត ជនខ្លះគ្មាន ។ ដូចជាក្នុងការជ្រើសតាំងទីប្រឹក្សាព្រះរាជអាណាចក្រមួយនាក់ ដែលជាអ្នកតំណាងអ្នកជំនួញស្រែ មានតែអ្នកជំនួញស្រែប៉ុណ្ណោះទេ ដែលមានសិទ្ធិឆ្នោះឆ្នោតបាន ។ ឯជនមិនបានធ្វើជំនួញស្រែ ធ្វើតែជំនួញឯទៀត ឬមិនបានធ្វើជំនួញទេ នោះគ្មានសិទ្ធិឆ្នោះឆ្នោតជ្រើសតាំងទីប្រឹក្សាព្រះរាជអាណាចក្រនេះបានទេ ។

Traité : សន្ធិសញ្ញា គឺលិខិតសញ្ញាដែលប្រទេសមួយបានធ្វើនឹងប្រទេសមួយទៀត ដើម្បីឲ្យមានការចាក់ចងភ្ជាប់គ្នាទៅវិញទៅមក ។ សន្ធិសញ្ញានេះ ជាលិខិតសញ្ញាដែលមានសារៈសំខាន់ជាងលិខិតសញ្ញាដទៃទៀត ។ ឧ. ប្រទេសឥណ្ឌូជា បានធ្វើសន្ធិសញ្ញាមួយជាមួយនឹងប្រទេសបារាំងនៅ ត.ស. ១៨៦៣ ។

Union française : សហភាពបារាំង : ការរួបរួមជាមួយនឹងប្រទេសបារាំង ។ ឧ. ប្រទេសបារាំងនៅទ្វីបអឺរុប ទេគឺបារាំងនឹងដែនដីបារាំងឯនាយសមុទ្រ នេះជាបែកមួយ ។ ដែនដីសមាគម ឬសមាគមរដ្ឋ នេះជាបែកមួយទៀត រួមគ្នាទៅហៅថា សហភាពបារាំង ។

Universel : សាកល ; ទាំងអស់ ; ទាំងមូល ។ ល. ចោះឆ្នោតសាកល គឺចោះឆ្នោតទាំងអស់គ្នា គឺពលរដ្ឋត្រូវបានចោះឆ្នោតទាំងអស់គ្នា ទ្បើតែមានលក្ខណៈសម្បត្តិត្រឹមត្រូវ ។

Volonté : ឆន្ទៈ ; គឺសេចក្តីតាប់ចិត្ត សេចក្តីថ្នាថា បំណងយ៉ាងមុតមាំ ។

Voix : មតិ ; សេចក្តីឃល់ ឃោបឃល់ ។

(3)

ប្រវត្តិសាស្ត្រនិងសិល្បៈខ្មែរ

ហ្លួងធិពន្ធមន្ត្រីញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

ប្រសិនបើមិនមានចំនងដូច្នេះទេ ខ្ញុំតែងតែមិនចំណុចបំរុងសាសនាព្រាហ្មណ៍ឡើយ ។

ក្រៅពីលទ្ធិសាសនាព្រាហ្មណ៍ នៅមានលទ្ធិសាសនាដទៃទៀត ហើយមានតណ្ហាចង់កាន់តាមក្បាច្បាប់ខ្លួនឯង ព្រះបាទអសោកក៏មិនខ្វល់បារម្ភនោះឯណា ។ គោលនៃខ្ញុំសំដែងព្រះពុទ្ធបំណងឲ្យម្ចាស់សាសនានោះ ។ ទាំងអស់ជួយចំណុចបំរុងសិលធម៌របស់ប្រជាជន ។ ព្រះតម្រិះនេះខ្ញុំបានចារឹកចុងលើភ្នំថ្មសិលាហើយនាំយកប្រតិស្ថានចុងក្នុងតំបន់ផ្សេង ។ សិលាចារឹកអស់នោះ នៅមានតំណែងហូតមកដល់សម័យនេះ មានសិលាចារឹក ១ ផ្ទាំងនោះ សម្រាយឃើញបរិយាកាសដ៏ប្រពៃរបស់ព្រះបាទអសោកមហាពុទ្ធបរិស័ទមានសេចក្តីប្រែខាងក្រោមនេះ :

"ពាក្យស្តែងតម្កល់ជាកូនរបស់ខ្ញុំ ខ្ញុំតែងសាងឲ្យកូនក្នុងខ្លួនរបស់ខ្ញុំប្រកបដោយសុខសួស្តីក្នុងលោកនេះត្រមណា ខ្ញុំក៏ប្រាថ្នាឲ្យគេស្តែងមានសេចក្តីសុខសួស្តីត្រមណោះដែរ ។ ខ្ញុំបានដាំដើមឈើជាច្រើនតាមផ្លូវ ដើម្បីឲ្យមានម្លប់ត្រជាក់ដល់មនុស្សនិងសត្វ ។ ខ្ញុំបានដាំបង្អែរស្វាយ ជីកស្រះសង់សាលា សម្រាប់ជាទីស្នាក់របស់មនុស្សនិងសត្វ ។ ខ្ញុំតាំងអ្នក

ថែរក្សាសាសនា សម្រាប់ធ្វើការកុសលដ៏ប្រសើរហើយប្រតិបត្តិនាទី
របស់សាសនាដ៏ខ្ជាប់ខ្ជួនកាយ ។ ដោយខ្ញុំយកចិត្តទុកដាក់ទំនឹងព្រះសង្ឃរបស់
ព្រះពុទ្ធសាសនា ហើយសូមឲ្យពួកព្រាហ្មណ៍ដែលកាន់សាសនារបស់ពួក
សុំទាន ទំនឹងលទ្ធិសាសនាដទៃៗទៀត ខ្ញុំក៏យកចិត្តទុកដាក់ដែរ" ។

កាលពុទ្ធសករាជ ២០១ នោះ ព្រះបាទអសោកធ្វើចាត់ឲ្យមាន
សង្ឃាយនាជាគ្រាទី ៣ នៅស្រុកបាដលីបុត្រ ដែលជាក្រុងរបស់ព្រះ
អង្គ ។ ការប្រជុំធ្វើសង្ឃាយនាគ្រានេះ មានព្រះសង្ឃមកប្រជុំចាត់
ពាន់អង្គហើយនៅគ្រានេះឯង ដែលសម្រេចថា ត្រូវចាត់បញ្ជូនឆន:
ធម្មទូតឲ្យចេញទៅប្រកាសព្រះសាសនាក្នុងទិសានុទិស គឺព្រះមហា.
រក្ខិត ត្រូវទៅប្រកាសព្រះសាសនាខាងទិសខែត្តដែនក្រិក ព្រះមជ្ឈន្តិក:
ទៅប្រកាសខាងស្រុកកស្មីរ: ទំនឹងដែនគន្ធារ: ព្រះមហាធម្ម: ទំនឹងព្រះ
មហាទេវ: ទៅប្រកាសខាងអាណាចក្រតូចផ្សេងៗ ខាងភ្នំហិមាល័យ
ព្រះមហាធម្ម: ទៅប្រកាសខាងទិសត្រូវដែនមហារដ្ឋ ព្រះមហាទេវ:
ទៅប្រកាសខាងម៉ាស្សរ, ព្រះសោណ: ទំនឹងព្រះទត្តរ: ទៅប្រកាសខាង
ប្រទេសភូមាទំនឹងមន, នៅចំពុត ព្រះពាជនុរសទំនឹងព្រះពាជធីតារបស់
ព្រះបាទអសោក ត្រូវឲ្យលានាទីឲ្យចេញទៅប្រកាសសាសនាខាងកោះ
លង្កា ។ បណ្តាដែនដី ដែលព្រះបាទអសោក បញ្ជូនព្រះថេរទូតឲ្យ
ចេញទៅប្រកាសព្រះសាសនានោះ មានអាណាចក្រខ្លះមិនបានទៅ

ត្រកាមអំណាចរបស់ខ្លួនទេ តែដោយគាស្រ័យ ខ្លះជាមហាអំណាច នៅកន្លែងស្រែរៀងរួចហើយ ទើបមិនមានខ្លះណាហ៊ានខ្លាំងទាស់ឡើយ ។ មួយវិញទៀត ព្រះពុទ្ធសាសនាជាសាសនា ជួយសង្គ្រោះដោះទុក្ខរបស់មនុស្សលោកបានពិត។ ទើបដែនដីតាំងឡាយ ក៏មានសទ្ធាជ្រះថ្លាជាច្រើន ហើយតណ្ហាជម្ងឺតដែលចេញទៅប្រកាសសាសនាអស់នោះ ក៏បានធ្វើគុណប្រយោជន៍យ៉ាងសំខាន់ដល់ដែនដី ដែលខ្លួនបានប្រកាសផ្សាយព្រះពុទ្ធសាសនាជូនដែនជេតកាន់ រៀងមកនោះដែរ ដែលនៅជាវៃព្រៃវែងនៅឡើយ ក៏បានទទួលសេចក្តីចំរើន រុងរឿងឡើងដោយអំណាចព្រះពុទ្ធសាសនា ហើយតំបន់ដែលសំខាន់ចំផុត គឺ កោះលង្កាទ្វីបនេះ ។

ព្រះមហិន្ទទេរ ព្រះនាងសង្ឃមិត្តា ជាព្រះរាជទេវីនៃព្រះរាជធីតារបស់ព្រះចក្រពត្តិអសោកបានមកដល់កោះលង្កា បានជ័យនាំមហាក្សត្រកោះលង្កាខ្លះនៃព្រះនាមទេវនម្បិយតិស្សៈ ឲ្យមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ជាហេតុនាំឲ្យព្រះពុទ្ធសាសនាចែកស្ថានទុកក្នុងកោះលង្កាយ៉ាងម៉ាំមួន កាលព្រះពុទ្ធសករាជ ៣១៣ ។ កាលដែលព្រះមហិន្ទទេរនាងសង្ឃមិត្តាថេរីនិមន្តទៅកោះលង្កានោះ បានយាយមែងពោធិព្រឹក្សដែលបានសាងចេញពីរដើមដែលព្រះអង្គបានត្រាស់ដឹង ១ មែងទៅដាំនៅកោះលង្កា ហើយបានធំចំរើនឡើងរហូតមកដល់វេលានេះ ។

លុះព្រះពុទ្ធសាសនាចំរើនឡាប់ឆ្នូនក្នុងលង្កាទ្វីប ហើយពួកពុទ្ធសាសនិក-ជនលង្កាក៏ទស្សាហ៍ច្រើនរៀបរៀនសូត្រ ទំនៃតែងតម្រាជាគា ហើយបាន ប្រកាសផ្សាយចេញទៅប្រទេសកូមា ជាទំនឥណ្ឌូចិនពាំនអស់ផង ។ អំណើះតាលតមនដល់សម័យនណ្តាល ព្រះពុទ្ធសាសនា ត្រូវបណ្តេញ ចេញពីឥណ្ឌូ ដោយការចៀនចៀនរបៀនពួកសាសនាហិណ្ឌូនិងមហាយ៉ាន ទើបគោរលង្កាក្លាយទៅជាតំបន់សំខាន់ ជាទីប្រជុំរបស់ព្រះពុទ្ធសាសនា ថែកខាងហីនយាន ។

ចំណែនខាងស្រុកខាងដើង តែខាងនស្ម័រនិងនន្ទារនោះ ព្រះ សារីតជាអ្នកប្រកាសសាសនា បានធ្វើប្រយោជន៍មិនតិចជាងខាងស្រុក ដទៃ ៗ ទេ ព្រោះព្រះមជ្ឈន្តិក: អ្នកនាំព្រះពុទ្ធសាសនាទៅប្រកាសផ្សាយ ក្នុងថែននេះ បាននាំព្រះភិក្ខុសង្ឃទៅផងចំនួនដល់ ៥០០ អង្គ លោក អស់នេះហើយ ដែលបានធ្វើទ្បាកែតសេចក្តីចំរើនខាងផ្លូវចិត្ត ទំនិងសីល-ធម៌ដល់ប្រជាជនទៅស្រុកអស់នោះ ហើយបានជួយពន្យល់ចំភ្លឺ ដល់ ប្រជាជនទ្បាបានចំរើនខាងវប្បធម៌វីតវប្បធម៌មនុស្សដោយទ្បែកថែម ទៀតផង ។ ស្រុនពាំនពីរនេះ ហើយដែលបានប្រកាសព្រះពុទ្ធសាសនា ទ្បាផ្សាយចេញទៅស្រុកចិន និងយមហាយានតកែតទ្បើងក្នុងស្រុក ពាំនពីរនេះដែរ ។

ពុកជាព្រះបាទអសោកធ្វើបានចំពុកចង្អុលព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងដល់ម្ល៉ោះហើយក៏ដោយ តែនៅតែមិនបានសព្វព្រះពុទ្ធហ្ន៎ឯណា តែធ្វើនៅតែទំនងជាតិចជាងផ្សាយព្រះពុទ្ធសាសនាចេញទៅទៀត រហូតដល់ដែនដែលពួកក្រិចពួលមកតាំងនៅ តាំងអំពីសម័យព្រះបាទអាលេក្សង់ដ្រីមហាពជ ហើយធ្វើបានផ្សាយព្រះពុទ្ធសាសនាចេញទៅរហូតដល់ទ្វីបអឺរ៉ុបនឹងទ្វីបអាហ្វ្រិកទៀតផង ។ មានសិលាចារឹកដែលធ្វើឲ្យចារឹកព្រះនាមរបស់ក្សត្រែបរទេសផ្សេង ។ ដែលធ្វើជួយប្រសសផ្សាយព្រះពុទ្ធសាសនា តែធ្វើឲ្យចារឹកព្រះនាមព្រះមហាក្សត្រែតអស់នោះជាភាសាបាឡាំងអស់ ដូចជា អន្តិយក: (ឥព្រះបាទអន្តិយូអ្នតុសទី ២ ត្រង់ស្រុកស៊ីរី) ១ តុរមាយ: (ព្រះបាទចំតូលេមេ ត្រង់ពជ្យប្រទេសអ៊ីស៊ីប្ដ៍) ១ អន្តិគោន: (ព្រះបាទអន្តិកូន ត្រង់ស្រុកម៉ាសេដ្ងាន) ១ អលិចសន្ទរ (ព្រះបាទអាលេក្សង់ដ្រ ត្រង់ស្រុកអេពីរុស) ១ ទំង់ស្តេចមក: (ស្តេចម៉ាគុសត្រង់ឧត្តរភូមិមួយ នៅទិសខាងកើតប្រទេសអេស៊ីប្ដ៍) ១ ដោយហេតុនេះ ទើបត្រូវតែពាក់ថាព្រះបាទអសោកបានប្រកាសផ្សាយព្រះពុទ្ធសាសនាបានធំទូលាយសំបើមអស្ចារ្យ មិនមានពុទ្ធសាសនិកជនណាមួយធ្លើបានដូចព្រះអង្គឡើយ ។ ក្នុងគ្រានេះយើងល្មមយល់បានថា ហេតុដូចម្តេច នៅលជមិនាថាសំខាន់ៗក្នុងគ្រិស្តសាសនាប្រហែលគ្នានឹងព្រះពុទ្ធសាសនាជាច្រើន ប្រសិនបើព្រះបាទអសោក

មិនទ្រង់ចំរើនតទាប់តទេ ឬថាកាលទ្រង់ចំរើនហើយ មានមហាក្សត្រ
ប្រតិបត្តិតាមស្នាមសំអាងរបស់ព្រះអង្គដោយសទ្ធាជ្រះថ្លាមុនមាំ ហើយ
មានព្រះរាជអំណាចច្រើនហួល ។ ទើបព្រះបាទអសោកហើយ មិនបាន
សង្ឃ័យទេឬយ អ៊ីរុចពាំនឹងខ្ជិចមុខជាបែរមុខមកកាន់ព្រះពុទ្ធសាសនា
ពាំនឹងអស់ ហើយព្រះពុទ្ធសាសនាទើបទៅជាទីគោរពកប់ឆាននៃលោក
ពាំនឹងមួល ហើយសភាពរបស់លោក ទើបសភាពរបស់ស្រុកទេស ទើប
ខុសប្លែកពីសម័យសព្វថ្ងៃនេះជាច្រើន ។

កាលអស់ចុណ្ណព្រះបាទអសោកមហារាជហើយ ក៏មានមហា-
ក្សត្រគ្រងរាជសម្បត្តិក្នុងដែនមគធៈតៗ មកទៀត ៦ អង្គ តែមិនបានផ្លើ
ទ្បាដែនមគធៈឲ្យចំរើនរុងរឿងឡើយ ទើបជាហេតុឲ្យព្រះបាទអគ្គិព្រហ្ម
ទី ៣ នៃប្រទេសស៊ីរីលើកទ័ពចូលលុកលុយប្រទេសឥណ្ឌា លុះដល់
ក្នុងពុទ្ធសករាជ ៦៧៤ ក្សត្រមោរិយៈអង្គចុងក្រោយបង្អស់នោះត្រូវមេទ័ព
របស់ទ្រង់ឆ្មើតតទៅ ពាជវង្សមោរិយៈចំណាប់ចុងត្រឹមណេះឯង ។ មេទ័ព
ដែលឆ្មើតតទ្រង់នោះឈ្មោះ បុសយមិត្រ តាំងខ្លួនឡើងជាក្សត្រគ្រងរាជ្យ
តាំងវង្សថ្មីហៅថាពាជវង្សសុង្គៈ នៅក្នុងទំព្រឹងបាដលិបុត្តដដែល តែព្រះ
ពាជអំណាចថយចាកបុរាណ ព្រះបាទបុសយមិត្រទ្រង់កាប់អាន្ទសាសនា
ព្រាហ្មណ៍ ទើបជាសត្រូវនឹងព្រះពុទ្ធសាសនាយ៉ាងខ្លាំងពេក បានជួត
រំលាយសាលាដែលព្រះបាទអសោកមហារាជ បានតសាងទុកមកនោះជា

ចំនួនច្រើន លុះមកដល់ពុទ្ធសករាជ ៣៨៨ ពួកក្រិកដែលនៅត្រួតត្រងដែនបាកត្រៀន តាំងពីសម័យព្រះបាទអាលេក្សង់ដ្រមហាពាជកំលុកលុយចូលមក ព្រះបាទបុសយមិត្រនឹងក្សត្រវង្សសុង្គៈតៗមក ក៏បានព្យាយាមទប់ទល់រហូតដល់ឆ្នាំពុទ្ធសករាជ ៤៧១ ដកបដល់ផុតពាជវង្សសុង្គៈ ហើយមានក្សត្រ ១ វង្សទៀតហៅថាវង្ស ៣ ខ្នា តែពាជវង្សនេះគ្រងពាជ្យបានត្រឹម ៤៥ ឆ្នាំ លុះដល់ពុទ្ធសករាជ ៥១៦ ក៏ផុតអំណាចអស់ទៅដែនមគធៈទាំងមូលក៏ធ្លាក់ទៅនៅក្រោមអំណាចក្រិក ។ ពន្ធ័ស្ថិនៃដែនមគធៈ ដែលធ្លាប់ថ្កុំថ្កើងរុងរឿងមក តាំងអំពីសម័យពុទ្ធកាលរហូតមកនោះ ក៏អស់ពន្ធ័ស្ថេក្នុងត្រានេះឯង ។

ដើម្បីឲ្យយល់ច្បាស់ក្នុងសាស្ត្រ(ស្តាវណ្ណ) ក្នុងចំណែកនេះឲ្យបានច្បាស់លាស់ យើងត្រូវបន្ថែមទៀតនិយាយអំពីអាណាខ្មែរនៅទិសខាងជើងដែលព្រះបាទអាលេក្សង់ដ្រ បានតាំងជាអាណាចក្រហើយនោះ ព្រោះនៅកូម៉ែចខេសនោះ មានមហាក្សត្រ ១ អង្គកើតឡើង ដែលជាក្សត្រដ៏ខ្លាំង ១ អង្គក្នុងពាក្យការថៃរបស់ព្រះពុទ្ធសាសនា គឺព្រះបាទមិលិន្ទ ។

(មានត)

(3)

សម័យនគរភ្នំ

មហាក្សត្រសេម ខេត្តតំបូរ រៀបរៀង

(តមក)

ព្រះបាទកោណ្ឌញ្ញជយវរ្ម័ន

ព. ស. ១០១៣-១០៥៦, គ. ស. ៤៧០-៥១១,

ព្រះមហាក្សត្រិយ៍អង្គនេះ មានក្រសែព្រះលោហិតជាក់ខន់ដោយ ព្រាហ្មណ៍ ព្រះនាមដើម កោណ្ឌញ្ញ (ដូចរជ្ជកាលទី ១) ស្តេចមកដល់ អណ្តៀបូលមកកន្លែងនៅភ្នំមោ ចេញពីភ្នំមោបូលមកកន្លែងស្រុកភ្នំន់ភ្នំន (កន្លែងដែនមលយូ)។ កាលព្រះបាទស្រីន្ទ្រវរ្ម័នទី ១ សោយទិវង្គត ហើយ(១) ឯជនជាតិនៅភ្នំ បានដំណឹងថា ស្តេចមកដល់ស្រុកភ្នំន់ភ្នំន ក៏គ្រងអារ ហើយចាត់ខ្លួនឲ្យទៅទូលអញ្ជើញស្តេចមកគ្រងពិភពនៅភ្នំ មានព្រះបរមនាមថា «កោណ្ឌញ្ញជយវរ្ម័ន» ខ្លះមានព្រះអគ្គមហេសីព្រះនាម សោមាទេវី ជាព្រះពុទ្ធសាក្យត្រិយ៍កន្លែងព្រះពុទ្ធវង្សមុន, ក្រោយមកខ្លះមានព្រះពុទ្ធទុសេប្បង ព្រះនាម ពាលាទិត្យ, ខ្លះមានព្រះពុទ្ធតាបន្ទាប់ ព្រះនាម សារស្វតី ។

---

១ ក្នុងពេលនោះ ប្រហែលជាគ្មានព្រះរាជវង្សដ៏សមគួរនឹងទទួលរាជសម្បត្តិ ។

ការដែនដី : ក្នុងផ្លូវដ្ឋប្បសាសនោបាយ ខ្ញុំដឹងឃើញការណ៍ដែលខ្ញុំបានចាត់តាំងកងទ័ពជើងគោក-ជើងទឹក ព្រមទាំងរបបរបរមកចាំការពារព្រំដែនឲ្យត្រឹមការដែលយកក្នុងសម័យបច្ចុប្បន្ន ខុសព្រមសម្រាប់ការពារប្រទេស, ឥឡូវនេះខ្ញុំបានតែងតាំងជនជូនឲ្យទាំព្រះពុទ្ធសាសនៅស៊ុំចង់សម្ពន្ធមិត្តនឹងស្តេចប្រទេសចិន ។ ពួកជូនដែលនៅប្រទេសចិនក្នុងគ្រានោះ ជាព្រះថេរៈនាម សក្យានុសេន ។ ព្រះមហាក្សត្រិយ៍ខ្មែរបានបញ្ជូនពួកជូនទៅស៊ុំចង់សម្ពន្ធមិត្តនឹងស្តេចចិនពាក់ជាគ្រាទី ៣ ក្នុងរជ្ជកាលនេះ ។

សង្គ្រាមបាម្ប៉ាគ្រាដំបូង

ព្រះសក្យានុសេន ត្រឡប់មកអំពីប្រទេសចិន បានទិមន្តគាត់នគរបម្ប៉ា, ស្តេចបាម្ប៉ាព្រះនាម ហៅតាមចិនថា (តាំងហោឆេ)[1] បានឲ្យមហាឧបដ្ឋាយកពួកជូនដែលស្តេចចិនផ្ញើមកថ្វាយ ព្រះបាទកោណ្ឌញ្ញជយវ៌ែនអស់ ហើយថែមទាំងប្រាប់ថា ឥឡូវកុំឲ្យមកវាយប្រទេសខ្មែរទៀត ។ ព្រះបាទកោណ្ឌញ្ញជយវ៌ែនកាលដែលដឹងដំណឹងតាមដែលព្រះសក្យានុសេនថ្វាយព្រះពរហើយ ដឹងព្រះទ័យថាតាំងហោឆេជាបុគ្គលតាលហួសប្រមាណ ឥឡូវបណ្តោយឲ្យបុគ្គលតាលមានអំណាចតទៅមិនជាការសួរសម ក្នុងការណ៍នេះជាមុខងារដែលព្រះអង្គ

---

๑ ពង្សាវតារចិនថា តាំងហោឆេ ជាតំណាខ្មែរតែជាខ្ញុំតារតំអំពីខ្មែរទៅនៅនគរបម្ប៉ា កំពប់ពួកបាមលើកទ័ពទៅសម្លាប់ស្តេចបាមបង់ តាំងហោឆេ កំបានឡើងសោយរាជ្យនៅបម្ប៉ា ។

ត្រូវតែចាត់ការកម្ចាយទៅបន្តែងតែងកងខ្លួនឲ្យទៅសុំកងទ័ពចិនមកជួយ
តម្ចាយ ។ ស្តេចចិនទ្រង់ជ្រាបសេចក្តីកងព្រះពជសារហើយ ក៏គ្រាស់
ថាតាន់ហោឆេមើលងាយព្រះចេស្តាព្រះអង្គ ទើបគ្រាស់ឲ្យសេនាបតី
រៀបឥតទ័ពទៅវាយតាន់ហោឆេ ដោយរុសពន់តាមសេចក្តីសុំរបស់ព្រះ
ចាវកោណ្ឌញ្ញជយវ័ន្ម ។ គ្រានោះ កងទ័ពចិនលើកមកវាយចម្បាំងផ្ទប់
ឥទាន់ផើង, កងទ័ពខ្មែរលើកទៅវាយផ្ទប់ឥទាន់ត្បូង ដោយព្រះចាវ
កោណ្ឌញ្ញជយវ័ន្មទ្រង់តំណែងជាកូនត្រួយស៊ីកចេញចម្បាំងដោយព្រះអង្គ
ឯង ។ តាន់ហោឆេក៏បរាលចេញចម្បាំងតទល់តេញទំហឹង តែទប់
កំម្បាំងកងទ័ពខ្មែរនឹងចិនពុំបានក៏ចាកជ័យទៅកន្លះវេលាមិនយូរប៉ុន្មាន
តាន់ហោឆេក៏ត្រូវប្រហារជើរតែបង់កងទ័ពរឿនឡើ ។ ព្រះចាវកោណ្ឌញ្ញ-
ជយវ័ន្មទ្រង់តាំងព្រះពជវង្សខ្មែរ ១ ឲ្យជាឧបជ្ឈាយ៍ត្រួតត្រាគន្លងចម្បាំ
កងហានេះជាប្រទេសកជ, ចម្បាំបានឡាំមកនៅគ្រាមឥទ្ធិពលខ្មែរក្នុង
គ្រានោះ (ព.ស.១៩៨៧) ជាដំបូង ។ សាលស្រែចព្រះពជសង្គ្រាម
ហើយ ទ្រង់ជម្រើសឯតាហានចិនទាំងព្រះពជតានរង្វាន់តាមសមគួរហើយ
តំបញ្ជូនត្រឡប់មកក្រុងចិនវិញ ។ ចំណែងព្រះអង្គក៏ស្តេចលើតទ័ព
ត្រឡប់មកព្រះនគរ ។

សង្គ្រាមគ្រានោះ ធ្វើឲ្យព្រះមហាក្សត្រិយ៍ចិនឃើញឥទ្ធិពលព្រះ
ចាវកោណ្ឌញ្ញជយវ័ន្មដែលទ្រង់ជាវីរៈក្សត្រិយ៍ខ្លាំងក្លាក្នុងវិជ្ជាលយុទ្ធ

ដ៏ឯកនោះ ទើបទ្រង់តាំងក្នុងតំណែងជាបមង្គ័ព ដ៏មានកិត្តិយសខ្ពស់ហៅថា «មហាក្សត្រតែយ៍សឹកក្នុងប្រទេសម៉ែកខាងត្បូង» ។ ក្នុងបណ្តាព្រះមហាក្សត្រតែយ៍ទាំងឡាយរបស់ខ្មែរ ព្រះបាទកោណ្ឌញ្ញជយវ៌្មន ទ្រង់បានទទួលព្រះកិត្តិយសជាមហាក្សត្រតែយ៍សឹក ប្រាកដនៅក្នុងប្រវត្តិសាស្ត្រ ជាអគ្គដំបូង ។

ក្រោយនោះ ទ្រង់បានលើកកំឡាំងទៅកាន់ប្រទេសម៉ែកខាងលិច ទីដែលម៉ែកខាងជើង ។ ម៉ែកខាងលិចទ្រង់ក៏យកបានប្រទេសមនទាំងមូល ដល់ទៅទន្ទឹងភាគ ។ ម៉ែនខាងជើងទ្រង់ក៏យកបានតតក្អែរថែរលាវ ទីដែលក្រុងវៀតលើខៀត ដល់នគរគុងឆីង ។ ក្នុងគម្ពីរគោកូមា (๑) ថាមនុស្សជាតិដែលតែងតែដែនមន មុនដែលកូមាផ្សាយពីទីបែតមក គឺជាតិខ្មែរ មានអំណាចធំក្រៃលែង គ្របដណ្តប់ដែនសុវណ្ណភូមិ មានព្រំប្រទល់អាណាខែត្រ (កាតខាងនេះ) តាំងពីទន្ទឹងភាគ ទៀតរហូតទៅដល់នគរគុងឆីងកាតខាងលើ បើមិនឆ្ងាយជាងនេះក៏ដល់ខែត្រអស្សមក្នុងបច្ចុប្បន្ន» ។

តាមប្រវត្តិសាស្ត្រដ៏មានមក យើងអាចកំណត់ដែនព្រំប្រទល់ព្រះពរអាណាចក្រក្នុងរជ្ជកាលនេះបាន គឺ

---

๑ ច្បាប់នៃលក្ខុមព្រះនាងធិបប្រែពន្ធពាស្ត្រទ្រង់ប្រែជាភាសាសៀម ។

ទាងកើត ផុតដែនបម្ប៉ា

ទាងលិច ផុតដែនមន

ទាងត្បូងទល់សមុទ្រ

ទាងទិសតឺ ដល់ពាក់ចណ្តាលដែនម៉ាលយូ

ទាងជើង ដល់ខេត្តកុងកង ។

តាមផ្លូវនេះ ឃើញថា ព្រះពុទ្ធអាណាចក្រខ្មែរក្នុងសម័យនេះក្នុងជាងកន្លងសម័យណាៗ ទាំងអស់ ។

ប្រវែងគ្រប់គ្រងផ្លូវក្រោម

វិធីគ្រប់គ្រងផ្លូវក្រោមរបស់ខ្មែរកន្លងសម័យនេះក្នុងនេះឃើញថា ផ្លូវយុទ្ធបែបគ្រប់គ្រងយ៉ាងឥតល្អៀមរៀបរៀង ស្មើរតែគ្រប់យ៉ាងដូចនៅនេះ ។

ក្នុងសម័យដែលព្រះមហាក្សត្រិយ៍មានអំណាចវាសនាក្លាធំមានព្រះពុទ្ធអាណាចក្រធំទូលាយ, ព្រះពុទ្ធអាណាចក្រទាំងមូលនោះ, វែមគ្រែវែងជា ២ សង្កាត់ គឺស្រុកទាំងឡាយដ៏តាំងនៅកន្លងសង្កាត់ទាងកើតថ្មសង្កាត់ទណ្តាល ហៅថា មជ្ឈមវង្គ (=ដែនកណ្តាល) សង្កាត់នេះនៅកន្លងអំណាចគ្រប់គ្រងរបស់ព្រះមហាក្សត្រិយ៍ ពុទ្ធធិពុទ្ធ ។ ស្រុកធំៗ ដែលតាំងនៅតាមជាយដែន គ្រែអំពីមជ្ឈមវង្គចេញទៅសឹងធ្វើជាប់ស្រយាលអំពីព្រះពុទ្ធធានីធំ មិនមានតំណត់ចំនួនចាត់ជាវង្គមួយ ។ ហៅថា បច្ចន្តវង្គ (=វង្គជាយដែន) ។ បច្ចន្តវង្គនេះ មានការគ្រប់គ្រង

ជាប់ដោយឡែក ដោយព្រះពាធពិពាធខ្លាំងតែងតាំងព្រះពាធវង្សវែលមានសមត្ថភាពនឹងជាទីពុះព្រះពាធហួចទ័យឲ្យទៅរៅគ្រប់គ្រង ខ្លាំងព្រះពាធមានអំណាចឲ្យចញ្ចតច្បាប់សម្រាប់ប្រើក្នុងរដ្ឋនោះ ។ ឲ្យមានអំណាចតែងតាំងមន្ត្រីមានទេសនាចរជាដើម ទឹងតាំងត្រួសួងការពាំងពួនដោយខ្លួនឯង តែក្នុង ១ ឆ្នាំ គឺកងទុនសច្ចូលឆ្នាំកល់ ។ ឆ្នាំត្រង់ឆ្នាំជ្រូមាសឆ្នាំច្រាក់ ទឹងសួយសាគរ ជាជាលវោរ ក្នុងស្រុងនោះ ។ មកថ្វាយព្រះមហាក្សត្រិយ៍ពពាធជ ។

ស្រុកដែលច្បាប់តាំងជាបច្ចន្តរដ្ឋ មានព្រះទុបពជគ្រប់គ្រងក្នុងសម័យនគរកុំ ឬរហូតដល់សម័យនគរធំ គឺរដ្ឋស្រែធម្មនគរ (នគរស្រែធម្មជ) ក្នុងដែនម៉ាលយូ ក្នុងបច្ចុប្បន្ននេះជារបស់សៀម តាំងពជជានីរៅស្រែធម្មនគរ ។ រដ្ឋក្តាវតី តាំងពជជានីរៅអយុជ្ឈា តែជួនកាលលើកទៅតាំងរៅលវោ (លពបុរី) ។ រដ្ឋគោត្របុរៈ តាំងពជជានីរៅកិម៉ាយ ។ រដ្ឋនគរកុំ តាំងពជជានីរៅនគរកុំរៅជាមានលិចជាវែងត្រសត្វថ្ងៃ ភូមិភាគខាងលើ តពីនគរកុំរៅចល់នគរកុងកំពង់ តង់មានតាំងជារដ្ឋសម្រាប់ព្រះទុបពជ ១ អង្គទៀត តែមិនដឹងជាតាំងពជជានីរៅណាជាប្រាកដ ដោយសន្និដ្ឋានថា ប្រហែលជាតាំងរៅវាងវៀងចន្ទ ទឹងហ្នឹងព្រះបាង ។ រៅមណ្ឌលភូស័ងស៊ុនក៏ច្បាប់មានព្រះទុបពជគ្រប់គ្រង ១ អង្គដែរ តាំងពជជានីរៅឃ្លាំង ជួនកាលតាំងពជជានីរៅទីជាវែងទៀតក៏មាន ។

ចំណែកប្រវេណីគ្រប់គ្រងប្រទេសកាដផែលជារបស់ជាតិដទៃ តែត្រូវផ្ទាក់មកនៅក្រោមអំពើលទ្ធែ បើមិនត្រូវការជាក់ប្រទេសនោះចញ្ចូលមកក្នុងព្រះពុទ្ធអាណាចក្រទេ ត្រូវខុនប្រទេសនោះជាប្រទេសកាដ ត្រូវតាំងក្សត្រិយ៍ក្នុងប្រទេសនោះឲ្យគ្រប់គ្រងខ្លួនឯង តែត្រូវទាំកាដចណ្ណាការមកថ្វាយព្រះពុទ្ធជាធំកាដរៀងកល់ឆ្នាំ ដូចព្រះបរមាដផែលគ្រប់គ្រងឥឡូវនេះដ ។

ក្រៅអំពីការពង្រីកព្រះពុទ្ធអាណាចក្រ ព្រះបាទកោណ្ឌញ្ញាដយ-វរ្ម័ន ទ្រង់បានចំពេញព្រះពុទ្ធកណីយកិច្ចទំនុកបំរុងប្រជាជនស្តួ តាមហានៈព្រះអគ្គដាមហាក្សត្រិយ៍ម្ចាស់ផែនដ៏ គឺការទុស្សាហកម្ម ទ្រង់ទំនុកបំរុងជនស្តួឲ្យសិក្សាវិជ្ជាជំនាន់ផ្សេង ។ មានការគ្សាញសំតាំដាដមធ្យស្អរលើសក្នុងកាលមុន ។ មក ទ្រង់រៀបចំការតែងកាយឲ្យមានរបៀបថ្លៃថ្នូរឡើង, ការសេដ្ឋកិច្ច ទ្រង់ឲ្យដឹកស្រះ ដីកន្ល ផ្លូវទំនប់ទឹកដ៏ជាប្រយោជន៍ក្នុងការប្រើប្រាស់ទ្រង់ក្នុងការធ្លើរបរសេដ្ឋកិច្ច, ការវេដ្ឋកម្ម ទ្រង់ទំនុកបំរុងវិជ្ជាពេទ្យទ្រង់តាំងអាពាគ្សាសាលាមន្ទីរពេទ្យខ្លួនៗក្នុងព្រះពុទ្ធអាណាចក្រ ។

ការព្រះសាសនា = ព្រះបាទកោណ្ឌញ្ញាដយវរ្ម័ន ទ្រង់គោរពប់អានតាំងសាសនាព្រាហ្មណ៍ តាំងព្រះពុទ្ធសាសនា, ទ្រង់ទំនុកបំរុងសាសនាតាំងពីរនេះ ពស្តុតាងក្នុងរឿងនេះ គេច្រៃរយើញសិលាចារឹត

๒ អង្គ្ខ តឺសិលាចារឹក ๑ សំដែងសេចក្តីរំលឹកដល់ព្រះវិស្ណុ សិលាចារឹក
នេះនៅជាប់ម្ខាង តំបន់ភាលកក់ ក្នុងដែនកូសង៌ស៊ីន ។ សិលាចារឹក
๑ ទៀត រំលឹកដល់ព្រះពុទ្ធ គេឃើញនៅស្រុកបាទី (ខេត្តតាកែវ
ចារឹកអាង៌ពីរនេះគេសាង៌ឡើងក្នុងរវាង ព.ស. ๑๐๔๐ ដល់ ๑๐๙๑
សឲ្យឃើញថា ក្នុងសម័យនោះ សាសនាទាំង៌ពីរបានមកតែងស្ថាន
ក្នុងប្រទេសខ្មែរយ៉ាង៌ចម្រើណាហើយ តែទាង៌សាសនាព្រាហ្មណ៍នោះ
គេនិយមកាន់ណែន ព្រះហរិហរៈ ច្រើនជាង៌យ៉ាង៌ដទៃ ដោយមានរូបភាព
ព្រះហរិហរៈ ច្រើនជាង៌រូបភាពយ៉ាង៌ដទៃ នៅដល់សព្វថ្ងៃនេះ ។ ឯព្រះ
ពុទ្ធសាសនាក្នុងសម័យនោះ មានទាំង៌លទ្ធិស្ថវីរៈ (ហីនយាន) ទាំង៌លទ្ធិ
មាហាយាន (មហាយាន) ព្រះបាទកណ្ហទាជយវរ្ម័នច្រើនតែនិយមក្នុង
ព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈ ជាង៌លទ្ធិដទៃ ព្រោះដូច្នេះបានជាគេរកឃើញ
ក្នុងប្រទេសរបស់ព្រះបាទ កាណ្ហទាជយវរ្ម័ន មានតាជមក្នុងព្រះពុទ្ធ-
សាសនាច្រើនជាងគេ ។ ក្នុងលទ្ធិស្ថវីរៈនឹង៌អាចារ្យកនោះ គេសង្កេត
ឃើញលទ្ធិស្ថវីរៈរុងរឿង៌ជាង៌ ដោយហេតុអ្នកស្រុកបានទទួលសិក្ខា
នឹង៌ដង្រៃហ្វូក្នុង៌ទម្លាប់ព្រៃតែចំដូចជារបស់ទាំង៌លទ្ធិស្ថវីរៈដែលបានបែបបទមក
ពីលង្កាក្នុងរជ្ជកាលព្រះបាទបន្ទូន:, ទាំង៌ក្នុង៌វេលានោះមានព្រះមហាថេរ
๒ អង្គ្ខ តឺព្រះសង្ឃទាតសេន មកអំពីវណ្ណ ๑ ព្រះសង្ឃឃោល ๑

តាំងពីអន្លង់នេះជាអ្នកខ្លែងនូវព្រះវិតែចំដកយ៉ាងចរចូលណា, ព្រះសង្ឃ-
ចុលប្រវែលជាមានតំណែងជាសង្ឃនាយក: ព្រះពុទ្ធសាសនាបាន
រុងរឿងខ្លាំងក្នុងវេលានោះ ដោយអំណាចព្រះមហាវេរៀងទាំង ៦ អង្គនេះ
ទំនងដោយអំណាចព្រះមហាកស្សបត្ថេរខ្លង់ខ្លួលៗបត្តម្ភ ។

ក្នុងគ្រាចង់សម្ពន្ធមិត្តនឹងប្រទេសចិន ព្រះចុងភោណ្ឌញ្ញជយវ៉ែន
ខ្លង់អាចនាព្រះសក្យនាគសេនឲ្យជាកងខ្លួនទៅប្រទេសចិន, គ្រាយ
ពីនោះមក ២០ ឆ្នាំ ព.ស. ๑๐๒๖ ស្តេចចិនឲ្យកងខ្លួនាំព្រះពជបណ្ណាការ
មកសុំព្រះសង្ឃនាគសេនទៅផ្សាយនៅប្រទេសចិន ។ ព្រះចុង
ភោណ្ឌញ្ញជយវ៉ែនខ្លង់អាចនាព្រះសង្ឃចុលឲ្យទៅ ប្រវែលរយៈពេលធម៌
នៅក្រុងចិន អស់វេលា ៤ ឆ្នាំ ទើបត្រឡប់មកវិញ ។ ក្នុងរឿងនេះ
ពាក្យថាផាកគ្គិយស ๑ ហ៊ានរបស់ខ្មែរយើង ។

ការកន្លងពជត្រកូល, ព្រះចុងភោណ្ឌញ្ញជយវ៉ែនខ្លង់តែងតាំងព្រះ
នាលាទិត្យឲ្យទៅគ្រងអនគ្គិតបុរៈ (នៅភោះនៃខាងលិចព្រហ្មទេត)
ខ្លង់ព្រះពជទានព្រះនាងសាសូតី ឲ្យជាតំរោតព្រាហ្មណ៍ច្រាជ្ញធំឈ្មោះ
វិស្សវូប ។ ព្រះពជវង្សភោណ្ឌញ្ញបានតំណែកជសន្តតិវង្សនឹងផ្សាយចេញ
ទៅដូច្នេះ:

(មានត)

② លោកវ៉ាយ-ប៊ុក ពាក្យរៀង

(តមក)

២ បណ្ឌិតវិគ្គ

១ - ទ្រព្យធនកើតក្រោយកាយា ចោរកកាយាវើសមាយោ
ក្រទ្រព្យមាសប្រាក់បញ្ញាធ្លាត ហៅមានតាមខ្លួនតន់ពាក្យខ្លី ។

២ - មនុស្សម្នាក់មានគេស្អប់ស្រឡាញ់ ពាលអាងគាប់ជាញ់
ចាក់សម្លាប់ បណ្ឌិតអាងក្តីសុចរិតគាប់ ពារកឥតស័ក្តអាងតែយំ ។

៣ ធម្មជាតមនុស្ស សុចរិតល្អស្មោះ មិនបានមួយជាតិ មាន
ទុសត្រង់ខ្លះ ប្រព្រឹត្តជាអាទិ៍ ចំណេញឬខាត ធម្មតាលោកិយ ។

៤ - វត្តកន់លោក មនុស្សសត្វទ្រព្យគោគ អប់រំនិស្ស័យ បង្ហាត់
បង្រៀន តាក់តែងសម័យ តន់មានជំរៀ ក្នុងប្រជុំជន ។ មាសតេជ
ចរណៃ ដុសខាត់ភាត់ប្តៃ ត្រូវឲ្យតយតន់ រុកជាតិភាត់មែក ពត់តេន
ល្អលន់ បត់បែនតាមជន ជាតិយើងនិយម ។

ក្របី ដែលគេត្រង់ទុកយូរមានកូនស្អុយ លាយទឹក ៧-៨ ភាគ ទឹកមូត្រ ១
ភាគ ។ នៅពេលធ្វើកូនច្នាំ អ្នកធ្វើបរនេះគេសំចៃទឹកមូត្រមិនហ៊ាន
ចោលទេ ។ កូនច្នាំខោះលុះត្រូវដីទឹកដងភ្លៀង ក៏លូតលាស់យ៉ាងរហ័ស ។

កាលកូនច្នាំមានស្លឹកធំជាងប្រាក់កាក់ឡើងទៅ គេរុះដំបូលចេញ
ដើម្បីឲ្យត្រូវចំហាយថ្ងៃ តាំងពីថ្ងៃសាបមកជាង ១ ខែ កូនច្នាំក៏មានស្លឹក
ប៉ុនប្រាក់រៀល ។

២ — ស្លឹង

កាលកូនថ្នាំសំណាបមានស្លឹកធំប៉ុនថ្ងាក់រៀលហើយ គេដកចេញពីរងសំណាបយកទៅស្ងួត លើរងសំខ្ទួនទៅតែម្តងគ្មានទេ ។ មុនឆឹងដកកូនសំណាបទៅស្ងួត គេស្រោចទឹកកូនថ្នាំក្នុងរងសំណាបឲ្យជោកសព្វ ហើយគេរើសដកយកតែកូនសំណាបណាដែលមានកំពស់ ៣-៤ ផ្ចាប់ គេរលាស់ដីដែលជាប់នឹងឫសចេញខ្លះ រួចគេយកទៅស្ងួតលើរងសំខ្ទួន ក្រោយដែលគេស្រោចទឹកឆ្អែមជ្រងខ្លាំងស្រេចហើយ ។

របៀបស្ងួតគេយកមែកឈើបុបុស្បីតូចប៉ុនកូនមេដៃ ចុចទៅលើជ្រងដោយដៃទ្វេង ហើយគេចាប់កូនថ្នាំដោយដៃស្តាំ យកគល់កូនថ្នាំញាត់ទៅក្នុងចំណុចរណ្តៅ ហើយយកដៃចំឆឹងគល់កូនថ្នាំ គេស្ងួងឲ្យឃ្លាតពីគ្នា ៣-៤ ផ្ចាប់ ។ តាំងពីស្ងួងហើយមានកំច្រត្រូវចែកក្សាដោយស្រោចទឹកឆឹងជាក់ដីឆីឆមន្តែមដូចកាលនៅជាកូនសំណាប ។ ដល់កូនសំខ្ទួនដុះស្រស់ល្អមានដើមរឹងប៉ឹងទ្បើង គេបើកដំបូលចេញឲ្យត្រូវកំដៅថ្ងៃ ។ តាំងពីថ្ងៃស្ងួងមកចំនួនជាង ១ ខែ កូនសំខ្ទួនធំមានស្លឹកមូលពងក្រពើរឹងទឹង ៣-៤ ផ្ចាប់ បណ្តាយ ៥-៦ ផ្ចាប់ ដើមប៉ុនខ្នាត កំពស់ពីគល់ដល់ចុងសន្ធឹក ១ ភាមប្ត ១ ចំអាម ល្មមដកយកទៅដាំក្នុងបម្លាប្រហាន ។

របៀបធ្វើកូនថ្នាំដែលមានសាបមានស្ងួងដូច្នេះ ជារបៀបសម័យ

ប្អូនណា ឯសម័យបច្ចុប្បន្ននេះគេមិនប្រាថ្នាស្លូងទេ គ្រាន់តែសាបហើយ គេ
ទុកកូនសំណាបនោះឲ្យធំល្មមដាំបាន ទើបគេជីកយកទៅដាំតែម្តង ។

៣- ជាំ

ការដាំចុងខែកត្តិកឬដើមខែមិគសិរ (ធ្លាដេសម្រិ) ដែលកូនថ្នាំ
មានទំហំធំប៉ុនដែលពោលមកក្នុងថ្នាក់ទី ២ ខាងដើមនោះ គ្រានឹងពេលដ
ចម្ការ ក៏ទឹកទើបនឹងស្រកធុតទៅថ្មីៗ ដីទៅសើមល្អ អ្នកធ្វើរបរឲ្នាំគេទៅ
ធ្វើដីចម្ការ ។ របៀបធ្វើដីចម្ការគេធ្វើត្រង់ក្បាលចម្ការមុន គឺមុនដំបូងគេ
កាប់ព្រៃព្រៃតែងស្មៅដុតចោល ហើយក្លែរកស៊ីធ្វើជារបាំងកូនឲ្នាំដោយ
គ្រឿងប្រដាប់អំបាលនេះ គឺ:

ក) ខ្វែរត្រង់ មានឆ្អែដែកប្រវែង ១ ហត្ថ ទទឹង ៤ ឆ្នាប់ កម្រាស់ មៀន
ដែកប្រវែង ៣ ឆ្នាប់ មានខ្សាត្រង់សីតទៅកណ្តាលឆ្អែឈើប្តឹងពីរប៉ុនកំដៃ
កេង ប្រវែង ២ ហត្ថ ១ ចំអាម ។ (ច្បាប់ដើមមានគូរូបខ្វែរត្រង់ធង) ។

ខ). ខ្វែរបក មានឆ្អែដែកប្រវែងជាង ១ ចំអាម ទទឹង ៥ ឆ្នាប់ មៀន
ដែកប្រវែង ៣ ឆ្នាប់ មានខ្សាក្រង់ក់ មានធង់ទំហំនឹងប្រវែងប៉ុនខ្វែរត្រង់។
(ច្បាប់ដើមមានគូរូបខ្វែរបកធង) ។

គ) រនាស់ធំ មានមេឈើ ៤ ដុំធំ ពង់សំបែតបន្តិច ទំហំទោល ៤
ឆ្នាប់ បន្ទា ៥ - ៦ ឆ្នាប់ ប្រវែង ៤ ហត្ថ ឆ្នេញឈើខ្ទឹម ចំនួន ៨ ឬ ១០
ប្រវែង ១ តក់ ទំហំ ២ ឆ្នាប់ គល់ ៤ ដុំធំ ចុងមូលស្រួច សីតទៅកណ្តាល

ដំណាប់មេ, ដងឈើប្រវែង ៦ ឬ ៧ហត្ថ គល់ដងជ្រុង ចុងមូលកន្លះបែតងបន្តិច គេចោះដងតន់កជាក់គិល មានទឹមឈើប្តូរប៉ុនកំភួនដៃ ប្រវែង ៤ ហត្ថ បង្កាប់ទឹងដងដោយខ្សែតាមធ្លៅពីស្បែកគោឬក្តៅរោញ មានខ្សែទាម ២ ត្បាញកណ្តាល រោញចុង-ដើមដោយផ្តៅ បង្កាប់ទឹងទឹម ១ ម្ខាង សម្រាប់រឹមគោ ៤ ហៅថា ១ ទឹម ។ (ច្បាប់ដើមមានគូរូបទោសធំតាមទំងន់ទឹមផង) ។

ឃ) ខ្នង់ល មានក្តៀងឈើ មុខស្រួច មានតម្លៀងជាក់ជាលជែកគ្រោយមានស្បាបជាចំតាម បណ្តោយប្រវែងជាង ១ ហត្ថ តវែងស្បាបបញ្ឈរ ១ ទោម មានកន្ទុយកាង ៤ ជ្រុងសំប៉ែតបន្តិច ទំហំ ៤ ឬ ៥ ធ្នាប់ តន់កន្ទុយមានដំណាប់សម្រាប់បញ្ចេះយោមឈើរាងមូលគោង ប្រវែង ៣ ហត្ថ ។ (ច្បាប់ដើមមានគូរូបខ្នង់លផង) ។

ង) គប់ មានផ្ទៃឈើមូលប៉ុនក្តៅ ប្រវែងជាង ១ ចំអាម ដងឈើមូលប៉ុនកដៃ ។ (ច្បាប់ដើមមានគូរូបគប់ផង) ។

ច) ឈើបុះ ទំហំប៉ុនកំភួនដៃ ប្រវែង ៤ ហត្ថ រៀងចុងស្រួចគល់ ។ (ច្បាប់ដើមមានគូរូបឈើបុះផង) ។

ឆ) ខ្សែសិន មានដងប្រហែល ២ ទំហំដំណាំមេដៃ ប្រវែង ១ ហត្ថ ១ គក់ បង់ខ្សែ ១ បង្ហាយស្តាប់តិចដង ១ ទោដង ១ ប្រវែងខ្សែតាមចំនួនតវឹងបម្លាស់ ។ (ច្បាប់ដើមមានគូរូបខ្សែសិនផង) ។

គេតាប់តែតែគន់ដោយខ្នែរគន់ បកស្មៅដោយខ្នែរបុក ពាស
តែគន់ខឹងស្មៅដោយរមាស់ ភ្ជួរដោយនង្គ័ល ពាយដំណុំ ។ ដោយគប់
ហើយគេពាស់ដោយខោស់ បង្ក្រាបដីឲ្យរាបល្អ ។ លុះធ្វើដីបានស្រួលបួលហើយ គេផ្តើមដាំកូនច្នាំដំបូងដែនខែវិច្ឆិកាសៅរ៍ ព្រោះមានកូនតែមាដាំដំណាំច្រាប់ថា បើដាំដំណាំយកស្លឹកត្រូវដាំថ្ងៃនេះ តែអ្នកខ្លះគេផ្តើមដាំតាមក្បួនដោយសុខោដូចគោលមកក្នុងច្បាប់ទី ១ ក៏មាន, អ្នកខ្លះគេដាំដោយមិនប្រាប់មើលបុក្ខរថ្ងៃក៏មានដែរ ព្រោះដាំកូនច្នាំគេតែមានរឿបសំណែនអ្វីទេ គ្រាន់តែមើលបុក្ខរថ្ងៃប៉ុណ្ណោះឯង ។ មុនខឹងដាំ ១ ថ្ងៃ គេទៅស្រោចទឹកកូនច្នាំនោះឯងសិនទុង ហើយដែលដកយកតែកូនច្នាំណាដែលមានដំហាំធំប៉ុនដែលនិយាយក្នុងច្បាប់ទី ២ នោះឯង ដាល់ឬស្ដីធ្វើមទឹកគ្រប់ចំនួនក្នុងប្រមូងឥលូវ ដល់ស្អែកឡើងព្រលឹមថ្ងៃសៅរ៍ គេយកខ្សែសំនៅទាញសន្ធឹងតឹងចម្ការពីព្រំម្ខាងទៅម្ខាង ដោតប៉ាន់ស្មើសុខខ្សែសំន ហើយយកឈើបុះ បុះដំតាមឆ្នូរខ្សែសំនទោះឃ្លាតពីគ្នាប្រវែង ១ ហត្ថ ១ ចំការ ឬ ១ ឆ្នូរ ហើយគេបុះ ១ ឆ្នូរទៀត ឃ្លាតឆ្នូរពីគ្នាប្រវែង ១ ហត្ថ ១ តក តាំគេយកឯងខ្សែសំនមោះជាឡាត ។ លុះបុះរណ្តាហើយ គេយកកូនច្នាំទៅដាំក្នុងរណ្តានោះហើយគេលុបដីបន្តិចៗ គ្របឫសកូនច្នាំ អ្នកខ្លះដាំទៅមុខ អ្នកខ្លះស្រោចទឹកតាមក្រោយដោយកូនក្អម ១ តូច ។

សុភាសិតភាគទី ១

លោកព័ន្ធ - ប៊ុត រៀបរៀង (តទៅ)

៣ – ពាលវគ្គ

៣០– ពូជឆ្កាមិនដែលចាកចោលសៀព្រៃ មច្ចាឆលស័ម្យមិនចោលខឹក ពូជចោរមិនចោលចោរកម្មិក ឆនពាលប្រមឹកមិនចោលខ្ញុច ។

៣១– ពោគាត្រូវមានទុសចរែក កើតទុក្ខចិត្តប្រែធម៌ជាច្បាំ ពេលក្រលំប៉ាកទន្តីគ្នា ចិត្តពាលប៉ាងធ្លាំគ្មានច្បាំគែ ។

៣២– មនុស្សយើងសព្វថ្ងៃ ហ្វូងគោវែស័យ ធ័ស្មៅខៅពាលធាតុឡាកជស័ហ៍ ប្រឹងស្មៀតគ្រប់គាល មិនចោលក្បួនពាល ចាំចាប់បំរោគ ។

៣៣– រង៉ាឆល្មួន ក្លៀងឡាក់ប៉ុង៉មុខ ល្អធាអាក្រក់ ដំខៅធាតូច ពាលខ្លើយសសត្តំ មិនខំប៉ានប្រាក់ ឈើក្រាក់ដុះត្រួយ ។

៣៤– គ្រីហាប៉ាក់បែកនាប់ទប់ទល់ កុមារល្ងង់សល់នាប់ប្រួលប្រែ បើខុសយូរថ្ងៃគាន់ម្នាំថែ ចិត្តពាលពេលកែលំប៉ាកកែក ។

៣៥– សម័យបច្ចុប្បន្នពាលច្រើនភាគ សាសនាគ្មូរធ្លាបឲ្យចេះសេចញ រលែងរលើឡើងឆួបពាលគេញ ខ្ពើមទុក្ខគោសមិញគន់តែជួប ។

៣៦– ក្អែងធាតុត្រូវពាត់ព័ត្ថុបតាប មនុស្សធាតុគេអាចពាត់ព័ក្អែងសិក្សាវិជ្ជាត្រូវខ្នះខ្នែង ឲ្យចាំធាក់ស្ពឹងពីដំបូង ។

๓๗ — ตาលស្តាលខ្លួនឯងឯងតាលតាំត បណ្តិតតោលថាឯង ច្រើនឯងឯង ដើរតាលអួតគុណដែលមិនមាន កុំស្មានដើរខ្លួនតាំតាលខ្លៃយ ។

๓๘ — ឯងតំតាលឃើញតាលចូលគ្នាឯង ឯងតំសង្កាលច្រើនណាមិនឆ្គួត តូចចោរយកចោរឯងមិត្តភ័ក្តិ បណ្តិតសោតាគប់សប្បុរស ។

๓๙ — អាចារ្យច្រៃចំតួនអាចោរ ខ្លួនទំមែកតោធ៌ស៊ីឆ្កែឆ្កៃ ខុចរំតនាំខ្លួនឲ្យហ៊ានហៃ អាស្រយ័យសុចរិតកំតសុខ ។

๔๐ — ក្អែកស្តាលខ្លួនក្អែក តង់ច្រៃតាមឆ្នែក ឯងហង្សាវិញ តោឯងឆស៊ាហ៍ ខុសត្រូវម្តេចមិញ លុំតចូលភ្នំចេញ តេញឯងលុង់ពំត ។

๔๑ — ទ្រព្យតាលប្រយោជន៍រូបអាត្មា ទ្រព្យសប្បុរសាសាសនាឯតំ ដូចទឹកអណ្តូងក្តៀងឯងអាទិ៍ អ្នកឆងសង្ឃាតឯងអស្រយ័យឯង ។

๔๒ — សាស្តាសោតំណាមានគប់ច្នាក់ សង្ឃខុវាសកច្រតិបំត្តិតិប មិនឃើញអ្នកណាឯងសម្រេច ទិព្វាត្តិស់ឯងឯលសិរហាន ។ ច្រើលអ្នមិនឃើញវ័តន៍បុគ្គល តេសង្ឃ័យខ្លួនឯលឯងដើមឯង ឯបុរមាណូវិត្តិ តូហាន តូលញ្ជីដែលឯងឯងបំឆ្ងាញលោក ។

ឥត្តីវិគ្គ

๔๓ — នារីរូបខ្មៅរកត្រកំត្រែ មារយោងច្នៃតាំងចំត្តក៏សោតា រំសេសឯង់ស្រែលូ្អឯងា ចំត្តលោតាមិនលួមនឹងតាមពាត ។

៤៦ — តរុណីស្អាតរូបសម្បុរយែកក កុមារីប្លែកចិត្តសណ្ត សម្បុរយ
ចិត្តាក្តីបវរ ក្នុងលោកកម្រែនធីឯបានដូច ។

៤៥ — ប្រុសស្រឡាញ់នារីច្រើនមិនបានការ ចំណីអាហារ
ច្រើនមុខលំបាកលូក ចិត្តសង្ស័យដៃមិនធាក់ក្តាន់ប្តូរក រកលួកមិន
ប្តូរឆ្កែរសោះនែវទេ ។

៤៦ — ប្រុសរើសកិរិយា រូបខ្មៅក្តីចា ចិត្តាមិនត្រូវ ម្តុយសល្អដែរ
ខាស់តែលូងខ្លៅ ចង់ដើរច្រើនឆ្ងាយ ដួចក្អែកស្រលៀង ។

មនុស្សរើសចំណី ឆ្តោប្លាមិនដឹង រើសអើងបែរបៀង រកឆ្កែមាន់
ខា សម្រាប់ដប់លៀង ដល់ឃ្លានមិនទៀង លួកតាងត្រហុក ។

៤៧ — ពោលច្រើនស្រែចស្រី ខុសច្រើនស្រែដី អ្នកចំឆ្លើការ
គិតច្រើនអាតាម ប្លាឆ្ងាញ់តាលា កូនច្រើនមេប្លា ប្លាឆ្ងាសោកំណ ។

៤៨ — ស្រីស៊ីវិល័យយកប្តីចិត្តឯង៎ ស្រីបុកណាតែងតាមម៉ែ
គោឯតកូនស្រែគង់ស៊ីស្រូវ នារីរើសឆ្កែក្តាត់កិរិយា ។

៤៩ — ប្រុសស្ងាប់ឆ្កាប់មុខស្រឡាញ់ស្រី ខារពេជ្រមាសខ្ចី
ខ្សែទំហំ សំពត់ការហូលព្រៃគំនូរ គិតគូរក្រឡឲ្យតាមពេញចិត្ត ។

៥០ — លំអងកអូបការពោរឆ្កា លំអងកញ្ចាការពារស្រី ក្នុង
ការនេះយោប្លាយតួកនារី ស៊ើបការច្បាំ ។ សឹងប្លាខឆល ។

៥១ — ឋច្ចុប្បន្នសត្វថ្ងៃ នារីសម័យ មានសមភាព ស្មើនឹងបុរស មិនមែនបោកខាប ប្រុសខ្លះចាញ់ពាប ប្រៀបផ្ទឹមពុំបាន ។ នាងរៀនអក្សរ ហត្ថកម្មបវរ ក៏ចេះចំណាន រៀនបើកវេយ្យន្ត បុរាកាសយាន ស្មើគ្រែធ្វើការហាន វិស័យកូនប្រុស ។

៥២ — កញ្ញាសោឡសដូចគំនូរ លាបពណ៌តិតគូរសាមសិបគត់ ជ្រលក់ល័ខពិតដោយសន្ទុត សែសិបឆ្នាំកត់តាមមាត្រា ។

៥៣ — នារីមាយាស្មើមិនស្តី បើខ្លួនបេតីព្រងើយច្បាណា ញ៉ែរខ្លួនគតគោលពាក្យកលល្បាណ ពិនិត្យតាមដានឲ្យដឹងច្បាស់ ។

៥៤ — ពេលទ្រព្យបុណ្យសំភ័ន្ធឯស្ត្រី ប្រែខុសប្រក្រតីដូចសុរិយា មិនដែលនៅទៀងទិសបូតា នេះជាធម្មតាតាក់តែងឡើង ។

៥៥ — នារីស៊ីវិល័យក៏ស្រស់ស្អាត ប្រព្រឹត្តខុសច្បាប់ទទបវេណី ប្រុសស្រីដើរលេងដូចអគ្គី កំប្រៀងធឹកស៊ីនេះដល់ចិត្ត ។

៥៦ — ស្នេហ៍តាមបច្ចមសប្បាយប្លែក ដល់ក្រោយដេកស្រែកយំទុក្ខសោក ជាតិអាហារល្ងីងច្បាយច្រកឆោក ឆ្កាញ់តាមបរោគក្រោយហើមពោះ ។

៥៧ — សម័យភ្លុនារីថ្ងៃ ដោយស៊ីវិល័យតែងច្បាណស្រស់ ស៊ីតសក់ឆ្នេញសសាច់លាបប្រស់ ប៉ាំងមន្ទិលអស់ប្រុសព្រិលក្លែក ។

36 - Ni regret du passé, ni peur de l'avenir -

៣៦ - កុំស្តាយអតីត, កុំខ្លាចអនាគត-

" បើដើម្បីខ្ញុំ ព្យាយាមរំលុះ ឧបសគ្គគ្រប់យ៉ាង កែខ្លួនជាច្រើន កុំបីច្រើសកង់ ចំគិតកសាង ជាគំនរស្តុកគាត្មា " ។

37 — Noblesse oblige

៣៧ - សកាពអភិជន នាំឲ្យប្រព្រឹត្តធម៌ថ្លៃថ្លា -

" គ្រកូលខ្ពង់ខ្ពស់ យល់ហេតុផលស្មោះ ហិរិត្តប្បា ប្រព្រឹត្តសោភ័ណ ទើបឋានថ្លៃថ្លា គេលើកទុកជា អភិជនពិត " ។

38 — Hors l'honneur nul souci —

៣៨ - ខ្ញុំគ្មានបារម្ភអ្វី ក្រៅពីកិត្តិយស-

" ត្រូវរក្សាកិត្តិយសតាមហានា ការពារកុំឲ្យមានសៅហ្មង ដូចបុត្រប្រឹមប្រិយនៃខ្ញុំនហោង គួរចង់ចិត្តចាំកុំប្រហែស " ។

39 — Tiens quoiqu'advienne—

៣៩ - ត្រូវប្រឹងខ្លួនជាមុន ក្នុងការដែលមានគ្រោះថ្នាក់-

" គ្រោះថ្នាកមកដល់ ត្រូវឆ្លងតាមកល ញញឹមកក្តា ធ្វើចិត្តឲ្យមុតតយុទ្ធបុប្ផា - មិត្តមកពុះពារ កុំឲ្យរន្ធត់ " ។

40 - Plus deuil que joie -

៤០ - មានសេចក្តីទុក្ខសោកច្រើនជាងរីករាយសប្បាយ -

"កង់នាលៅកំយ ចាំង់ប្រុសចាំង់ស្រី ត្រូវខំប្រឹងប្រែង ស្វែងរកភ្លឺ
សុខ ដែដើង់ខ្លាត់ខ្លែង ខ្លាំងខ្លាយចាត់ចែង កិច្ចការសារពើ ។ ទើបបាន
កេរ្តិ៍ឈ្មោះ នាមល្បីពីពេះ សាយសព្ទអន្ទៃ ដោយទុក្ខព្រួយសព្ទ ដួយ
ជាតិស្មោះស្មើ ឋានឡើង់គ្រាន់បើ ទុក្ខទោសអនេក" ។

41 — Qui n'a confience n'a rien—

៤១ — បើគ្មានទុកចិត្ត ក៏គ្មានចំណានអ្វីឡើយ—

"កិច្ចការពាក់ព្រៃវ ដែលយើង់ជម្រះ ឲ្យឆ្លើងដូចម្តេច លុះតែ
យើង់ឈឿ ទុកចិត្តជាស្រេច ទើបបានសម្រេច ដូចយើង់បំណង" ។

B) - DIVERSES DEVISES

ផ្នែកជាវិបនាផ្សេងៗ

1 - Liberté, Egalité, Fraternité —
Devise de la république française

១ — សេរីភាព, សមភាព, ភាតរភាព

ជាវិបនាសាធារណរដ្ឋជាតិបារាំង ។

2— Dieu protège la France —
Devise de la monarchie française

២ — ព្រះម្ចាស់សូត៌ ទ្រង់ការពារប្រទេសជាតិបារាំង-

ជាវិបនា រាជាធិបតេយ្យជាតិបារាំង ។

3— Honni soit qui mal y pense —
Devise des chevaliers de la Jarretière

៣ — អ្នកដែលគិតអាក្រក់ ត្រូវឆ្លើងឲ្យខ្មាសកណ្តាលដំនុំជន-

ជាវិបនា របស់ពួកដំរៀនដ៏ សារីរៃវ ។

4— Je maintiendrai —
Devise de la maison de Nassau

៤ — ខ្ញុំនឹងជានាឲ្យខ្ជាប់ដំណតទៅ

ឃ្លាវចនា នៃពូជវង្សណាសូ្ប ប្រទេសហុល្លង់ដ ។

5 — Droit et vérité —
Devise de l'ancien Royaume de Suède et de Norvège

៥ — សិទ្ធិ និង សច្ចៈ

ឃ្លាវចនា ពូជាធិបតេយ្យនៃពូជអាណាចក្រចុងក្រោយ ប្រទេស-
ស៊ុយអែត និងណរវែស ។

6 — L'union fait la force —
Devise de la Belgique

៦ — សាមគ្គី ធ្វើឲ្យ កំឡាំង

ឃ្លាវចនា ប្រទេសបេលហ្ស៊ិក ។

7— Dieu et mon droit
Devise de la maison Royale d'Angleterre

៧ — ព្រះម្ចាស់និងសិទ្ធិរបស់ខ្ញុំ

ឃ្លាវចនា ពូជាធិបតេយ្យប្រទេសអង់គ្លេស ។

8 — Par le glaive et par la charrue
Devise du Maréchal Bugeaud

៨ — ដោយដាវ ឬ ដោយផ្លឹស

ឃ្លាវចនា ឧត្តមសេនីយ ប៊ុយសូដ ។

9 — Plus ultra (Encore plus loin)
Devise de Charles Quint

៩ — ឲ្យឆ្ងាយទៅទៀត —

ឃ្លាវចនា មហាពូជ សាល - កាំង -

10 Le méchant ne voit que l'épine
Devise de Mme Tallien

១០— ជនខូចភាព មើលឃើញតែបន្លា

ចារឹកថា អ្នកស្រីតាល់យាន ។

11— Gradatius (Pas à pas)
Devise de Descartes

១១— សន្សឹមៗ កុំបំបោល-

ចារឹកថា អ្នកចាប់ផ្លេស្លាត ។

12 — Quo non asecendam (où ne monterai-je pas)?
Devise du surintendant Fouquet

១២— ម្តេចក៏ខ្ញុំមិនឡើងទៅខ្ពស់-

ចារឹកថា រដ្ឋមន្ត្រីហ៊ាញ ហ្វូគេត ។

13 — Nec pluribus impar (Je suffirais à plusieurs) (emblême un soleil)
Devise de Louis XIV

១៣— ខ្ញុំមានចរិយាជន៍ សមាប់ជនច្រើន (មានរូបព្រះអាទិត្យជាបដិមា)

ចារឹក - ស្តេចល្អិតី ១៤ ។

14 Beau, dru et court-
Devise de la famille de Beaudricourt

១៤— ល្អ, ខ្ចាំង, ខ្លី—

ចារឹកថា នៃកជវង្សបូឌ្រីគួរត៍

15 — A tout venant beau jeu-
Devise de la Famille de Beaujeu

១៥— អ្នកណាក៏ដោយ ត្រូវខ្ជូលកត់ខាត់ខ្ចាំងអស់

ចារឹកថា បេសកជវង្សបូហ្ស៊ឺ ។ (នៅមានត)

4 — Je maintiendrai —
Devise de la maison de Nassau

៤ — ខ្ញុំនឹងជានាឲ្យនៅស្ថិតស្ថេរ

ជាវចនា នៃពូជវង្សណាស្សូ ប្រទេសហុល្លង់ដ ។

5 — Droit et vérité —
Devise de l'ancien Royaume de Suède et de Norvège

៥ — សិទ្ធិ នឹង សច្ចៈ

ជាវចនា ពូជាធិបតេយ្យនៃពូជអាណាចក្របុរាណ ប្រទេស-
ស៊ុយអែត នឹងណារ៉ែស ។

6 — L'union fait la force —
Devise de la Belgique

៦ — សាមគ្គី ភ្លើត កំឡាំង

ជាវចនា ប្រទេសបេលហ្ស៊ិក ។

7 — Dieu et mon droit
Devise de la maison Royale d'Angleterre

៧ — ព្រះម្ចាស់នឹងសិទ្ធិរបស់ខ្ញុំ

ជាវចនា ពូជាធិបតេយ្យប្រទេសអង់គ្លីតែរ ។

8 — Par le glaive et par la charrue
Devise du Maréchal Bugeaud

៨ — ព្រួញជារ ឬ ព្រួនឆ្នាំស

ជាវចនា ឧត្តមសេនីយ ប៊ុយសូដ ។

9 — Plus ultra (Encore plus loin)
Devise de Charles Quint

៩ — ឲ្យឆ្ងាយទៅទៀត —

ជាវចនា មហាពូជ សាល - កាំង-

10 Le méchant ne voit que l'épine
Devise de Mme Tallien

១០— ជនខូចភាច មើលឃើញតែបន្លា

ចារឹចនា អ្នកស្រីតាលីយាង ។

11— Gradatius (Pas à pas)
Devise de Descartes

១១— សនៀមៗ កុំបំបោល-

ចារឹចនា អ្នកជ្រាជ្រេស្លាត ។

12 — Quo non asecendam (où ne monterai-je pas)?
Devise du surintendant Fouquet

១២— ម្តេចកើឡើមិនទៀងតទៅទៀត-

ចារឹចនា រដ្ឋមន្ត្រីហ៊ីរញ្ញវត្ថុ ហ្វូកេត ។

13 — Nec pluribus impar (Je suffirais à plusieurs) (emblême un soleil)-
Devise de Louis XIV

១៣— ខ្ញុំមានប្រយោជន៍ សម្រាប់ជនច្រើន (មានរូបព្រះអាទិត្យ ជាបដិមា)

ចារឹចនា - ស្តេចល្អិតី ១៤ ។

14 Beau, dru et court-
Devise de la famille de Beaudricourt

១៤— ល្អ, ខ្លាំង, ខ្លី—

ចារឹចនា នៃពូជវង្សបូទ្រីគួរត៍

15 — A tout venant beau jeu-
Devise de la Famille de Beaujeu

១៥— អ្នកណាក៏ដោយ ត្រូវទទួលការតតាំងស្មើ

ចារឹចនា របស់ពូជវង្សបូហ្ស៊ឺ ។ (នៅមានត)

ពាក្យផ្តើម

ក្នុងទស្សនាវដ្តីខែមុននេះ យើងបានចុះផ្សាយពាក្យប្រែនិងពាក្យអធិប្បាយ ដែលយើងបានដកស្រង់យកមកអំពីច្បាប់ដើមមន្តាញ ប្រទេសកម្ពុជា ។ ក្នុងទស្សនាវដ្តីខែនេះ នឹងខែជាលំដាប់តទៅ យើងនឹងចុះផ្សាយពាក្យប្រែផ្សេង ។ របស់គណកម្មការវប្បធម៌ តាំងពីពេលចាប់ផ្តើមធ្វើទ្បើងជាដំបូង គឺលើថ្ងៃ ៣០ កញ្ញា ឆ្នាំ ១៩៤៦ ម៉ោង ១៩ នឹង ៣០ នាទី ក្រោមអធិបតីព្រះសង្ឃអគ្គមន្ត្រីស៊ុសុវត្ថិ - យុត្តិវង្ស ដំនុំទៅធ្លុះលោកហែម - ចំរើន ឆ្លងកាត់ហាន់ កុំពេញ ។

រហូតមកដល់ដើមឆ្នាំ ១៩៤៧ គណកម្មការវប្បធម៌លើកទៅដំនុំប្រែពាក្យផ្សេង ។ ទៅបន្ទប់លេខានុការដ្ឋសភា ក្រោមអធិបតីអ្នកអគ្គមន្ត្រីសុវត្ថិធម៌ ។

រួចតមកក្នុងដើមឆ្នាំ ១៩៤៨ ទើបពង្រាងតាំងគណកម្មការវប្បធម៌ជាផ្លូវការ ចាប់ដំនុំដំបូងនៅមន្ទីរក្រសួងសិក្សាធិការ ក្រោមអធិបតីលោកឈាន - រ័ម រដ្ឋមន្ត្រីសិក្សាធិការ ។ ដោយហេតុក្រសួងសិក្សាធិការតាំងនៅទីប្រជុំផ្លូវធំ ជាទីអ៊ូអរពេក មិនស្រួលដល់កិច្ចដំនុំរបស់គណកម្មការដែលត្រូវការទីស្ងាត់ ទើបគណកម្មការលើកទៅដំនុំនៅទីចាត់ការ សាលាចុល័ជាន់ខ្ពស់ ក្រោមអធិបតី ព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ដរាបមកដល់សព្វថ្ងៃនេះ ។

តាំងពីពេលដែលរាជការចាត់តាំងគណកម្មការជាន្សការខ្លឹង គណ-
កម្មការត្រូវជំនុំគ្នាក្នុង ១ អាទិត្យ ២ ដង គឺថ្ងៃអង្គារ នឹងថ្ងៃសុក្រ ពីម៉ោង
១៨ ទៅម៉ោង ២០ ។

ពាក្យចុះទាំងឡាយ ដែលយើងនាំយកមកចុះឲ្យាយក្នុងទស្សនាវដ្តី
នេះ មានតែពាក្យចាំាងនឹងពាក្យប្រែជាភាសាខ្មែរ គ្មានពាក្យអធិប្បាយ
ប្រកបធងន់ទេ តាំងពីដំបូងមក ។ ការចុះឲ្យាយពាក្យចុះៗនេះ ជានយោ-
ប៉ាយមួយ ដែលជួយពង្រីកភាសាខ្មែរ ឲ្យកាន់តែស្តុកស្តម្ភចំរើនឡើង
ក្នុងឃ្លាំងនៃអក្សរសាស្ត្រខ្មែរបច្ចុប្បន្ននេះ ។

ហ្វូងនិពន្ធមន្ត្រី ញ៉ុក - ថែម

ស័ព្ទទាក់ទងច្បាប់ជាខ្មែរ

របស់គណៈកម្មការវប្បធម៌ ឃានច្បែគ្រោមអធិបតី

នៃព្រះសង្ឃអគ្គមាស៊ី ស៊ីសុវត្ថិយុត្តិវង្ស

Loi = បញ្ញត្តិ (ព្រះរាជបញ្ញត្តិ)

Loi organique = បញ្ញត្តិរបៀប

Décret = កិត្យ, ព្រះរាជកិត្យ

Arrêté = អនុកិត្យ, ព្រះរាជានុកិត្យ

Décision = សម្រេច (សម្រាប់រដ្ឋមន្ត្រី)

— id — = ដីកា (សម្រាប់ចៅហ្វាយខេត្ត)

Réglement = បទបញ្ជា

— id intérieur = បទបញ្ជាក្នុងក្រសួង

Droit = ច្បាប់

Droit (faculté) = សិទ្ធិ

Droit civil = ច្បាប់រដ្ឋប្បវេណី

Droit public = ច្បាប់មហាជន

Droit privé = ច្បាប់ឯកជន

Droit civique = ច្បាប់ពលរដ្ឋ

Droit pénal = ច្បាប់ព្រហ្មទណ្ឌ

Droit international = ច្បាប់រវាងប្រទេស

Droit international privé = ច្បាប់ឯកជនរវាងប្រទេស

Droit international public= ច្បាប់មហាជនរវាងប្រទេស

Voter = បោះឆ្នោតយល់

Discuter = ពិភាក្សា, ជជែកគ្នា,

Promulguer = ប្រកាសឲ្យប្រើ

Sanctionner = ឲ្យអនុម័ត

Ratifier = ឲ្យសច្ចាបំផុ

Initiative = ដើមគំនិត

Projet de loi = សេចក្តីព្រាងច្បាប់

Proposition de loi = សេចក្តីស្នើច្បាប់

Code = ក្រម

Article = មាត្រា, ប្រការ,

Législature = នីតិកាល

Session = សម័យប្រជុំ

Séance = ពេលប្រជុំ

Bureau = ក្រុមអគ្គិបាល (សំព្ធរដ្ឋសភា)

Bureau définitif = ក្រុមអគតិជ្ញាលេស័ម - ពេញអ៊ី

Président = ប្រធាន, អធិបតី

Vice président = អនុប្រធាន, អធិបតីរង

Secrétaire = លេខាធិការ

Secrétaire Général = អគ្គលេខាធិការ

Attribution = មុខងារ

Condition d'éligibilité = លក្ខណសម្បត្តិនៃបេក្ខជន

Loi en vigueur = ធរមានបញ្ញត្តិ

Finances = ហិរញ្ញវត្ថុ

Budget = ថវិកា (ការគ្រោងប្រាក់ចំណាយចំណូល)

Question sociale = បញ្ហាសង្គម

Question culturelle = បញ្ហាវប្បធម៌

Pétition = ពាក្យប្តឹងសុំ

Exposé des motifs = សេចក្តីថ្លែងហេតុ

Cause = បុព្វហេតុ

Avis = យោបល់, ប្រកាស

Voeu = បំណង

Disposition spéciales = វិធីប្បញ្ញត្តិពិសេស

Interpellation = សំនួរដេញដោល

Famille = គ្រួសារ គ្រកូល, អំបូរ

Tribu = ភូលសម័ន្ត

Clan = បក្ខសម័ន្ត

Peuplade = វិប្រជាគម

Société = សង្គម

Association = សមាគម

Patriarcat = បេតេយ្យាកា

Matriarcat = មត្តេយ្យាកា

Nation = ប្រជាជាតិ

National = នៃប្រជាជនតិ, របស់ប្រជាជាតិ

Etat = រដ្ឋ

Peuple = ប្រជាពស្ត្រ, ប្រជាខ្មុរស្ត្រ

Population = ប្រជាជន

Habitant = អ្នកស្រុក

Sujet = អន្តរស្ត្រ, អន្តរជន

Titre = ចំណុក

Partie = ភាគ, ចំណែក (មាន)

ប្រវត្តិសាស្ត្រនៃខ្មែរ

ហ្វូងធំពន្លឺ ញ៉ុក-ថែម រៀបរៀង

(តមក)

វគ្គទី ៣

ព្រះបាទមិលិន្ទ-រង្វែយ្យអេជិ លទ្ធិមហាយាន

មានដែនដីមួយកន្លងសម័យបុរាណហៅថា ប៉ាកត្រែន ហើយក្នុងវេលានេះហៅថា ខ្លូតគីស្ថាន នោះលក្ខណៈរបស់ភូមិប្រទេសក្នុងសម័យគ្រានោះ មានទំនងដូចគ្នានឹងការប៉ាកាដិស្ថានក្នុងសម័យនេះ គឺថាជាស្រុកសំខាន់តាមផ្លូវយុទ្ធសាស្ត្រនឹងធ្វើដំណូញ ជាទីសម្បាប់ភ្ជាប់តគ្នារវាងដែនអ៊ីរ៉ានឆ្ងាយនឹងតំណែ ហើយមានឆ្ងាយឆ្ងាយអំពីតំណែទៅស្រុកចិនឆ្ងាយដែរ ក៏មានជាតិល្អច្រើន ។ ចំពោះដែនប៉ាកត្រែននេះ គួរពោលថាជាដែនដីរបស់ពួកអរិយកៈសុទ្ធ ព្រោះពួកដែលលុកចូលមកកន្លងតំណែក្តី បុដែលលើកចូលទៅក្នុងប្រទេសបុរីហើយក្លាយទៅជាពួកមែតដូចពោលរួចមកហើយក្តី សុទ្ធតែជាពួកប៉ាកត្រែននេះឯង ។ ដូចពួកនេះប៉ានចែករក្សាសភាពដ៏ពិតប៉ាកដរបស់ខ្លួនគុកប៉ាន មិនប៉ាច់លាយច្របល់ធ្លុះធ្លឹងជាតិដទៃទេ កាលព្រះបាទអាលេក្សង់ដ្រីចូលលុកលុយដល់ដែនដីនេះ ក៏ធ្វើយល់ភ្លាមថាជាទីតំបន់ដ៏សំខាន់មួយ ទើបទ្រង់យកទ័ពប៉ាកត្រែននេះ ជាទ័ពមួយចំណុះផ្សេងៗរបស់ព្រះអង្គ

ទឹងស្រែកចំណុះដងខ្លែត ។ នៅតំបន់អស់នោះ ដែលព្រះចៅអាលេក្សង់ជ្រើ
ខ្ងែតាំងមេទ័ពឲ្យកាន់កាប់រក្សាជាដំណាងព្រះអង្គ គឺខែត្រសែកជ្រៃង,
តាវៀ, ម៉ាយៀង, ជ្រាន់យៀង, ភាពកូស៊ីងគន្ធារៈ ក៏ជាចំណុះរបស់
ស្រែកថ្មាកត្រែនទាំងអស់ ហេតុដូច្នេះ អាណាខែត្រថ្មាកត្រែននេះ
ខើបគ្រាយទៅជាអាណាចក្រកំកសុខ ។ ភ ។

បណ្តាស្រែកចំណុះអស់នេះ ព្រះចៅអាលេក្សង់ជ្រើខ្ងែតាំងតាហាន
រក្សាខុតជាចំនួនច្រើន ទៅតំបន់នុះ មានពួកតាហានជាតិអ៊ីងឌីងជាតំ
កែកជាចំនួនភាំងហ៊ីនក៏មាន ។ តាលអស់បុណ្យព្រះចៅអាលេក្សង់ជ្រើ
ទៅពួកមេទ័ពតាងព្រះនេត្រព្រះកាណិអស់នោះ ក៏មានចិត្តរំលោកឡើង
វៀងខ្លួនគិតតាំងខ្លួនជាឯកពាធ្យឡើង ។ គ្រានោះ មានមន្ត្រីស្តេចតាលេ-
ក្សង់ជ្រើម្នាក់ឈ្មោះខិយោងុត ដែលជាអ្នកគ្រប់គ្រងខែត្រថ្មាកត្រែន ថ្មាន
ប្រកាសតាំងខ្លួនឡើងជាក្សត្រគ្រងរាជសម្បត្តិ តាលពុទ្ធសករាជ ២៩៣
ខ្ងែព្រះនាមព្រះចៅខិអុងុតទី ១ ហើយព្រះមហាក្សត្រអង្គនេះ ថ្មាន
សំដែងសេចក្តីក្លៀវក្លាអង់អាចចូលលុកលុយរហូតដល់ខែត្រប៉ាងធី តែបួន
ជាគ្រានមិនល្អ ខ្ងែទ័ពត្រឡប់ទៅមុនដើការថ្មានសម្រេចរៀបរយ ។ ព្រះពាធ-
នរបស់ព្រះអង្គ ខ្ងែព្រះនាមខិអុងុតទី ២ ថ្មានខ្លួលគ្រងរាជ្យជាដំណ
តមក តែត្រូវពួកមន្ត្រីកែកប្រចាំខែត្រសែកជ្រៃងឈ្មោះ យុធិដ្ឋិម លុប
លាងអំណាចអស់ទៅតាលពុទ្ធសករាជ ៣១៨ ហើយតាំងខ្លួនជាក្សត្រ

គ្រងរាជ្យនៅសុកដៀន, ឯកត្រៀន, ម៉ារយៀនទឹងអារៀហូតដល់ឆ្នាំ
ពុទ្ធសករាជ ៣៤៣ ។ ព្រះបាទយុធិដែមស្ទើរតែទៅជាមហាក្សត្រ
ដែលមានអំណាចយ៉ាងធំរៀតលែងមួយកន្លែងបន្តិចទេសតណ្តៀ តែបន្តិចជា
មានមហាក្សត្របទេសស៊ីរីខ្លះ ព្រះនាមអន្តិអូគុសទី ៣ ឯានធ្វើចម្បាំង
លុកលុយឯានជ័យជំនះពួកឯ៉ាវធ៌ ហើយខ្លះលុកចូលតមកទៀតក្នុង
ដែនឯកត្រៀន ។ ដំបូង ព្រះបាទយុធិដែមខ្លាំពា្យាយាមតស៊ូទប់ទល់
យ៉ាងម៉ឺងម៉ាត់ តែដល់មកចុងក្រោយគោងទទួលចុះចាញ់ ហើយបណ្តា
ការណាខ្មែរបស់ព្រះបាទយុធិដែម ក៏ធ្លាក់ទៅនៅក្រោមអំណាចរបស់
ព្រះបាទអន្តិមអូគុសជាច្រើន ឯព្រះបាទយុធិដែមនៅតំណែងតែព្រះពាង-
អំណាចត្រឹតត្រាឯានត្រឹមដែនឯកត្រៀនទឹងសុកដៀនប៉ុណ្ណោះ ។ ការ
ព្រះបាទយុធិដែមក្រុយព្រះជន្មហើយ ព្រះពាងនុះរបស់ខ្លះៗព្រះនាម
ឌីមីត្រីអូសឯានទទួលគ្រងរាជសម្បត្តិតមក ហើយគ្រប់គ្រងដែនដីតាំងពីរ
ចំណែកនេះ ក្នុងរវាង ព. ស. ៣៤៣ ដល់ ព. ស. ៣៥៦ ខ្លះមាន
អំណាចខ្លាំងក្លាឡើងជាងដើម ដោយចម្បាំងលុកលុយឯានដែនបញ្ជាប
ក់យឯានស្រុក សង្គ្រាមហើយចុះមកទាងត្បូងក់យឯានស្រុកបំកគា លេខ
ក្នុងសម័យនេះហៅថា សិន្ធនីងដែនសុកស្ត្រ ។

ប៉ុន្តែការធ្វើយអំណាចរបស់ព្រះបាទឌីមីត្រីអូសនេះ ត្រូវការតាំងចិ
ចេញក្នុងការតស៊ូការ ដោយមានមេទ័ពម្នាក់របស់ខ្លះក្បត់ទឹង

ខ្ញុំ គ្រាតែខ្ញុំត្រូវប្រគល់ដែនឲ្យកេរត្រឹមនឹងសកដៀន ហើយខ្លៅ
ដែនឯទៀតៗដូចអារៀនឹងគន្ធារៈក៏គាំងជានគរតូចៗទៅវិញ មានជនជាតិ
ក្រិកផាទៅហ្វាយត្រួតគ្រានគរ ។ លុះតមកដល់ពុទ្ធសករាជ ៣៦៣
ព្រះហ្វាទយុគ្រាតិជាស ទើបត្រឡប់រួបរួមយកស្រុកអស់នោះមកទុកក្នុង
អំណាចរបស់ព្រះអង្គហ្វានវិញ ទើបគួរពាប់ថា ខ្ញុំជាមហាក្សត្រ ១
អង្គរបស់ជាតិក្រិកក្នុងតណ្ឌ តែខ្ញុំមិនឲ្យានជាយកព្រះទ័យទុកដាក់
ឆ្ងល់ដែនដ៏ធំទូលាយរបស់ក្រិកខ្លៅខាងលិចឆ្ងាយឡើយ ទើបជាហេតុឲ្យជន
១ ពួកដែលមានឈ្មោះចា យូអេដ៏ មានភូមិលំនៅក្នុងតំបន់អស់នោះ
រួបរួមកំឡាំងតាំងជាកងទ័ពឡើង ហើយហ្វានលៅវាយជណ្តើមយកខែត្រ
សកដៀនលៅហ្វាន អំពីព្រះហ្វាទយុគ្រាតិជាស តែខ្ញុំខ្លៅមានកំឡាំង
ទប់ទល់ការពារដែនហ្វាកត្រឹមទុកហ្វាន តែខ្ញុំមិនឲ្យាន់អស់គ្រោះតមក
ព្រះអង្គត្រូវព្រះរាជទាស ១ អង្គរបស់ខ្ញុំធ្វើគត់លៅ កាលពុទ្ធសករាជ
៣៧៤ ។ កាលអស់បុណ្យព្រះហ្វាទយុគ្រាតិជាសហើយ អាណាចក្រ
របស់ក្រិកក្នុងតណ្ឌក៏បែកខ្ញែកចេញជាភាគៗអស់លៅ ។ ១ភាគធ្លាក់
លៅជារបស់ អាប៉ូលណៅដូត ដែលជាព្រះរាជទាសឬង្ស របស់ព្រះ
ហ្វាទយុគ្រាតិជាស ។ ចំណែកខាងគន្ធារៈ, បុរុមៈបុរៈ នឹងស្រុក
តក្កសិលាខ្លៅរួមគ្នាជាអាណាចក្រ ១ ទៀត មានក្សត្រគ្រប់គ្រងតមក ។
ក្នុងពុទ្ធសករាជ ៣៩៦ មហាក្សត្រដែលគ្រងអាណាចក្រនេះ ជាពួជ

ត្រកូលជាតិកំកែព្រះនាម មេនខ្មែរ តាមគម្ពីរព្រះពុទ្ធសាសនាហៅថា ព្រះបាទមិលិន្ទ ខ្ញុំមានវិប្បដិសារអំណាចលុបលាងអំណាចក្សត្រ ដែលខ្ញុំលគ្គនឹងរាជសម្បត្តិតមកបស់ព្រះបាទយុ គ្មានតំណាសចេញបានសម្រេចហើយ ខ្ញុំទៅជាមហាក្សត្រដ៏មានវិប្បានុភាពខ្លាំងក្នុងតំបន់នោះ ខ្ញុំបានតាំងទីក្រុងមេស្រុកសង្កែ: ខ្ញុំបានចាត់ការត្រួតត្រាយ៉ាងរឹងប៉ឹង ខ្ញុំបានតឹកអាណាខែត្រ មកខាងខ្ញុំគង្គាបើគិតប្រៀបធៀបពី ព្រះរាជអំណាច ក្រៅពីព្រះបាទអាលេក្សង់ដ៏មហារាជហើយ មិនមានក្សត្រជាតិកំកអង្គណាធ្លាប់បានស្មើនឹងព្រះអង្គខ្លួយ ។

តមក ខ្ញុំបញ្ជូនយូទៅដ៏លុកលុយចូលមកក្នុងអាណាខែត្របស់ព្រះអង្គ ព្រះបាទមិលិន្ទ ខ្ញុំនាំគាហានយមកកកណ្តាលដែនដីនៃប្រទេសតណ្ឌៀបន្តិចម្តង ។ ជរាបដល់បានស្រុកមធុរ: ដែលតាំងនៅតាមមាត់ច្រាំងទន្លេយមុនា ហើយហួសចូលមកក្នុងដែនកោសល ខ្ញុំយកបានស្រុកសាកេតនឹងអយោធ្យា ហើយលុកយកក្រុងរាជគ្រឹះ (ដែលបានឆ្លាស់ឈ្មោះថា វិហារ តាលរាជ្យព្រះបាទអសោក) ហើយខ្ញុំលុកហួសចូលទៅដល់ស្រុកបាដលីបុត្រ ដែលសព្វថ្ងៃនេះហៅថា បំតនា រួមសេចក្តីថា ព្រះបាទមិលិន្ទខ្ញុំកយលុកយកឥណ្ឌៀបានដែនដីច្រើន ជាងព្រះបាទអាលេក្សង់ដ៏មហារាជទៅទៀត ហើយខ្ញុំបាននាំយកអារ្យធម៌បស់ក្រិកមកធ្វើលាយគ្នានឹងព្រះពុទ្ធសាសនា ។

តាមដោយពិត ក្នុងជាន់ដំបូង ព្រះបាទមិលិន្ទទ្រង់ឱ្យបង្ហូរនូវ
សាសនារបស់ក្រិក ដែលមានចំនួនព្រះរាប់មិនអស់ ដូចបានតោលមក
ហើយក្នុងពង្សាវតាររបស់ក្រិក ។ មួយវិញទៀត ការដែលព្រះបាទ
មិលិន្ទលើកទ័ពមកញាំញីនឹងធ្វើអន្តរាយដល់ស្រុកសំខាន់ផ្សេងៗ ដូចក្នុង
រាជត្រីនឹងបាដលីបុត្រជាដើម ទ្រង់មានព្រះបំណងនឹងបំផ្លាញព្រះពុទ្ធ-
សាសនាដោយពិត តែចួនជាយប់ ១ នោះ ព្រះចន្ទកំពុងពេញវង់ក្នុង
ថ្ងៃពេញបុណ៌មី ព្រះបាទមិលិន្ទមានព្រះរាជហឫទ័យជ្រាថ្នាំនឹងទ្រង់ប្រ-
ស័យសន្ទនានឹងអ្នកប្រាជ្ញណាមួយ ដែលជាតិក្នុងព្រះពុទ្ធសាសនា
បុរាណ ព្រាហ្មណ៌ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាអ្នកប្រាជ្ញ នៅទីបំផុត
ទ្រង់ចាន់ដួបប្រទះនឹងព្រះនាគសេនត្ថេរ ទើបមានការដែកគ្នានឹង ១ ប្រ-
ស្នាផ្សេងៗ ដូចមានសេចក្តីពិស្តារក្នុងគម្ពីរមិលិន្ទបញ្ហានោះស្រាប់ តួរ
រាប់ថាជាគ្រាដំបូងក្នុងពង្សាវតារ ដែលអ្នកប្រាជ្ញជាតិក្រិកជាអ្នកមានសំដីថ្លៃ
មាត់យ៉ាងល្បីល្បាញក្នុងលោក ប៉ានមកល្បួងសំដីថ្លៃមាត់នឹងព្រះសាវក
របស់ព្រះពុទ្ធជាម្ចាស់ នៅទីបំផុតនៃការសាកល្បង ព្រះរាជាជាតិក្រិក
ព្រះអង្គក៏ទ្រង់ជាញ៉ាំព្រះពុទ្ធសាវក ហើយទ្រង់ប្រកាសព្រះអង្គជាពុទ្ធមា-
មក: ទ្រង់ទទួលជាសាសនូបត្ថម្ភក៍យ៉ាងម៉ឺងម៉ាត់ គួរតែរាប់ថាជាទីពីរបន្ទាប
អំពីព្រះបាទអសោកមហារាជមក ដោយទ្រង់ប្រាន់ទីនុកបំរុងព្រះពុទ្ធសា-
សនា ឲ្យបានចំរើនរុងរឿងឡើងពិតៗឡើងវិញទៀតក្នុងប្រទេសតំណែ

ខ្ញុំបានកសាងវិហារសាលាខ្មៀនជាច្រើនគ្រឿងដំកើងព្រះកិត្តិយសរបស់ព្រះអង្គជាច្រើន ។

ព្រះបាទមិលិន្ទខ្ញុំទិដ្ឋភៅក្នុងព្រះពុទ្ធសកាជ ៩១៣ កិច្ចការដែលខ្ញុំបានធ្វើ គឺខ្ញុំបានទាំយកគំនិតគតិគន្ថរបស់កែកមកធ្វើលាយគ្នានឹងលទ្ធិពុទ្ធសាខា ជាហេតុនាំឲ្យព្រះអង្គបានទទួលសេចក្តីនិយមកាប់អានជាយូរអង្វែងតមក មាមក្យត្រែតព្រះវង្សដែលជាជាតិកែកបានទទួលកជសម្បត្តិតមក អង្គចុងក្រោយបង្អស់ គឺហេរមេអូស ដល់មកក្នុងពុទ្ធសកាជ ៩១៣ ជាវង្សរបស់ព្រះបាទមិលិន្ទក៏ជាចុងក្រោយ ដោយត្រូវពួកយូអេជ៍ លុកលុយចូលមកគ្រប់គ្រងខែត្រដែនបាក់ត្រៀន ។

ឯពួកយូអេជ៍ខេះ ជាជាតិខ្មែរគឺនឹងម៉ុងកូលីលាយគ្នា ចាប់តាំងអំពីចន្លោះជាតិជាអាណាចក្រចាន់មាំមួនឡើងរាល់ពុទ្ធសកាជ ៣២៣ មានកើតចលាចលរឹតវែងក្នុងទ្វីបអាស៊ីកាត់កណ្តាលជាច្រើន ។ ព្រះរាជាធំជាងរបស់ចិនអង្គដំបូង។ ចាន់ពង្សីកអាណាខេត្តដេញពួកជនជាតិសំបុរលឿងដែលហៅថា ហាន់ប្តូហ៊ន ដែលត្រូវជាបុព្វបុរសរបស់ពួកខ្មែរគ័ប្តម៉ុងកូលីក្នុងសម័យខេះ ទើបធ្វើឲ្យហ៊ានខឹងចិនទៅជាសត្រូវគ្នាយ៉ាងធំ ដូចមានសេចក្តីសារសំគ្រក្នុងប្រវត្តិសាស្ត្រចិនរួចមកហើយ ។ ក្នុងខណៈដែលចិនកំពុងមានអំណាចបណ្តេញពួកហ៊ាន ឲ្យបែកខ្ញែកខ្ចាយក្នុងខ្មែរគ័ស្ថានខោះ ពួកហ៊ានក៏ចុះយកចេញរហើយរុតលុកចូលទៅ

ក្នុងដែនដីរបស់ពួក យ៉ូអេឌ ហើយពួកយ៉ូអេឌក៏ត្រូវតែថយចុះទៅខាងក្រោមទៀត ជួនជាមានគ្រោះស្លុត ឬនឆ្នើជានាយទៅហ្វាយធំទៀងក្នុងប្រទេសតណ្ឌ ។

ពួកយ៉ូអេឌនោះមានឈ្មោះច្រើនយ៉ាង តែពាក្យថា យ៉ូអេឌ ហៅតាមចិន ពួកឧបក័និយមហៅតាមចិនរហូតមកដល់សម័យសព្វថ្ងៃនេះ ។ ឯស្រុកទេសដើមរបស់ជនពួកនេះនៅក្នុងខ្ទរគីស្ថានទិសខាងកើត តែឫសគល់ដើមកំណើតមានមកយ៉ាងណានោះ អ្នកឫាជប្រវត្តិសាស្ត្រក្នុងសម័យនេះមិនទាន់ដឹងច្បាស់ជាទេ ឯសំដីភាសាមានទំនងប្រហែលទៅខាងភាសាអ៊ុយហ្គ័ន ។ លុះជនពួកនេះលុកចូលមកដល់ខែត្រដែនសកដៀនធឺងឫាកន្ត្រៀនហើយជនពួកនេះក៏បែងចែកទឹកដីចេញជា ៥ អាណាចក្រទៅតូចតូចផ្សេងគ្នាដោយឡែកពីគ្នាមិនឫានចំណុះគ្នាទេ ធ្វើដូច្នេះអស់រយៈពេលជាង ១ សតវត្សរ៍ ។ ដល់អំណើះកាលតមកដល់ពុទ្ធសក្ករាជ ៩១២ មានអាណាចក្រហៅថា កូគាន្យឫានប្រមូលអាណាចក្រទាំង ៤ ទៀតនោះរួមគ្នាជាអាណាចក្រតែមួយឫានសម្រេច ។ ឯនាយករបស់ពួកកូគាន្យនេះហៅថាកាតហ៊ីសេស ឫានតាំងខ្លួនឡើងជាស្តេចហើយតាំងវង្សត្រកូលគ្រប់គ្រងអាណាចក្រយ៉ូអេឌ តមកជាយៈពេលជាងពីរសតវត្សរ៍ ហើយមានអំណាចរួបរួមបញ្ចូលដែនដីផ្សេងៗ ដែលពួកកិកត្រួតត្រាក្នុងគ្រានោះមកជារបស់ព្រះអង្គឫាន ។ (នៅមានត)

អ្នកឧកញ៉ាវិបុលរាជសេដ្ឋា ឬរ-កន រៀបរៀន

(ត្រមក)

លីសុកឆ្លើយថា ចូរអ្នកនាំខ្ញុំទៅគាំទាប់តែងឆ្លួនជាបុត្តាចិញ្ចឹមអ្នកចុះ លី-ប៉ោក៏បណ្តេញមនុស្សទាំងអស់ឲ្យដើរចេញហើយទូលថ្វាយថា អ្នកធំស្រាស្រីឯទេដឹង? ខ្ញុំនឹងអ្នកដឹងស្គាល់មាតាបិតាគាំងសង្ខាងតាំងពីតូច ហេតុដូចម្តេចបានជានិយាយដូច្នេះ ដែលយើងមកនៅឆ្ងើការនឹងតែងឆ្លួនហៅថាបិតានោះ ព្រោះចាំចិត្តគិតតែផ្តើរួនឲ្យបានសុខប៉ុណ្ណោះទេ លីសុកថា ទូលអ្នកមានថ្លៃដែលស្បែឈ្មោះខ្ញុំងតែកងការសង្ឃឹមជាច្រើនដណាស់ បើនឹងគិតរកបស់អ្វី ក៏គង់សម្រេចសេចក្តីប្រាថ្នា ហេតុម្តេចមកចាំចិត្តនៅដូច្នេះ ។ លីប៉ោតបថា ដែលអ្នកនិយាយនោះក៏មែនហើយ តែយើងស្មែងរកពីពឹងដែលជាបង្គោលមាំនោះនៅមិនទាន់បាន ។ លី-សុកញញឹមហើយឆ្លើយថា ធម្មតាសត្វបក្សីតែងពឹងពៃព្រឹក្សា ដែលមានផលានុផលទើបបានសេចក្តីសុខសប្បាយ ប្រសើរណាមាហ៊ុនខ្ញុំរាជការទាំងឡាយ បើព្រះមហាក្សត្រគ្រងធ៌ទសពិធរាជធម្មដ៏ប្រពៃ ក៏រមែងបានសេចក្តីសុខក្រៃមួយប៉ព្រះបរមនោធិសម្ភារជាជាងប ដែលអ្នកថាចាំចិត្តនៅឆ្ងើការជាមួយនឹងតែងឆ្លួនេះ នឹងប្រាថ្នាប្រយោជន៍អ្វី អំណើរទៅឯមុខអ្នកគង់មិនបាន

សេចក្តីសុខនឹងបានខុកខ័យអន្តរាយ គួរខ្វល់ខ្វាយរកនាយចៅហ្វាយជាច្រើនជាជាង ។

លីប៉ោបានឮដូច្នោះ ក៏សាកសួរលីសុកថាអ្នកធ្វើការក្នុងស្រុកក្រែង គង់បានដឹងឮថា នាហ៊ីនណាមានបុណ្យអំណាចអាចតាំងនៅក្នុងផ្លូវសុចរិតយុត្តិធម៌ ទើនិយាយការរាជការស្រេចជាច់ខាតបាន លីសុកឆ្លើយថា ខ្ញុំសំឡឹងរកមើលបណ្តានាហ៊ីនមុខមន្ត្រីក្នុងដីក្រែងនោះដែលនឹងឲ្យមានសតិបញ្ញាក្លាហានបានត្រមនោះ នរណាក៏មិនស្មើនឹងតាំងតុសោះឡើយ ឯតាំងតុនោះគឺប្រកបទៅដោយសតិបញ្ញាក្លាហាន មានសន្តានដ៏សុចរិតពិតត្រង់តាំងដួងចិត្តក៏ល្អិតល្អន់នឹងពួកនាហ៊ានមានតែឲ្យបំណាច់រង្វាន់តាមគុណូបការជាលំដាប់ មិនស្រឡាញ់ទ្រព្យរបស់តែងយកចិត្តមនុស្សជាប្រមាណ អំណើះទៅខាងមុខខ្ញុំឃើញថា តាំងតុគង់នឹងបានជានាហ៊ីនធំបំផុតប្រាកដមិនខាន ។

លីប៉ោបានស្តាប់ក៏មានចិត្តសោមនស្សត្រេកអរសរសើរថា ខ្ញុំប្រាថ្នានឹងរកឪពុកយ៉ាងនោះជាយូរមកហើយ តែថារកឱកាសនឹងចេញទៅមិនទាន់បាន ទើបលីសុកស្រាយយកមាសមួយពាន់ដំឡឹង នឹងឆ្លងពេជ្រតាំងគ្រាប់ប្រដាប់ខ្សែក្រវាត់ក្បាលទឹមទាត់តាំងអស់មកជាក់ចំពោះមុខ លីប៉ោឃើញដូច្នោះក៏សួរថារបស់តាំងនេះអ្នកយកមកធ្វើអ្វី? លីសុកឆ្លើយថា តាំងតុមានចិត្តស្រឡាញ់អ្នកច្រើនណាស់ ទើបប្រើខ្ញុំឲ្យ

នាំសេះទឹងរបស់តាំងអស់នេះមកដូន ឯលីចោ៉ាជាមនុស្សលោភ លុះ
ឃើញរបស់មានដម្លៃ ក៏មានសេចក្តីត្រេកអរពន់ប្រមាណ បានធ្វើយតប
ថា ដែលតាំងតុ:មានចិត្តស្រឡាញ់ ហើយឲ្យនាំសេះទឹងរបស់មកឲ្យនោះ
ខ្ញុំទឹងមានវត្ថុអ្វីទៅតបស្នងសងគុណលោកវិញ ។ លីសុកធ្វើយតបថា
អម្បាលដូចខ្ញុំពុំមានថ្លៃដៃអ្វីសោះ ម្តេចតាំងតុមានចិត្តសប្បុរសស្រឡាញ់
សរសើរ ជួយស្នើសេចក្តីគាប់គុណឲ្យបានធ្វើជានាយទាហានប៉ុណ្ណោះ
ចំណង់បើខ្លួនអ្នកមានចំណេះវិជ្ជាខ្ទាំងពូកែជាងខ្ញុំ បើអ្នកទៅនៅជាពួក
ក្រុមហើយក៏គង់ទឹងឡើងយសសក្តិជានាហ្នឹងធំពុំខាន លោកសក្ការតាំង
អម្បាលម៉ានក៏ទឹងមានដល់ខ្លួនអ្នកជាច្រើន ។

លីចោ៉តបថា ខ្ញុំទឹងយកសេចក្តីគាប់ឯណាទៅជាដំណូនតាំងតុ ។
លី-សុកធ្វើយថា បើអ្នកទឹងយកសេចក្តីគាប់ទៅដូនបានដោយងាយណាស់
ត្រែងតែអ្នកមិនព្រមធ្វើ បើអ្នកធ្វើហើយក៏គង់ទឹងបានក្តងមួយជំទាស់
ម្រាមដៃ លីចោ៉ក៏ស្រឡឹមអង្គុយគិតមួយស្របក់ហើយធ្វើយថា ដែល
ទឹងយកសេចក្តីគាប់អ្វីៗ ក៏គ្មានសោះ មានតែតេងឆ្លួនជាគូវៃក្នុងទឹងតាំង
តុ ខ្ញុំទឹងកាត់ក្បាលតេងឆ្លួនយកទៅដូនតាំងតុ ហើយសេចក្តីគាប់ប្រ-
សើរតង់ទឹងមានដល់អ្នកជាច្រើនណាស់ ឯគំនិតនេះត្រូវគិតយ៉ាងរហ័ស
រួសពន់ តែយូរទៅទឹងលាន់ឮបែកការ លីចោ៉ក៏ទទួលពាក្យប្តេជ្ញា
ថាអ្នកចូរវិលទៅដំរាបតាំងតុចុះ ព្រឹកនេះខ្ញុំទឹងកាត់យកក្បាលតេងឆ្លួន

ទៅជួនតាំងតុជាប្រាកដ ហើយខ្លួនខ្ញុំនឹងសុំទោសធ្វើពាធការជាមួយនឹងតាំងតុតទៅ ។ លីសុភកិលាលីចាំទៅវិញ យកសេចក្តីនេះឆ្លើយតាំងតុត្រង់ប្រការ លុះដល់ពេលយប់ប្រមាណយាមពីរចាំយ លីចាំក៏យកត្រីប៊ីសៀតចង្កាប់នៅចង្កេះ. ហើយដើរចូលទៅដល់ដំណេកគេឆ្លងឃើញគេឆ្លងកំពុងតែមើលសំបុត្រ ។

ឯគេឆ្លងឃើញលីចាំចូលទៅក៏សួរថា កូនអើយអ្នកចូលមកមានការអ្វី? លីចាំក្រែកគំហឹកថា ខ្លួនអញជាប្រុសចំពោះមានថ្លើដែលល្បីល្បាញប្រាកដ ឯងនឹងមកលើកខ្លួនជារាពុកហៅអញជាកូនខ្មោះមិនសមគួរសោះ គេឆ្លងបានឮដូច្នោះក៏តំណាស់សុះក្រែកឡើងនិយាយថា ហេតុម្តេចចៅគិតគ្រប់ចិត្តដូច្នេះ លីចាំមិនឆ្លើយតបសោះ ហូតត្រីប៊ីសុះចូលទៅកាប់គេឆ្លងស្លាប់ទៅខ្មោះ ហើយកាត់យកក្បាលយុះឡើងក្រែកប្រកាសដល់ភាហានតាំងតួនថា គេឆ្លងមិនមែនជាមនុស្សខ្លួនគ្រង់នឹងរាជការផែនដីសោះ ចំពោះធ្វើការលាមកអាក្រក់ណាស់ ឥឡូវនេះ យើងសម្លាប់ចោលហើយ អ្នកតាំងឡាយនឹងចង់ទៅធ្វើការជាមួយនឹងយើងប៉ុន្មានតាក់ បុមិនសុំគ្រងឹងទៅធ្វើការទេ ក៏ចូរគិតអានលិទៅស្រុកទេសនៃខ្លួនចុះ ភាហានតាំងពួងបានឮយើញដូច្នោះ នរណាដែលស្អប់មិនស្រឡាញ់លីចាំ ក៏រត់បែកខ្ទេចទៅប្រមាណពាក់កណ្តាលក្រៃពីខ្មោះ នរណាដែលរាប់អានស្រឡាញ់លីចាំ

ក៏បបួលគ្នាទៅតាមទៅទីធ្លីលីហ៊ោ ប្រមាណពាក់កណ្តាល លុះដល់ពេលព្រឹកព្រហាម លីហ៊ោក៏ខ្ចីដំសេះយួរក្បាលតេងដួនចូលទៅកេលីសុភក្តិបន្ទាយតាំងតុ លីសុកឃើញលីហ៊ោ យួរក្បាលតេងដួនចូលទៅដល់ក៏ត្រេកអរណាស់ រលេះរលាំងមាំខ្លួនលីហ៊ោយួរក្បាលតេងដួនចូលទៅគំនាប់តាំងតុក្នុងបន្ទាយ ។

ឯតាំងតុឃើញលីសុកមាំខ្លួនលីហ៊ោទៅដល់ ក៏មានទំនេចក្តីត្រេកអរពន់ប្រមាណ ឃាននើរចេញពីទីលំនៅទៅគំនាប់ខ្ពស់លីហ៊ោហើយចាខ្លួនឯងជាមជ្ឈដ្ឋានធ្លើស្រែឃាននៃប្រដាស់ស្រូវអស់ហើយ ខ្ពស់ក្រៃដំរាំងគោកនឹកអស់ ស្រែស្រូតលាស់មិនរួចក៏ត្រៀមស៊ូតទុចទៅ អ្នកមកវេកយើងតទ្បូវនេះដូចស្រែឃាននឹកក្រៃដាក់មកពេញស្រែ ជម្ងាស្រែតែត្រូវនឹកក្រៃដំហើយរមែងបែកគុម្ពស្រស់លូតលាស់សន្ធឹកល្អ. លីហ៊ោឃើញតាំងតុលូតដងដំចុះគំនាប់ដូច្នោះ ក៏តំយុណាស់ស៊ុះទៅទបលើកតាំងតុឲ្យអង្គុយលើកេរអី ហើយត្រាបគំនាប់ដំរាបចា ខ្លួនខ្ញុំឃាននមានមិត្តភក្តិស្រឡាញ់ចង់ចូលមកធ្វើរាជការជាមួយនឹងលោក ដែលលោកមានសេចក្តីមេត្តាអាណិតខ្ញុំឃាន។ ក៏ឃើញជាក់ច្បាស់អស់ហើយ ខ្ញុំឃានសូមលោកខុកជាបិតាត្រាតែអស់ជីវិត តាំងតុឃានស្តាប់ក៏ចាប់ចិត្តអាណិតស្រឡាញ់លីហ៊ោណាស់ ទើបយកការយ៉ាងល្អនឹងក្រឹសមាសមួយប្រដាប់ពេជ្រមកឲ្យលីហ៊ោ ។

តាំងអំពីតាំងតុបានលីចោ"មកដួយជាតំឡាំងវេលាណា ការពាជការគ្រប់យ"ាងក៏សំរេចលើតាំងតុតាំងអស់ ក៏កាន់តែតំរើបចិត្តអាក្រក់ឡើងជាងពីដើម បណ្តានាម៉ឺនមុខមន្ត្រីតូចធំក៏សឹងកោតខ្លាចអំណាចតាំងតុតាំងអស់ ទើបតាំងតាំងប៊ុនជានាយទាហានធ្វេង តាំងលីចោ"ជាបុត្រចិញ្ចឹមជានាយទាហានស្តាំ តាំងតុក៏លើកព្យុហយោធាចូលមកនៅកងកំពែងក្រុង ។

លុះអំណើះតមក លីយូនិយាយទឹងតាំងតុថា ការពាជការក្នុងស្រុកក្រុងសព្វថ្ងៃនេះ ក៏ជាកម្មសិទ្ធិជាច់ខាតលើលោកតាំងអស់ហើយបើទឹងគិតប្រការម្តេច សូមឲ្យលោកវិះគិតយ"ាងស្រួលហ៎សចុះ តាំងតុបានស្តាប់ដូច្នោះ ក៏ឃើញត្រូវផង លុះពេលព្រឹកភ្លឺស្រាង តាំងតុឲ្យលីចោ"ឃុំនាំទាហានមួយពាន់ចូលយ ចូលទៅឡោមព័ទ្ធនៅកងព្រះបរមរាជវាំង ឯតាំងតុក៏ចូលទៅកងព្រះរាជវោងវម្យ ជួបជុំសេវាមាត្យមុខមន្ត្រី តាំងតុឲ្យរៀបលៀងគោជនាហារចំណីបរិភោគក្នុងព្រះគំនាល់នោះ លុះរៀបចំរួចស្រេច តាំងតុក៏កាន់គ្រប់ឈរកណ្តាលទីប្រជុំហើយស្រែកប្រកាសថា ហង៎ដូចនេះគ្មានសតិបញ្ញាសោះ ទឹងបណ្តោយឲ្យសោយរាជ្យតទៅមិនបាន យើងត្រូវដកហូតចេញ ហើយតាំងហង៎ដូចហ្នឹងជាព្រះអនុជឲ្យឡើងសោយរាជសម្បត្តិជាថ្មី ព្រោះមានសេចក្តីធ្វើវង្វាតវាងវៃ បើ

អ្នកឯណាមិនចុះចិត្តយល់ព្រមតាមយើងទេ យើងនឹងសម្លាប់ចេញឥឡូវនេះ នាហ្នឹងគាំងអស់ក៏នៅអង្គុយតែស្ងៀម ។

នៅក្នុងទីប្រជុំនោះមានមន្ត្រីម្នាក់ឈ្មោះអ្នងសៀវ ក្រោកឈរឡើងសែកតបទៅថា ហាងជូពៀនជាព្រះរាជបុត្រឯកព្រះចៅខ្សែនតេ ជាព្រះវរោជបិតាបានលើកពាជសម្បត្តិឲ្យហាងជូពៀនជាស្រេចជាច់ខាតហើយ វេលានេះក៏ព្រះអង្គមិនមានសេចក្តីខុសអ្វី ហេតុម្តេចក៏ខ្លួនអាចហ៊ានចេញសំដីថានឹងដកហូតចេញ ហើយលើកហាងជូហៀបជាព្រះរាជបុត្រទី ២ ឲ្យសោយរាជសម្បត្តិវិញ ឬខ្លួនមានប្រាជ្ញាទឹងគិតក្បត់ផែនដី ។ គាំងតុត្បូដូច្នោះទើណាស់ឆ្លើយថា រាជសម្បត្តិសព្វថ្ងៃនេះ នៅក្នុងកណ្តាប់ដៃយើងអស់ហើយ យើងយល់ថាមិនត្រូវ ទើបធ្វើឲ្យត្រូវឡើងវិញ បើខ្លួនរឹងទឹងមិនស្តាប់យើង ចូរក្រែកឡែកមើលមុខគ្រប់ដែលយើងកាន់នេះមុតឬទេ ។ អ្នងសៀវតបថាយើងក៏មានគ្រប់កាន់ដូចខ្លួនដែរ បើខ្លួនមិនស្តាប់ហ៊ានគាំងដូហៀបឲ្យខុសពីសណ្តាប់បុរាណរាជបវេណី ចូរក្រែកឡែកមើលមុខគ្រប់ដែលយើងកាន់នៅដៃនេះ ទឹងមុតឬមិនមុតសោត គាំងតុក្រែវក្រោធខន់កំ ឡាំងគាំងតែហូតគ្រប់គិតទឹងសុះទៅកាប់អ្នងសៀវ លីយូយើញដូច្នោះសុះចូលទៅយាត់ហើយឱ្យបាំបថា យើងប្រឹងនឹងគិតការធំប្លែក ។ បើមកឈ្លោះជជែកដល់ចាក់កាប់គ្នាដូច្នេះ ការដែលគិតនោះនឹងមិនបង់អសារខេឬ ។ គាំងតុស្តាប់លីយូហាមឃាត់ក៏ឃាត់មាត់និយាយ

ឯអ្នកនៅក៏លាបណ្តានាហ៊ុនតូចធំទាំងឡាយ តាន់គ្រប៊ីដើរចេញទៅ
ហើយ នាំពួកពលនាហានលើកចេញទៅនៅក្រុងគីជីរ ។

ចំណែកតាំងតុនិយាយនឹងអ្នកឯងថា អ្នកនៅវានោះអង់
អាចរឹងទឹងនឹងយើងណាស់ នេះដ្បូងឆាយើងឃ្លានគ្នាតល់មា ប៉ើកុំមាន
ម្ចាមកនៅក្នុងខ្ទមនេះផង យើងនឹងសម្លាប់ចេញមួយរំពេចដែរ យើងគិត
ការទាំងអម្បាលនេះតើយល់ថាខុសឬត្រូវម្តេចខ្លះ ។ អ្នកឯងឆ្លើយថា
ដែលលោកជាធំគិតនឹងត្រឡប់ផែនដីចេញនោះត្រូវហើយ តាំងតុថា
បណ្តានាហ៊ុនមុខមន្ត្រីតូច-ធំទាំងពួង បើនណារឹងទឹងនឹងយើងដូចយ៉ាង
អ្នកនៅវាហើយ យើងនឹងសម្លាប់ចេញតឡូវនេះ នាហ៊ុនទាំងអស់ពុំ
ដូច្នោះក៏គោតខ្លាចតាំងតុ ទើបឆ្លើយថាលោកគិតការដូច្នេះ ខ្ញុំឯងភ័យស
យើញដូចលោកទាំងអស់គ្នា លុះបរិភោគអាហារហើយ ក៏លាទៅតាន់
ទីលំនៅវៀងខ្លួន ។

ឯតាំងតុនោះកន្ទក់កន្ទែលនោះ លុះនាហ៊ុនទាំងពួងចេញទៅអស់ហើយ
ក៏សួរបេរីវ៉ាំងនឹងដោះទៅថា អ្នកនៅវាលើកពលទៅនៅស្រុកគីជីវានោះ
ប្រហែលជានឹងគិតការយ៉ាងណាខ្លះ? បេរីវ៉ាំងឆ្លើយថា អ្នកនៅវាទៅ
គ្រានេះដោយអំណាចកំហឹង ប្រហែលនឹងគិតជាធំពុំខាន ។ មួយ
ទៀត សែអ្នកនោះតែងឃ្លានជានាហ៊ុនតៗគ្នាមកចំនួន ៤ ដួរមនុស្សហើយ
អាណាប្រជានុកូលគ្រប់ខែត្រខ័ណ្ឌសឹងប្រកាន់ខាងអ្នកនៅវាជាច្រើន

ចិត្តអ្នកនៅស្រែក៏មានមានៈណាស់ មុខជានឹងគិតបញ្ចុះបញ្ចូលអ្នកស្រុកហើយតាំងខ្លួនជាធំនៅក្នុងតំបន់ណាមួយមិនខាន ប្រហែលជាលោកនឹងបង្ក្រាបមិនបានទេ បើដូច្នេះសុំឲ្យលោកមានសំបុត្រព្រះតម្រាស់ចេញទៅតាំងអ្នកនៅស្រែជាចៅហ្វាយកខែត្រមួយ នោះប្រហែលអ្នកនៅស្រែនឹងនៅជាប្រក្រតីវិញ ។

ដោយខ្ញុំឆ្លើយថា អ្នកនៅស្រែនោះជាមនុស្សមានគំនិតណាស់ តែថានឹងគិតការអ្វីមិនសូវដូចជាយទេ បើលោកមានសំបុត្រព្រះតម្រាស់ទៅតាំងជាចៅហ្វាយស្រុកហើយ ប៉ះពួចយើងចង់ចិត្តភ្លក្លុក អ្នកនៅស្រែនោះក៏នឹងអស់ចិត្តតគរហាមំខ្លាដល់លោកផង ។ តាំងតុស្តាប់ឃើញត្រូវក៏ទៅតែងសំបុត្រជាព្រះតម្រាស់ ហើយចាត់ប្រើខាហានឲ្យកាន់ទៅប្រគល់ដល់អ្នកនៅស្រែ តាំងអ្នកនៅស្រែជាចៅហ្វាយស្រុកពុតហៃ បណ្តាខាហ្មឺនតូច-ធំក៏ទៅក្នុងបង្គាប់បញ្ជាតាំងតុទាំងអស់ ។

លុះទៅយូរមកតាំងតុឲ្យអញ្ជើញហាង់ដូពៀនចេញមកកាន់ទីព្រះគំនាល់ឈ្មោះព្រះទីនាំងកែងកៀន ហើយឲ្យប្រជុំខាហ្មឺនមុខមន្ត្រីតូច-ធំឯប្រជុំក្នុងទីនោះ តាំងតុក៏កាន់គ្រប់ឈរប្រកាសថា សព្វថ្ងៃនេះ អាជ្ញាសិទ្ធិទៅលើដៃយើងហើយ យើងឃើញថាហាង់ដូពៀនមានសតិបញ្ញាគិតមិនគួរស្ថិតទៅក្នុងភាពសម្បត្តិបានសោះ យើងពិគ្រោះឃើញថាហាង់ដូហៀបមានសតិបញ្ញាពង្រីកគួរទើងគ្រងផែនដីជាព្រះមហាក្សត្រសោយភាព-

សម្បត្តិតទៅ បណ្តានាហ្មឺនតាំងពួនក៏គ្មាននរណានឹងធ្វើយ តាស់ថាប្រការម្តេច ទើបតាំងតុបង្អាប់ឲ្យពួកខ្ញុំតាហាងជូរឿនចេញចាកទីព្រះគំនាល់ ហើយដកហូតយកត្រាសម្រាប់រាជសម្បត្តិ ដែលចងនឹងព្រះសុវណ៌ហង្សជូរឿននោះចេញ ហើយឲ្យហង្សជូរឿនគាល់តាមតំណែងព្រះរាជបុត្រនៃអម្ចាស់ផែនដី ហើយបង្អាប់ឲ្យយកខ្លួនព្រះនាងហោរហៅ មកដកហូតគ្រឿងប្រដាប់សម្រាប់ដំណែងយស ព្រះរាជដនទីនោះចេញតាំងអស់វេលានោះព្រះនាងហោរហៅនឹងហង្សជូរឿន ក៏មានសេចក្តីបរិទេវនាការទ្រង់ព្រះកន្សែងសោកាតាំង ២ អង្គ បណ្តានាហ្មឺនតូចធំដែលជួបជុំនៅទីនោះតាំងប៉ុន្មាន លុះបានឃើញដូច្នោះក៏ខ្សឹកខ្សួលក្តួលចិត្តអាណិតជាខ្លាំងស្រក់ទឹកភ្នែកតាំងអស់គ្នា ។

តេង្គនជានាហ្មឺនសុបរិតបានពិនិត្យឃើញដូច្នោះ ក៏គោមនស្សក្តៅចិត្តណាស់ក្រែកណរឡើងស្រែកថា អាតាំងតុនេះជាសត្រូវរាជសម្បត្តិរាល់គិតកំចាត់ដកហូតស្តេចជាអម្ចាស់ផែនដីតាមអំពើចិត្តវា ចាហើយក៏កាន់ដាវសុះ ម្ចាស់ទៅនឹងគាប់តាំងតុ។ ឃើញដូច្នោះ មានបញ្ជាឲ្យពេជ្ឈឃាតព្រួតចាប់យកខ្លួនតេង្គនទៅសម្លាប់ ឯពួកពេជ្ឈឃាតក៏ព្រួតចាប់ខ្លួនតេង្គនបាន តេង្គនមិនមានភ័យគិតគក់សូន្យខ្លាចស្ងាប់សោះ ថែមតាំងស្រែកដេរទ្រគោះជាពាក្យគ្នុតនិដៀលតាំងតុ តាល់តែពេជ្ឈឃាតនាំទៅដល់ទីកន្លែងពិឃាតសូន្យជីវិតទើបឈប់មាត់ ។ (មានត)

ត្រៃកូដធម៌

វិបស្សនាទេសនា ព្រះបាឡាត់ឧត្តមលំពិត សុង សុវ៉ែ វត្តលង្កា

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមាំង ព្រះធម៌ហើយនឹង ព្រះអរិយសង្ឃ ដោយគោរព) ។

វេលានេះអាត្មាភាពសូមដកស្រង់យកធម៌បីយ៉ាង គឺ: សច្ចំ សេចក្តីពិតត្រង់ ១, ទន្តី សេចក្តីអត់ធន់ ១, កតញ្ញតា សេចក្តីដឹងគុណ ១, ធម៌ទាំងបីនេះមានសំដែងជាបុគ្គលាធិដ្ឋាន កងគម្ពីរមហាបដ្ឋាន ត្រង់សរូបចតុក្កីសតិបច្ចយាការៈ ជាធម្មសវនាការដូចតទៅនេះ:

ធម៌ទាំងបីគឺ:សច្ចំ, ទន្តី, កតញ្ញតានេះ ឈ្មោះថាត្រៃកូដធម៌ ឬឧត្តមវរធម៌ ឬថា បធានធម៌ ព្រោះធម៌ជាកំពូលនៃលោកឬប្រសើរវិសេសជាងធម្មដ៏ជាធម៌ទាំងពួង ។

សេចក្តីអធិប្បាយ

ទី ១ – សច្ចំ សេចក្តីពិតត្រង់ គឺមិននិយាយបំផ្លើសឲ្យលើសពីសភាវៈពិត បើឃើញថាឃើញ ឮសថាឮស, ត្រូវថាត្រូវដូច្នេះជាដើម ហៅថាសច្ចៈសេចក្តីពិត បើសំដែងដោយ១ក្រដ្ឋបានដល់អរិយសច្ចទាំង ៤, ពាក្យថា អរិយសច្ចនេះប្រែថា សេចក្តីពិតរបស់ព្រះអរិយបុគ្គល, សេចក្តីពិតឥតស្មើមាន៤យ៉ាងគឺ: ១ – ទុក្ខៈ សេចក្តីព្រួយលំបាក,

๒—សមុទយៈ កំណើតទុក្ខ ឬហេតុដែលនាំឲ្យកើតទុក្ខ, ๓— និរោធៈ សេចក្តីរលត់ទុក្ខ ឬធម៌សម្រាប់រំលត់ទុក្ខ, ๔— មគ្គៈ ផ្លូវឬឧបាយនៃសេចក្តីរលត់ទុក្ខទាំង๔យ៉ាងនេះ ជាសច្ចៈពិតតែមានស្ថិតនឹងនិមិបែរភៅជាមិនពិតទៅវិញពុំបានឡើយ ។

ក៏សច្ចៈធម៌នេះព្រះសម្មាសម្ពុទ្ធទ្រង់សំដែងដោយពិស្តារក្នុងសុត្តន្តបិដក គម្ពីរមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក: តន្តិចង្កីសូត្រ ក្នុងសូត្រនោះមានសេចក្តីដំណាលថា: មានមាណពម្នាក់ឈ្មោះកាមទិក: មានក្បាលរោវរលីងមានអាយុ ๑๖ ឆ្នាំពីកំណើត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុនឹងគម្ពីរកេដុភ: ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានឹងនិរុត្តិដែលមានគម្ពីរតតិហាសៈជាគំរប់ ๔ ជាអ្នកស្ទាល់នូវបទនឹងវេយ្យាករណ៍ជាអ្នកមិនខ្ចោះខ្ចាយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ ទឹងមហាបុរិសលក្ខណព្យាករណសាស្ត្រ, ឯទៀតក៏ជាអ្នកស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ ទឹងមហាបុរិសលក្ខណព្យាករណសាស្ត្រ, ឯទៀតសូរតែធម៌ដែលនាំឲ្យកើតសច្ចៈចំពោះព្រះមានព្រះភាគ។ ទ្រង់ត្រើយតបថា: ម្នាលកាមទិក: សច្ចៈគឺសេចក្តីពិតត្រង់កើតឡើងដោយអាស្រ័យការព្យាយាម។ កើតឡើងដោយអាស្រ័យការពិចារណា។ កើតឡើងដោយអាស្រ័យការប៉ឺនប្រែង។ កើតឡើងដោយអាស្រ័យឆន្ទៈការពេញចិត្ត។ កើតឡើងដោយអាស្រ័យការចូលចិត្តធម៌ក្នុងគំនិត។ កើតឡើងដោយអាស្រ័យការពិចារណានូវអត្ថ។ កើតឡើងដោយការចេះចាំនូវធម៌។ កើតឡើងដោយអាស្រ័យការស្គាប់ធម៌។

កើតឡើងដោយអាស្រ័យការផ្តេងត្រចៀកប្រុងស្តាប់។ កើតឡើងដោយអាស្រ័យការចូលទៅអង្គុយជិត។ កើតឡើងដោយការចូលទៅរក។ កើតឡើងដោយអាស្រ័យសន្ទានៈសេចក្តីដឿ: បើបុគ្គលណាគ្មានសទ្ធាហើយ ការចូលទៅរកក៏មិនមាន, ការចូលទៅអង្គុយជិតក៏មិនមាន, ការផ្តេងត្រចៀកប្រុងស្តាប់ក៏មិនមាន, ការស្តាប់ធម៌ក៏មិនមាន ការចេះចាំទ្រទ្រង់ធម៌ក៏មិនមាន, ការពិចារណាន្ទរអត្ថក៏មិនមាន, សេចក្តីចូលចិត្តធម៌ក្នុងគំនិតក៏មិនមាន, ឆន្ទៈការពេញចិត្តក៏មិនមាន, ការប្រឹងប្រែងក៏មិនមាន, ការពិចារណាក៏មិនមាន, សេចក្តីព្យាយាមក៏មិនមាន, សច្ចៈសេចក្តីពិតត្រង់ក៏មិនមាន, បុគ្គលខោះលែងស្គាល់ទុក្ខសត្រូវ, គុណាទោស, បុណ្យ-ប្បាប លុះទៅក្នុងអំណាចនៃលោភៈ, ទោសៈ, មោហៈ ការណ៍ដែលមិនពិតហ៊ានថាពិត, សេចក្តីទុក្ខហ៊ានថាត្រូវ គឺតឃើញតែប្រយោជន៍ផ្ទាល់ខ្លួន មិនឃើញសេចក្តីទុក្ខរបស់អ្នកដទៃ: មនុស្សប្រែបនេះនឹងក្លាយខ្លួនទៅជាអប្បុសក្នុបុគ្គល រកសុគតិទីភ្នាននឹងឈានសមាបត្តិមិនឃើញឡើយ, ពីព្រោះសត្វសត្វទាំងអស់ក្នុងពិភពលោក ដែលមានមុខឆ្ពោះសញ្ជ្ញរទៅរកវឌ្ឍនធម៌ប្បាន ដោយសារតែមានសច្ចៈជាចន្លុះដួយគល់ទ្រូ បើប្រាសចាកសច្ចៈហើយ នឹងរកវឌ្ឍនធម៌មិនឃើញឡើយ ។ ដូចជាក្នុងលោកសត្វនៃនេះ បើប្រទេសណាមិនមានសច្ចៈធម៌ជល់គ្នានឹងគ្នា គឺពួកពលរដ្ឋគ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនឹងពួកសេវកាមាត្យ។

ក៏គ្មានសច្ចៈពិតត្រង់ចំពោះព្រះមហាក្សត្រនឹងពលរដ្ឋទេ ប្រទេសនោះមិនអាចជាតំណាងរបបរបូណ៌ដោយមហិទ្ធិរិទ្ធិឡើយ មុខជានឹងស្គមស្គិតតិចបុន្ដែអំណាចពួករាជទេសជនទាំងឡាយ នឹងជិះជាន់កេរជញ្ជក់យកសាច់ឈាម នឹងក្លាយទៅជាប្រទេសទាបទាសពុំមូលភាពមិនខាន ។

មួយទៀតសម្បីមាតាបិតានឹងបុត្រាបុត្រី ស្វាមីនឹងភរិយា ឬក៏គ្រូឧបជ្ឈាយាចារ្យនឹងសិស្សានុសិស្ស បើគ្មានសច្ចៈពិតត្រង់ទៅវិញទៅមកទេ សេចក្ដីវិនាសតែងកើតឡើងធ្វើឲ្យដល់ជនទាំងឡាយនោះ ។ សច្ចៈធម៌នេះជាគុណប្រសើរបំផុតក្នុងលោកបានជាព្រះសម្ពុទ្ធជាអគ្គបុគ្គលទ្រង់សំដែងថា: **សច្ចំ ហិ បរមំ លោកេ សច្ចំ លោកេ បធានកំ សច្ចម្ហិ វិជ្ជមានម្ហិ សព្ពបុញ្ញា វិជ្ជតិ** ។ សេចក្ដីថាសច្ចៈជាធម៌ដ៏ឧត្ដមក្នុងលោក សច្ចៈជាប្រធានក្នុងលោក កំបុណ្យទាំងអស់រមែងមានក្នុងសច្ចៈ ។ បើធ្វើសច្ចកសច្ចៈហើយបុណ្យក៏មិនមាន បើគ្មានបុណ្យហើយ រមែងបានដួបតែនឹងសេចក្ដីទុក្ខលំបាកលុងខ្លៅក្រៃថោកទាបជានិច្ចៈ ព្រោះហេតុនោះលោកអ្នកសប្បុរសទាំងឡាយគួរទំញុំាងសច្ចៈគឺសេចក្ដីពិតត្រង់ឲ្យកើតមានឡើងគ្រប់ៗ គ្នា ។

ទី ២ – ខន្ដី សេចក្ដីអត់ធន់ទុកជាចន្លៀងទីពីរសម្រាប់ទល់ទ្រសួយសត្វឲ្យមានមុខឆ្ពោះទៅរកអរិយធម៌; ខន្ដី ប្រែថាសេចក្ដីអត់ជាគូនឹងតតិក្ខា

ស្រែថាសេចក្តីធន់ សព្វទាំងពីរនេះមានសេចក្តីជាមួយគ្នា ទើបរួមចូលគ្នា ហៅថាសេចក្តីអត់ធន់ សេចក្តីអត់ធន់នេះលោកចែកជាបីយ៉ាងគឺ:

១ — អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោក:,

២ — អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតទោស:,

៣ — អត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតមោហ: ។

ឯការអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោក:នោះបាន ខាងការអត់ទ្រាំនឹងចំណង់ផ្សេងៗដែលកើតឡើងក្នុងខ្លួនទាំង៦ ។ ពាក្យ ថាអត់ទ្រាំគឺមិនប្រព្រឹត្តទុច្ចរិតតាមចំណង់ ឬសេចក្តីស្រែកឃ្លានទោះៗ ។ បុគ្គលចំពូកខ្លះព្រោះតែមិនចេះអត់ទ្រាំនឹងចំណង់ ឬសេចក្តីស្រែកឃ្លាន បានជាហ៊ានលួចឆក់ដណ្តើមបំបាត់ប្រវ័ញ្ចន៍ទ្រព្យសម្បត្តិរបស់គេ កាលបើ ប្រព្រឹត្តដូច្នោះ រមែងជួបប្រទះនឹងសេចក្តីទុក្ខព្រួយដែលជាផលរបស់ទុច្ច-រិតនោះៗ មានត្រូវគេសម្លាប់គុកច្រវាក់ជាដើម ។ បុគ្គលណាជាមនុស្ស មិនស្ងៀវវៃរកមធ្យោបាយ ចេះអត់ទ្រាំបាន បុគ្គលនោះឯងតែងប្រកបដោយ សុខភាពនឹងអនាម័យដ៏ល្អ ។ ១ន្តិ សេចក្តីអត់ធន់បែបនេះ ហៅថាអត់ធន់ ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតលោក: សូម្បីអត់ធន់ចំពោះសេច-ក្តីទុក្ខដែលជាហេតុឲ្យកើតពគ: គួរសង្រ្គោះចូលក្នុង១ន្តីនេះដែរ ។ ឯ សេចក្តីអត់ធន់ចំពោះសេចក្តីទុក្ខដែលជាហេតុឲ្យកើតទោស:នោះ បាន ខាងសេចក្តីអត់ធន់នឹងពាក្យបរប្បវាទ ដែលបុគ្គលដទៃស្តីថា រិតនង់ឬក្មេ

តិះដៀល ឬអត់ធន់ទ្រាំអំពើដែលបុគ្គលឯទៀតបៀតបៀនដែលជាហេតុឲ្យ
កើតទោស: ។ ធម្មតាមនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ ដែល
ថាមិនឲ្យគេស្តីថាមិនឲ្យគេរិះគន់ បុគ្គលតិះដៀលនោះគ្មានទេ, អម្បាលព្រះ
អាទិត្យព្រះចន្ទ្រ ដែលឆ្នុះបំភ្លឺលោកជាប្រក្រតី ម្តេចក៏គង់មានគេតិះ
ដៀលខ្លះដែរ, ចំណង់បើមនុស្សក្នុងលោកនឹងរកនរណាឲ្យជាមនុស្សឥត
គេតិះដៀលនោះមិនមានឡើយ; ទុកជាព្រះសាស្តាបរមគ្រូជាម្ចាស់ដែល
ប្រកបដោយព្រះមហាករុណាគុណ ក៏គង់មានគេតិះដៀលខ្លះដែរ, បើ
យល់ដាក់យ៉ាងនេះហើយគួរឲ្យមានទន្ទីអត់ធន់កុំគ្រាធទើង ។ ឱបាឋណា-
ចារ្យទាំងឡាយ លោកសំដែងប្រាប់ៗឱយ គឺយោបល់ជាគ្រឿងរំលត់
សេចក្តីគ្រាធទើងថា: "ទុកជាមានក្អែកកូកកូកត្រូវធ្លាប់ដូចជាងងឹត, មាន
ទៀកស្តាប់ឮ ក៏ត្រូវធ្លាប់ដូចជាឮដែរ" ដូច្នេះទើបអត់ធន់សេចក្តីគ្រាធទើង
នោះបាន, ប្រសិនបើធ្លាប់មនុស្សក្អែកទិព្វត្រទៀកទិព្វ ទេះតែឃើញ
ទេះតែឮ. ហើយនៅជាបុថុជនចិត្តស្រាលឆង ក៏នឹងរក្សា ខន្តី សេចក្តី
អត់ធន់នោះបានដោយកម្រណាស់ ។

ឯការអត់ធន់ចំពោះសេចក្តីទុក្ខ ដែលជាហេតុឲ្យកើតមោហៈនោះ
បានខាងសេចក្តីអត់ធន់នឹងទុក្ខវេទនាឲ្យធ្ងន់ ។ ដែលកើតឡើងក្នុងកាយនឹង
ចិត្ត មិនលុះក្នុងអំណាចទុក្ខវេទនា ហើយនៅប្រព្រឹត្តទុច្ចរិតឡើយ ។
សូម្បីការដែលអត់ធ្មត់នឹងទុក្ខវេទនាក្នុងរោគឈឺចាប់នោះសោត ក៏ជា

ហេតុដូច្នេះ ឲ្យមានសតិសម្បជញ្ញៈ គឺសេចក្តីភ្ញាក់រឭកនឹងសេចក្តីដឹងខ្លួន ដែលជាគុណវិសេសគួរឲ្យមានគ្រប់កាលទាំងពួង, តាំងនៅរហូតក្នុងវេលាមានព្យាធិដែលជាហេតុឲ្យដល់មរណៈ: ក៏ត្រូវតែមានខន្តីយ៉ាងមាំមួនខាងមុនឯណោះឡើយ ។ ។ ចុងដែលនឹងឲ្យកើតខន្តីក្នុងវេលានោះ គឺត្រូវតំតឲ្យឃើញតាមសេចក្តីពិតថា ព្យាធិនឹងមរណៈនោះ ជាទុក្ខដែលសត្វទាំងឡាយត្រូវតែជួបប្រទះពាល់ៗគ្នា គេចមិនរួចឡើយ; ក្នុងអតិល្លាបប្បច្ចវេក្ខណៈ ដែលព្រះបរមសាស្តាទ្រង់ប្រដៅឲ្យនឹករំពឹងជារឿយៗ ថា: "ភ្យានិ ន ម្មោ ម្ហិ ព្យាធិ អនតីតោ អាតាអញមានជម្ងឺជម្ងាត់ជាធម្មតា នឹងចៀសចាកជម្ងឺជម្ងាត់មិនបានឡើយ" ដូច្នេះនោះ ក៏គប្បីឲ្យប្រែប្រួលអំពីកាលដែលនៅជានៅឡើយ, បើចាំនៅនឹករំពឹងក្នុងពេលដែលជម្ងឺជម្ងាត់មកដល់តែម្តង ក៏មុខជាកម្រនឹងបាន, ព្រោះវេលាដែលឈឺនោះឯងតែងមានទុក្ខព្រួយលំបាកច្រើនយ៉ាងណាស់; កាលបើអត់ទាំងទុក្ខវេទនាមិនបាន សតិសម្បជញ្ញៈក៏នឹងខ្វែតខ្វាតនៅមិនតាំងនៅខ្ជាប់ឡើយ, ដូចជនដំពូកខ្វះដែលមិនបានហាត់ចិត្តទុកអំពីកាលនៅជានោះ លុះវេលាដែលមានជម្ងឺយ៉ាងធ្ងន់មកដល់ ក៏ច្រើនតែមានចិត្តរវើរវាយឲ្យឆ្ងល់ ជាបដល់ដើរអំពើទុច្ចរិតមានសម្លាប់សត្វជាដើម ដើម្បីបូជាគ្រោះ ដោយចង់រស់តែខ្លួនឯង មិនគំនរអាណិតសត្វជនៃក៏មាន ។ ព្រោះហេតុដូច្នោះ ការដែលបង្ហាត់ចិត្តបង្ហាត់ស្មារតី ដើម្បីឲ្យកើតខន្តី

ខោរ ដាក់ក្តីដែលយើងត្រូវការតែប៉ុណ្ណោះ ដើម្បីសម្រាប់តយុទ្ធនឹងសត្រូវ គឺព្យាធិទុក្ខ ក្នុងវេលាដែលជំងឺនឹងដល់មរណៈទុក្ខខោរ ។ ចំណែកអ្នកដែលមានប្រាថ្នារៀនកន្ទួរកោតខ្លៀ នឹងរៀនសាស្ត្រមានអក្សរសាស្ត្រ ឥតិហាសាស្ត្រ នឹងពាណិជ្ជកម្ម កសិកម្មជាដើម បើមានទុន្ទីអត់ធន់ទ្រាំការស្រែកឃ្លាន មានក្រ ក្តៅត្រជាក់ជាដើមហើយ រំឭកនឹងកោតខ្លៀ ក៏រមែងសម្រេចដល់បុគ្គលខោរដោយមុហុត្តភាព បុគ្គលខោរនឹងឆ្លើយទៅវិញថាមនុស្សចំរើនលោកឯង ។ ម្យ៉ាងទៀតអ្នកដែលមានទុន្ទីរមែងជាខ័ប៌តានៃទេវតានឹងមនុស្សទាំងឡាយ, សមនឹងពុទ្ធភាសិតថា: **ទុន្ទិតោ មេត្តវា លាភី យសស្សី សុខសីលវា ឥតិយោ ទេវមនុស្សានំ មជ្ឈាចរោ ហោតិ ទុន្ទិតោ** "អ្នកមានទុន្ទីជាអ្នកមានមេត្តា ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកមានទុន្ទីរមែងជាខ័ស្បែរញ៉ាំជាខ័ប៌តាប់ចំពួនៃទេវតានឹងមនុស្សទាំងឡាយ" ។ ទុន្ទីនេះជាគុណធម៌ប្រសើរបំផុតក្នុងលោក ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងថា: **ទុន្ទិ ហិ បរមំ លោកេ ទុន្ទិ លោកេ បភាសតា ទុន្ទិយា វិប្បមាជាយ សព្ពបុញ្ញា វិនស្សតិ** ។ សេចក្តីថា "ទុន្ទីជាធម៌ដ៏ខ្ពស់ក្នុងលោក ទុន្ទីជាធម៌ដ៏ប្រសើរក្នុងលោក កំបុណ្យទាំងអស់មានដោយសារទុន្ទី" ។ បើប្រាសចាកទុន្ទីហើយរមែងដួលតែនឹងសេចក្តីទុក្ខ លំបាកក្រៃលែង ដោយ

តាបជាន់ច្រើន ព្រោះហេតុនោះលោកអ្នកសប្បុរសទាំងឡាយ គួរខំប្រឹងប្រែងធ្វើឲ្យមានឡើងគ្រប់ៗគ្នា ។

ទី៣— កតញ្ញូតា សេចក្តីដឹងគុណខុសជាចម្លែកពីរបៀបសម្លាប់សត្វឲ្យដល់នូវអនាគតភាពដ៏ល្អ ។ កតញ្ញូតាធម៌ជាគូនឹងកតវេទិតាធម៌ គឺបើដឹងថាអ្នកណាមួយមានគុណដល់ខ្លួន ហើយត្រូវធ្វើគុណតបអ្នកនោះវិញ បើគ្មានតែជាមឹងៗ តែប៉ុណ្ណោះ គឺមិនអាចញ៉ាំងប្រយោជន៍ឲ្យសម្រេចបាន ដូចជាដឹងថាព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ, មានគុណជាអនន្តចំពោះសព្វសត្វទាំងអស់ក្នុងលោក សត្វទាំងនោះគួរតែតាំងចិត្តឲ្យស្មោះចំពោះព្រះពុទ្ធ; ព្រះធម៌, ព្រះសង្ឃយកជាទីពឹងទីរឭកស្មើដោយជីវិតទាំងទំប្រតិបត្តិតាមឧត្តមប្បដិបត្តិរបស់ព្រះសម្ពុទ្ធជាម្ចាស់ ពុំប្រព្រឹត្តកន្ទងដូច្នេះជាដើម ឈ្មោះថាមានកតញ្ញូកតវេទិតាធម៌ចំពោះព្រះពុទ្ធ, ព្រះធម៌, ព្រះសង្ឃ; ត្រមទាំងដឹងគុណចំពោះបុព្វការីទាំងឡាយមានមាតាបិតាជាដើម ត្រូវថែរក្សាដោយស្មោះស្ម័គ្រ បើលោកមិនទាន់មានសទ្ធា, សីល:, ចាគ:, បញ្ញាគប្បីឲ្យមានឡើង: បើបុគ្គលណាមួយប្រកបដោយកតញ្ញូកតវេទិតាធម៌ដូច្នេះហើយ បុគ្គលនោះឈ្មោះថាបិទទ្វារនៃអបាយទាំង ៤ មិនឱកាសជាដើមនឹងបានប្រកបដោយសុខគ្រាន់តែអនាគតដ៏ល្អ ។ ប៉ុណ្ណោះបណ្តិតទាំងឡាយមានព្រះសម្ពុទ្ធជាដើមដែលខំសែងគេតំនាងសុខ ស្មើគ

មិនដែលលះបង់នូវគតញ្ញូគតវេទិតាធម៌នេះឡើយ. ដូចគាលព្រះសម្ពុទ្ធ
ឆាស្ថាសទ្រង់សោយព្រះឆាតំណាស្តេចសេក ឆ្លងឆាប្រកបដោយគុណគាត
ទៅជាប់លប់អ្នកស្រែហើយចាន់ត្រឡប់រួចរស់ជីវិតទៅវិញ កំដោយ
សារតែគុណនៃគតញ្ញូគតវេទិតាធម៌ ។

មួយទៀតក្នុងប្រទេសនិមួយៗ ពួកពលរដ្ឋទាំងឡាយត្រូវមានគតញ្ញូ
គតវេទិតាធម៌ចំពោះព្រះមហាក្សត្រ ស៊ុយគគម្ចាំងកាយនឹងគម្ចាំងចិត្ត
ឆនឆ្លើឆាពលី ក្នុងគ្រលែងតែគតអសន្តិសុខម្តង។ ក្នុងប្រទេស
ហើយត្រូវស្រឡាញ់ព្រះមហាក្សត្រជាស់ខ្លួនស៊ើដោយជីវិត, ត្រូវធ្វើ
គុណតួកសេវកាមាត្យទាំងឡាយ ដែលជាមតែងតាំងប្រាប់ ឲ្យប្រតិបត្តិ
ដើម្បីបានសេចក្តីសុខចំរើន, បើតួកសេវកាមាត្យទាំងនោះមានកើតអា-
សន្ន ដោយហេតុណាមួយត្រូវជួយសង្គ្រោះស៊ុតត្រ ទាំងទ្រប្រតិបត្តិ
តាមប្រាប់ ពុំហ៊ានប្រតិត្តគន្ធដូច្នេះជាដើមឈ្មោះថាមានគតញ្ញូគតវេទិ-
តាធម៌ចំពោះសេវកាមាត្យ ។ ត្រូវប្រកបដោយមេត្តាអាសុរប្រណីចំពោះ
ពលរដ្ឋទាំងសកលរដ្ឋ ត្រូវតាមសច្ចៈនឹងទង្គិចឲ្យឆ្លាប់កុំលុះក្នុងអំណាចនៃ
អគតិធម៌ទាំង ៤ មានឆន្ទាគតិជាដើម ។

កិច្ចធម៌ទាំងប៉ុន្មានសច្ចំ, ទន្តិ, គតញ្ញូតានេះ បើមានទៅភូមិ, ស្រុក, ខែត្រ
ប្រទេសណាហើយ ភូមិ, ស្រុក, ខែត្រ, ប្រទេសនោះនឹងសម្បូណ៌ដោយ

វិញ្ញាណក្ខន្ធ ជាតិធំលុតណាស់ទៀតដែរ ដែលមានបុគ្គលរៀនដោយមុខហ្មត់ចត់ មិនអាចក្លាយទៅជាប្រទេសនាឋាសស្ត្រីទុខទៀតឡើយ, ដូចកុមារីលោកស្មែ ដែលមានអាយុតែ ៤ ហ្នឹង ៥ ឆ្នាំនេះយ៉ាងនេះ ខ្ញុំសង្ឃឹមស្មោះចង់ឲ្យគាត់ចេះ ព្រោះតែគាត់ជាមាតុគាមដែលមានបុព្វហេតុមកអំពីជាតិមុនៗ ក៏មិនអាចញ៉ាំញីឆ្នើមភ្លឺឲ្យញាប់ញ័រឡើយ ដោយមានបុរសប៉ិនល្អ ប្រសប់ពីគ្រាមយ៉ាងណាមិញ ត្រូវតែកូនធម៌ខាងប៉ា ខ្ញុំកដូចជាចង់ឲ្យលោកស្ត្រីកូនពិតៗលោកមិនឲ្យអន្តរាយទៅរកហ៊ានភាពក៏ដូច្នោះដែរ ។

ឯត្រូវតែកូនធម៌នេះកុំនិយាយឡើយដល់ទៅមនុស្សគោរពជាតិនិយាយក៏ដោយ ឲ្យតែចេះរក្សាខ្លួនវាត្រូវតែកូនធម៌នេះដោយទៀងទាត់ប្រាកដ ក៏អាចឆ្លើយឲ្យក្លាយទៅជាទេវតាឋាន ដូចមានន័យតាមមួយកន្លែងពហុលាគារំសូត្រ គម្ពីរមហាបដ្ឋាន ត្រង់សរូបចតុព្វីសតិបច្ចយការៈ ដំណាលថាៈ មានសត្វបីតីមេគោ១, កូនគោ១, ខ្ទាំង១, ជាអ្នករក្សាខ្លួនធម៌ទាំងប៉ី, មេគោរក្សាសច្ចធម៌, កូនគោរក្សាកតញ្ញូតាធម៌, ខ្ទាំងរក្សាខន្តិធម៌, ដោយអំណាចធម៌ទាំងប៉ី សត្វទាំងនោះ ក៏ឋានទៅរសាយទុក្ខសម្លឹងទៅស្មានត្រូវតែត្រឹមត្រូវគ្រប់ប្រពៃណៅដោយយសបរិវារជាអស្ចារ្យ, រឿងនេះចំចង់ជ្រាបដោយពិស្តារ សូមមើលក្នុងពហុលាគារំសូត្រនោះចុះ; គ្រានតែងំណាលមកដោយខ្លីប៉ុណ្ណេះឲ្យឃើញថាធម៌ទាំងប៉ីគឺ សច្ចំ, ខន្តី, កតញ្ញូតានេះ

ម៉ាន់មហិទ្ធិបុទ្ធិគ្គរអស្ចារ្យ ប៉ះសំដែងដោយ ក្រែងយើញថាមានអត្ថ
ដ៏ប្រសើរយ៉ាងពន់ពេក ។

ន័យមួយទៀត ព្រះសម្ពុទ្ធសំដែងថា: សច្ចៈ រម្ងាប់លោភៈ, ទន្តិ រម្ងាប់ទោសៈ, កតញ្ញូតា រម្ងាប់មោហៈ ។

សំដែងមកកន្លងធម៌ទាំងបី គឺ សច្ចំ, ទន្តិ, កតញ្ញូតា ដែលហៅថា ត្រៃកូដធម៌: ប្រកបដោយវចីធម៌ បុណ្យបានធម៌ ក៏សន្តុតចាប់ដោយសង្ខេបតែប៉ុណ្ណោះ ។

ឯទ្ធនេសនាតែងផ្តើម: ដោយតែងនៃធម្មទេសនាសូមទេវតាទាំងមួយហ្នឹងលោកធាតុ ពិទ្ធគ្រក្សាព្រះបរិយត្តិធម៌ ព្រមទាំងព្រះពុទ្ធរតនៈ ព្រះធម្មរតនៈ សម្តេចព្រះវររាជបិតា សម្តេចព្រះវររាជជននីនាថ សូមប្រទានប្រសិទ្ធដោយចតុពិធពរ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ, បរិបូណ៌ដោយព្រះសតិបញ្ញាបរិហារកម្មដ្ឋានប្រទេស ឲ្យបានលុះដល់នូវគតិដោយមុហុត្តកាលដ៏រួសរាន់ទាន់សម័យ: ទាំងសូមបរិសំទទាំងឡាយ គ្រប់ធាន់ ដែលបានប្រតិបត្តិតាមសាសនៈវិន័យ ក្រែងអធិប្បាយនៃព្រះសម្មាសម្ពុទ្ធឲ្យបានប្រតិបដោយសុខកាពអនាមយដ៏ល្អ ដើម្បីផាសុវិហារធម៌ ប្រតិបត្តិសាសនាក្នុងហានបានមគ្គផលសម័យសមតាមអធ្យាស្រ័យវត្ថុបំណងកុំបីឃ្លាតឡើយ ។

(ចប់)

ព្រះបាឡាត់នូវគ្គមលិខិត (សុធ - ស៊ីវ)

ប្អូនឯងពាក្យមន្ត្រីញាក-បែមប្រែរឿបរឿង

(តទៅ)

ព្រះពាជទ្រសែគាស់សួរតទៅទៀតថា "ប៉ែនឯងខ្ញុំនេះមានជីវិតរស់នៅយ៉ាងយូរ ឯងខ្ញុំនេះក៏គង់តែដូច្នេះដែរ. ប្រសិនប៉ះយ៉ាសោធកមានជីវិតរហូតដល់ ៨០ឆ្នាំ. សេចក្តីថាសំឯកធ្វើឲ្យ ព្រះនាងបានខ្លួលដូចគ្នាយ៉ាងនោះដែរឬ? ចាលិន, ខាងទ្រព្យនា. គោតម. តង្ឃា. ខ្ញុំឯអ្នកឯទៀតៗ ក៏គង់តែយ៉ាងនោះដែរ? នាយសារថីក្រាបទូលអ្នកថា "ត្រូវហើយព្រះអង្គ។ ខ្ញុំគាស់ថា ប៉ើដូច្នោះ ចូរបពាជរថត្រឡប់ព្រះពាជកំណើតវិញចុះ, ខ្ញុំបានឃើញប្រសើរដែលមិនខឹកថា ខ្ញុំបានឃើញខោះហើយ" ។

ដោយហេតុខ្ញុំព្រះអំពីឯដល់ភាពដែលខ្ញុំបានឧត្តមនេត្រមកខោះ ទើបព្រះសិទ្ធត្ថមានព្រះគាការស្រពោនស្តេចយាងចូលតំណាក់ជ័ណ្ឌវិចិត្រ ឥតត្រេកត្រអាល ដោយមានព្រះភក្ត្រសោកសូត ហើយមិនខ្ញុំសោយទំស ខ្ញុំដែលឈើដែលឆ្លាប់ប្រើជាព្រះក្រយាសោយ ក្នុងវេលាល្ងាចខោះ ហើយក្នុងវេលាល្ងាចខោះ ព្រះអង្គមិនខ្ញុំឧត្តមតិតិលរមិលមើលពួកនាងស្នងខប្រុងដើរតោមនៃព្រះពាជកំណើដែលព្យាយាមធ្វើឲ្យព្រះអង្គខ្ញុំសម្រើបខោះឡើយ មិនខ្ញុំហើបហាព្រះទស្សនីព្រះនាងយសោធកដែលស្ងួនស្ងុតព្រះទ័យ ក្រាបចុះនឹងព្រះបាទយុគលទូលអង្វរ

សួរថា "ព្រះអង្គនឹងមិនមានសេចក្តីសុខចំពោះខ្ញុំម្ចាស់ហើយឬ? ព្រះអង្គ
ត្រាស់ថា "នុ៎ះតើណាអ្នក? សេចក្តីសុខស្រួលមានឫប៉ែយ្យនានាពាលសេចក្តី
សុខដែលនាំដួងវិញ្ញាណរបស់បងឲ្យរងកម្ម គាលនឹងយើញថាកតែងតែ
ធុតអស់ខ្លៅនៅវេរីបំផុត ហើយយើងតាំងព័ន្ធនាក់ គឺត្រូវតែងលន់នូវឯកាគាព,
យសោធនាអើយ! កាលដល់ពារៈអស់តម្រែក ត្រឡប់ក្លាយទៅជាគួរ
ខ្ពើមរអើម,ខយរខ្ពាយកំឡាំងហើយខ្លួងកោងចុះទៅខ្ចៃត,តិតមែនណាស់
ប៉ុន្តែជាយើងមានមធិតិ៍ខ្លួស្នេហាយ៉ាងស្ងួងដ៏ក្រៃលែង ស្មើរដែកដង្កើម
រួមថ្លៃគ្នាត្រៃបំពិភពត្រី តែគាលវេលាដែលកន្ទុងទៅ។ តែងដណ្តើមយក
ភាគៈតណ្ហា របស់បងនឹងរបស់នាងជាប់ទៅជាមួយនឹង, ប្រៀបដូចភក្តី
គាលដំឡើងនឹត តែងលុបលាងស្នាមណាកុលាបដ៏ភ្លឺស្វាងលើកុំតាំងនោះ
ដោយអាការសន្ធឹមៗបំខុំងនឹតទៅ។ ដូច្នោះឯង, ខេរហើយរបស់ដែល
បងឃ្លានកយើញ ហើយដួងចិត្តរបស់បងតាំងមូលតែងញាប់ញ័ររន្ធត់
ដោយសេចក្តីរំពឹងពិចារណាដូច្នេះ ហើយដួងចិត្តរបស់បងតាំងមូល រំតិត
តែរកវិធីការពារសេចក្តីស្នេហាឲ្យធុតពីការប៉ះពាល់ នៃគាលវេលាដែល
ចូលមកពីឃាងដើម្បីឲ្យកើតបាសឆកងលមនុស្សលោក" មានព្រះឧទ្ទារ
ដូច្នេះហើយ ព្រះសិទ្ធត្ថក៏ទ្រង់គង់នៅសូមស្តេចមហុតអស់ពាតិ៍ដោយ
សេចក្តីត្រេកត្រអាល ម៉ែនអាចធ្វើឲ្យលក់ទៅបានឡើយ ។

មួយវិញទៀត ក្នុងរាជត្រីកាលនោះ ឯព្រះបាទសុរិន្ទ្រាទេវៈ មហារាជធ្វើព្រះសុបិនយ៉ាងចំឡែកនាំឲ្យកើតអាស្រ័យក្នុងព្រះហប្ញទ័យ និមិត្តដំបូង ធ្វើព្រះសុបិនឃើញទន់ដំយ ១ គេបង្ក្រតឡើងយ៉ាងរុងរឿង មានជួងអាទិត្យធ្លុះពន្លឺមាសចោលមកច្រាលន្លៀ តំរស្មីព្រះតន្លុះចុះបាំងមក តែតមកមានឲ្យលប់ជាតំមកខាល់តែខ្លាំងជ័យដ៏សំគ្គសិទ្ធិនោះធាប់ជាបាត់ម្យ៉ាកទៅ ធ្លាក់មកលើធូលីពសុធា, តមកទៀត មានទេវតាហោះចុះមកវែសយកទន់ដែលអន្តរាយនោះឡើងវិញ ហើយនាំយកទៅដាក់ទៅទិសខាងកើតទ្វារព្រះកុដ្ឋធានី ។ ព្រះសុបិនជាគំរប់ពីរថា ព្រះអង្គធ្វើទន្តព្រះនេត្រឃើញតន្តសារ ១០ មានក្តុកជាប្រាក់ ដើរជញ្ជែងព្រះឆវីញាប់ញ័រយ៉ាងធ្ងន់, ដំរីទាំងនេះដើរមកពីទិសខាងត្បូង អ្នកដែលដឹងលើកតន្តសារទី ១ គឺព្រះរាជទេវីរបស់ព្រះអង្គ ដំរីឯទៀតៗ ដើរតាមៗគ្នាមក ។ ព្រះសុបិនជាគំរប់ ៣ ថាមានរថដ៏វិចិត្រដោយរស្មីដ៏រុងរឿងទីមដោយពាជិ ៤ ព្រួសផ្សែងសេចញ្ចឹមកតាមរន្ធច្រមុះ ហើយរំពាអៀងចេញពពុះមកជាភ្លើង ព្រះសិទ្ធត្ថទ្រង់គង់លើរាជរថនោះ ។ ព្រះសុបិនគំរប់ ៤ ថាមានកង់ដែលវិល, វិលមិនឈប់ មានដុំធាមាសរចនាដោយកែវមណីរត្ន ហើយមានរូបគំនូរយ៉ាងចំឡែកទៅតាមហាមកង់ ហើយកង់នេះខណៈដែលកំពុងវិលនោះ ហាក់ដូចជាកើតជាភ្លើងទន្ទឹមគ្នា ។ ព្រះសុបិនជាគំរប់ ៥ ថាមានស្តេរធំមហិមា តាំងនៅកណ្តាលស

ផ្សេងពីព្រះរាជធានីនឹងក្នុង ព្រះរាជបុត្រទ្រង់ឮដូច្នេះ ដោយជុំជែកមានសូរសំឡេងរំពង ហាក់ដូចសូរសំឡេងស្ការលាន់រំពងខ្ទេចខ្ទាយ៉ះឆ្ងាយខ្លាំងក្រៃពេក ។ ព្រះសុបិនគំរប់ ៦ ថាមានបញ្ជាខ្ពស់ឡើងទៅលើ, ខ្ពស់ឡើងជានិច្ច ទាល់តែគេអាចមើលទៅឃើញសព្វព្រះរាជធានី, មានកំពូលខ្ពស់ត្រជែតត្រជាំមជ្ឈមេឃ ហើយនៅលើបញ្ជានោះ មានព្រះរាជបុត្រស្តេចគង់ទៅ, ទ្រង់ព្រះសាបពេញ ។ ព្រះហស្តទៅសព្វទិសានុទិស ហាក់ដូចជាព្រះពុំរាណបុប្ផជាតិនឹងតួងទឹម ហើយជនទាំងឡាយបៀតសៀតបះបៀតគ្នា ដើម្បីរើសច្រមូលយកព្រួយដ៏មានដំឡៃដែលធ្លាក់ចុះមកត្រង់ទីតំបន់ ។ ហេតុនេះទើបគំរប់ ៧ គឺឃាតព្រួយអើកធឹកដោយសំឡេងសៀវយ៉ះសោក ហើយទ្រង់ទតឃើញមនុស្ស ៦ នាក់ស្រែកទ្រហោយំទាំងធ្លាញ យកដៃបំទាមាត់សោកស្ទុះទន្ទ្រង់ដោយសេចក្តីអស់សង្ឃឹម ។

នេះគឺព្រះសុបិនទាំង ៧ ប្រការមុនគួរសេចក្តីដែលព្រះបាទសុទ្ធោទនៈទ្រង់ព្រះសុបិនយល់ឃើញ, ប៉ុន្តែនឹងកហោរាដែលឈ្មោះកាឡាណាមួយ អាចទាយព្រះសុបិននេះថ្វាយពុំមានខ្សោយ ហេតុដូច្នោះហើយ ព្រះរាជាដែលទ្រង់ត្រាស់ប្រកាសក្នុងព្រះទ័យទ្រង់បន្ទូលព្រះឧទានថា "គង់តែនឹងមានទុក្ខអ្វីមួយមកប៉ះពាល់ដល់ព្រះរាជកំង៉ងរបស់យើងដោយពិតហើយក្នុងចំណោមពួកអ្នកទាំងនេះ តែអ្នកណាមួយដែលមានចំណេះ

ចេះដឹងធ្លាស់ប្តូរតាមគ្រានេះមើលឲ្យដឹងអារម្មណ៍ដែលព្រះជាម្ចាស់ជ័ន្ធ
ខ្ញុំអានុភាពមកនិរមិត្តឲ្យប្រាកដដល់យើងដោយផ្លូវព្រះសុបិនទេះ
ឡើយ" ដូច្នេះ ព្រះពុទ្ធជានី ទើបមានតែទុក្ខសោក ព័ត្រោះព្រះពុទ្ធ
ខ្ញុំព្រះសុបិនមិនល្អ រកនរណាមួយទាយថ្វាយគ្មាន តែវេលាគ្រានោះ
មានបុរសជាម្នាក់ ស្បែកពាក់ស្បែកសត្វដូចជាតាបស គ្មាននរណាមួយ
ដែលស្គាល់សោះ មកឈរនៅព្រះទ្វារហើយស្រែកឡើងថា "ចូរអ្នក
នាំយើងទៅគាល់ព្រះពុទ្ធ, ព្រោះយើងអាចថ្វាយទំនាយ ព្រះសុបិននិមិត្ត
នោះបាន" លុះតស័នោះបានចូលទៅគាល់ ស្តាប់ព្រះធម្មទេសនា ព្រះ
សុបិនទាំង ៧ ប្រការនោះហើយ ក៏បង្អោនកាយចុះដោយសេចក្តីគោរព
ហើយក្រាបទូលថា "ខ្ញុំ! ព្រះមហាភាគ, ខ្ញុំលព្រះបង្គំសូមគោរព
ព្រះពុទ្ធតែកូល ដែលនឹងបានកត់ប្រសប់ដាក់សូស្តីសឹងមានស្មើដ៏រិចិត្ត
តែកាលកែលែងជាងគួរអាទិត្យ ! សូមឲ្យព្រះអង្គខ្ញុំជ្រាបចុះចា
ព្រះសុបិនដែលធ្វើឲ្យព្រះអង្គខ្ញុំរន្ធត់ញាប់ញ័រនេះ ជាព្រះសុបិនសុទ្ធតែ
ជាមង្គលទាំងអស់, ដោយពិតនោះ ខ្ញុំជ័យដែលបក់វិល យ៉ាងវុង
រឿនខ្ញុំនោះជាច់ខាតហើយសោត់ធ្លាក់ចុះនោះ សំដៅដល់ភ្នំរៈជាទីបំផុត
នៃការធ្វើប្រការទាំងឡាយ ហើយនឹងចាប់ផ្តើមកើតលទ្ធិថ្មី ព្រោះ
ខ្ញុំឃើញទាំងឡាយរមែងមិនកែប្រែតំណាងមនុស្សលោកទេ, តប្បជាប្រែន
តប្បដែលកន្ទុងរំលងធុតមក ក៏មានខ្នងដូចជាទឹកភ្លៀដែលកន្ទុងផុតទៅ

ផែរ គឺសារទាំង ១០ ធ្វើឲ្យផ្លែឈើនៃដំណាំបញ្ចប់ទោះ សំដៅដល់ព្រះមហាបារមីនៃធម្មវិសេសទាំង ១០ ប្រការ ដោយអំណាចព្រះធម្មវិសេសទាំង ១០ នេះ ព្រះពោធិសត្វទើបត្រាស់ដឹងព្រះអង្គឯង ទើបធ្វើឲ្យពិភពលោកញាប់ញ័រ ដោយការដឹកនាំលោកឲ្យបានលុះដល់ការរះដ៏ឯកផ្លែនៃសេចក្តីខ្វៃខាត់, អស្សគរទាំង ៤ ដែលទឹមពាហ ព្រួសដង្ហើមចេញមកជាភ្លើងនោះ គឺព្រះបុញ្ញាធិការដែលព្រះពោធិសត្វបានសម្រេច គឺសច្ចៈទាំង ៤ ដែលទើបនាំព្រះអង្គឲ្យបានឆ្លងផុតពីកង្វាក់ទើបការដ៏ធំ ទៅកាន់ពន្ធុដ៏ស្វាងខែងនៃបុណ្យបារមី, កងវិលជាសុវណ្ណប្រដាប់ដោយកែវចិន្តាមណីទើបពេជ្រត្បូង ជាកងវិសេសក្រៃលែង នៃព្រះវិនិយដ៏បរិសុទ្ធ ដែលទើបវិលឲ្យប្រចក្ខុច្បាស់ដល់លោកទាំងមូល, ស្តេរដែលព្រះពោធិសត្វខ្ចីភយដំ លាន់ពុគីកកងរទៅគ្រប់ប្រទេសនោះ សំដៅដល់ការកងរពិតដូចធ្លាគ្រាមាម នៃព្រះធម្មទេវដែលព្រះពោធិសត្វទ្រង់ទូន្មានប្រៀនប្រដៅ, បន្ទាញដ៏ខ្ពស់គ្រប់ជែតទាល់មេឃនោះប្រែចា ព្រះគម្ពីរដ៏វិសេសជាឯករបស់ព្រះពុទ្ធជាម្ចាស់, គ្រឿងត្បូងពេជ្រទើបចិន្តាដែលប្លាយសាចចុះមកអំពីបញ្ចានោះ គឺសម្បត្តិដ៏មានដំឡៃក្រៃលែងរបស់ព្រះធម្មវិនិយនេះ ដែលជាវត្ថាប់ចិត្តរបស់ទេវតា ទើបមនុស្សទាំងឡាយ ហើយមនុស្សគ្រប់រូបទើបត្រូវការចង់បានទាំងអស់,

ប្រវត្តិព្រះមហា វស់ - គោ

អាចារ្យបង្រៀនសាលាបាលីវគ្គ វត្តកែវព្រះភ្លើង សង្កាត់លេខ ៥

ក្រុងកំពតេញ

ភិក្ខុ ខ្ប្បរ ឈ្ប

សំស្បុច្ចាត់ថ្នាក់ទី ១ នៃសាលាបាលីជាន់ខ្ពស់ រៀបរៀង

ព្រះមហា វស់ - គោ បិតា នាម វស់ ធ្វើតញ្ជា មាតា នាម ចិន រួលកកើតពីថ្ងៃពុធ ១ កើតខែកត្តិក ឆ្នាំវកគោសំក ព. ស. ២៤៦២ គ. ស. ១៩១៩ នៅភូមិគោកគ្រាប ឃុំភ្នាត ស្រុកពួក ខែត្រ សៀមរាប ។

កាលលោកនៅជាកុមារ អាយុ ៥ ឆ្នាំ បិតាអនិច្ចកម្មចោលនៅអាយុ ៨ ឆ្នាំ ឃុនទៅសិក្សាអក្សរសាស្ត្រខ្មែរ នឹងលេខនព្វន្ត ក្នុងសំណាក់លោកគ្រូធម្មសត្ថានៃយ៉ាង នាម (អ៊ឹម - ធុយ) ខេត្តអធិការវត្តឃ្លាសាទ អាយុ ១០ ឆ្នាំ មាតាក៏អនិច្ចកម្មទៅទៀត អាយុ ១២ ឆ្នាំ ទៅនៅស្រុកពួក ក្នុងសំណាក់លោកគ្រូ (គង់) នឹងលោកគ្រូ (ឡុប) ដើម្បីរៀនកុមារវណ្ណនតទៅទៀត; ចូលអាយុ ១៣ ឆ្នាំ ក៏ត្រឡប់មកនៅ វត្តឃ្លាសាវិញ ដល់ចុងអាយុ ១៣ ឆ្នាំ ជាដែល ឃុនលាលោកគ្រូព្រមទាំងបងប្អូនប្រុស - ស្រី ទៅនៅសិក្សាការសាបាលី នៅពីសាលាបាលីវគ្គ វត្តដំណាក់ (សៀមរាប) ក្នុងសំណាក់អាចារ្យ (វស់ - គុយ) ជាបងថ្នាក់

អាយុ ១៥ ឆ្នាំ ត្រឡប់ទៅបព្វជ្ជា ជាសាមណេរ នៅវត្តច្បាសាខ វិញ លុះបព្វជ្ជាហើយ ក៏ត្រឡប់មកកាន់វត្តដំណាក់ នៅបាន ២ ឆ្នាំ ក៏ចេញមកនៅវត្តលង្កា សង្កាត់លេខ ១ ត្រង់ភ្នំពេញ ក្នុងសំណាក់ លោកគ្រូអាចារ្យ "ប្រែស" បាន ១ ឆ្នាំ ក៏ត្រឡប់ទៅកាន់ខែត្រ សៀមរាប ដើម្បីប្រឡងយកឥណា "មហាបរិយត្តិបឋមវិជ្ជា" លុះ ប្រឡងជាប់រួចហើយ ក៏ត្រឡប់មកនៅភ្នំពេញវិញ ក្នុងថ្ងៃអាទិត្យ ១ កើត ខែអាសាធ ឆ្នាំឆ្លូវនព្វស័ក ព. ស. ២៤៨០ គ. ស. ១៩៣៧ ឆ្នាំនោះ លោកគ្រូអាចារ្យ "ប្រែស" ក៏ចេញទៅនៅឋានដំបងទៅ! ។

សាមណេរ រស់-កោ ក៏ចេញទៅសូមនៅវត្តកែវព្រះភ្លើង (ភ្នំពេញ) បានប្រឡងចូលរៀននៅសាលាឋាលីជាន់ខ្ពស់, លុះបានរៀនផុត ១ ថ្នាក់ ក៏វិលទៅកាន់ស្រុកកំណើតវិញ ដើម្បីបំពេញឧបសម្បទា ជាកិក្ខុភាព ក្នុងថ្ងៃសុក្រ ៨ កើតខែឆ្លូវនឆ្នាំថោះឯកស័ក ព. ស. ២៤៨២ គ. ស ១៩៣៩ ក្នុងព័ទ្ធសីមា វត្តច្បាសាខ ឃុំឱ្ងាត ស្រុកពួក ខែត្រសៀមរាប ដរាបដល់; លោកគ្រូធម្មសត្ថាវិនិយធរ នាម "ឆុយ" ជាឧបជ្ឈាយ៍, លោក គ្រូព្រហ្មជោត នាម "យក" ជាកម្មវាចា, លោកគ្រូធម្មជោត នាម "សិទ្ធិ" ជាអនុសាវន៍; ឧបជ្ឈាយ៍ឲ្យនាមបញ្ញត្តិជាកោវិទគ្នេរៈ ។

លុះបានឧបសម្បទារួចហើយ, កិក្ខុ រស់-កោ ក៏ត្រឡប់មកកាន់វត្ត កែវព្រះភ្លើងវិញ ក្នុង ព. ស. ២៤៨៥ គ. ស ១៩៤២ ចូលរៀននៅ

សាលាបាលីជាន់ខ្ពស់គ្រប់ ៤ ឆ្នាំហើយ ក៏ចេញមកធ្វើជាអាចារ្យបង្ហាត់បង្រៀនទៅសាលាបាលីវត្តកែវព្រះភ្លើងដដែល ។

លោកអាចារ្យអង្គនេះ ជាអ្នកយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនដោយធ្ងន់តឹងខ្លាចខ្លឹយគ្រួយខ្លឹយ ដើម្បីនឹងបំរើសាសនា, ខាតុភូមិដែលជាទីស្រឡាញ់របស់លោក ឲ្យបានទៅជាអារ្យជាតិក្នុងលោក; ហើយតាំងទៅក្នុងនិព្វានៈជាធម្មតាចិត្តយ៉ាងឯក សំដែងធម៌ទេសនាប្រៅប្រជាជន គ្រប់ទីដំបន់ ខិតជនបទមានមា ក្នុងដែនកម្ពុជាយើងនេះ ។ អ្នកធឹងបានស្តាប់ធម៌អាច់ពាក្យសំដីចូមាត់របស់លោក ហើយតែងមានសេចក្តីស្ងើចសរសើរស្ងើរតែកាល់មាត់ ។ ទៅៈពេលខំនេរខ្លះ លោកបានទៅតរៀបរៀងក្សួនច្បាប់ ទុកសម្រាប់កុលបុត្រសិក្សារៀនសូត្រជាច្រើន ដូចរៀបកប់ខ្លះ តទៅ ។

១ — ភូមិសាស្ត្រសង្ខេបនៃមហាចូតាំទ្វីប, ២ — វិធីសាធសំឡេង' ៣ — ការសិក្សាប្រកបដោយអង្គ ៣, ៤ — សាមគ្គីកថាជាដើម ។

ឯសៀវភៅក្សួនច្បាប់ទាំងនេះ សុទ្ធតែជាស្នាព្រះហស្តរបស់លោក ទាំងអស់ដកបដល់លោកមានការធ្លាក់ឈាមជាមួយ ជិត ១ ឆ្នាំ ។

លោកអនិច្ចធម្មទៅថ្ងៃចន្ទដប់កេចខែចែត្រឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៤៩១ ថ្ងៃ ៣ ខែ ទសភា ឆ្នាំ ១៩៤៨ ដោយពេតដូចខាងលើ ក្នុងឆន្ទាយុគំរប់ ៦៩ ឆ្នាំ ។

ពួកសិស្សានុសិស្ស នឹងពួកញាតិមិត្តព្រមទាំងឧបាសក ឧបាសិកា បានជំគល់សពលោកឧកញ៉ាអស់កំឡុង ៧ ថ្ងៃ នៅទីសាលាឧបោសថវត្តតែព្រះភ្លើងដែលរចនាតាក់តែងដោយគ្រឿងសក្ការៈដ៏ថ្លៃថ្លា ដើម្បីធ្វើទក្ខិណានុប្បទាន ឧទ្ទិសបុញ្ញកុសលប្រគេនលោក គឺយប់ចំរើនព្រះបរិត្ត - ទេសនា ព្រឹកឡើងវេរកត្តិប្រគេនសង្ឃជានិច្ច ។ ដល់ថ្ងៃអាទិត្យ ៦ កើតខែពិសាខឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ ត្រូវនឹងថ្ងៃ ៩ ខែ សីហា គ. ស. ១៩៤៨ វេលាម៉ោង ១៥ រសៀលដួបជុំពួកពុទ្ធបរិស័ទ រំកិលសពចេញពីសាលាឧបោសថ នៅជំគល់លើរថយន្ត រៀបក្បួនហែ មានលោកសង្ឃសិស្សានុសិស្ស នឹងទិស្សតែ នៃសាលាគរុវិទ្យា ព្រមទាំងពួកឧបាសក ឧបាសិកាជាច្រើន ដង្ហែតាម រិចឧកញ៉ាអ៊ុំ - សុខ្នាវង្ស (ឈប់បង្សុកូលនៅទីសាលាឧបោសថ) រិចឧកញ៉ាឈុន - ឱ្ងារដើឡាត្រែ (ឈប់បង្សុកូលនៅមុខសាលាគរុវិទ្យា) រិចវៃពានគរ នៅតាមចិញ្ចើមថ្នល់ មានឧបាសក - ឧបាសិកាត្រៀបត្រាមានគ្រឿងសក្ការៈនៅដៃ រៀងចំហែសពលោក ដែលសំដែងទឹកមុខជ្រប់ស្រពោនយ៉ាងសូចស្ងៀម គួរឲ្យកើតធម្មសង្វេគ (ឈប់បង្សុកូលនៅត្រៃកោយវត្តប្រយុរវង្ស - ខ្ពូនមណ្ឌារាម) បត់តាមរិចឧកញ៉ា អ៊ុំ ចូលមកកាន់វត្តតែវិញ រំកិលសពចាករថយន្ត នៅជាក់ដំគល់លើបាំរាស្រមាប់បូជា ដែលរៀបតាក់តែងដោយក្តីផ្កាយ៉ាងពិចិត្រ ។

នៅថ្ងាំសម្រាប់ទទួលភ្ញៀវ ព្រះតេជព្រះគុណ សម្តេចព្រះធម្ម-លិខិត (ល្វី - ឯម) ចៅអធិការវត្តលង្កា; ព្រះតេជព្រះគុណ ព្រះវនរតន៍ (មឿង) វត្ត ណ្ណាលោម, ព្រះតេជព្រះគុណ ព្រះទេពសត្ថា (សូរ - ហាយ), វត្ត ណ្ណាលោម, ព្រះតេជព្រះគុណ ព្រះមហា (ប៉ាង - ខាត់) វត្ត ណ្ណាលោមជាដើម ព្រមទាំងឥស្សរជនឯទៀតជាច្រើន ឋានានុក្រម នឹងអញ្ជើញមកជាអធិបតីបុណ្យ ។ មោង ១៧ រៀបបូជា. មុននឹងបូជា លោក (គង់) ទីប្រឹក្សាព្រះរាជាណាចក្រ ឋានសូត្រប្រវត្តិរបស់លោកនឹងសុន្ទរកថាលុះចប់ សម្តេចព្រះធម្មលិខិតប្រទានភ្លើង ។ ព្រឹកឡើងថ្ងៃច័ន្ទ វេរកត្តប្រគេនសង្ឃ មោង ២០ និមន្តធម្មកថិកពីរអង្គសំដែងធម៌ បុច្ឆា - វិស្សជ្ជនា ផ្សាយតាមវិទ្យុគ្លាសនស័ព្ទ ជាកិច្ចធ្វើបុណ្យតែប៉ុណ្ណេះ ។

ក្បួនហែសពវិលាយប់

សង្ឃាត់ទី ១ – ពួកអ្នកកាន់គប់ភ្លើង
– ២– កិត្តិសាមណេរ ១៥០
រូបចំរើនមរណាស្សតិ
សង្ឃាត់ទី ៣– រថយន្តដំកល់សព
– ៤ – ក្រុមស្ត្រីដើរហែ
– ៥ – ក្រុមបុរសដើរហែ

លុះហែទៅដល់វត្តពិពិធរហើយ មានអុជកាំជ្រួចភ្លើង - សម្រែក សត្វទទួលសពជាកិត្តិយស ហើយនិមន្តធម្មកថិក ១ រូបសំដែងធម៌ទេសនា លុះចប់និមន្តព្រះសង្ឃ ៨ រូបសូត្រព្រះអភិធម្ម ។

៤– ថ្ងៃ ៥ កើត ត្រង់នឹងថ្ងៃទី ៣-៤-៤៩ វេលា ព្រឹកប្រគេនយាគូ ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃទៅវត្តពិពិធ ៥០ រូប ទៅវត្តពោធិ៍វាល ២០០ រូប វេលាម៉ោង ១៥ រំកិលសពទៅដំកល់លើរូបភាព-សីហ៍ ដែលរចនាដោយស្មឹកឈើស្រស់ជារបស់ចំឡែកគួរឲ្យទស្សនាការ ហែសពត្រឡប់មកវត្តពោធិ៍វាលវិញ ។

ក្បួនហែសពវិលាថ្ងៃ

សង្ឃាត់ទី ១ – ភ្លេងពំណាពាទ្យ អ្នកចាត់រៀបចំ នាយឈុប-

សង្កាត់ទី ២ – ប៊ុស្សប៊ុកដំកល់ព្រះពុទ្ធរូបបរិនិព្វាន អ្នកចាត់. នាយសារុន

– ៣ – សម្តេចព្រះសង្ឃនាយកទាំង ២ គណៈ : អភិធម្ម – ស្បឹក

– ៤ – លោកគ្រូអនុគណទាំង ៨ មាតិកា – វន្ទា

– ៥ – កិក្ខុសាមណេរ ២០០ រូបចំរើនមរណៈសូត្រ ទូត

– ៦ – សង្ឃឹកជាក់គ្រឿងបរិក្ខារប្រគេនសង្ឃ – ស្រគំ

– ៧ – ក្រុមភ្លេងវែតវង់ – ប៊ុទ្ធិ

– ៨ – ក្រុមអាចារ្យយោគីកាន់ទង់ ៨ –ស៊ីនលី

– ៩ – ក្រុមអ្នកកាន់ផ្កាកម្រង –យឿម

– ១០ – អ្នកកាន់ទង់ស្បង់សរសេរធម្មសង្វេគ –គ្រូសំអាត

– ១១ – អ្នកកាន់ទង់សំពត់សសរសេរធម្មសង្វេគ –គ្រូឈឿម

– ១២ – អ្នកកាន់ទង់សំពត់ទៀសរសេរធម្មសង្វេគ – គ្រូកូយ

– ១៣ – ក្រុមភ្លេងក្លងខែក – នាយអ៊ិន

– ១៤ – ឧបាសកកាន់ឆ្នៃ – ឈឿម

– ១៥ – រាជសីហ៍ដំកល់សព –ស៊ុយហេង

– ១៦ – ក្រុមអ្នករាជការដើរហែ – សុវណ្ណ

– ១៧ – ក្រុមបុរសដើរហែ – សំផៅ

– ១៨ – ក្រុមស្ត្រីដើរហែ – នាយហុក

ទង់ស្បង់ - សំពត់ស - សំពត់ទៀទាំងអស់សុទ្ធតែសរសេរធម្មសង្វេគ

មានសរសេរថា "រូបំ អនិច្ចំ ទុក្ខំ អនត្តា" ដូច្នេះជាដើម ។

កឋិនក្បួនហែនេះមានចាត់អធិបតីជា ២ ផ្នែកគឺ អធិបតីខាងលោកសង្ឃ ១ ផ្នែក ខាងឧបាសក ១ ផ្នែក ។

អធិបតីខាងលោកសង្ឃ

១ – ព្រះមហាវ៉ាត អធិបតី

២ – កិក្ខុ សួន - យ៉ឹន នឹងកិក្ខុ សួន - សុវិន្ទ រងអធិបតី

អធិបតីខាងឧបាសក

១ – អ្នកអាចារ្យ អ៊ូច អធិបតី

២ – ហ៊ាប៊ុន - កាត់នឹងហ៊ាប៊ុន រងអធិបតី ។

អ្នកចាត់រៀបចាំងអស់ សុទ្ធតែកាន់ទង់ស ១ ខ្មៅ ១ តូច ៗ គ្រប់គ្នា ទង់សបក់សញ្ញាថា "ទៅ" ទង់ខ្មៅបក់សញ្ញាថា "ឈប់" ។ ក្បួនហែមានរបៀបរៀបរយល្អ មនុស្សហែរាប់ពាន់នាក់ ស្ងាត់មាត់ឈឹងរំពឹងមរណាសន្យតិគ្រប់ៗគ្នា ក្បួនហែចេញពីមុខវត្តពិពិធព័ន្ធផ្សារ ចេញមកវិថីនរោត្តមឆ្ងងស្ពានថ្មដម្រង់ចូលទៅវត្តពោធិ៍ភល លុះដល់ហើយលើកហែមទៅជុំគល់លើគ្រឿងជាន់ក្នុងចាំរាំយ៉ាតវត្តពោធិ៍ភល សឹងមានព្រះមហាតន្ត សុទ្ធ ជាអធិបតីកឋិនវិចារណកិច្ចនេះ ។

វេលាលើកសពជុំគល់លើគ្រឿងជាន់ស្រេច អស់លោកមន្ត្រីខ្មែរចាំរាំង យកផ្កាកម្រង់ទៅគំនាប់សព ហើយមានវិធីចែកចាយដល់ក្រុមអ្នក

ដំនួយនឹងសៀងគោជនាហារមន្ត្រីខ្មែរ-ជាកំង ។ ពេលម៉ោង ១៩ និមន្ត
ព្រះសង្ឃចំរើនព្រះបរិត្ត ធ្វើកិច្ចពុទ្ធាភិសេក ម៉ោង ២១ និមន្តព្រះតេជ-
គុណ ព្រះមហា សុមេធាធិបតីសង្ឃនាយកគណមហានិកាយសំដែងធម៌
ទេសនា លុះចប់ទើបព្រះតេជ-គុណ ព្រះមុនីកោសលថ្លែងប្រវត្តិអ្នកអា-
ចារ្យហ៊ុន-សុជ ដូចមានសេចក្តីបរិយាយតទៅខាងមុខនេះ ។

ប្រវត្តិអ្នកអាចារ្យហ៊ុន – សុជ ឆឹងសេចក្តីថ្លែងអាល័យ

ព្រះតេជព្រះគុណព្រះមុនីកោសលមេគណ ខេត្តបាត់ដំបង ថ្លែងបំភ្លោះពួកពុទ្ធបរិស័ទ

សូមទូលពុទ្ធដីកាព្រះថេរានុត្ថេរៈទាំងឡាយ !

សូមជំពាក់ចលោកអ្នកសប្បុរសទាំងអស់ !

ទុកាសនេះ ខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងប្រវត្តិអ្នកអាចារ្យ
សុជ លើកយកគុណធម៌ដែលគាត់ចាន់ធ្វើហើយក្នុងវត្តនេះ ឲ្យលោក
អ្នកទាំងឡាយចានជ្រាបថា មនុស្សម្នាក់នេះធាកំឡាំងដៃធ្វេងនឹងដៃស្តាំ
របស់ខ្ញុំព្រះករុណា អាត្មាភាព គួរនឹងសំដែងកិត្តិគុណឲ្យសមនឹងបំណាច់
ដែលគាត់ចានធ្វើរួចមកហើយ មានសេចក្តីដូចតទៅនេះ

ជាតិភូមិ

អ្នកអាចារ្យ សុជ បិតាឈ្មោះ ហ៊ុន មាតាឈ្មោះ គិម កើតនៅភូមិមុខ
វត្តពោធិ៍ ឃុំសង្កែ ខេត្តបាត់ដំបង ក្នុងថ្ងៃ អង្គារ ១៤ កេីត ខែអស្សុជ

ឆ្នាំកុរឯកស័ក ព.ស ២៤៤២ វេលាម៉ោង ៥ កន្លះអរុណដែរ មាន
បងប្អូន ២ នាក់ ទី ១ ឈ្មោះ ទី ២ អ្នកអាចារ្យ សុជ

ការសិក្សា

កាលកុមារ សុជ មានអាយុ ៩ ឆ្នាំ បិតាបានឲ្យសិក្សាអក្សរសម្រាប់
ជាតិ ចេះសរសេរ - អានបាន ដល់អាយុ ១៣ ឆ្នាំមាតាបិតាបាននាំ
មកផ្ញើនឹងព្រះគ្រូ កម្ពុជរតនវង្សី (សន) វត្តពោធិ៍វាល ។ លុះរៀនលេខ
នឹងធម៌ចេះហើយ មាតាបិតាបានធ្វើមង្គលកាត់ដុក ហើយបំបួសជា
សាមណេរ ព្រះគ្រូកម្ពុជរតនវង្សីជាព្រះឧបជ្ឈាយ៍ ។ លុះបួសរួចហើយ
សាមណេរសុជ រៀនព្រះវិន័យបិដកក្នុងសំណាក់ ព្រះគ្រូកម្ពុជរតនវង្សី
បួសបាន ៣ វស្សា លោកគ្រូអនិច្ចធម្ម ទើបចេញទៅរៀននឹងលោកគ្រូ
អាចារ្យឈិន លោកគ្រូអាចារ្យទុកវត្តសង្កែ រៀននឹងលោកគ្រូមហាកាជ
លោកគ្រូមហាកូនៅវត្តកណ្តាល ។ ដល់អាយុ ១៧ ឆ្នាំ បួសបាន ៥
វស្សា បានចូលទៅសិក្សានឹងលោកគ្រូមហាប៉ាន់ វត្តចក្រវត្តិ-ពាជាវាស
ក្រងបាងកក លុះអាយុគ្រប់ ២០ ឆ្នាំ ក៏ចូលឧបសម្បទាមិនមន្តព្រះមង្គល-
ទិព្វមុនីជាព្រះឧបជ្ឈាយ៍ និមន្តព្រះមហាប៉ាន់ ព្រះគ្រូបាឡាត់តាន ជា
កម្មវាចា ក្នុងព័ទ្ធសីមាវត្តចក្រវត្តិ បួសបាន ១ វស្សា ក៏ចូលមកនៅវិញ
ប្រាត់ដំបងវិញ ។

សមណាស័ក្តិ

បួសបាន ៥ វស្សា អាយុ ២៥ ឆ្នាំ ធ្វើជាគ្រូសុត្រ ដំនួយចៅអធិការ ដល់អាយុ ៣២ ឆ្នាំ ពេជការបានតាំងជាគ្រូបង្រៀនសាលាបាលីវត្តពោធិ៍-ពល អាយុ ៤២ ឆ្នាំ វស្សា ២២ បានទទួលនាទីជាព្រះគ្រូធម្មវិសុទ្ធិ ។

ការបរិហារ

កិច្ចការទាំងឡាយក្នុងវត្ត បើចៅអធិការរៀបចំដូចម្តេចក៏ជួយជាកំឡាំងស្មើគ្នាឥតមើលបំណាំ ទស្សាហ៍ដឹកនាំប្រៀនប្រដៅភិក្ខុសាមណេរ ឲ្យមានកិរិយាមារយាទរៀបរយសមគួរជាសមណៈ ទំាងជួយតែងសេចក្តីបញ្ញត្តិផ្សេងៗសំរាប់វត្ត ឲ្យមានរបៀបរៀបរយទាំងភិក្ខុសាមណេរ ឧបាសក ឧបាសិកា ។ កិច្ចការទាំងឡាយបើចាប់ធ្វើហើយ គោះមានឧបសគ្គមកខ្ទាំងខ្ទប់ក៏ខំប្រឹងដោយសេចក្តីព្យាយាមដរាបដល់បានសំរេច ។

ការបង្ហាញគន្ថធុរៈទំាងវិបស្សនាធុរៈ តាំងអំពីត្រឡប់ពីស្រុកស្បែមមក ក៏ខំប្រឹងបង្ហាត់បង្ហាញធម្មវិន័យដល់ភិក្ខុសាមណេរគ្រាលថ្ងៃឥតមានធុញទ្រាន់ បានឃើញអ្នករៀនទំាងគ្រូកម្មដ្ឋានឃ្លៀងឃ្លាតអំពីពុទ្ធវចនៈមានសេចក្តីសុតចិត្ត ខំសិក្សាក្នុងវិបស្សនាធុរៈយល់សព្វគ្រប់ ទើបតាំងបង្ហាត់បង្ហាញព្រះកម្មដ្ឋានដល់ ឧបាសក-សិកា មានក្តីឈ្មោះដរាបដល់មានភិក្ខុសាមណេរ ឧបាសក-សិកាធ្ងន់ខ្ពែតមករៀនជាច្រើន ។

ការបដិសង្ខរណៈព្រះអារាម

ព្រះតេជ - គុណ !

លោកអ្នកសប្បុរសទាំងឡាយ !

វត្តពោធិវ៌លកង់សម័យពុទ្ធសករាជ ២៤៦០ វិហារ-កុដិ-សាលាធម្ម-មន្ទីរទ្រុឌ្រួលការពេញខាំង ខ្ញុំព្រះករុណាអាត្មាការភ្ជាំ អ្នកអាចារ្យសុជាក្តី ឥតមានទំនេរ ទំប្រឹងប្រែងជួសជុលទង់កសាងជារាបមក រឿងបុរាណវត្ត គឺអ្នកអាចារ្យសុជជាអ្នកផ្តើមគិត ដើម្បីរក្សាបុរាណវត្តកង់ខែត្រនេះឲ្យគង់ទៅ ខ្ញុំព្រះករុណាអាត្មាការភ័ំទំប្រឹងជួយចាត់ការឲ្យបានសំរេចដូចប្រាថ្នាស្មាដៃដែលអ្នកអាចារ្យសុជកសាងចំពោះខ្លួន ដោយខ្ញុំព្រះករុណាអាត្មាការឥតបានជួយនោះគឺ: វិបស្សនាមន្ទីរនិងកុដែលប្រតិស្ឋានព្រះពុទ្ធរូបពុក្កវតិយោ

ជីវិតអវសាន

អ្នកអាចារ្យសុជមានអធ្យាស្រ័យម្យ៉ាងគឺ: ខ្លួនដូចម្តេច ចង់ឲ្យសិស្សប្រព្រឹត្តដូចខ្លួន និស្ស័យធ្ងន់ចិត្តរឿងសិស្សប្រជៀត កើតសេចក្តីអផ្សុកចាកសិក្ខាបទ. ថ្ងៃ ១៣ កើតខែបុស្ស ឆ្នាំម្សាញ់ ព. ស. ២៤៨៤ ប្រកបកិច្ចការរកទ្រួលទានដោយសេចក្តីព្យាយាមមកុដល់ថ្ងៃ ១០ កើត ខែអាសាធ ឆ្នាំមមី ក្រុមញាតិបានចាត់ធ្វើវិវាហមង្គលនិងថែដិប បានប្រកបកិច្ចការរកទ្រួលទានចំរើនដោយទ្រព្យសម្បត្តិល្មមសមគួរដល់ហាន: លុះដល់មកថ្ងៃ ១៥ កើត ខែមាឃ ព. ស.

๒๔๙๗ ចាប់ជម្ងឺដោយពេគគ្រុនបាន៣ថ្ងៃ ឃានអញ្ជើញពេទ្យមកពិនិត្យ
មើលថាពេគកណ្តាល (អុតដំ) ភរិយាព្រមទាំងសិស្សានុសិស្សនឹងញាតិ
មិត្តចំប្រឹងប្រែងរកគ្រូជាច្រើនមកព្យាបាលអាការៈពេគ មានកំឡាំងផុត
និស្ស័យហ្មាពេទ្យនឹងរក្សាបាន ។ សូម្បីទាហានយ៉ាងឯកនៃស្តេចមកចូល
មកញាំញីពាងកាយឲ្យបានខ្លួលន្ទួលទុក្ខវេទនាជាខ្លាំងម្ល៉ោះ ភរិយាអ្នក
អាចារ្យសុជសូប់ស្ងៀមឥតមានញាប់ញ័រ មិនដែលថ្លែងប្តោលពាក្យអ្វីឲ្យ
ញាតិមិត្តសង្កេតបាន សិស្សខ្លះនឹកសង្ស័យសួរថា: លោកគ្រូ! យើងខ្ញុំ
មើលឃើញពាងកាយលោកគ្រូគួរឲ្យទុក្ខវេទនាខ្លាំងណាស់ ប៉ុន្តែលោកគ្រូ
ព្រងើយចិត្តហាលជាខាងកងមជ្ឈមទេឬ? អ្នកអាចារ្យឆ្លើយថា តាមទុក្ខ-
វេទនាឥតមានអ្វីនឹងប្រៀប ពាងកាយទាំងមូលគ្មានសាច់ត្រង់ណាដែល
ចន្លោះមិនឈឺនោះគ្មានសោះ ដែលអត់ធន់បាន មកអំពីខ្ញុំធ្លាប់គិតធ្លាប់
ហ្វឹកហ្វឺនចិត្តមក ។ លុះដល់ថ្ងៃ៨ កើតដឹងខ្លួនថា: ជីវិតនឹងទ្រទ្រង់
នៅមិនបាន ទើបនិមន្តខ្ញុំព្រះករុណាអាត្មាភាពចូលទៅដិត ហៅភរិយា
មកអង្គុយជិតខាងហើយថ្លែងថា: ខ្ញុំព្រះករុណាធ្លាប់គិតមកវែយៗចំពោះ
អនិច្ចតាធម៌នេះ គ្រឿងប្រើប្រាស់ដែលចំឡើច្រើនតាំងចិត្តថា: កើតមក
មួយជាតិឲ្យមានគ្រឿងប្រើប្រាស់គ្រប់គ្រាន់ប៉ុណ្ណោះ ភរិយាខ្ញុំព្រះករុ-
ណាឃាត់មិនឲ្យធ្វើ ព្រោះគ្មានកូននឹងទួលមតក ខ្ញុំព្រះករុណាថា:
គ្មានកូនស្ងាប់ទៅយើងយកទៅផង ទើបភរិយាខ្ញុំព្រះករុណាព្រមឲ្យធ្វើ
និយាយតែប៉ុណ្ណោះឈប់មួយស្របក់ ទើបបែរទៅសួរភរិយាថា ចៃឲ្យអ្វីខ្ញុំ

ខ្លះ? កវិយោគបថា របស់ណាដែលមានហើយ លោកគ្រូត្រូវការអ្វីខ្ញុំ
ជូនទាំងអស់ របស់ណាដែលមិនទាន់មាន លោកគ្រូត្រូវការអ្វីខ្ញុំចាត់
ការជូនទាំងអស់តាមត្រូវការ សូមលោកគ្រូកុំត្រែងចិត្តឡើយ អ្នកអា-
ចារ្យទទួលថា សាធុ! ហើយប្រាប់ថា ខ្ញុំធ្លើគ្រឿងបូជាដោយប្រាក់មិនទាន់
គ្រប់ សូមចែចាត់ធ្វើឲ្យគ្រប់តាមបំណងខ្ញុំចុះ លុះរាត្រីថ្ងៃ ១១ កើតនិមន្ត
ឲ្យទៅដិតហើយប្រាប់ថា: យប់នេះខ្ញុំព្រះករុណាសូមឲ្យស្វាត់ ខ្ញុំព្រះ
ករុណា អាត្មាភាពក៏ដឹងថាន ថា អ្នកអាចារ្យនឹងលះលោកនេះទៅក្នុងរាត្រី
នេះក៏សំរួលតាមអធ្យាស្រ័យ ។

គួរអស្ចារ្យណាស់ ព្រោះខ្លឹមវេលាទៀបត្រឹក. អ្នករាទទួលទាន
តែងក្រោកឡើងធ្វើការងារ រនេះសេះប្តូរនេះឡានក៏តែងបើកបរ រាត្រី
ដែលអាចារ្យសូមឲ្យស្វាត់ ជាអានិសង្សដែលអ្នកអាចារ្យធ្លាប់អប់រម្យមក
ទើបរាត្រីនោះក៏ស្វាត់ រហូតដល់ពេលដែលអ្នកអាចារ្យអស់ត្រូវការ
តអំពីសូមស្វាត់មក អ្នកអាចារ្យក៏សូប់ស្ងៀមនូនស្តាប់ឮសំលេអស្សាស:
បស្សាស: ឮតំសួល "អរហំ" រាល់ដង្ហើមចេញចូល លុះវេលា
ម៉ោង ៥ កន្លះ អ្នកអាចារ្យក៏លះលោកនេះទៅគាន់លោកខាងមុខដោយ
សេចក្តីសូប់ ក្នុងថ្ងៃ អង្គារ ១១ កើតខែមាឃ ឆ្នាំរកាសប្តស័ក ព. ស.
២៤៨៧ ត្រង់នឹងថ្ងៃ-វេលាដែលអ្នកអាចារ្យកើត ហេតុដែលអ្នកអាចារ្យ
ធ្វើមរណកាលដោយមានសតិសម្បជញ្ញៈនេះ ជាព័ស្តុតាងមួយដ៏សមរម្យ
តាមហានៈជាអ្នករៀនជាអ្នកប្រដៅព្រះកម្មដ្ឋានដោយពិត ។ (ម១៣)

អំពីតាំងថ្មៅអធិការ

(តមក)

សញ្ញាប័ត្រលេខ ២១៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ យ៉ង់-ខៅ នាមធាយា ធម្មត្ថេរបញ្ញា កើតឆ្នាំខាល អាយុ ៣៥ វស្សា ២ ជាគ្រូសូត្រស្តាំ វត្តគីរី ឃុំឆែប ស្រុកឆែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២១៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ តឹម-សុំ នាមធាយា ធម្មសត្ថា កើតឆ្នាំជូត អាយុ ២៥ វស្សា ២ ជាគ្រូសូត្រឆ្វេង ខៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២១៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឆួន-អ៊ុល នាមធាយា ធម្មញ្ញាណ កើតឆ្នាំជូត អាយុ ២៥ វស្សា ២ ជាថៅអធិការវត្តទេពនិមិត្ត ឃុំមូ ស្រុកឆែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២១៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង-ណាក់ នាមធាយា ធម្មិស្សរៈ កើតឆ្នាំចោះ អាយុ ២៦ វស្សា ២ ជាគ្រូសូត្រស្តាំ ខៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២១៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ឿ-តុល នាមធាយា ធម្មជោត កើតឆ្នាំឆ្លូវ អាយុ ២៤ វស្សា ២ ជាគ្រូសូត្រឆ្វេងខៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សូរ-យឹម សុវណ្ណប្បញ្ញោ កើតឆ្នាំថ្នូរ អាយុ ២៤ វស្សា ៤ ជាចៅអធិការវត្តគីរីវន ឃុំចាប់ ស្រុកឆែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២២១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រំ - ចិន នាមធាយោ ធម្មត្ថេរ កើតឆ្នាំកុរ អាយុ ២៦ វស្សា ៤ ជាគ្រូសូត្រស្តាំនៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ហ៊ីង - សុខ នាមធាយោ ធម្មសុវណ្ណ កើតឆ្នាំម្សាញ់ អាយុ ២០ វស្សា ១ ជាគ្រូសូត្រឆ្វេង នៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ពុត - សម នាមធាយោ ធម្មសត្ថា កើតឆ្នាំរោង អាយុ ២១ វស្សា ១ ជាចៅអធិការវត្តសំពៅកែវនិមិត្ត ឃុំពើក ស្រុកឆែប ខេត្តកំពង់ធំ ។

សញ្ញាប័ត្រលេខ ២២៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី-អៀង នាមធាយោ ធម្មប្បញ្ញោ កើតឆ្នាំរោង អាយុ ២១ វស្សា ១ ជាគ្រូសូត្រស្តាំ នៅវត្ត-ឃុំ-ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គុច-សៃ នាមធាយោ ធម្មជោត កើតឆ្នាំរោង អាយុ ២១ វស្សា ១ ជាគ្រូសូត្រឆ្វេងនៅវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២២៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អែម - ហែម នាមធាយ ចន្ទត្ថេរ កើតឆ្នាំម្សាញ់ អាយុ ៣២ វស្សា ១ ជា ចៅអធិការវត្តគគីរ ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង ។

សញ្ញាប័ត្រលេខ ២២៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៊ុញ - ប៊ុត នាមធាយ ធម្មកេសរ: កើតឆ្នាំកុរ អាយុ ២៦ វស្សា ៦ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៣០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក - តន់ នាមធាយ ចិត្តត្ថេរ កើតឆ្នាំច អាយុ ៥១ វស្សា ៣០ ជា ចៅអធិការវត្តពោធិ៍ទង ឃុំកញ្ជើច ស្រុកកញ្ជើច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ តែវ - ឡូង នាមធាយ យសត្ថេរ កើតឆ្នាំមមី អាយុ ៥៤ វស្សា ៣៤ ជា ចៅអធិការ វត្តត្រពាំងថ្លាន់ ឃុំព្រាល ស្រុកកញ្ជើច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ៣២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ អ៊ុម - គង់ នាមធាយ គិតត្ថេរ កើតឆ្នាំវក អាយុ ៥៣ វស្សា ៣៣ ជា ចៅអធិការវត្តក្រឡាមាយ ឃុំស្នោត ស្រុកកញ្ជើច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៣.៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ល្អុក - មៅង នាមធាយ ធម្មត្ថេរ កើតឆ្នាំថោះ អាយុ ៤៦ វស្សា ២៩ ជាចៅអធិការវត្តស្នោត ឃុំស្នោត ស្រុកកញ្ជើច ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៣៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ពេជ្រ - គង់ នាមឆាយា ឥន្ទសេសរ កើតឆ្នាំថោះ អាយុ ៧០ វស្សា ៤៩ ជាចៅអធិការវត្តពោធិ៍ខ្វាវ ឃុំព្រាល ស្រុកកន្ត្រៃច ខេត្តតៃព្រៃវែង ។

សញ្ញាប័ត្រលេខ ២៣៥ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គុយ - គង់ នាមឆាយា ធម្មត្ថេរ កើតឆ្នាំជូត អាយុ ២៥ វស្សា ៥ ជាចៅអធិការវត្តពង្រ ឃុំគោកគង ស្រុកកន្ត្រៃច ខេត្តតៃព្រៃវែង ។

សញ្ញាប័ត្រលេខ ២៣៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ - សេង នាមឆាយា គម្ពីរបញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្តព្រះស្រែ ឃុំ - ស្រុកកន្ត្រៃច ខេត្តតៃព្រៃវែង ។

សញ្ញាប័ត្រលេខ ២៣៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ឆាង - ជួប នាមឆាយា សារប្បញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ៦ ជាគ្រូសូត្រឆ្វេង នៅវត្ត ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៣៨ ចុះថ្ងៃអង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ សិង - ផុន នាមឆាយា ឥន្ទសត្ថា កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជាចៅអធិការវត្តពោធិ៍ព្រះចាន (ចប្បារអំពៅ) ឃុំចប្បារអំពៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ២៣៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាប - អ៊ុម នាមឆាយា សុវណ្ណប្បញ្ញត្ត កើតឆ្នាំខាល អាយុ ៤៧

វស្សា ២១ ជាចៅអធិការវត្តឫស្សីស្រែស ឃុំចារអំពៅ ស្រុកកៀនស្វាយ ខេត្តតណ្ដាល ។

សញ្ញាប័ត្រលេខ ២៤០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ញឹក - យិម នាមឆាយា សុវណ្ណកេសរ កើតឆ្នាំថោះ អាយុ ៥៨ វស្សា ៣៧ ជាចៅអធិការវត្តស្វាយរមៀត ឃុំក្តឿងពាយ ស្រុកកញ្ជ្រៀច ខេត្តត្រៃវែង ។

សញ្ញាប័ត្រលេខ ២៤១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ជ្រាជ - ឯម នាមឆាយា ញាណវិសុទ្ធ កើតឆ្នាំខាល អាយុ ៣៩ វស្សា ១៩ ជាចៅអធិការវត្តត្រៃពស្វាយ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តត្រៃវែង ។

សញ្ញាប័ត្រលេខ ២៤២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ - មូល នាមឆាយា សុវណ្ណត្នេរ កើតឆ្នាំរោង អាយុ ៦៩ វស្សា ៤៩ ជាចៅអធិការវត្តសំរោង ឃុំក្តឿងពាយ ស្រុកកញ្ជ្រៀច ខេត្តត្រៃវែង ។

សញ្ញាប័ត្រលេខ ២៤៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ចន្ធូ - យ៉ា នាមឆាយា ធម្មប្បញ្ញោ កើតឆ្នាំមមី អាយុ ៣១ វស្សា ៩ ជាចៅអធិការវត្តចុងអំពិល ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តត្រៃវែង ។

សញ្ញាប័ត្រលេខ ២៤៤ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ គល់ - ឡាយ នាមឆាយា ព្រហ្មកេសរ កើតឆ្នាំមមី អាយុ ៤៣ វស្សា ២២ ជាចៅអធិការវត្តកណ្ដាល ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តត្រៃវែង ។

សញ្ញាប័ត្រលេខ ២៤៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ យស់ - ប៊ុត នាមឆាយា បុស្សរេកៅ កើតឆ្នាំមមី អាយុ ៣១ វស្សា ១០ ជាគ្រូសូត្រស្តាំ វត្តចាំងស្វាយ ឃុំចុងអំពិល ស្រុកកញ្ជ្រៀច ខេត្តវៃព្រវែង ។

សញ្ញាប័ត្រលេខ ២៤៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ស្រី - យ៉ង់ នាមឆាយា បញ្ញាសរោ កើតឆ្នាំច អាយុ ២៧ វស្សា ៥ ជាគ្រូសូត្រឆ្វេង នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៤៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ថោង - តុប នាមឆាយា ចន្ទមង្គល កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តព្រៃកទ្រមាក់ ឃុំព្រៃកទ្រមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ២៤៨ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ឡុង - ឆេង នាមឆាយា ពុទ្ធប្បញ្ញោ កើតឆ្នាំឆ្លូវ អាយុ ៣៦ វស្សា ១២ ជាចៅអធិការវត្តកោងកាង ឃុំកោងកាង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

សញ្ញាប័ត្រលេខ ២៤៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ប៉ែន - ជុម នាមឆាយា ឥន្ទប្បញ្ញោ កើតឆ្នាំរកា អាយុ ៤០ វស្សា ១៩ ជាចៅអធិការ វត្តត្រពាំងឈូក ឃុំឮយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។

(មានត)

សូមជូនដំណឹង

.....

ការផ្សាយរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលគាត់ទាន់ចោះពុម្ព
មកឃ្លាតហើយ ដោយខ្វះអក្សរ ន័ធក្រដាស តម្លៃវិនេះ ចាប់ផ្តើមចោះ
ពុម្ពបានខ្សែរំញ្ជែរហើយ មានសៀវភៅគាណាការៈ ចាលី, សម្ពន្ធមាលា,
ចាដិមោក្ខសង្ខេប, វិធីទាន្តសមាសសង្ខេបជាភាសាចាវំងន័ងរឿងមួយ
ពាន់មួយយប់ជាដើម ដែលទើបនឹងចេញពីពោធពុម្ពកន្លងពេលថ្មីៗនេះ
ហេតុនេះ បើអស់លោកអ្នកចាប្ចាចង់ចានសៀវភៅដូចមានឈ្មោះខាង
លើសូមអញ្ជើញចូលទៅជាវនៅក្រុមពុទ្ធសាសនបណ្ឌិត្យតាមត្រូវការ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ


IMPRIMERIE ROYALE

កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា ទំនៀមអក្សរសាស្ត្រ ចោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ឹក - ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា ស្សរ - ហ៊ុយ
ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ផ្នែកអក្សរសាស្ត្រ	ប្រធានបទ	ទំព័រ
អ្នកឧកញ៉ាឈឹម - ក្រែសេម	ព្រះរាជពង្សាវតារភាគទី១ សម័យនគរភ្នំ (តឆប់)	៤០១
នាងនៀត្រ - ឡាំងសី	របរឡាំងក់ (តមក - ចប់).....	៤១៧
លោក វ៉ាយ - ប៊ុក ក្រមការ	សុភាសិតភាគទី១ (តមក - ចប់).....	៤២៧
—	ប្រជុំពាក្យព្រៃងនឹងពាក្យចចាមអាំង (តមក - ចប់)	៤៣២
ហ្លួងនិពន្ធមន្ត្រី ញ៉ឹក - ថែម	ប្រវត្តិសាស្ត្រសង្ខេប ប្រទេសឥណ្ឌា (តមក)..	៤៤១
អ្នកឧកញ៉ា ព្រះឃ្លាំងខាង	រឿង «ភោគកុលកុមារ» (ពាក្យកាព្យ) (តមក)	៤៥០
ផ្នែកសាសនា		
មហាឧម - ណាត្រី	មុនីសុភាសិត	៤៥៦
ហ្លួងនិពន្ធមន្ត្រី ញ៉ឹក - ថែម	ពន្ធអាស៊ីទ្វីប (តមក).....	៤៦៤
កំណត់ទំនឹងប្រវត្តិការណ៍		
ភិក្ខុ សូន - សុរិន	បុណ្យប្តូរជាសពអ្នកអាចារ្យហ៊ុន-សុដ (តចប់)...	៤៧០
ក្រែសូងធម្មការ	អំពីការតាំងហើអធិការថ្មី (តមក)	៤៧៨

ឆ្នាំទី ២១ — លេខ ៦ ខែមិថុនា ឆ្នាំ ១៩៤៩ — ជំរៀងវរ ១ ឆ្នាំ ៩៦ រៀល ។

KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantrî Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Vénérable Brah Déb Sattha So-Hay membre de la Commission du Tripitaka

TABLE DES MATIÈRES

Partie littéraire :

		page
Neak Oknha Chim-Krasem député	Histoire ancienne du Cambodge, 1er partie (suite et fin)	401
Néang Net-Langsey	Culture du tabac au Cambodge (suite et fin)	417
M. Ray-Buc kramakar (I. B.)	Proverbes et maximes tome I (suite et fin)	427
—id—	Recueil des Dictons et des devises français (suite)	432
Luong Nibandhamantrî Nhok-Thèm	Histoire sommaire de l'Inde (suite)	440
Vén. Neak Oknha Breah Khleang Nong	« Bhog kulkumar » (en vers) (suite)	450

Partie religieuse:

Maha Om-Nagry Luong Nibandhamantrî Nhok-Thèm	Munisubhasit	456
	Lumière de l'Asie (suite)	464

Notes et chroniques

Vén. Suon-Surin	Compte-rendu sur les cérémonies de crémation de l'Achar Hin-Such (suite et fin)	470
Ministère des cultes	Nomination des nouveaux chau Adhikar (suite)	478

21e Année: No 6 Juin 1949 — Prix d'abonnement: 96$00 par an.

ព្រះរាជនិពន្ធរបស់ព្រះបាទ ១

(4)

សម័យនគរភ្នំ

ក្រសួង ទេពពិន្ទុ រៀបរៀង

(ភាគ)

ព្រះចាន់គោណ្ឌញ្ញ ព្រះនាងសោមាទេវី
ព្រះពាលាទិត្យ សារស្វតី កវិយាវិស្សរូប
រាជនុសេច្ឆឆ មហេន្ទ្រទេវី មហេសិមហេន្ទ្រវ័ន
ទៅអនិន្ទិតបុរៈ រាជេន្ទ្រវ័ន ។

ព្រះចាន់គោណ្ឌញ្ញាជយវ័ន ចាក់ដង ព្រះកិត្តិយសជាមហាធីរាជ, ជាមហាក្សត្រិយ៍សឹក, ជារាជាធំរាជ ឬជាកែពត្តិ ក្នុងប្រវត្តិសាស្ត្រ ។

ព្រះចាន់រុទ្រវ័ន

ត. ស. ១០៧៤ - ១០៨៨, គ. ស. ៥១១ - ៥៤៤

ព្រះរុទ្រវ័នអង្គនេះ ប្រហែលជារាជនុសព្រះចាន់គោណ្ឌញ្ញាជយវ័ន ដែលមានព្រះនាមដើមថា ពាលាទិត្យ, រីឯទ្បើងសោយរាជ្យ គេថ្វាយព្រះបរមនាមថា រុទ្រវ័ន, ទ្រង់មានព្រះអគ្គមហេសី ព្រះនាមរុទ្រទេវី ។ ព្រះចាន់រុទ្រវ័ន ទ្រង់មានព្រះរាជនុសេ ១ អង្គ តែមិនចាក់ដងព្រះនាមដូចម្តេច ហើយព្រះរាជនុសេនោះប្រហែលជាប្រសូតអំពីព្រះជាយាដវៃ កាលពីមុនបានសោយរាជ្យ មិនមែនជា

ប្រសូតអំពីព្រះនាងវុទ្ធទេវីដ៏ជាអគ្គមហេសី ។ តាលទីនេះទ្រង់សោយរាជ្យ
ត្រូវព្រះរាជឧស្សាហ៍ដែលមិនស្គាល់ព្រះនាមនោះ ក្សត់ដណ្តើមរាជបល្ល័ង្ក
ទ្រង់គោរងសម្លាប់ព្រះឧស្សាក្សត់នោះបង់ហើយ ទើបបានឡើងគ្រងបល្ល័ង្ក
រាជ្យតមក ។

ការផែនដី : ក្នុងពេលដែលប្រទេសខ្មែរនៅសង្រែនដីថ្មី តាំងមាន
ក្សត់ផែនដីផងនេះ ជាឧកាសឲ្យចាម្បាកការបះបោរឡើង ដើម្បីដោះខ្លួន
ឲ្យរួចអំពីអំណាចខ្មែរ តាលព្រះបាទវុទ្ធរ៉ែនទ្រង់ជ្រាបហើយ ក៏ស្តេចយ
លើកកងទ័ពទៅកម្រាប ចាន់ត្រឡប់រាបរាបដូចដើមវិញ ។

សាងព្រះនគរបុរី

គ្រោយកម្រាបចាមហើយ បានស្តេចទៅសាងព្រះរាជធានីថ្មី នៅ
ស្រុកព្រៃកប្បាស សង្ឃមិនឆ្លាយប៉ុន្មានពីនគរភ្នំជ្រោកដណ្តើរនៅក្នុង
ពាក្យសច្ចាប្រណិធាន (ធឹកចឹកសំបថ) ថា "នគរអធិបតី" (១) តែគ្រោយ
មកគេហៅថា នគរបុរី នៅមានតំស្តុតាងជ្រោកដ ដរាបដល់សព្វថ្ងៃនេះ ។
គ្រៅពីនេះទ្រង់បានសាងទេវស្ថាន ១ នៅភ្នំដា ដ៏តនគរបុរី ទឹងឲ្យចា-
រិកសិលាចារិក ១ ទុកនៅជ្រោសាទតាព្រហ្ម (ចាទី) ។

---

១ ឈ្មោះនេះជាតក្យាយទៅជារឿងព្រៃងគេហៅថា "នគរស្វាយចន្ទី" រឿងព្រៃងនេះ អ្នក
ស្រុកព្រៃកប្បាសនៅចាំ ទឹងទីឃាយដំណាលបានហ្មងហែ ដរាបដល់សព្វថ្ងៃនេះ ។

មិនដឹងជាដោយហេតុអ្វី ដល់មកក្នុងឆ្នាំ ព. ស. ១០៨៨ ព្រះបាទ
រុទ្រវ័ន្តសោយតែកៀសព្រះអង្គបាត់អំពីព្រះនគរទៅ [1] ។
ព្រះស្រីសុវ័ន្តបានទទួលគ្រងរាជសម្បត្តិតមក ។

ព្រះបាទស្រីសុវ័ន្ត

ព. ស. ១០៨៨-១១០៩, គ. ស. ៥៦៤-៥៨៩

ព្រះស្រីសុវ័ន្តអង្គនេះ ជាព្រះរាជនុសព្រះបាទរុទ្រវ័ន្តប្តូជាព្រះ
រាជវង្សដទៃទេ គេមិនអាចដឹងបានជាប្លែកឯ ស្តេចមកពីនគរប៉ាក់ងមា
វេលានោះក៏បានទទួលគ្រងរាជសម្បត្តិតំពីព្រះបាទរុទ្រវ័ន្ត, មានព្រះបរម
នាមសម្រាប់ហៅ ២ យ៉ាងទៀត គឺស្រីសុវ័ន្ត ឧទ្ទឹងត្នូវ័ន្ត, ទ្រង់មាន
ព្រះអគ្គមហេសី ទ្រង់ព្រះរាជនុសត្រះរាជធីតាប្តូទេ មិនប្រទេះដំណឹង ។

ការវិនដី: ក្រោយដែលបានទទួលពិធីរាជាភិសេកហើយ ព្រះ
បាទស្រីសុវ័ន្ត ទ្រង់តែងរាជឱ្យតាំរាជសារទូរាជបណ្ណាការ ទៅសុំបង
សម្ពន្ធមេត្រីភាពនឹងស្តេចចិន, ខាងស្តេចចិនក៏បានទទួលបងមិត្រភាពង
ហើយតែងរាជឱ្យនាំព្រះរាជសារទូរាជបណ្ណាការ មកតបវិញតាមទំ-
ខៀម ។ ព្រះមហាក្សត្រិយ៍ទ្វេរបានទ្រង់តែងរាជឱ្យទៅសុំបងជាសម្ពន្ធ-
មិត្រនឹងស្តេចក្រុងចិនរាប់ជាគ្រាទី ៤ ក្នុងរជ្ជកាលនេះ ។

---

១ តាមរដ្ឋសេដ្ឋិដ្ឋានថា ប្រហែលជាមានព្រះរាជវង្សអង្គនិមួយគិតក្បត់ កាលទ្រង់ជ្រាប
ហើយទ្រង់មិនត្រូវការនឹងគស្ងួ ទើបទ្រង់ភេសៅដោយស្ងាត់ ។

ត្រាយដែលបានចងសម្ពន្ធមេត្រីភាពជាមួយនឹងស្តេចចិនហើយ មាន
សេចក្តីប្រាកដក្នុងពង្សាវតារចិនថា ស្តេចខនគលិនយី (ចាម្ប៉ា), ចង់រាយ
ស្រុកគៅដីរបស់ចិនយកមកជាសម្បត្តិរបស់ខ្លួន ទើបបានបញ្ជូនពលទូត
ឲ្យសូមកងទាហានស្តេចខនគរកុំ (ខែរ) ទៅជួយវាយ តែស្តេចខនគរកុំ គឺ
ព្រះបាទគន្ធរ៉ែន ពុំព្រមព្រះពលទាមតាមសុំ ព្រោះទ្រង់បានចង
សម្ពន្ធមេត្រីភាពជាមួយនឹងស្តេចចិនទៅហើយ ។ ន័យ១ទៀត ចាម្ប៉ាឯង
កងវៃលានោះទៅកងអំណាចតន្ត្រីពលរបស់ខែរ មិនត្រូវតឹកអាណាខេត្ត
ដោយអំពើចិត្តឯងដូច្នេះ ទើបមិនទ្រង់ប្រាសព្រះពលទាហានតាមសុំ។

សាងព្រះនគរស្រីស្តុបុរៈ

ព្រះបាទស្រីសូរ្យវ៉ែន បានស្តេចឡើងទៅសាងព្រះពលធានីថ្មីទៅបូ-
ដោម កន្លែងត្រសឹងត្រែង ចម្ងាយ ១២ គីឡូម៉ែត្រពីស្ទឹងត្រែង ហៅថា
"ស្រីស្តុបុរៈ" ហើយស្តេចទៅគង់នៅក្នុងថ្មីនេះ ប្រោះបង់ចាលនគរកុំ
ស្រឡះ នគរកុំបានរលាយទៅក្នុងឆ្នាំ ព. ស. ១០៩៣ (គ. ស. ៥៥០) ។

កាលដែលព្រះបាទស្រីសូរ្យវ៉ែនទៅគាំង ព្រះពលធានីទៅដែនដីភាគ
ខាងលើនោះ បានប៉ះរស្មីគ្មានឹងព្រះភវ៉ែនដ៏ជាឧបាសក សឹងគាំង
ពលធានីទៅត្រង់មជ្ឈមនៃទន្លេមេគង្គ ជាចន្លោះ ១ទ ទឹង ចាវៃក បាន
កើតជាសង្ឃាមគ្នាឡើងក្នុងប្រទេស ដោយព្រះភវ៉ែនជាអ្នកលើកកំឡាំង

មកវាយក្រុងស្រីសុព្រះ: មុន ។ ផលនៃការសង្គ្រាមក្នុងទីបំផុត ព្រះភវរ័ន
មានជ័យជំនះ ប៉ាន់គ្រប់គ្រងដែនដីទាំងមូល ដោយជាច់ខាត ។

ក្នុងគ្រាសង្គ្រាមនោះ ព្រះភវរ័ន ជាពាជបុត្រក្សត្រិយ៍ចាម្ប៉ាបានទ្រង
ដោយយើញខ្មែរជាប់ដៃច្បាំងគ្នាឯងក្នុងប្រទេស ក៏ប្រកាសខ្លួនជាឯករាជ្យ
ភ្លាម ។ ពិតដូច្នេះ ខាងខ្មែរកំពុងជាប់ដៃច្បាំងគ្នា ក៏គោងបណ្តោយឲ្យ
ចាម្ប៉ាតាំងខ្លួនខៅតាមការ, កាលឈប់ច្បាំងហើយ ព្រះភវរ័ន ក៏មិនខ្វល់
លើកកំលាំងទៅបង្ក្រាបចាម្ប៉ា ដោយខ្វល់យល់ឃើញថា ទាហានរបស់
ព្រះអង្គស្ទុតស្ទាប់ជាច្រើន ដែលរស់នៅកំពុងខ្វៃយហត់ខ្លាំងណាស់ ។
គិតបរិមាណឆ្នាំដែលចាម្ប៉ាឆ្លាក់មកនៅវៀតរាមអំណាចខ្មែរ តាំងពីកងវដ្ត-
កាលព្រះបាទគោណ្ឌញ្ញាជយវរ័ន មកដល់កងវដ្តកាលព្រះបាទស្រីសូរ្យវរ័ន
(ព. ស. ១០២៦ - ១០៩៣) រួមប្រមាណ ៦៥ ឆ្នាំ ។

ព្រះមោឧភវរ័នទី ១

ព. ស. ១១០៩ - ១១២៩, ត. ស. ៨៦៥ - ៨៨៥

មានព្រះរាជវង្ស ១ អង្គ ព្រះនាម "វីរវរ័ន" ជាព្រះរាជវង្សនៅ
នគរកុំ ត្រូវតាំងបរាជឲ្យទៅគ្រប់គ្រងដែនដីភាគខាងលើ តាំងពីកង
វដ្តកាលព្រះបាទគោណ្ឌញ្ញាជយវរ័ន មានឧកញ៉ាវង្ស "ហៅថា" កម្ពុជវង្ស
ខ្លះមានព្រះទេវី ព្រះនាមដូចម្តេច មិនប្រាកដ តែមានព្រះរាជឱរស
សំខាន់ ២ អង្គ ព្រះនាម ភវរ័ន ១ មហេន្ទ្រវរ័ន ឬហៅថា ចិត្តសេន ១ ។

កាលព្រះអរិយមុនីសុគតទៅហើយ ព្រះកវីរ៉ន ទុរសច្បង់ក៏ប្លាន់ខ្លួន សោយរាជសម្បត្តិ ក្នុងដំណែងជាន់ចុងរាជតមក តែក្សត្រិយ៍អង្គនេះជាអ្នកក្លាហានក្នុងការរណរង្គ ។

កាលព្រះបាទស្រីសូរ្យវ៉ន់ទៅគាំង ព្រះពាជធានីនៅបាដោម ក៏កើតប៉ះវស្ដីគ្នាកើតជាសង្គ្រាមក្នុងប្រទេសឡើង ដោយព្រះកវីរ៉នជាអ្នកលើកមកពាយមុន សឹងមានព្រះអនុជមហេន្ទ្រវ៉ន់ជាអ្នកជំនួយ ផលនៃការសង្គ្រាមក្នុងទីបំផុត ព្រះកវីរ៉នមានជ័យជំនះ ឃានគ្រប់គ្រងផែនដីគាំងមូល ក្នុងកាល ព. ស. ១១០៨ ទ្រង់មានព្រះអគ្គមហេសី ព្រះនាមកវាន់ មានព្រះពាជទុរស ព្រះពាជធីតា ឬទេ មិនឃ្លាតដក្នុងប្រវត្តិសាស្ដ្រនោះ ។

ការផែនដី ព្រះបាទកវីរ៉ន កាលទ្រង់ឃានគ្រងពិភពផែនដីគាំងមូលហើយ ទ្រង់ឃានចេញព្រះរាជប្រកាសឲ្យហៅជាតិខ្មែរថា "កម្ពុជា" នាមនេះ មានអត្ថរិត្តហាថា «កេម្ពុជា សព្ទកោដ ឯដន្តំ[1] តស្សរូបោហារតោតិ កម្ពុជ » ប្រែថា "ជនពួកណាវុងរឿងដោយមាស ជនពួកនោះឈ្មោះថា កម្ពុជា ពួកអ្នកវុងរឿងដោយមាស" គាំងឈ្មោះប្រទេសដែលឆ្លាប់ហៅតំុមកអំពីដើម ក៏ទ្រង់ប្រកាសឲ្យហៅថា កម្ពុជា ដែរឲ្យស្របគ្នានឹងឈ្មោះជាតិ ។ ដូច្នេះ គប្បីដឹងថា ជាតិខ្មែរនឹងប្រទេសខ្មែរ ឃានឈ្មោះថា កម្ពុជា ពីគ្រឹមរដ្ឋកាលព្រះបាទកវីរ៉នទី ១ មក ។

---

[1] ឧជធាតុ ប្រែត្រង់ទៅក្នុងអត្ថថា រុងរឿង ។

ចំណែកខាងចិនដែលឆ្លាប់ហៅប្រទេសខ្មែរថា ហ្គូណាន តាំងពីដើម
មក ក៏ប៉ានឆ្លាស់ហៅទៅតាមឈ្មោះខ្មែ តែហៅមិនច្បាស់ថា ចិនឡា
(កម្ពុជា) តាំងពីក្នុងរជ្ជសម័យនេះ ដូចមានប្រាកដក្នុងពង្សាវតារចិនស្រាប់ ។

សាងព្រះនគរភវបុរៈ

កាលរៀបចំប្រទេសឲ្យប៉ានសាន្តត្រាណហើយ ព្រះបាទភវវ័ន្ទទ្រង់
ទុកឲ្យព្រះមហេន្ទ្រវ័ន្ទឲ្យទៅគ្រងក្រុងស្រីសុភបុរៈ ក្នុងដំណែងជាឧបរាជ
ហើយស្តេចចេញទៅសាងព្រះរាជធានីថ្មីនៅតំបន់ព្រៃពនគរ ហៅថា
"ភវបុរៈ" ។ ស្តេចគង់នៅក្រុងថ្មីនេះ រហូតដល់សោយទិវង្គត ។

ព្រះរាជមហេន្ទ្រវ័ន្ទ

ក ស. ១.២៨-១.៣, ក ស. ៥៨៩-៦១០

កាលព្រះបាទភវវ័ន្ទទី ១ សោយទិវង្គតហើយ ព្រះអនុជាធិរាជ
មហេន្ទ្រវ័ន្ទប៉ានឡើងសោយរាជ្យ ស្តេចគង់នៅក្រុងស្រីសុភបុរៈដដែល,
ទ្រង់មានព្រះអគ្គមហេសី ព្រះនាម មហេន្ទ្រទេវី ជាធីតាព្រះនាងសាសូតី
នឹងវិសូរបុមានព្រះរាជនុរសដែលប្រាកដព្រះនាម ១ អង្គគឺព្រះរាជេន្ទ្រវ័ន្ទ
ដែលប៉ានសោយរាជ្យក្នុងឆ្នាំ ៣. ស. ១១៩៣ ។

ការផែនដី ការគ្រប់គ្រងផែនដីក្នុងរជ្ជកាលនេះប៉ានប្រព្រឹត្តទៅដូច
ក្នុងរជ្ជកាលមុន ។

សាងព្រះនគរសុវប្បុរៈ

ក្រោយដែលបានទទួលរាជាភិសេកហើយ ព្រះបាទមហេន្ទ្រវរ្ម័ន ស្តេចទៅសាងព្រះរាជធានីថ្មី នៅតាមដងទន្លេមេគង្គ ហៅថា "សុវប្បុរៈ" ក្រុងនេះនៅមានព័ស្តុតាងនៅដល់សព្វថ្ងៃនេះ តែគ្រាយមកគេហៅថា "សំបូរ" ទៅវិញ ស្តេចទៅគង់នៅក្រុងថ្មីនេះ ដរាបដល់សោយទិវង្គត ។

ព្រះចាន ឬ សាណាវរ្ម័ន

គ.ស. ១០៥៣-១១៣៣, ព.ស. ៦១៦-៦៣០

កាលព្រះបាទមហេន្ទ្រវរ្ម័នសោយទិវង្គតហើយ ព្រះឬសាណាវរ្ម័ន (១) បានឡើងសោយរាជ្យតមក ព្រះមហាក្សត្រិយ៍អង្គនេះមិនដឹងជាតវង្សមកអំពីក្សត្រិយ៍អង្គណាជាប្រាកដ ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេច នឹងមានព្រះរាជនុរសព្រះរាជធីតាប្រុទេ មិនប្រាកដក្នុងប្រវត្តិសាស្ត្រនេះ ។

ការផែនដី : ការគ្រប់គ្រងផែនដីនៅប្រព្រឹត្តទៅស្មើដូចកន្លងមកក្នុងកាលមុន ។ ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់ជាអ្នកគាប់អានព្រះពុទ្ធសាសនា ដោយប្រាកដសេចក្តីនៅសិលាចារឹកជាភាសាខ្មែរ ដែលទ្រង់ឲ្យចារឹកទុកនៅនគរបុរី ក្នុងឆ្នាំ ម. ស. ៥៣៣ មានសេចក្តីពិយ

---

១ តាមក្នុងព្រះរាជពង្សាវតារនិងបានម្តងព្រះមហាប៉ាក្រុងចាស់ថ្មី ។ ឲ្យថា ព្រះឬសាណាវរ្ម័ន ជាវរជនរបស់ព្រះបាទមហេន្ទ្រវរ្ម័ន(ក្រ) ។

ពាប់មុខរបស់ដង្វាយដែលទ្រង់ប្រទានថ្វាយជាពុទ្ធបូជានៅទីក្រុងចាស់នោះ នឹងថា ទ្រង់តែងធ្វើសង្ឃទានរាល់ ៗ ថ្ងៃសីល ។

គួរកំណត់សំគាល់ថា ព្រះមហាក្សត្រិយ៍អង្គនេះ ទ្រង់បានចារឹកភាសាខ្មែរទុកនៅផែនថ្ម មុនក្សត្រិយ៍អង្គឯទៀតទាំងអស់ ។

សាងព្រះឧគរត្តៀសាណបុរៈ

ព្រះបាទត្តៀសាណវ័ន បានស្តេចទៅសាង ព្រះរាជធានីថ្មីទៅស្ទឹងវែនហៅថា "ត្តៀសាណបុរៈ" ហើយស្តេចទៅគង់នៅក្រុងថ្មីនេះជាបឋមរៀងមក ។

មកដល់ចុងរជ្ជកាល ក្នុងឆ្នាំ ៣. ស. ១១៧០ (គ. ស. ៦២៧) ទ្រង់បានតែងរាជទូត ឲ្យនាំព្រះរាជសារទូរាជបណ្ណាការទៅសុំចងសម្ពន្ធមេត្រីភាពនឹងស្តេចចិន ។ ឯស្តេចចិនក៏ព្រមទទួលនឹងតែងរាជទូត ឲ្យនាំព្រះរាជសារទូរាជបណ្ណាការមកតបវិញក្នុងឆ្នាំនោះ ។ ប្រទេសខ្មែរបានចងសម្ពន្ធមេត្រីភាព នឹងប្រទេសចិន ជាគ្រាទី ៥ ក្នុងរជ្ជកាលនេះ ។

ព្រះចាន្ទកវ័ន ទី ២

៣. ស. ១១៧៣ - ១១៧១, គ. ស. ៦៣០ - ៦៣៨ -

ព្រះមហាក្សត្រិយ៍អង្គនេះ ប្រាកដតែព្រះបរមនាមក្នុងសេចក្តីកត់ហេតុតែប៉ុណ្ណោះ ប្រវត្តិការណ៍ទាំងពួងបានសូន្យទៅជាមួយនឹងកាល

ដែលតទូន្មនទៅ ។ ទោះបីយ៉ាងណាក៏ដោយ ព្រះរាជអង្គនេះ គង់មានក្រសែលោហិតខាត់ទង់មកអំពីព្រះបាទកន្ទ្រែន ទី ១ ។

ព្រះចាន ជយវ៌្ម័ន ទី ១

ព. ស. ១៤៨១[2] - ១៥៤៣, ត. ស. ៦៣៨ - ៦៨០

ប្រវត្តិសាស្ត្រកម្ពុជរដ្ឋកាលនេះបានសូន្យទៅវារយៈពេលខ្លី, ទង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេច មានព្រះរាជទុរស ព្រះរាជធីតាប្តូរទេ មិនប្រាកដ ប្រាកដតែក្នុងរដ្ឋកាលនេះ មានអសន្តិសុខជាញឹកញាយ គឺមានការបះបោរ នឹងកើតសង្គ្រាមក្នុងប្រទេសឆាប់ខ្លីនលើក ទោះបីដូច្នោះ ព្រះបាទជយវ៌្ម័ន ទី ១ ទង់ក៏ប្បាំងតស៊ូ រក្សារាជបល្ល័ង្កទុករហូតមកដល់ឆ្នាំ ព. ស. ១១៨៣ ។

---

១ ក្នុងឆ្នាំដែលព្រះបាទជយវ៌្ម័ន ទី ១ សោយរាជ្យ កើតមានសកវាជ ១ យ៉ាង ដែលហៅថា បុលស្សសកវាជ គេតាំងឡើងក្នុងឆ្នាំកុរ ព. ស. ១១៨១ ម. ស. ៥៨៣ ហើយរាប់ឆ្នាំកុរនោះដា ឯកស័ក ទំនៀមរាប់ស័កខ្វិថា ឯកស័ក ទោស័ក ។ល។ ឧពស័ក សម្រិទ្ធិស័ក កំពាប់ម្ភៃនប្រើឡើងជាមួយនឹងឆ្នាំកំណើតនៃបុលស្សសកវាជនេះ ។ ការតាំងបុលស្សសកវាជនេះ ដោយកំណត់យកជំណើរគោចរនៃព្រះអាទិត្យ ត្រង់វេលាដែលវិលខួបដួបបញ្ចូលមកកាន់មេសរាសីវិញ គឺត្រូវត្រង់ថ្ងៃទី ១៥ ខែមេសា ជាកែណ្តា ។

សកវាជនេះ អ្នកណាតាំងឡើង ក្រែកងតាមដែលបានស្រែវគ្រាវមកហើយ ដំក្សត្រិយ៍មនព្រះនាម សង្ឃរាជ ឬហៅ បុព្វសោរហ៊ន ជាក្សត្រិយ៍ ទី ១៩ ក្នុងរង្វង់ សម្ភទច្ចទ្ធិ ទ្រង់តាំងឡើង តែក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជា ដែល ម. ឡូជាដំណាក្រៃ រួបរួមថា ពញាក្រែក ក្សត្រិយ៍ខ្មែរ ទ្រង់តាំងឡើង ហើយថាពញាក្រែកនោះសោយរាជ្យ . ខ្ញុំគង់នៅក្រៃគន្លងធំ បើយើងពិនិត្យមើលកំណើតក្រៃគន្លងធំ ក៏ខ្ញុំងឃើញថាក្នុងរាជវង្សកវាជប៉ុណ្ណោះ គេពុំទាន់ជានសាងនៅឡើយ ។

ព្រះចាន ភ ឆ្នូរព្រ័ន ទី ១

ព. ស. ១៩៣ - ១២២៣, ជ. ស. ៦៥០ - ៦៨០

ព្រះមហាក្សត្រិយ៍អង្គនេះ ជាព្រះរាជនុសនៃព្រះបាទមហេន្ទ្រវរ្ម័ន ទ្រង់បានសោយរាជ្យក្នុងវ័យជាបន្តិចហើយ ទ្រង់មានព្រះអគ្គមហេសី ព្រះនាមដូចម្តេច នឹងមានព្រះរាជនុសព្រះរាជធីតាឬទេ មិនទាន់បានបទះដំណឹងជាពិតប្រាកដ ។

ការផែនដី: រឿងរ៉ាវផែនដីក្នុងរជ្ជកាលនេះ បានរលាយសូន្យទៅជាមួយនឹងកាលដែលកន្លងទៅយូរហើយ នៅមានសល់ដំណឹងខ្លះតែខាងសាសនា ។ ការព្រះសាសនាប្រាកដថា ទ្រង់រាប់អានលទ្ធិសៃយ: មានសេនាបតី ១ នាក់ ជាអ្នកសាងទៅស្ថានថ្ងាយសម្រាប់ព្រះមហាក្សត្រិយ៍អង្គនេះ សាងវត្តខាងព្រះពុទ្ធសាសនាសម្រាប់ខ្លួនឯង ។

ព្រះចាន ឧបុស្ការ

ប្រមាណ ព. ស. ១២២៣ - ១២៦៣, ជ. ស. ៦៨០ - ៧២១

ព្រះរាជាអង្គនេះ មិនដឹងជាតាក់ទងមកពីព្រះរាជវង្សណា រៀលដែលទ្រង់សោយរាជ្យនោះ ទ្រង់គង់នៅអនិន្ទ្រិតបុរ: ។ រឿងរ៉ាវទាំងពួងបានសាបសូន្យទៅអស់ ។

ព្រះចាន ឧបុស្ការកាស្យ

ប្រែមាណ ព. ស ១២៦៣ - ១២៧៣, ជ. ស. ៧២០ - ៧៣០

ព្រះរាជាអង្គនេះ ប្រហែលជារាជនុសព្រះបាទឧបុស្ការ: ។ ប្រតិត្តិ

ការណ៍តាំងតួងក្នុងវត្តកាលនេះ ឃានៈលាយសូន្យទៅអស់ដូចក្នុងវត្តកាលព្រះឃោសបុស្ការៈ ។

ព្រះចាន្ទពាលាធិត្យវ័ន្ត

ច្រមាណ ព. ស. ១២៩៣ ឆ.ស. ៧៤០ ៨៤០

ព្រះមហាក្សត្រិយ៍អង្គនេះ ស្តេចគង់នៅក្រុងតន្ទ្រាបុរៈ នៅភូមិមៀន ជិតនគរធំសព្វថ្ងៃនេះ ។ ក្រុងនេះជាក្រុងថ្មី ប្រហែលជាសាងក្នុងវត្តកាលព្រះឃោសពាលាទិត្យវ័ន្តនេះឯង ។

សង្គ្រាមជ្វាគ្រាដំបូង

ក្នុងវត្តកាលនេះមានដំណឹងថា ទ្រង់ធ្វើសង្គ្រាមទឹងជ្វាដែលលុកលុយចូលមក ។

ជ្វាក្នុងវេលានោះ តាំងព្រះរាជធានីនៅស្រីវិជ័យ ក្នុងគោះសូមាត្រាជាអ្នកមានអំណាចពាជសក្តិធំ ឃានរួបរួមយកគោះឆ្ងាយ ។ ក្នុងប៉ែកអាគ្នេយ៍នេះឃានតាំងអស់ ហើយពង្រីកអាណាខែត្តចូលមកដល់ពាក់កណ្តាលដែនមាលយូ គឺមកដល់ទឹងព្រំដែនប្រទេសកម្ពុជា ។ មិនតែប៉ុណ្ណេះមកដល់ក្នុងឆ្នាំ ម. ស. ៧២៣ បុងវត្តកាលព្រះឃោសពាលាទិត្យវ័ន្ត ជ្វាឃានលើកទ័ពតាមផ្លូវដើងទឹកមកវាយប្រទេសកម្ពុជាពីខាងត្បូង រាយលុករហូតដល់ក្រុងតន្ទ្រាបុរៈ ព្រះឃោសពាលាទិត្យវ័ន្ត ទ្រង់ទប់ពុំឃាន ក៏គោងចុះ

ចាញ់ផ្លាហើយទៅកងអំណាចផ្លាកងឆ្នាំ ម. ស. ៧២៣ ដល់កងឆ្នាំ ៧២៤ ។ ផ្លានឹងខ្មែរចម្បាំងគ្នាគ្រានេះជាដំបូង ។

សរុបសេចក្តី

១ – សម័យនគរភ្នំ ជាសម័យដំបូងដែលខ្មែរស្គាបនាត់ស្បែរកាត ខ្លឹងកងដែនដីនេះ សម័យនគរភ្នំកំណត់រាប់ពីឆ្នាំ ៣. ស. ៦៩៣ ដល់ ១៣៤៣ ឆុត រួមប្រមាណ ៦៥០ ឆ្នាំ ។

ព្រះមហាក្សត្រិយ៍ទាំងឡាយកងជាន់ដើម កងសម័យនោះតែងសព្វ ព្រះពជហឫទ័យកងការធ្យាយតន្ត្រីពិណ ពន្លឹកព្រះពជអាណាខេត្តចេញ ទៅ ដោយហេតុនេះ ព្រះពជអាណាចក្រកម្ពុជាកងសម័យនោះ ទើបមានអាណាខេត្តធំទូលាយជាងកងសម័យណាៗទាំងអស់ ដូចមានសំដែងអំពីព្រំប្រទល់ទុកកងរដ្ឋកាល ព្រះចាខេកោណ្ឌញ្ញាជ័យរ៉ែនស្រាប់ តែមកដល់ចុងសម័យនគរភ្នំ ព្រះមហាក្សត្រិយ៍ទាំងឡាយថយព្រះតេជានុភាពចុះដោយលំដាប់ ព្រោះតែដូច្នេះហើយ កងចុងសម័យនគរភ្នំ ទើបមានការបះបោរ ទឹងកើតសង្គ្រាមកងប្រទេសជាញឹកញយ ស្ទើរតែគ្រប់រដ្ឋកាល ព្រះមហាក្សត្រិយ៍នោះ ។ រាល់តែកម្រាបការបះបោរកងប្រទេស មិនមានឧកាសទឹងពន្លឹកព្រះពជអាណាខេត្តចេញទៅដូចរដ្ឋកាលមុន ។ ព្រះពជអាណាខេត្តទើបមិនបានតែធំទូលាយចេញទៅទៀត កុំថាឡើយដល់ទៅពន្លឹកចេញទៅទៀត សូម្បីតែស្រុកចំណុះដែលធ្លាប់

មានមកស្រាប់ហើយ ក៏មិនអាចនឹងគ្រប់គ្រងរក្សាឲ្យគង់នៅបាន ចាម្ប៉ានឹងមនបានរបូតផុតទៅអំពីកណ្តាប់ដៃខ្មែរកងពុងសម័យនគរកុំនេះ មិនត្រឹមតែប៉ុណ្ណោះ លុះមកដល់ពុងត្រោយបំផុត ប្រទេសកម្ពុជាបានធ្លាក់ទៅជាចំណុះផ្លា ១ ពេល ដូចមានឆ្កាកដក្នុងប្រវត្តិសាស្ត្រកងរដ្ឋកាល ព្រះបាទតាលាទិត្យវរ្ម័ននោះស្រាប់ ។

. ២ – ព្រះមហាក្សត្រិយ៍តាំងឡាយ ក្នុងសម័យនគរកុំច្រើនសព្វ ព្រះរាជហឫទ័យផ្លាស់ព្រះរាជធានីចេញពីព្រះរាជធានីចាស់ ទៅសាងព្រះរាជធានីថ្មីៗទៀត ជាច្រើនអន្លើរដោយហេតុនេះ ព្រះរាជធានីក្នុងសម័យនោះ ទើបមានចំនួនច្រើន ដូចមានរាយឈ្មោះតទៅនេះ

១ – នគរកុំ ជាបឋមនគរ

២ – នគរវ្យាឆបុរៈ

៣ – នគរបុរី ឬនគរអធិបតី

៤ – នគរស្រីសូរបុរៈ

៥ – នគរកវិបុរៈ

៦ – នគរសម្ភុបុរៈ

៧ – នគរគ្លៀសាណបុរៈ

៨ – នគរអនិន្ទិតបុរៈ

៩ – នគរតន្ទ្រីបុរៈ ។ នគរតន្ទ្រីបុរៈនេះហើយដែលកង

ព្រះពាជពង្សាវតារក្រុងកម្ពុជាហៅថា "ឥន្ទបត្ថបុរី" ។ ក្នុងព្រះពាជ-ពង្សាវតារច្បាប់ដដែលនេះថា ព្រះមហាក្សត្រីយ៍ខ្មែរអង្គអាទិពជ គឺព្រះ ថោង ទ្រង់សាងក្រុងនគរធំ ជាដំបូង ដោយមានពួកនាគមកជួយសាង ផងនោះខុសស្រឡះ អ្នកសិក្សាប្រវត្តិសាស្ត្រមិនត្រូវជឿតាន់យកជា ប្រមាណ ។

៣) ការសាងចុង្កុ-ចុង្កាទក្នុងសម័យនគរកុំ មានចំនួនតិច ហើយ ចុង្កុ-ចុង្កាទក្នុងសម័យនោះ មានសាងតែដោយឥដ្ឋ មានថ្មប្រកប ខ្នុះបន្តិចបន្តួច ចំពោះតែដំមេគ្វារ-មេបង្អួចប៉ុណ្ណោះ ។ ចុង្កុ-ចុង្កាទ ក្នុងសម័យនោះ ឃាត់បែកអស់ហើយ នឹងយកចុង្កុ-ចុង្កាទណាមួយ មកបង្ហាញឲ្យឃើញជាក់ស្តែងក្នុងវេលានេះពុំបាន សុំឲ្យអ្នកសិក្សាពិនិត្យ មើលដំណែលចុង្កុ-ចុង្កាទ ដែលមាននៅនគរបុរីជាដើមនោះចុះ ។ សិលាចារឹកក្នុងសម័យនោះក៏មានចំនួនតិច ចារឹកជាភាសាខ្មែរ មានតែក្នុង រជ្ជកាលព្រះជ័យវរ្ម័ន ក្រៅពីនេះ ច្រើនតែជាភាសាសំស្ក្រឹត ។

៤) ការសាសនា : ក្នុងសម័យនគរកុំ សាសនាក្នុងប្រទេស មាន ២ យ៉ាង គឺ សាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈ (ហីនយាន) តែប៉ុណ្ណោះ ព្រះពុទ្ធសាសនាលទ្ធិមហាយាន ពុំទាន់ ផ្សាយមកដល់នៅឡើយ ។ ក្នុងសាសនាព្រាហ្មណ៍នោះ គេរាប់អាន ព្រះហរិហរៈធ្ងន់ជាងព្រះដទៃគាំងអស់ ដូចមានរូបព្រះហរិហរៈក្នុងសម័យ

នោះ នៅសល់ជាតំស្កុតាង់ជាបដល់បច្ចុប្បន្ននេះ ។ ចំណែកឯទេពាវក្យ (អ្នកគា) គេកាប់ព្រះកាឡីជាធំសំខាន់ជាងគេបង្អស់ ។

៥) ព្រះមហាក្សត្រិយ៍តាំងឡាយក្នុងសម័យនគរកុំពង់ជាន់ដើមទង់ធ្លាតក្នុងផ្លូវរដ្ឋបាលនោះជាយជាបំផុត គឺទង់ប្រសប់ក្នុងការសម្រុះសម្រួលប្រជាជនរវាងជាតិខ្មែរ ទឹងជាតិជ្វា - ជាតិលាវ ឲ្យរួបរួមទៅជាជាតិតែ ១, ជាតិជ្វាទឹងលាវមិនដែលមានខ្វែកបះបោរតស៊ូទឹងព្រះចេស្តាជារមដល់ម្តងសោះ មានក្បត់ផែនដីខ្លះ តែក្នុងពួកព្រះរាជវង្សខ្មែរ ឬអ្នកដែលតាក់តាមដោយពួកនេះ. ដោយអំណាចលោកចេតនាចង់បានមកុដរាជ្យប៉ុណ្ណោះ ។

ព្រះរាជពង្សាវតារសម័យនគរភ្នំចប់ចុះតែត្រឹមប៉ុណ្ណេះ ។

របស់នាងនេត្រ – ឡាំងសី

ខេត្តកូម៉ិចឹងកេងកង ឃុំលេខ ១ ក្រុងភ្នំពេញ

រង្វាន់លេខ ១

(៣ - ចប់)

ដែលគេចោះត្រង់ក្អេងឲ្យមានប្រហោងប៉ុនម្រាមដៃ ហើយដងទឹកទៅស្រោចឲ្យហូរតាមចំណោះកូនក្អមនោះពេញ។ រណ្តៅកូនថ្នាំ ។ ពេលដាំកូនថ្នាំ គេមិនដែលដាំព្រឹកទេ គេដាំតែក្នុងពេលរសៀល ដើម្បីកុំឲ្យស្ងោកកូនថ្នាំ ដាំហើយគេស្រោចទឹកព្រឹកល្ងាច ២–៣ ថ្ងៃទើបឈប់ បណ្តោយឲ្យវាជុះតាមទឹកសន្សើម ទំរាំចំហាយព្រះអាទិត្យ ។ កូនថ្នាំនោះវាសន្ធប់ក្នុងវេលាថ្ងៃ ស្រស់ប្រៃប្រក្នុងវេលាយប់ ហើយក៏ជុះធំថ្ងៅសឡើងតាមលំដាប់ គេដាំក្នុង ១ រណ្តៅ ១ ដើម បើមានងាប់រណ្តៅណាគេជួសវិញ ។ ក្នុងចម្ការមួយៗ គេដាំច្រើនម៉ឺនដើម ។

តាមធម្មតាអ្នកធ្វើរបរថ្នាំ កាលគេដាំកូនថ្នាំហើយភ្លាមគេតែងធ្វើតដាំត្រសក់ស្រូវ ត្រសក់ផ្អូរ ឪឡឹក រពៅ តាមចន្លោះជួរកូនថ្នាំផង ។

៤ – ជ្រុជី

ដោយអំណាចដីកោះមានល្បាប់ល្អ ហើយពេលនោះជារដូវមានអាកាសត្រជាក់ កូនថ្នាំរហ័សជុះលូតលាស់ឡើងតាមលំដាប់ មិនយូរ

ប៉ុន្មានគ្រឹម ១ ខែមានកំពស់លិចមាន់ ។ តាមទំនៀមអ្នកឆ្នើចម្ការច្នាំ គាំងពីពេលដាំកូនច្នាំដំបូង រហូតដល់កូនច្នាំពេញដំទង់ បើមានស្បូវ-គ្រាសប្តូនគ្រាស គេតែងយកស្លឹកខ្ចីមួយ ១ មែក ដោតត្រង់ក្បាលចម្ការ កណ្តាលចម្ការ ទីងចុងចម្ការ ដោយគេជឿជាក់ថា គ្រាសកន្ធង់កូនច្នាំពុំបាន ។ កាលកូនច្នាំមានកំពស់ត្រាមដង្កង់ គេតែងដំរេះស្មៅជុំដីជាំនគល់រាល់ដើមដោយចបតាប់ ។ គាំងពីពេលជុំដីជាំនគល់មក កូនច្នាំល្អណាស់ ខ្ពស់រហ័សមានសន្លឹកធំៗ ទទឹង ១ ចំអាម បណ្តោយ ១ ចំអាម កន្លះ ក្នុង ១ ដើមៗ មាន ៩ ឬ ១០ សន្លឹក ។

៥ – កិច្ចត្រួយក្រៀវខ្នែង

កាលកូនច្នាំនោះធំខ្ពស់ដូចគោលហើយ ពេលនោះជាពេលត្រូវក្តិចត្រួយ ដើម្បីឲ្យដើមច្នាំមានស្លឹកត្រាស់ធំ ទឹងបង្ខន់ដ៏រឹងស្លឹកកុំឲ្យមានវិសជាតិស្លីងពេក ច្នាំនោះកាលដំអស់ទំហំ មានដើមប៉ុនកដៃក្មេង កំពស់ពាក់កណ្តាលខ្នងមនុស្សចាស់ក៏មាន គ្រឹមកឬលិចក្បាលក៏មាន (ត្រង់នេះចាប់ដើមមានគូរបូដើមច្នាំផង) កាលគេក្តិចត្រួយហើយ មានដុះខ្នែងតាមគល់សន្លឹក កាលដុះខ្នែងឡើងប្រវែង ២ – ៣ ឆ្នាប់ គេក្រៀវខ្នែងនោះចេញ ។ កិច្ចក្រៀវខ្នែង គេក្រៀវរឿយៗ ក្នុងច្នាំ ១ ដើមយ៉ាងយូរគ្រឹម ៧ – ៨ ថ្ងៃគេក្រៀវម្តងវិញរហូតដល់ពេលបេះស្លឹកអស់ទើបឈប់ ។

៦- ការបស្ចឹកនិងរៀបស្ចឹក

ចុងខែមាយឬដើមខែឧសភា (មិនា - មីរ៉ា) គេតែងបេះស្ចឹកគ្រាមៗ ហៅថារះដើង ។ ស្ចឹកថ្នាំមាន ៣ ថ្នាក់គឺ ៣ សន្ទឹក គ្រាមបន្ទះហៅថា ថ្នាំដើង ៤ - ៥ សន្ទឹកកណ្តាលហៅថា ថ្នាំចង្អេះ ៣ សន្ទឹកចុងបំផុត ហៅថាថ្នាំចុងសន្ទឹក ។ ថ្នាំដើងជាថ្នាំខ្សោយមិនសូវឆ្ងាញ ថ្នាំចង្អេះ ខ្លាំងសមគួរ ថ្នាំចុងសន្ទឹកខ្លាំងជាបំផុត ហើយឆ្ងាញ់ជាងគេ ។ កាលបេះស្ចឹកថ្នាក់ណា គេពិនិត្យមើល បើឃើញថាចាស់ខ្លីងគ្រហមខ្លាច ។ ទាល់ចន្លងសន្ទឹកទើបគេបេះ ២ - ៣ សន្ទឹកក្នុង ១ ដើម ដាក់កន្ងជាលដែលត្បាញពីចម្រៀកឫស្សី មានកំពស់និងដម្រៀជាង ១ ហត្ថ ទំហំមាត់ជិត ២ ហត្ថកាន់មូល (ត្រង់នេះច្បាប់ដើមមានគូរបូជាលផង) ញាត់ពេញហើយគេចូលនឹងក្បាលយកទៅផ្ទះ ឬទៅរោងហាន់ថ្នាំ អ្នកណាមានរនេះគោ គេបេះស្ចឹកថ្នាំដាក់រនេះទឹមគោ (ត្រង់នេះច្បាប់ដើមមានគូរបូបរនេះគោផង) យកទៅផ្ទះ ឬទៅរោងកិមាន ។ កាលបានស្ចឹកថ្នាំទៅដល់រោងហើយគេរៀបសន្ទឹកថ្នាំតាជាត្រួបក ។ ដូចត្រួបកម្ម មួយត្រួបកចំនួន ១០ ឬជាង ១០ សន្ទឹក ហើយគេបត់ចុងសន្ទឹកដាក់តម្រៀបទុកបន្តុំ ។

៧ - បន្តុំ

កាលគេរៀបស្ចឹកថ្នាំរួចហើយ គេជញ្ជូនយកទៅបន្តុំក្នុងដង្រែកដែលមានទីបិទបាំងក្នុងរោងឬគ្រាមផ្ទះ ទំហំដង្រែកបណ្តោយ ៥-៦ហត្ថ ទទឹង

៣ - ៤ ហត្ថ ដម្រៃ១ហត្ថ បិទបាំងដោយស្លឹកស្មោត ឬស្លឹកត្រែង ត្រាលកន្ទេលបបុះ ឬស្លឹកត្រែងពីខាងក្រោម ហើយរៀបដាក់តុបកថ្នាំ មានគល់ចុះក្រោមជាជួរ ។ ក្នុង ១ ជួរជាង ១០ តុបក តុបកន្ទេលបបុះពីលើឲ្យហប់ យ៉ាងយូរត្រឹម ៣ - ៤ យប់ ស្លឹកថ្នាំក៏ទុំពេញភាំងជង្រុក មានសម្បុរលឿងទុំស្រស់ល្អ ។

៨ - ហាន់

កាលសន្ទឹកថ្នាំទុំស្រុះល្អហើយ គេផញ្ជួនចេញពីជង្រុកយកមកសក ទង តែប់សន្ទឹកចេញ ហើយយកទៅហាន់ដោយគ្រឿងប្រដាប់អម្បាលនេះគឺ :

ក) - ផ្ទាំឈើ មានមេបញ្ឈរកំពស់ ១ ហត្ថ ១ បំអាម គេចោះប្រហោងកណ្តាលជាវង្វង់រាងពងក្រពើ ទំហំដិត ១ ខាម មានទូកសណ្តកពីលើភ្ជាប់នឹងមេបញ្ឈរ គល់ទូកគេលកឲ្យមានសណ្ឋានក្បាច់រាងស្រទបចេក ផ្នូរងបុងដូចជារាងទូកង មានចន្ទល់ភ្ជាប់ពីទូកទៅនាប់ខាងក្រោម នាប់មានបណ្តោយ ១ ហត្ថ ១ បំអាម បន្ទា ៨ ធ្នាប់ គោល ៣ ធ្នាប់ ឆ្កែពីក្រោមទូក គេហៅថាផ្ទាំថ្នាំ ។ (ច្បាប់ដើមមានគូរូបផ្ទាំផង) ។

ខ) កាំបិតដែក មានមុខធំស្តើងរាងទូងបន្តិច ត្រាស់តែខ្នុងខ្នងបណ្តោយផ្នែក ១ បំអាមកន្លះ ទទឹងគល់ផ្នែក ៧ ធ្នាប់ បុង ៥ ធ្នាប់ មៀនដែក

ប្រវែង ៣ ធ្នាប់ ដងឈើប្តឹតធំពង់ប៉ុនកដៃក្មេង បណ្តោយ ៥ ធ្នាប់ ។ (ច្បាប់ដើមមានគូរូបកាំបិតធង) ។

គ) ឈើសង្កត ធ្វើពីឈើរលួសមានសាច់ទន់ ប្រវែង ១ ហត្ថ ១ ចំអាម ទំហំប៉ុនកំភួនដៃ តួ ៤ ជ្រុង ចុងមូលសម្រាប់សង្កតកាំបិតហាន់ថ្នាំ ។ (ច្បាប់ដើមមានគូរូបឈើសង្កតធង) ។

ឃ) ថ្ម គេរកថ្មគ្រាតប្រវែង ១ ត្រក់ ទោល ៤ ធ្នាប់ បន្ទាប់ ៥ - ៦ ធ្នាប់ ៤ ជ្រុងទ្រវែង សម្រាប់សំលៀងកាំបិតហាន់ថ្នាំ ។ (ច្បាប់ដើមមានគូរូបថ្មសំលៀងធង) ។

ង) កន្ទេលប្តឹថែប ត្បាញពីដើមបបុះ បណ្តោយ ៤ ហត្ថ ទទឹង ២ ហត្ថ ១ ចំអាម ។

របៀបហាន់ គឺគេមូរទេទំងស្លឹកថ្នាំដែលសុកហើយ ២ - ៣ ត្រុបកឲ្យណែនក្តន់ សឹកបញ្ចូលតាមបណ្តោយទូកជ្រញ់ទៅក្នុងរន្ធង់ឲ្យលៀនចេញបន្តិច ទើបគេអង្គុយទាងស្តាំជ្រញ់ ដៃទ្វេរុញរមូរថ្នាំ ដៃស្តាំកាន់កាំបិតហាន់ ។

៩. - ហាល

របរថ្នាំ មានកិច្ច ២ យ៉ាង ដែលផ្ទាស់ប្តូរគ្នាពុំបាន គឺប្រុសជាអ្នកហាន់ ស្រីជាអ្នកហាល ប្រុសហាន់បាន ១ ជ្រញ់ ស្រីតើបគំនរសរសៃថ្នាំនៅមុខជ្រញ់របស់ប្រុសយកទៅហាលលើកន្ទេលប្តឹថែប ។ របៀប

ហាលគឺ គេអង្ករយកានំដុំសរសៃថ្មាំដោយដៃស្តាំ អូសពីឆ្វេងទៅស្តាំ ធ្វើសរសៃថ្មាំឲ្យស្តើងស្មើគ្នាពេញតាំងកន្ទេល ។ គេហាលកង់មួយ ហើយគេសែងទៅហាលថ្ងៃ ១ ថ្ងៃទាល់ល្ងាច ។

១០— យកសន្សឹម

ថ្មាំដែលហាន់ហើយ គេតែងហាលថ្ងៃ ៣ ថ្ងៃ ហាលសន្សឹម ៣ យប់ ឲ្យមានសម្បុរក្រហមខុំណ្ឌ ដល់ថ្ងៃទី ៣ គេហាលថ្ងៃឲ្យស្ងួតស្រួយទើបគេកាត់បណ្តាយសរសៃថ្មាំទៅលើកន្ទេល ដោយដែកកាត់ធ្វើពីដែកធំត្រមានចុងសំប៉ែតមុខស្រួច ។ ប្រវែងជាង ១ ចំអាម មានមេទំង ២ ចោះរន្ធស៊ីកដែកធំត្រចំនួន ៥ ឬ ៦ ពត់ឲ្យចុងបន្តិច ស៊ីកទៅកង់មេឃ្លាតពីគ្នា ៥ ឆ្នាប់ មានដងឈើប្រវែង ២ ហត្ថ ១ ចំអាម (ត្រង់នេះច្បាប់ដើមមានគូរូបប្រដាប់សម្រាប់កាត់ថ្មាំផង) កាត់ហើយគេតម្រួតទុកដល់វេលាយប់ទើបគេដញ្ជូនទៅកយយកសន្សឹមឲ្យដៅកល្អ ហើយគេតម្រួតទុកនៅក្រោមផ្ទះប្លុកង់ពេលបម្រុងនឹងបត់ដាហ្វាញដាចេ៉ ឬ ដាក្រតើតទៅ ។

ខំនៀមអ្នកធ្វើថ្មាំនៅកោះរណ្តៅតូច ស្រុកកង់មាស កំពង់ចាម សម័យបុរាណ គេហាន់ ១ លើកហាលថ្ងៃ ៣ ថ្ងៃ ហាលសន្សឹម ៣ យប់ ហើយបត់ដាចេ៉ដាហ្វាញ់ឬក្រតើ ១ លើក។ តាមលំដាប់ហាន់ ដល់ហាន់អស់ពីចម្ការក៏ស្រេចតែម្តង ។

សម័យបច្ចុប្បន្ននេះ គេហាន់ ១ ថ្ងៃ ហាលតែ ១ ថ្ងៃ យកសន្សើម តែកន្ទុះយប់ ហើយគេចាក់គរទុកតែសាច់ច្នាំទេ ដោយយកស្លឹកត្រែង ១ណ្ឌ ១ សើៗ តម្រែតលើគ្នាជាគំនរធំខ្ពស់ លុះហាន់អស់ពីចម្ការកាលណា ទើបគេរើយកមកហាលថ្ងៃហាលសន្សើម ១ យប់ទៀត ហើយហាលថ្ងៃកាត់ជាក់សន្សើម ធ្វើជាចៀវឬត្រតើជាខាងក្រៅយសរុបគ្នាតែម្តង ។

១១ - បត់ជាបាញ់ឬចៀ

កាលគេយកច្នាំទៅលើកន្ទេល ដែលគេកាត់រួចទៅជាក់យកសន្សើមឲ្យមានសាច់ខន់ល្មមសមគួរហើយ គេតម្រែតទុកជាគំនរ ទើបគេយកសំពត់ ១ ផ្ទាំងធំហៅថា "សំពត់ជាន់ច្នាំ" មកគ្រលាសពីលើសាច់ច្នាំជាន់ដញ្ជាំឲ្យហាប់ស្អ ហើយទើបគេបត់ ។ របៀបបត់ គេត្រឡប់រឹមសរសៃច្នាំចាំងសងខាង ម្ខាងប៉ុនកូនដៃតាមជួរដែលគេកាត់ប៉ុន ៥ ធ្នាប់ ទទឹងកន្ទេលនោះបត់ឲ្យទៅជាមានបន្ទាទទឹង ៣ ធ្នាប់ បណ្តោយប្រវែងកន្ទេលច្នាំ ហើយគេបត់បណ្តោយឲ្យខ្ទីទៅទៀត ទៅតែប្រវែង ១ គក់ រួចគេជាន់បង្ហាប់ យ៉ាងនេះហៅថា "បត់ជាបាញ់ឬជាត្រតើ" ។ ម្យ៉ាងទៀតកាលដែលកាត់នោះ គេកាត់ទទឹងកន្ទេលផងបណ្តោយផង ប្រវែង ១ ទោម ៤ ជ្រុង ដល់ពេលបត់គេជាន់ឲ្យហាប់ដូចគ្នា ហើយគេបត់ត្រឡប់រឹមដុំវិញឲ្យខ្ទីបណ្តោយ ៤ ធ្នាប់ ទទឹងខាងធំ ៣ ធ្នាប់ ខាងតូច ១ ធ្នាប់យ៉ាងនេះហៅថា "បត់ជាចៀវឬជាដុំ" ហើយគេគរទុក ។

១២ – រៀបពូក ឬដាក់ដាល

ថ្នាំដែលគេបត់ជាប្រាក់ ឬជាក្រតើហើយ គេតែងរៀបជាពូក គឺរៀបដោយពុម្ពឈើដែលមានក្តារ ៤ ផ្ទាំង កំពស់ ១ ហត្ថ ១ ចំអាម ៤ ហំ ១ គក់ភ្ជាប់ជា ៤ ជ្រុង ចោះកន្ទាស់ភ្ជាប់ ប្រមុំជ្រុងគ្នា ៣ ផ្ទាំង ខុក ១ ផ្ទាំង ឲ្យមានគន្លឹះដកចេញចូលបាន (ត្រង់នេះច្បាប់ដើមមានគូរូបពុម្ពឈើ ៤ ជ្រុងផង) រៀលរៀបថ្នាំគេយកក្តារ ១ បន្ទះគាប់ពីក្រោម ហើយគេអង្កុយលើដើមម៉ាឈើ ឬកៅអី ហើយយកក្រតើថ្នាំរៀប ១ ម្តង។ បាន ៤ - ៥ សេះ គេយកក្តារ ១ បន្ទះ ៤ ជ្រុងប៉ុនពុម្ព កម្រាស់ប៉ុនម្រាមដៃ សង្កត់ពីលើ ហើយជាន់បង្ហាប់ម្តង ដរាបដល់ពេញពុម្ពទើបគេដកគន្លឹះហូតពុម្ពចេញ នៅតែថ្នាំនេះ បាន ១ លើកគេហៅថា ១ ពូក ឬ ១ តុប ។ ក្នុង ១ ពូក។ មានទម្ងន់ចំនួនពី ១៥ ទៅ ២០ គីឡូក្រាម លុះដកពុម្ពចេញហើយគេយកស្លឹកឆ្លាល់ ២ សន្លឹក ចងតាមបណ្តោយពូកថ្នាំនោះ ២ អន្លើ ហើយរៀបត្រៀបចំថ្នាំងខុកទៅ (ត្រង់នេះច្បាប់ដើមមានគូរូបរបៀបពូកចងថ្នាំផង) ។ ថ្នាំដែលគេបត់ជាចៅ ឬជាដុំ គេដាក់តម្រៀបក្នុងជាលត្បាញពីប្រឹស្សី ទំហំទទឹងជម្រៅ ១ ហត្ថ ១ ចំអាម ៤ ជ្រុង (ត្រង់នេះច្បាប់ដើមមានគូរូបជាលសម្រាប់រៀបថ្នាំផង) បានមួយលើក។ គេហៅ ១ ជាល ក្នុង ១ ជាល។ មានទម្ងន់ដល់រយគីឡូក្រាមក៏មាន ។ កាលរៀបពូកឬ

ជាក់ជាលបានច្រើនហើយ បើមានឈ្មួញមកឲ្យថ្លៃត្រូវចិត្តគេក៏លក់តាមត្រូវការ ។ ក្នុងឆ្នាំ ១៩៤៨ ថ្នាំខ្មន់ ១០០ គីឡូដំឡៃជាង ១.០០០ រៀល ។

អំពីសេបក្តីសប្បាយ

របរថ្នាំកូង ១ ដូវមានពេលសប្បាយ ២ លើក គឺនៅពេលស្លឹកកូនថ្នាំម្តង ពេលហាន់បានស្រែចជាច្រើនហើយម្តង ដោយពេលស្លឹងដែលកូនថ្នាំលូមដកយកទៅដាំ អ្នកដាំថ្នាំដែលគេមិនបានសាបស្លឹង គេយកម្ហូបចំណីនឹងផ្លែឈើច្រើនមុខមកដូរកូនថ្នាំយកទៅដាំ ។ ពេលហាន់អ្នកខ្ទេចអ្នកស្រែដែលមិនធ្វើថ្នាំ គេយកម្ហូបចំណីនឹងផ្លែឈើច្រើនមុខមកដូរថ្នាំ ។ នៅពេលនោះអ្នកធ្វើរបរថ្នាំសម្បូរម្ហូបចំណីប្រហែលផ្សារ ។

សេចក្តីបញ្ជាក់

របរថ្នាំ តាំងពីពេលសាបស្លឹង រហូតដល់ពេលហាន់ គេគ្រាន់តែមើលប្រក្សាថ្លៃ នឹងរៀបសំណែន គឺស្ទាធមិនឹងទៀងធ្លុប នៅពេលដែលផ្តើមសាបនឹងផ្តើមដាំកូនថ្នាំ ដូចពោលហើយកន្លងថ្ងាក់ទី ១ នឹងទី ៣ ប៉ុណ្ណោះ ឯត្រណមនឹងរឿងត្រែងគ្មានទេ ។

ប្រភេទជន

ថ្នាំជាកេសជ្ជៈមួយ៉ាង ដែលប្រជាជនគ្រប់ប្រទេសត្រូវការបរិភោគស្ទើរតែគ្រប់គ្នាជារឿយៗ ។ ថ្នាំតាមទំនើងក៏ជារបស់ទុកមិនសូវបាន

ឃ្លេខ តាំងពីហាន់ចាន់ជាសាច់ថ្មាំហើយ ខុកចាន់តែត្រឹមជាង ១ ឆ្នាំឡើង
ទៅ ក៏មានដង្កូវប្លុបយស៊ី បើខុកដល់ ២-៣ ឆ្នាំទំនងខូច ប្រើការបរិភោគ
ពុំបាន ប៉ុន្តែអាចធ្វើជាជីជាក់ដំណាំម្រេចតទៅទៀតបាន ដែលជាការ
ងារបស់អ្នកស្រុកកំពត ។

ឈ្មោះអ្នកតែង

នាង នេត - ឡាំសី នៅភូមិបឹងកេងកង - ឃុំលេខ ៦ ក្រុងកំពង់ចាម
តែងដោយចាន់សូរបញ្ជាក់ឈ្មោះ អ៊ុក - ឡុង ជាបងថ្លៃ នៅភូមិអន្ទង់ស
ឃុំតាមដឹកង ស្រុកកងមាស ខេត្តកំពង់ចាម ដែលជាអ្នកធ្លាប់ធ្វើបរ
ច្នាំយ៉ាងស្ទាត់ជំនាញ ។

នាង នេត - ឡាំង សី

សុភាសិត ភាគទី ១

លោក ព័យ - ប៊ុក រៀបរៀង (៣-ចប់)

ឥត្ថីវគ្គ (៣)

៥៨ – អ្នកមានទ្រព្យច្រើនមិនចេះចាយ កំរិយានៃបកាយមិនស្នេហ៍ស្និទ្ធ ធ្វើការក្រែងក្រែមមិនពេញចិត្ត តុះតេះតូចអស់ផ្លូវដើរ ។

៥៩ – កំរិយាមួយសុខស្រួលកាយចិត្ត កំរិយាពីរពិតជូចដេរដុំ កំរិយាបីដូចភ្លើងឆេះភ្នំ កំរិយាបួនសមអ៊ីចិ ។

៦០ – ទ្រព្យធនមាសប្រាក់ផ៉ាយរក្សា ជាតិស្រីកញ្ញាលំបាកថែ ចិត្តនៅយ្រេងយ្រោងយប់ថ្ងៃប្រែ គំនិតគេចកែមិនអាចស្គាល់ ។

៦១ – កុំឲ្យខុកចិត្តមិត្តយូរគាល ពួកសន្តិបាលមហាពាជ ទាំងស្រីគ្រហាក្រៃមអំណាច នេះពាក្យអ្នកប្រាជ្ញប្រដៅខុក ។

បកិណ្ណកវគ្គ

១ – អ្នកធំកុំប្រមាទអ្នកតូច ស្មៅវល្លិ៍រេញកូចចង់ដំរី ស្តេចពឹងក្រស្តេសង្ឃវិន័យ មច្ឆាជលស័យពឹងទឹក ។

២ – ធ្លៅស្រែលើខ្លួល សាកសួរទំនួល មនុស្សល្ងង់ល្ងិតយប់ទំពឹងអសប្បុរស ប៉ានខ្លួនោសសព្វ បណ្ឌិតសេពគប់ ប៉ានសុខសួស្តី ។

៣ – ខ្លួនតមាសប្រាក់ចង់តក្តី ចង់ប៉ានសេរីតវ៉ាសនា ឥតអាវុធមុតចង់ពុះពារ ខ្លួនជិតមរណារកពុទ្ធោ ។

៤ – គេមិនត្រូវការ តាំងចូលអាត្មា មើលការខុសត្រូវ ត្រួតត្រាឯកឯង សុខស្រួលគ្រប់ផ្លូវ បើគេមិនហៅ ខ្លួនឯងមិនគួរ ។

៥ – បើចុះធ្វើការធ្វើឲ្យអស់ចិត្ត ចាញ់ឈ្នះដាក់ពិតទើបពេញអង្គប្រុស បើដាបពាយ៉ាចាញ់គេចុះ ឲ្យតែប្រឹងពុះពារគង់ឈ្នះការ ។

៦ – រុក្ខជាតិឫសធំចាក់មាំជ្រៅ ខ្យល់ព្យុះសំឡេងមិនឈ្នះការ ពូជស្មៅដើងត្រាសដាប់បន្លា មុតរូបអាត្មាវង់ខ្លួនធំ ។

៧ – ត្រូវយកដើមត្រែងជាច្បាប់ប្រាណ រាយោបក់ចានមិនរលំ រុក្ខជាតិមានយ៉ាងធ្លឹកសុក្រឹ ខ្យល់ធំបក់ចំគង់រលើង ។

៨ – ផ្ទះមានឆ្កែកាចគេខ្លាចក្រែង ប្រទេសគេស្រឡាញ់មានបុរសៈវគ៌ ផ្លូវមានបន្លាខ្វាស់ខ្នុត អ្នកដើរវាមត់មិនប្រមាទ ។

៩ – ចូលក្នុងសាលា កូនចៅខេមរា ត្រូវខំរៀនសូត្រ ក្មេងចាស់ក៏រៀន ស្តាប់មន្ត្រីសោត ប្រឹងរៀនកុំខ្ជោត តាំងប្រុសតាំងស្រី ។

១០ – តារាសាស្ត្រមិនអាចស្គាល់ផ្កាយអស់ ភូមិសាស្ត្រស្មោះមិនស្គាល់ភូមិភាគ ប្រវត្តិសាស្ត្រមិនស្គាល់ស្តេចសព្វគ្រប់ ចេះផ្លូវលោកសព្វធម៌មិនយល់ ។

១១ – សេពគប់បណ្ឌិតដូចចន្ទន៍ក្រឹស្នា ក្រអូបអាត្មាក្លិនឈ្ងុយឈ្ងប់ ដូចជាតិស្ករវង្គមធ្វើនំសព្វ រសជាតិប្រៃឆ្ងាញ់ពិសា ។

១២ — សេពគប់ជនពាលដូចមច្ឆាស្អុយ ចេញចំហាយហុយ
ស្អុយស្អឹកខ្ពប់ អ្នកផងមិនត្រូវបួលសេពគប់ វៃគ្រង់អប់ក្លិនអសោចិ៍
ស្រោចអាត្មា ។

១៣ — វៃត្រលោកជាប្រទីបវៃត្រលក្ខណ៍ ជាតិភ្លឺច្បាស់ជាក់ផ្លូវ
សាសនា សាងជាតិឲ្យមើលអតីតា អង្គរវេមភមហាអំណាច ។

១៤ — វិទ្យាសាស្ត្រសេដ្ឋកិច្ចប្រៃលោកា ប្រៃជាតិមនុស្សាទស្សា-
ហកម្ម គ្រឿងយន្តបរមាណូប្រៃខ្លីបង្ហាំ នយោបាយមេនាំប្រៃស៊ីវិល្យ័យ ។

១៥ — សង្ឃារបង្កើតសង្កើចជិតមនុស្ស នៅកងសាច់ស្នោះមាន
ដង្កូវ មានជាតិគ្រានៅកងដើមស្រូវ នៅតាមវៃផ្លូវមានបន្ទូ ។

១៦ — បួសកងសាសនាលះបង់ទ្រព្យ កូនប្រពន្ធសត្វគេហដ្ឋាន
បួសកងជាតិត្រូវបួរអង្គប្រាណ ធ្វើចិត្តក្លាហានកុំខ្លាចស្ងាប់ ។

១៧ — ជាតិជាកូនប្រុស ធ្វើតាហានស្មោះ និត្យាលើតួក
ធីប្រាយក្រហម ដួយជាតិគោកធ្លក លីប្រាវសាងលោក ស្ងាប់ក្រោមទង់ជ័យ ។

១៨ — ពេលមានតិចតួចស្លូចស្លើងពិត ប្រុសស្រីគួរគិតកសាង
ជាតិ ឲ្យបានរឹងរឿងទើបហៅឆ្នាត សង្ឃាតសាងលោកឲ្យក្សេមក្សាន្ត ។

១៩ — កវែប្រទៅជិតគុម្ពខ្ពស់ មិនស្គាល់ជាតិឈូកក្លិនគន្ធា
កន្ទុងនៅឆ្ងាយត្រែចត្រង់ផ្កា ជញ្ជាប់រសាកេសរបាន ។

២០— កុំដួសចុះយកក្តាំងបណ្តេញក្ងែរ ចុះយប្រចៀវគ្រាប់ឬរ
ស្រីស្អាតមិនស្មើនឹងស្រីល្អ ជាតិអ្នកគ្រូតធ្មេងមានតាអាំង ។

២១— ព្រឹក្សាឥតបុប្ផាមិនសោភ័ណ នគរវៃគ្មនិច្ចឥតនារី
គ្រឹហាឥតក្មេងមិនសោភី ភរិឥតមច្ចាមិនសោភា ។

២២— ធ្វើសុមយាចក ចោកតាបអាក្រក់ កុងនាលោកិយ
ក្រៃព្យសម្បត្តិ មារយោធសោភ័ ខុកជាប្រុសស្រី ពាប់មុខខុកចិត្ត ។

២៣— ធម្មតារុក្ខជាតិដុះកងធើង ចង់ចានរុងរឿងដូចឈើព្រៃ
មនុស្សចោកតាបលង់ចង្រៃ ប្លាប្លាចង់ថ្ងៃដូចម្តេចកើត ។

២៤— ធម្មតាជាតិដែបញ្ចើក្អែក ខំលើឱើរមែកឈើព្រឹក្សព្រៃ
ជញ្ជប់យកវសឥតប្រណី តាលតែកូណែកូយវិនាសបង់ ។

២៥— មនុស្សមានប្លាជ្ញា មានតូជសោភា វិជ្ជាចំណេះ មារ-
យាទគួរគួម សមចិត្តវិសេស ធ្វើការមិនធ្វេស កេរ្តិ៍ឈ្មោះល្អល្បី ។

២៦— បច្ចុប្បន្នសម័យមានពេងចក្រ ពេងយន្តតាមថ្នាក់វិទ្យា-
សាស្ត្រ អាកាសយានគ្រប់បែបប្លាជ្ញធ្វើឈ្វាស គ្រប់សាស្ត្រសុីវិល័យ
ទៅតាមកាល ។

២៧— ចោរព្រៃហ៊ានដោយសារចោរស្រុក ខ្មោចក្រៅលុយ
លុកខ្មោចកងញាំង មហាប្រទេសមិនហ៊ានចូលចម្បាំង បើមិនមាន
ខ្មាំងពួកចិត្តក្បត់ ។

๒๘ – មាតុកូមិដូចបុរុក្ខជាតិធំ មានមូលត្រសុំសាយត្រជាក់ មានបុសចាក់ជ្រៅជាំនាក់ ប្រុសស្រីចូលស្នាក់ស្រួលសប្បាយ ។

– (ខ) មូលមាតុកូមិ ត្រជាក់ស្រួលល្មម ដល់ថ្លើមហទយា ប្រុសស្រីចូលជ្រក សុខស្រួលកាយា ត្រេកសោមនស្សា សប្បាយក្សេមក្សាន្ត ។

๒๙ – ជីវិតិន្ទ្រីយ៍នឹងហទយា សូតជាគ្រឹមុខនឹងមត្តលុង្គំ បើគ្រឿងច័ក្រមិនប្រប្រួលខ្លាំង អត្តភាពមិនតាំងនៅបានឡើយ ។

๓๐ – ចន្ទេនចង់លេបផែនដីអស់ មនុស្សអស់ប្បុរសចង់បានហួសខ្នាត ខ្ជួនតូចកំសោយត្រូតលោកសង្ឃាត កាន់សីលមិនស្អាតចង់បាននិព្វាន ។

๓๑ – ចេញរកអាស័យឲ្យត្រាប់ក្លៅក ត្រាប់ជាងត្រួញលោកនយោបាយ ចម្រើនជាតិត្រាប់ប្រជាធិបតេយ្យផ្សាយ ប្រជៀសិស្សតាំងឆ្ងាយត្រាប់សូនធ្នាំង ។

๓๒ – ការធ្វើបដិវត្តដល់ប្រទេស បើតាមច្បាប់ចេះនាំចំរើន ប្រែប្រួលទឹកដីទំក្រើន សព្វត្រាប់លឿនគាន់កាលសម័យ ។

16— Dieu le veut —
Devise de Godefroy de Bouillon.

១៦— ព្រះជាម្ចាស់ ទ្រង់មានបំណងដូច្នោះ—

ឋាវចនា កូដឹហ្គុយដឺប៊ុយ៉ុង ។

17— Sans peur et sans reproche- —
Devise du Chevalier de Bayard.

១៧— ឥតខ្លាច, ឥតសៅហ្មង—

ឋាវចនា លោកមេទ័ពតាដឺដឺឋាយ៉ារដ៍ ។

18— Aut Cœsor aut nihil (ou César ou rien) —
Devise de César Borgia

១៨— ឬសេសារឬគ្មាន—

ឋាវចនា របស់សេសារបូស៊ុយ៉ា ។

19— Aplanos (Sans écart)—
Devise de la Famille de Montmorency.

១៩— ឥតឃ្លៀងឃ្លាត—

ឋាវចនា រាជវង្ស ដឺ ម៉ុងម៉ូរ៉ង់ស៊ុ ។

20— Cominus et Eminus (De près et de loin) -
Devise de Louis XII

២០— ជិតនឹងឆ្ងាយ-

ឋាវចនា មហាពដល្លឺ ១២ ។

21 — Plus ne m'est rien, rien ne m'est plus —

Devise de Valentine de Milan.

៤១ — ខ្ញែនពេកខ្ញុំក៏មិនខ្ញែតអារ, គ្មានសោះក៏ខ្ញុំមិនខ្ញួយ—

ជាវចនា ព្រះនាងវ៉ាឡង់ទីន ដឺមីលឡង ។

22 — A ma vie —

Devise de la ville de Reims.

៤២ — កុំប៉ះពាល់ដល់ជីវិតខ្ញុំ (មានសត្វសំពោចជាសញ្ញា)—

ជាវចនា នៃក្រុងរ៉ែមស៍ ។

23 — Servaborrectore Deo (Je serai sauvé par la main de Dieu)—

Devise de la ville de la Rochelle.

៤៣ — ព្រះម្ចាស់ទ្រង់ជួយសោចស្រង់ខ្ញុំ ដោយព្រះហស្ត

របស់ព្រះអង្គ—

ជាវចនា នៃក្រុងដឺឡារ៉ូសែល ។

24 — Dignité, courage, discipline —

(emblème: tête d'éléphant avec 3 fleurs de lotus)

Devise du Parti Démocrate du Cambodge.

៤៤ — ឋិតិ, ក្លាហាន, វិន័យ—

ជាវចនា គណៈប័ក្សប្រជាធិបតេយ្យកម្ពុជា (មាន

រូបក្បាលដំរីតាំងជាឈូកបីជាសញ្ញា) ។

25 — Perva sed virtuosa (Petite main courageuse) —

Devise de la ville de Mézières

៤៥ — ដៃតូចក្លាហាន—

ជាវចនា ក្រុងដឺមេស៊ីយ៉ែរ ។

26 — Vérité, sincérité, équité (emblème: une ruine) —

Devise du Parti Libéral du cambodge.

២៦ – សុច: សុចរិត យុត្តិធម៌ (សញ្ញា: រូបស្វ៊ាន)–

ចារឹកនាគណៈសេវ័កាត កម្ពុជា ។

27 — Sans tache comme lui (emblème: un cygne)

Devise de la ville Du Blanc

២៧– តតមានមន្ទិល ដូចជាសត្វនោះ (សត្វក្រាន ជាសញ្ញា)–

ចារឹកនៃក្រុងប៊ូឆ៍ ។

28 — Travail, Famille, Patrie –

Devise du maréchal Pétain.

២៨ – កិច្ចការ, គ្រួសារ, មាតុភូមិ–

ចារឹកចមពល ប៉ែតាំង ។

29 — Decus et Robur (Honneur et Force) -

Devise de la ville De Châlons

២៩ – កិត្តិយសនឹងពលភាព–

ចារឹកនៃក្រុងដឺសាឡុងស៊ូ ។

30 — Tout le monde y travaille (emblème une ruche) -

Devise de la ville d'Elbeuf

៣០– ជនរាល់គ្នា ត្រូវធ្វើការ (សញ្ញា: សំបុកឃ្មុំ) –

ចារឹកនៃក្រុងអេលប៊ីហ្វ ។

31 – S'ils te mordent, mords les (emblème: lionet léapords) –

Devise de la ville de Morlaix.

៣១– បើវាខាំយើងត្រូវយើងខាំវាវិញ(សញ្ញា:រូបសិង្ហនឹងខ្លារខិន)-

ចារឹកនៃក្រុង ដឺ ម៉ារលេក្ស ។

32 — Plus penser que dire –

Devise de la ville de Bar-le-Duc

៣២– ត្រូវគិតឲ្យច្រើនជាងនិយាយ–

ជាវចនា នៃក្រុង ប៉ា - ឡ្ស៊ី - ឌុក ។

33 — Ny plus ny moins –

Devise de la Famille de Sales

៣៣– កុំច្រើនពេក កុំតិចពេក–

ជាវចនា នៃត្រកូល ដឺសាល្ស ។

34 — Lilium inter lilia (Lis entre lis) –

Devise de Blanche de Castille

៣៤ – បូរមើលសន្ធឹកបុប្ផលិស–

ជាវចនា ព្រះអគ្គម្ចាស់ក្សត្រីប៉ូឆដឺកាស្ទីយ ។

35 — Courte et bonne –

Devise de la Duchesse du Berry.

៣៥ – ខ្លីហើយល្អ–

ជាវចនា ព្រះអគ្គម្ចាស់ក្សត្រីឌុយបែរ ។

36 — Fluctuat nec mergitur (Il flotte et ne sombre pas) –
(emblème: un vaisseau) –

Devise de la ville de Paris

៣៦ – នាវាបើកលើគង្គា មិនដែលលិច (សញ្ញា : រូបនាវា)–

ជាវចនា ក្រុងប៉ារិស ។

37 — Invenit et perfecit (Elle inventa et perfectionna) –

Devise de l'Académie des Scienees.

៣៧ — សភាវិទ្យាសាស្ត្រ តែងបង្កើត ទឹងកែប្រែឲ្យបានល្អឡើង —

ចារបន្ទា បណ្ឌិតសភាវិទ្យាសាស្ត្រ ។

38— Audaces fortuna juvat (La fortune aide les audacieux) —

Devise de Guillaume de Nassau le Taciturne.

៣៨ — ឆោតតែងជួយជនក្លាហាន —

ចារបន្ទា ស្តេចតន្រីយោមដំណាស្យូឡឺតាស៊ីន ។

39— Lou souleu me fai canta (Le soleil me fait chanter) —

Devise du poète Mistral

៣៩ — ព្រះអាទិត្យធ្វើឲ្យខ្ញុំច្រៀង —

ចារបន្ទា តើនិពន្ធ មិសគ្រាល ។

40— Sais—je ? —

Devise de Montaigne

៤០ — ខ្ញុំចេះឬ ? —

ចារបន្ទា ដើ ម៉ង់តែញ ។

41— Vitam impendere vero (consacre sa vie au vrai) —

Devise de J. J. Rousseau.

៤១ — ត្រូវប្រើជីវិតខ្លួនស្វែងរកការពិត —

ចារបន្ទា សង់សាក់ស្យូ ។

42— Concordia, Industria, Integritas —

Devise de le Famille de Rothschild

៤២ — សាមគ្គី, ឧស្សាហ៍, យុត្តិធម៌ —

ចារបន្ទា តែកូលដ៏រុតស៊ីលង់ ។

43— Honneur et Patrie —

Devise de la Légion d'Honneur.

៤៣— កិត្តិយសនឹងមាតុភូមិ—

ជាវចនា មេដែយ៍ លេស្យុងដូណឺរ ។

44— Liberté et Patrie —

Devise de la Croix de Juillet.

៤៤— សេរីភាព និងមាតុភូមិ—

ជាវចនា គ្រឿងតស៊ូរបួយសងឺស៊ុយេត ។

45 — Valeur et Discipline —

Devise de la médaille militaire.

៤៥— ជំនៀឡ នឹងវិន័យ—

ជាវចនា. មេដែយ៍ តាហាន ។

46 — Si j'avance, suivez moi; si je recule, tuez-moi; —
si je meurs, vengez-moi —

Devise de la Rochejaquelein.

៤៦— បើខ្ញុំទៅមុខ ឲ្យតាមខ្ញុំទៅ; បើខ្ញុំថយក្រោយ ឲ្យ
សម្លាប់ខ្ញុំទៅ; បើខ្ញុំស្លាប់, ឲ្យសងសឹកជួសខ្ញុំ—

ជាវចនា ដឺឡារ៉ូសឺសាក់គឺឡាំង ។

47— Ne perdez point de vue mon panache blanc, vous le —
trouverez toujours sur le chemin de l'honneur —

Devise de Henri IV.

៤៧— កុំភ្លេចក្រែកឡែកមើលស្លាបសត្វពណ៌សដែលដោតនឹងមួកខ្ញុំ, អ្នកមុខជាឃើញស្លាបសត្វនោះនៅលើផ្លូវប្រកបដោយកិត្តិយសជាមិញ—

ជាវចនា ស្តេចហង់រីទី ៤ ។

48— Satya Grihà –
Devise de Mahatma Gandhi

៤៨ – ការប្រែកាន់ពាក្យសត្យ–

ជាវចនា មហាត្មៈគន្ធីរ ។

49— Sattyam Nasti Paro Dharmah (Il n'y a pas — de religion supérieure à la vérité) (emblème: un serpent – mordant la queue)
Devise de la Société Théosophique de Madras (Indes).

៤៩ – សត្យំ នស្តិ បរោ ធម៌:–

'មិនមានសភាវៈអ្វីក្រៃលែងជាងពាក្យសត្យ (មានសញ្ញា: ពស់ខាំកន្ទុយ)–

ជាវចនា នៃសង្គមសាសនា មន្ទ្រស (តំណាង) ។

50— Par dessus les tombeaux, en avant
Devise de Gœthe.

៥០ – ត្រូវលោតលើផ្នូរខ្ចប (សេចក្តីស្លាប់) ទៅខាងមុខ

ជាវចនា របស់ កីត ចិត្តសាស្ត្របណ្ឌិត, អាល្លឺម៉ង់ ។

51— Les académiciens penseront beaucoup, écriront peu et parleront le moins possible –
Devise de l'Académie silencieuse de Hamadan – (Arabie)

៥១ – ពួកសភាបណ្ឌិត គិតច្រើន សរសេរតិចហើយនិយាយតិចជាងនោះទៅទៀត–

ជាវចនា នៃបណ្ឌិតសភាសម្ងាត់ នៅក្រុងហាម៉ាដង់ (អារ៉ាប់) –

52 - Je crains que le ciel ne tombe sur ma tête -

Devise des Gaulois.

๕๒ - ខ្ញុំខ្លាចតែមេឃធ្លាក់មកលើក្បាលខ្ញុំ-

ឃ្លាបន្ទា ពួកកូល" ។

53 - Austrix est imperare orbi -

universo (A. E. I. O. U.)

Il appartient à l'Autriche de commander l'Univers.

Devise de la Maison d'Autriche

๕๓ - គួរឲ្យប្រទេសអូទ្រីសត្រួតត្រាលើសកលលោក-

ឃ្លាបន្ទា សន្តតិវង្សអូទ្រីស ។

54 L'Amérique aux Américains -

Devise de Monroë.

๕๔ - ទ្វីបអាមេរិក ត្រូវបាន ទៅជាតិអាមេរិកាំង-

ឃ្លាបន្ទា លោកមុងរ៉ូអេ ។

55 - Scio cui crédidi (Je sais à qui je me suis confié) -

Devise de Pascal.

๕๕ - ខ្ញុំដឹងថាបុគ្គលណាដែលខ្ញុំត្រូវផ្ញើអាយុជីវិត-

ឃ្លាបន្ទា ប៉ាស្កាល ។

ប្រវត្តិសាស្ត្រសង្ខេបប្រទេសឥណ្ឌា

ហ្វ៊ូនិពន្ធមន្ត្រី ញ៉ុក-ថែម វែប-រៀបរៀង

(តមពី)

ព្រះមហាក្សត្រកុងរាជវង្ស យូអេដ៏ សុទ្ធតែជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយបានព្យាយាមចង់ស្គាន់មេត្រីនឹងជាតិកែក នឹងធ្វើតាមបែបមហាក្សត្រកែក គឺខ្លះនាំយកអារ្យធម៌របស់កែកនឹងរបស់ព្រះពុទ្ធសាសនាមកផ្សំលាយគ្នា តែជនពួកនេះប្លែកជាងជាតិឯទៀត។ មួយយ៉ាងគឺខ្លួលយកជាតិតណ្ហៀមកជាជាតិខ្លួន រំលាយជាតិខ្លួនឲ្យទៅជាជាតិតណ្ហៀសុទ្ធៗទៅ ។ ព្រះបាទកាតហ៊ីសេស បឋមក្សត្រនៃរាជវង្សយូអេដ៏នោះគ្រងរាជសម្បត្តិជាវេលា ៤០ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៥១៣ មកដល់ ៥៥៣ បានពង្រីកអាណាចក្ររបស់ខ្លួនចូលទៅក្នុងរែងត្របញ្ចូលបាន ១ ចំណែក ។ អ្នកគ្រងរាជ្យបន្ទាប់មកតាំងអំពីពុទ្ធសករាជ ៥៥៣ ដល់ ៥៨៣ បានពង្រីកអាណាខែត្តទៅទៀត រហូតដែនបញ្ចាបចុះទៅដល់ទន្លេយមុនា ព្រះមហាក្សត្រអង្គទី ៣ ពង្រីកតទៅទៀតរហូតដល់ក្រុងពារាណសី ។

លុះមកដល់ក្សត្រទី ៤ នៃរាជវង្សយូអេដ៏ខ្លះព្រះនាមថា កនិស្ក: គួរពាប់ថាជាមហាក្សត្រយ៉ាងសំខាន់បំផុត ដែលមានទៅក្នុងរាជវង្សនេះ ហើយគ្រងរាជ្យបានដល់ ៣៣ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៦១៣ ដល់

ព្រះពុទ្ធសកវាជ ៦៤៥ រាជអាណាចក្រយេសូ ទ្រង់គួរកាប់ថាធំជាងក្រែលែងឡើង ច្រើន ទៅក្នុងដែនអ័រ៉ាន ជនពួកនេះមានអំណាចត្រួតត្រាជល់ខែត្រសកដឿន, ប៉ាកតៀនទំងអារៀ ហើយទៅក្នុងតំណាក់ប៉ាន់គប់គ្នាដែនគន្ធារៈ កស្មីរៈ បញ្ចាប, រហូតដល់ទៅស្រុកប៉ាជលីបុត្រធន ។ ទ្រង់ប៉ាន់តាំងទីក្រុងសម្រាប់រាជអាណាចក្រ ទៅស្រុកបុរុបៈបុរៈ សម័យនេះហៅថាបេហវ៉ា ។ ព្រះមហាក្សត្រអង្គនេះព្យាយាមធ្វើតាមយ៉ាងព្រះប៉ាទអសោកមហារាជ គឺពិតតែទ្រង់ម៉ាន់រិទ្ធិអំណាចយ៉ាងធំជាក្រែលែងយ៉ាងណាក៏ដោយ ទ្រង់ទៅតែប្រកាន់ថា រាជកិច្ចសំខាន់របស់ព្រះអង្គទៅលើសាសនា ។

សាសនាជាប្រស្នាយ៉ាងសំខាន់ ក្នុងការគ្រប់គ្រងស្រុកទេសរបស់ក្សត្រណ្តៀគ្រប់ ៗ អង្គរៀងមក ជនជាតិណ្តៀមិនសូវចេះនឹករលឹកស្រឡាញ់ជាតិកំណើតរបស់ខ្លួនទេ ហើយទាំងមិនយកចិត្តទុកដាក់ទឹងស្រុកទេសរបស់ខ្លួនផង តែមានរបស់មួយដែលជនជាតិយកចិត្តទុកដាក់ជាយ៉ាងក្រែលែងតាំងអំពីកំណើតពង្សវង្សរហូតមកដល់ឥឡូវនេះ គឺរឿងសាសនា ។ ឯព្រះមហាក្សត្រកុងរាជវង្សយូអេដ៏អំពីដើម ៗ មកខោះអង្គខ្លះក៏ខំទុកបំរុងសាសនាព្រាហ្មណ៍ដំកល់ដំកើងព្រះរបស់ហិណ្ឌូ តែមកដល់សម័យព្រះប៉ាទកនិស្កៈ ទ្រង់ខំទុកបំរុងព្រះពុទ្ធសាសនាយ៉ាងម៉ឺងម៉ាត់ដល់ទៅប៉ាក់សម្រាប់ចាយក់យកធ្វើរាជអាណាចក្ររបស់ព្រះអង្គ មានតាំង

ព្រះរូបរបស់ព្រះពុទ្ធជាម្ចាស់ធំធេង ហើយខ្ញុំបានកសាងវិហារសាលាធំធេងព្រះស្តូបឡើងថ្មីៗ រាប់មិនអស់ ។

រាជធានីពុទ្ធសករាជ ២៤៤ មានការប្រជុំធ្វើសង្គាយនាម្តងទៀតនៅស្រុកបុរុះបុរៈ តែសង្គាយនាគ្រានេះខុសពីរបៀបសង្គាយនាកាលគ្រាព្រះចៅអសោកមហារាជ គឺគ្រាព្រះចៅអសោកខ្ញុំគ្រាន់តែចាត់ការផ្សាយសាសនាទៅទិសទាំងត្បូង តែសង្គាយនាក្នុងគ្រានេះ ឋានតាំងបង្កើតជានិកាយមួយឡើងមានលទ្ធិប្លែកទៅទៀតហៅថា មហាយាន ហេតុដូច្នេះ ការប្រជុំធ្វើសង្គាយនានៅស្រុកបុរុះបុរៈនេះ ទើបគួររាប់ថាជាកំណើតនៃលទ្ធិមហាយាន ដូចជាក្រុងឋានលីបុត្តជាកំណើតនៃលទ្ធិហីនយានដូច្នោះដែរ ។

តាមដោយពិត ជារឿងយូរមកហើយ មុនខ្ញុំមានសង្គាយនានៅស្រុកបុរុះបុរៈនេះ សេចក្តីឃើញរបស់ពុទ្ធសាសនិកជន ឋានបែកខ្ញែកចេញទៅជា ២ ចំណែក ចំណែកខាងឆើងមានសំណាក់ជាច្រើនប្រជុំធំនៅស្រុកកស្មីរៈ ហៅលទ្ធិរបស់ខ្លួនថា មហាយាន ដែលប្រែថាយានធំ ១ លទ្ធិបែកខាងត្បូងហៅថា ហីនយាន ប្រែថាយានតូច ១ តាំង ២ ចំណែកនេះមានយោបល់ខុសប្លែកពីគ្នា ។ យោបល់តាំងសងខាងតែងខ្វែងឆ្ងល់គ្នាជាដរាបមក លុះដល់មកមានការសង្គាយនានៅក្រុងបុរុះ-បុរៈនេះឡើង ទើបចាត់របៀបសាសនាជាបែបផែនតាមយោបល់បែកខាង

ដើង ដោយពួកនិកាយខាងត្បូងមិនយល់ត្រូវដូចខ្លួយ ព្រះពុទ្ធ-
សាសនាទើបបែកចេញជាពីរនិកាយតាំងអំពីកាលនោះមក ។ គ្រានោះ
មានព្រះថេរៈ ១ អង្គឈ្មោះព្រះរ៉ាសុមិត្រ ដែលជាប្រធានក្នុងការផ្សះ
សង្កាយនាទៅទិសខាងដើងនោះ ត្រូវពួកព្រះមហាថេរៈទៅទិសខាងត្បូង
លុបឈ្មោះពីបញ្ជីគណៈសង្ឃ តែលទ្ធិមហាយានដែលបានតាំងខ្លើងថ្មីនេះ
បានទទួលសេចក្តីចំនុកបំរុងអំពីព្រះបាទកនិស្កៈដោយល្អ កាលព្រះបាទ
កនិស្កៈទិវង្គតទៅហើយ មានព្រះមហាក្សត្រ ២ ព្រះអង្គទៀតគ្រងរ៉ាជ-
នាមថា ហុវិសកៈ គ្រងរាជសម្បត្តិក្នុងរវាងពុទ្ធសករាជ ៦៤៥ ដល់ ៦៧៥,
ព្រះរាជា ១ អង្គទៀតគ្រងរ៉ាជនាមថា វ៉ាសុទេវៈ គ្រងរាជសម្បត្តិអំពី
ពុទ្ធសករាជ ៦៧៥ ដល់ពុទ្ធសករាជ ៧១៥ សុទ្ធតែគ្រងបានចំនុកបំរុងលទ្ធិ
មហាយាន ឲ្យកាន់តែចំរើនកៃលែងខ្លើងទៅទៀត ។

ការដែលពុទ្ធសាសនាមានលទ្ធិបែកខ្វែកគ្នាជាពីរនិកាយដូច្នេះ មុខ
គួរឲ្យស្តាយណាស់ ហើយមិនត្រូវនឹងព្រះបំណងរបស់ព្រះសម្មាសម្ពុទ្ធ
ជាម្ចាស់នឹងព្រះសាសនាសោះឡើយ តែការដែលព្រះរាជវង្សយូរអេដ៏
ចបត្តម្ភចំនុកបំរុងនិកាយនេះ គោងរាប់ថាជាផ្លូវចំរើនដល់ព្រះពុទ្ធសាសនា
មួយយ៉ាងដែរ ព្រោះក្សត្រក្នុងរាជវង្សមានស្តាន់មេត្តាចាក់ឥងនឹងប្រទេស
ចិនជាច្រើនក្នុងសម័យដែលរាជវង្សយូរអេដ៏គ្រប់គ្រងនៅណ្លៀនោះ ជា
ហេតុនាំឲ្យព្រះពុទ្ធសាសនាបានផ្សាយចូលទៅក្នុងប្រទេសចិន ជាដំបូង

គឺកាលកើតចម្បាំងវាងឆ័ចនឆឹងអាណាខែត្រផ្សេងៗ ក្នុងទូវគ័ស្ថានខោះ ពួកនាហានចិនដែលលុកចូលមកកាន់តំបន់អស់នោះ លុះដល់ត្រឡប់ទៅវិញ ប្រានយំយកព្រះពុទ្ធរូបឆាប់ទៅជាមួយផង ។ ព្រះមហាក្សត្រចិនទ្រង់ព្រះនាមមិងទី ដែលគ្រងរាជសម្បត្តិក្នុងវាងពុទ្ធសករាជ ៦០១ ដល់ពុទ្ធសករាជ ៦១៨ នោះ ក៏កើតមានរាជបំណងចង់ឃើញលទ្ធិសាសនាថ្មីនោះ លុះការវិវាទគាស់ខែងគ្នាស្ងប់រំងាប់ហើយ ទើបទ្រង់សុំឲ្យខាងឥណ្ឌូបញ្ជូនសមណៈទូតឲ្យចូលទៅក្នុងស្រុកចិន ។ គ្រានោះ ព្រះមហាក្សត្រក្នុងរាជវង្សអេដីបានចាត់បញ្ជូនព្រះមហាថេរៈ ២ អង្គ ឈ្មោះមាតង្គៈ ១ អង្គ ឈ្មោះគោការនៈ ១ អង្គ ហើយបានយំយកគម្ពីរទូវនាប់ទៅជាមួយផង ដោយសារការចេះដឹងនឹងការប្រុងប្រសប់របស់ព្រះមហាថេរទាំង ២ អង្គ ជាហេតុធ្វើឲ្យព្រះបាទមិងទី ប្រកាសព្រះអង្គជាពុទ្ធមាមក: កាលពីពុទ្ធសករាជ ៦០៧ ហើយព្រះពុទ្ធសាសនាក៏ធ្លាយចូលទៅប្រតិស្ឋានក្នុងស្រុកចិន តាំងអំពីកាលនោះមក ។

ព្រះរាជវង្សអេដីនេះ គួរគប់ចាំណាំរាជវង្សយ៉ាងធំវិសែសលង់របស់តណ្ឌូ ដោយហេតុមិនបានឆ្លងស្ពានមេត្រីភាក់ទង់នឹងស្រុកចិនតែមួយទេ គឺបានចងស្ពានមេត្រីភាក់ទង់គ្នាទៅដល់ទូបនុរបរហូតដល់ក្រុងរោមផង ។

ឯលទ្ធិមហាយានឥឹងហីនយាន ដែលជាហេតុបែងចែកព្រះពុទ្ធសាសនាជា ២ និកាយនេះមានខំនង់ដូច្នេះ :

ព្រះពុទ្ធសាសនាបែកខាងដើង ដែលបានប្រកាសផ្សាយចេញទៅខាងស្រុកកស្មីរៈនឹងគន្ធារៈ ដោយអានុភាពរបស់ព្រះបាទអសោកមហារាជនោះ បានចូលចេបូកចេបល់នឹងអាស្រៈធម៌របស់ក្រឹក ទើបកើតមានការប្រែប្រួលឡើងថ្មីទៀតជាច្រើន ។ យើងបានដឹងមកហើយថា ពួកក្រឹកគោរពកាន់អានព្រះច្រើនអង្គណាស់ ហើយព្រះអស់នោះសោតទៀត ក៏សុទ្ធតែប្រកាន់ថាសក្តិសិទ្ធិអាចនឹងបណ្តាលការអ្វីៗ ឲ្យបានសម្រេចដូចខ្លួនបានបន់ស្រន់សុំទាំងអស់ ទើបនាំឲ្យពុទ្ធសាសនិកជនទៅជំពប់អស់នោះកើតគំនិតគិតឃើញថា កាលបើព្រះរបស់ក្រឹកមានរិទ្ធិតេជះខ្លាំងពូកែដល់ម្ល៉ោះបាន ម្តេចក៏ព្រះពុទ្ធជាម្ចាស់របស់យើងមានរិទ្ធិអំណាចខ្លាំងពូកែដូច្នោះមិនបាន, បើព្រះរបស់ក្រឹកចាំជួយស្រោចស្រង់អ្នកដែលគោរពកាន់អានព្រះអង្គ · ម្តេចក៏ព្រះពុទ្ធរបស់យើងជួយស្រោចស្រង់ពុទ្ធសាសនិកជនមិនបាន, ដូច្នេះហើយជាឲ្យមានយោបល់យល់ខុសប្លែកពីគ្នារហូតដល់គោលសំខាន់បំផុតរបស់ព្រះពុទ្ធសាសនាគឺពាក្យថា "និព្វាន" ។ នោះតើសំដៅសេចក្តីដូចម្តេច ។ តាមយោបល់ខាងហីនយានយល់ថាបានដល់ការរលត់កិលេសនឹងខន្ធទាំង ៥ ចំណែកខាងមហាយានយល់ថា, ព្រះពុទ្ធជាម្ចាស់មិនបានរលត់សូន្យទៅណាឡើយ ទ្រង់គង់ប្រថាប់នៅក្នុងកន្លែងណាមួយ ដូច្នេះហើយទើបជាហេតុឲ្យពួកមហាយានទុកព្រះ

ពុទ្ធជាម្ចាស់ដូចទេវតា ១ អង្គនៅស្ថានសួគ៌ ។ រឿងនេះហើយជាហេតុនាំឲ្យបង្កើតព្រះពោធិសត្វឡើង ។

ឯគម្ពីរដែលមាននៅក្នុងស្រុកយើងវេលានេះ ក៏មានរឿងរ៉ាវរបស់ព្រះពោធិសត្វជាច្រើន ហើយគប្បីយល់ថាព្រះពោធិសត្វនោះ មិនមែនកើតឡើងដោយគំនិតបែកខាងយើងទេ គឺសុទ្ធតែខាងពួកមហាយានគិតឡើងទាំងអស់ ដូច្នេះហើយបានជាដែនដីខាងឦសាន ដែលលទ្ធិមហាយានផ្សាយចូលទៅដល់ គឺក៏ដែននេប៉ាល, ប្រទេសចិន, និងជប៉ុន ទើបនិយមរាប់អានព្រះស្រីអារ៉ីយ៍គឺព្រះអរិយមេត្រៃយ ដែលជាព្រះខាងសេចក្តីស្រឡាញ់, មេត្រី, ព្រះអមិតាភៈ ដែលជាព្រះម្ចាស់នៅស្ថានសួគ៌ទិសខាងកើតនឹងព្រះអវលោកិតេស្វរៈ ជាព្រះនៃសេចក្តីករុណា ។ ក្រៅពីនេះនៅមានព្រះជាស្ត្រីកេទទៀត ព្រះនាមថាមាយា ដែលមាននាទីជាអ្នករក្សាសុខ - ទុក្ខ សេចក្តីក្តៅក្រហាយរបស់ពួកមនុស្ស ។ ព្រះនាងមាយាគឺព្រះពុទ្ធមាតា ក្នុងលទ្ធិមហាយានច្រើនតែធ្វើព្រះរូបគួបនឹងព្រះរូបរបស់ព្រះពុទ្ធជាម្ចាស់ជានិច្ច លទ្ធិមហាយានមានព្រះថេរៈសំខាន់ៗជាទៀតដូចមានឈ្មោះតទៅនេះ :

អង្គដំបូង គឺព្រះវាសុមិត្តត្ថេរៈ ដែលជាអ្នកឆ្លើមឆ្លើសឡាយនាក្នុងដែនដីស្ថេចកនិស្កៈ ហើយបានប្រកាសតាំងលទ្ធិមហាយានឡើង កាលពុទ្ធសករាជ ៦២៤ ។ តមកៈ ព្រះអស្វឃោសត្ថេរកើតនៅស្រុកសាកេត

ជាគណាចារ្យមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងដែនមគធៈ តាមដំនឿរបស់
មនុស្សនៅដំបន់នោះនិយាយថា ព្រះបាទកនិស្កៈទ្រង់លើកទ័ពចូលទៅ
ច្បាំងនៅដែនមគធៈ ដោយទ្រង់ប្រាថ្នាខ្លួនលោកអស្សឃោសៈប៉ុណ្ណោះ ។
លុះបានលោកមកហើយ ក៏តាំងលោកជាទីប្រឹក្សាខាងផ្លូវសាសនារបស់
ព្រះអង្គ ហើយលោកអស្សឃោសនេះហើយដែលបានតែងរឿងពុទ្ធប្រវត្តិ
ជាពាក្យឆន្ទៈ ដំបូងបង្អស់ឲ្យឈ្មោះថា ពុទ្ធចរិត ហើយបានប្រែជាភាសា
ចិន កាលពីពុទ្ធសករាជ ៨៥៣ ។

តពីនោះមក មានព្រះថេរៈ ១ អង្គឈ្មោះនាគាជុនៈ បានតែងគម្ពីរ
មិលិន្ទបញ្ហានិងគម្ពីរឯទៀតៗ ហើយបានរៀបចំគោលចរិកដ៏ពិតប្រាកដ
សម្រាប់លទ្ធិមហាយាន អំពីរឿងនិព្វានថា និព្វាននោះមិនមែនជារបស់
សូន្យដូចយ៉ាងពួកមហាយានយល់នោះទេ គឺថានិព្វានជាស្ថានមានរូប
អ្នកដែលទៅនិព្វានហើយ ក៏នៅតែមានរូបនៅក្នុងទីណានិមួយ តែជា
រូបចរិសុទ្ធឥតមន្ទិលសៅហ្មង ហេតុនេះឯងបានជាប៉ែកខាងមហាយាន
ទើបដឿថា ក្នុងវេលានេះ ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅទីណាមួយជា
មិនខាន ។

លោកនាគាជុនៈមានសិស្សមកពីលង្កា ១អង្គឈ្មោះថាទេវៈ ក្នុងវេ-
លាតមកជាមហាថេរៈចាត់ជាអង្គទី ១៤ ។ ព្រះថេរអង្គនេះខ្ជាន់ថា
ពាក្យសូត្រមន្តរបស់ពុទ្ធសាសនិកជន តែងលាន់ឮរហូតទៅដល់អ្នកដែល
ចែកស្ថានទៅហើយ ព្រមទាំងព្រះពុទ្ធជាម្ចាស់ផង ព្រះថេរអង្គនេះ

ហើយដែលជាអ្នកផ្សាយលទ្ធិ ដែលជាទីគោរពរាប់អានព្រះអមិតាភៈ ឲ្យមានផ្សាយចេញទៅក្នុងប្រទេសតណ្ហៀងឡើង ។

លទ្ធិមហាយានដែលបានតាំងឡើងជាឫកហាន ដោយព្រះថេរៈដែលព្យាយាមផ្សាយលទ្ធិនេះយ៉ាងមុងមាត់ត ។ មកទៀតជាច្រើនអង្គ គឺៈ ព្រះអសង្ឃៈ, ព្រះវាសុពន្ធ, ព្រះពុទ្ធសិមាហ, ឯព្រះអសង្ឃៈ ទើងព្រះវាសុពន្ធនោះជាប់ងប្អូនទើងគ្នាជាអ្នកគន្ធារៈ ។ កាលដើមឡើយលោកទាំង ២ អង្គនេះ នៅក្នុងនិកាយហីនយាន ព្រះអសង្ឃៈបានចូលមកកាន់លទ្ធិមុន ឯព្រះវាសុពន្ធនៅតែកាន់លទ្ធិហីនយាននៅឡើយ មានពង្សាវតារមួយអន្លើតៅលទុកថា ថ្ងៃ ១ ព្រះអសង្ឃៈបានឆ្ពាំឲ្យព្រះវាសុពន្ធទៅដួបក្នុងវិហារមួយដ៏តស្រុកអយោធ្យា ហើយបានិយាយប្រស័យគ្នាតាមធម្មតា មិនបានដឹកនាំឲ្យប្អូនបែរមកកាន់លទ្ធិមហាយានទេ លុះបានបរិភោគអាហារ[1] រួចហើយ ក៏នាំប្អូនឡើងទៅលើមណ្ឌប ១ ខ្ពស់ ហើយនៅខាងមុខនោះមើលឃើញទន្លេគង្គា មានទឹកថ្ងាយង៉ែ មានពន្លឺរស្មីដួងព្រះចន្ទធ្លុះចាំងមកចាប់ទឹកទន្លេគង្គាក្នុងយប់ថ្ងៃនោះ ។ ព្រះវាសុពន្ធអង្គុយនៅក្បែរបង្អួចកំពុងតែរិះរិះអ្វីមួយយ៉ាងសូបស្ងាត់ មានភិក្ខុ ១ រូបទៅខាងក្រោមកំពុងសូត្រធម៌យ៉ាងបែបមហាយាន ធម៌នេះហើយជាហេតុធ្វើឲ្យព្រះវាសុពន្ធកើតសេចក្តីជ្រះថ្លា ដល់ទៅទឹកភ្នែកហូរសស្រាក់ស្រោចមកពេញមុខ ។ តាំងពីនោះមក ព្រះវាសុពន្ធក៏គោរពរាប់អានលទ្ធិមហា-

---

១ តាមលទ្ធិមហាយានថា លោកលង្ឃាឆ់អាហារវេលាល្ងាចបានមុនព្រះអាទិត្យលិច ។

យានយ៉ាងខ្លាប់ខ្ជួន ហើយបានប្រកាសផ្សាយលទ្ធិនេះឲ្យកាន់តែរីងចំរើន ចំរើនឡើងយ៉ាងខ្លាប់ខ្ជួនរហូតមកដល់ក្រុងរាជគ្រិះ ។ ព្រះរាជាពន្ធបានទទួលជ្រើសរើសជាព្រះសង្ឃរាជទី ២០ ហើយលោកអនិច្ចធម្មនៅស្រុកអយុធ្យា ។

កាលតាំងអំពីរវាងព្រះពុទ្ធសករាជ ៩០០ ឆ្នាំមក ព្រះពុទ្ធសាសនាមិនបានចំរើនរីកាយណាស់ទេ តែក្នុងប្រទេសឥណ្ឌាបានផ្សាយចេញទៅទិសខាងកើតយ៉ាងច្រើនគឺប្រទេសទូគីស្ថាន, ស្រុកចិន, ស្រុកកៅលី, ឥណ្ឌូចិន, នឹងក្នុងប្រទេសជប៉ុន ហើយនៅក្នុងរវាងនេះ មានសមណៈចេញចូលទៅមកក្នុងរវាងប្រទេសចិននឹងឥណ្ឌាជារឿយ ។ ហើយលទ្ធិមហាយានក៏ផ្សាយចេញទៅតាមសេចក្តីរហូតកាត់ធំនៃទ្វីបអាស៊ីនេះ ។

វគ្គទី ៤

ឥណ្ឌៀភាគកណ្តាល - ព្រះបាទសីលាទិត្យ

កាលព្រះបាទកនិស្ក:ទិវង្គតទៅហើយ ក៏មានក្សត្រជាដំណតព្រះរាជវង្សតមកទៀត ២ អង្គ ក៏នៅតែទ្រង់ទ្រង់ដ៏មហាអំណាចនៅបាន តែកាលអស់បុណ្យព្រះមហាក្សត្រទាំង ២ អង្គនោះទៅ អំណាចរបស់រាជវង្សយូអេជីក៏សាបសូន្យចុះទៅច្រើន នៅសល់តែមអាណាខែត្តគន្ធារ: កស្មីរ: (ក្នុងឥណ្ឌៀ) ហើយនឹងបាក់ត្រឹមនឹងតានសកដៀន (ក្នុងអឺរ៉ាន) ។

រឿងភោគកុលកុមារ

លោក ទុកញ៉ាត្រែះឃ្លាំង នង រៀបរៀង

(តមក)

ស្រែះស្រើជាទីជាតជល - សាសាន្តសុខសល់ សម្រាប់ក្សត្រា ។ ព្រះតន្ទ្រទេវិន្ទ្រឆ្លាំថា ចូរអ្នកនិត្យា នៅនេះសម្រាន្ត ។ ឈប់ស្ទេរនៅនេះនីងមាន ស្រីតាំង៣ប្រាណ មកដងគង្គា ។ នៅស្រង់នូវអង្គធីតា គីនាងសុខុមា - លន្ធាកល្យាណ ។ អ្នកនីងបានជំងឺពតិមាន ដៀងជាក់នឹងឃាន ដួចនឹងភរិយា ។ ផ្តាំស្រែចសម្តេចតន្ត្រា ហោះទៅសូតាំ ទិព្វទីលំនៅ ។ កោគកុលនិម៌លតតសៅ ក្រោយព្រះតន្ទ្រទៅ អ្នកចូលចុះស្រង់ ។ ក្នុងស្រះផ្កាជ្រះថ្លាយង់ ជម្រះព្រះអង្គ ជាសុខសប្បាយ ។ ភ័ឆលក្នុងជលរីកពាយ ព្រលិតលេចលាយ នឹងដើមស្ពន់ស្ពុះ ។ សត្បូលនីលុប្បលជាសដុះ ឈូកឈរច្រើនច្រុះ ច្រាសច្រាលសឹងផ្កា ។ ត្រកៀតសីកសៀតស្ទាបគា ស្ទោមស្ទាបច្រក កំពឹងតួយតំន្ត ។ សូងសាយសាកាយដើងមាន់ ក្រចាបំណែនណាន់ តែកួនកន្ត្រែត ។ មច្ឆាវេរាអណ្តែត ហាក់ហែបហែលហិត រកបរិភោគ្គា ។ អ្នកស្រង់កម្ទុងគង្គា ជម្រះកាយា ស្រែចបរិបូណ៌ឋាន ។ ឡើងពីស្រះស្រើក្សេមក្សាន្ត ដល់ឆ្នេរមើលមាន្ត សុទ្ធសឹងដើមផ្កា ។ មហាហង្សត្រយង់យុច្ចា ខ្ពឹងខ្ពុចម្សា ចម្សាចេកទេស ។ មុខ្ត្រែលន្តែកាវកេស ខ្លួនខ្លួនពិសេស ម្ចុះរួត

ម្ចិះលា ។ ឈូកវត្តព្រលិតក្តាំងងា រម្ដេញមាសច្បារ រំចេកមាលដី ។ រំចាកចោសនាគន្ធនស្រី ចន្ទសូរភី សៃរៀងរំដួល ។ ដាំដុះច្រើនច្រុះជាដួរ រៀងរាល់គាប់គួរ ដោយឆ្នេរស្រះស្រង់ ។ អ្នកខានសម្បាន្ត ធ្លុកធ្លង់ ព្រៃប្របកម្ពង់ ឆ្នៀឆ្នេរស្រះស្រី ។ លុះស្រាងពីកព្រាងរង្សី ឯក្សត្រធិបតី សត្តកូដរាជា ។ ព្រះអង្គស្ដេចទ្រង់ចិន្តា បង្គាប់ទៅថា នឹងមេទាសី ។ ឲ្យយកភ្លុមមកឲ្យានបី ទៅដងទឹកពី ស្រះស្រង់រង្ងាថ្ងា ។ មកស្រង់នៃអង្គធតា ដម្រះកាយា ផ្សះព្រះកេសី ។ ស្រីង្គាបរិពារនារី លុះឮពាក្យពី ស្ដេចទ្រង់បង្គាប់ ។ ម្ចីម្ចាហៅគ្នាប្រញាប់ កាន់ភ្លុមផ្លុំប្លុំ ទូលទុកសិរសោ ។ ផ្ដៀងផ្ដងត្រសង់នាំគ្នា ទាំងបីយាត្រា ដើរដល់ស្រះស្រង់ ។ ផ្ទាស់ពណ៌ចុះចរទៅក្នុង ជលសាថ្លាយង់ ដងដាក់ភ្លុមពេញ ។ នាំគ្នាលីលាវិលវិញ យួរយកភ្លុមមិញ ដាក់ដល់ឆ្នេរស្រះ ។ ស្រែចស្រតទៅងូតដម្រះ មន្ទិលអង្គរះ ក្នុងជលសាសាន្ត ។

បទកាពគតិ

កាលណោះព្រះពោ - ធិសត្វសេដ្ឋោ អ្នកទៅសម្បាន្ត ឈប់ខានឆ្នេរស្រះ ប្រទះយល់ប្ដីណា ស្រីទាំងញប្ដាន មកដងគង្គា ។ ទើបអ្នកគន់គិត អធិស្ឋានចិត្ត តាំងផ្សងឡើងថា ឯអស់ទេព្រក្ស អារក្ខទៅតាបិតឋានសួគ៌ា កពកូមិដែនដី ។ តេជះខ្ញុំរក សូមអ្នកចូលមក ជួយជាសាក្សី បើនាងសុខុមា - លក្ខាទេវី នឹងបានមេត្រី ជាគូផងគ្នា ។

សូមឲ្យក្អមនោះ ធ្ងន់ក្រៃចំពោះ ដូចឧសិលា កុំឲ្យអស់ស្រី តាំង៣ នេះឯា លើកក្អមគង្គា ដល់សិរសើបាន ។ ផ្សងស្រែចតុំលង់ ក្បាលណា នោះអស់អង្គ ស្រីតាំង ៣ ប្រាណ ឆ្លងទឹកស្រែចស្រាប់ ក្រឡាបវិលថ្ពាន ដល់ឆ្នេរផលសាន ហើយផ្ងាស់ពស្ត្រា ។ ដាក់ដៃថ្នាក់ថ្នម យួរយកទឹកក្អម ធ្ងន់ក្រៃមហិមា ពិតតុំកក្រើក ប្រែតលើកជួយគ្នា ក្អមទឹកនោះ វា នៅនឹងដូចគល់ ។ លុះលាន់មាត់ថា ពុទ្ធោលា។ គិតគួរតែធ្ងល់ ក្អមអ្វីនេះប្លែក ចំឡែកពេកសល់ អញតុំដែលឃុល់ ដែលឃើញដូច្នេះ ។ មេមួយជាត់ធំ ពាលពេញក្រែមុំ ដេរថាមេនេះ ហង៍ឯងដៀសចេញ ឲ្យអញឯងអេះ ធ្ងន់អ្វីប៉ុណ្ណេះ អញលើកដាក់ឲ្យ ។ ជាតែបុះបាយ ដណ្តើមប្រញាយ ដែលក្រយាស្ងួយ សេសសល់ចំណី បានធីបែរក្រោយ កម្ងាំងកំសោយ ដូចគេអត់ឃ្លាយ ។ ដេរហើយប្រឹងលើក ពិតតុំកក្រើក បែកញើសហូរខ្លាយ ហត់ហើយស្រដី ធ្ងន់អ្វីអម្បាយ អញគិតមើលងាយ ស្មានជាស្រាលទេ ។ មេនោះឆ្លើយវិញ ថា ហង៍ដេរអញ អួតឯងតូចតែ កន្ទួលតតបទ មានមាត់ស្រួចតែ រំលើកដេរគេ តាមតែនឹងថា ។ កាលណោះពោធី យល់មេទាំងប៉ី លើកក្អមគង្គា តុំរួចដាក់ដល់ មណ្ឌលសិរសា ទើបអ្នកយាត្រា ចេញចរទៀបទៅ ។ អស់ស្រីផងយល់ មានចិត្តអរសល់ ចោយដៃហើយ ហៅ អង្វរចរចា ។ លោមថាមែនទែ កំឡោះល្អញល្អៅ មានរូប

សោកា ។ សូមអ្នកជ្រោសព្រួយ អាសូរមកដួយ លើកក្អមគង្គា
ដោមដាក់ដំគល់ មណ្ឌសិរសា កុំអ្នកវិញ្ញា ធុញថានាយអាយ ។
ព្រះពោធិសត្វ មហាបុរសវត្ត លើសលោកទាំងឡាយ សាកសួរទៅ
រៀ ថាហៃនាងអាយ លំនាំនោមនាយ ហាក់ស្រីអ្នកលើ ។ មកដង
ទឹកឯង ប្តូរគេតាក់តែង បង្កាប់ច្បាប់ប្រើ មកដងទឹកនោះ ចំពោះបាន់បើ
ឆ្ងូតផឹកប្តូរធ្វើ អ្វីចូរច្បាយច្បាប់ ។ សារវែងទាំងប៉ា ឮពាក្យពៅធី- សត្វ
សួរសារសំឡូ ទើបមេមួយធ្វើយ អ្នកអើយអ្នកស្តាប់ ខ្ញុំនឹងច្បាយច្បាប់
ឲ្យអ្នកដឹងជាន ។ ដ្បិតរាជបុត្រី ក្សត្រាធិបតី តស្សរថ្កើងថ្កាន ព្រះតន្ធ
ចំមេថៅ យកទៅឲ្យមាន ប្តីនៅពាព - ណាសីនគរ ។ នាងនៅពុំសុខ
អំពល់ដាទុក្ខ ទើបនាងចាកចរ រៃលែងធ្លោះមក រួសរកព្រះវរ- បិតាភូ-
ជរ ខ្លួវព្រះមាតា ។ ទើបក្សត្រចត្តម ត្រាស់ប្រើយើងខ្ញុំ មកដងគង្គា
យកទៅជម្រះ ផ្សះព្រះកេសា នៃនាងនាថជា បុត្រីកល្យាណ ។
ពោធិសត្វស្តាប់ សារវែងច្បាយច្បាប់ ដឹងដើមពំតិមាន ថានាងមកដល់
មណ្ឌលរាជដ្ឋាន ត្រើសព្រះទ័យក្សត្ត សោមនស្សាសល់ ។ អ្នក
យកព្រះខ - ម្រែងមកដាក់ក្នុង ក្អមមាសនិមិល មិនឲ្យអស់ស្រី ពាសីងង
យល់ ទៀងទើបទុសពល អធិដ្ឋានថា ។ បើនាងស្រប់ស្រង់ ជម្រះ
អស់អ - ង្គាកាយធីតា សូមឲ្យទម្រែង បញ្ចេញដៃច្បា ចូលម្រាមហត្ថា
ដូចគេបំពាក់ ។ តាំងចិត្តសច្ចា ធ្លងស្រែចព្រះមហា - បុរសចមច្រែ យួរ

យកទឹកភ្នែម ថ្នាក់ថ្នមហើយអ្នក សូមស្តួយដល់ដាក់ លើក្បាលខាស៊ី ។
សារវ៉ៃត្រែតអរ អំពើចិត្តថ្ងូរ លាព្រះពោធិ ទូលទឹកភ្នែមទៅ លំនៅ
ទិព្វទី នៃនាងនារី ដល់ស្រែចម្ការថ្ងាយ ។ ទើបពាងដ៏តា ស្រែបស្រែង
គង្គា ជម្រះព្រះកាយ ផ្សះព្រះកេសា ហត្ថាពណ្ណាយ ជ្រោយជ្រង
សិរសាយ កេសីវរលក្ខណ៍ ។ សារវ៉ៃស្តួយភ្នែម មាសមែថ្នាក់ថ្នម
លើកឡើងផ្ទៀងចាក់ ទឹកទាំងព្រះទម្រង់ ទៅកង់ភ្នែមធ្លាក់ ដូចគេបំ-
ពាក់ ព្រះហស្តក្សត្រិយ៍ ។ នាងទតយល់ដាក់ ដឹងដើមរៀមរ័ក
ជាព្រះស្វាមី តាមមកដួចដល់ មណ្ឌលស្រះស្រី នាងនាដនារី
ត្រែតសោមនស្សា ។ អរឯងពេកពន់ នាងត្រាស់សួរដ- ណ្តឹងសារវ៉ៃដថា
ហង៍ទៅដងទឹក ពីព្រឹកសុរិយា ទៅលេងឯណា ឃាត់ឃ្យូរអម្បាយ ។
ហើយហង៍ឯងបាន ចិញ្ចៀនមាសមាន តួង៍រត្នពណ្ណាយ ដាក់កង
ទឹកភ្នែម លើកថ្នមមកថ្ងាយ ចូរហង៍និយាយ ឃាតព័នរណា ។
សារវ៉ៃបង្គំ ទូលថាគាលខ្ញុំ ទៅដងគង្គា អំពីកំពង់ ស្រែស្រែងដលសា
មានហេតុយល់ដា អស្ចារ្យពេកពន់ ។ ឃាតដាឃាត់ឃ្យូរ សូមម្ចាស់អា-
សូរ ឲ្យគង់ដីពដន្ត ភ្នែមទឹកស្រាលទេ ម្តេចប្រែជាធ្ងន់ ធ្ងន់ក្រៃពេកពន់
ខ្ញុំមិនដែលឃើញ ។ ព្រួតគ្នាដួយលើក មិនមានកន្ត្រើក ទៅទឹងដូចគល់
ភ្លោយរសាយដៃ គាប់ចៃឃាតយល់ ប្រុសមួយទិមិល កំឡោះសោភា ។
ដើរមកប្រទះ យើងខ្ញុំសំពះ អង្វរគ្រប់គ្នា គាត់មកជួយថ្នម លើកភ្នែម

គង្គា ជាក់ដល់សិរសា ខ្ញុំតាំងបីនាក់ ។ ទើបខ្ញុំទូលយក ក្អមទឹក
នោះមក ថ្វាយម្ចាស់ខ្ញែល់ក្ងណ៌ ចិញ្ចៀននេះឯង ខ្ញុំក្រែងតែអ្នក
ប្រុសនោះលបជាក់ មកកន្ងត់គង្គា ។ នាងស្តាប់សំដី ពាក្យពីទាស៍
នាងជ្រាបជាក់ជា ព្រះស្វាមីមក តាមរកធីតា ត្រេកសោមនស្សា
អរឥតចំណែកថ្លែង ។ ព្រះឥស្សរិព្ភូតន់ ត្រាស់ខ្ញែល់ចំអន់ ថាអស់ហាងឯង
ពើពាក្យមាយា មុសាឥតត្រែង នាំគ្នាដើរលេង ទៅរកសហាយ ។
ជួបជួនប្រុសប្រាណ ប្រទ្វេងគ្នាបាន កៀកកន្ងិយាយ អស់ចិត្តទើប
យក ទឹកមកថ្វាត់ថ្វាយ ករកូតប្រាប់ប្រាយ ថាក្អមទឹកធ្លន់ ។ សារវៃ
កាំងតិត ទូលថាបពិត្រ ម្ចាស់ថ្លៃមានបុណ្យ ខ្ញុំទូលពំនិត្យ ពាក្យពិត
ពេកពន់ ពិតជាក្អមធ្លន់ ពុំហានមុសា ។ នាងនាចកក់ស្រង់ ស្រែច
ក្សត្រីខ្ញែល់ ត្រើងពរណ៌ពស្ដា តាក់តែងព្រះអង្គ ហើយនាងលីលា
ទ្វើងគាល់បិតា ផិតដង្ហើងចូល ។ ដល់ស្រែចនាងថ្វាយ បុស្សង្ខ័ដកាយ
ករកបកោមល ទូលថាជ្បិតប្តី ស្វាមីនិមិល តាមខ្ញុំមកដល់ ស្រះ
ស្រង់ជ្រៀងជាក់ ។ ដុំដង្ហើយទាសី ទៅដងទឹកពី ស្រះជួបនឹងអ្នក
យកព្រះទម្រង់ រត្នជង់ំលាក់ ក្នុងក្អមដែលជាក់ ទឹកទូលទ្វើងមក
ខ្ញុំដូតគង្គា ទើបយកហត្ថា ជ្រងជ្រួយសក់សឹក ចិញ្ចៀនទម្រង់
ដោយក្នុងទឹកមក ដូចគេពាក់ច្រក ខ្មៅម្រាមកូនដៃ ។ (មាឧត)

មហា "ទិម - ណាគ្រី"

ឃុំស្វាយចេ៉ា ស្រុកសង្កែ ខេត្តបាត់ដំបង ប្រៃរៀបរៀង,

នមត្ថុ រតនត្តយស្ស

ខ្ញុំនាមដើម "ទម - ណាគ្រី" ទីបណ្ឌិត
សូមប្រណីតប្រណមក្បាយថ្វាយបង្គំ
ព្រះជិនន្ទ្ធពិន្ទ្ធសម្ពុទ្ធវុត្តម,
ព្រះសទ្ធម្ម, ក្រុមព្រះសង្ឃអង្គសាវក ។
រួចសូមប្រែកែសំដែងច្នៃឆ្នាសិត
ខុកជាក្រមផ្សំជាកិត្យមានសារៈ
ចែកចំណាយផ្សាយដំន្ទូនដូនលោកអ្នក
ពុទ្ធិកៈសប្បុរសទាំងប្រុសស្រី ។
ខ្ញុំដកស្រង់ពីក្នុងច្បាប់ច្រើនអន្លើ
យកមកធ្វើជាកាព្យឃ្លោងរយោងសេចក្តី
ខុកជាបទកត់ជាប្រៃបសង្ខេបខ្លី
ឲ្យឈ្មោះថ្នីថា "មុន្ទីសុភាសិត" ។
សូមសាសនាព្រះគោតមចម្រើរយើង
ប្រាន្តរុងរឿងថ្កើងរុងពោចន៍ទីងថេរបិត .

សូមស្រែកខ្ទរខ្ទែរទៅរកវឌ្ឍនៈបុគ្គិ
អបពាធិតសិទ្ធិជោគជូរកើតមាន !!! ។

ពុទ្ធគុណវិគ្គ

តាភាភសិ វិសាខា យា តាយ យុត្តោវ ចន្ទិមា
បុណ្ណោ តេន ច យុត្តា យា វិសាខបុណ្ណមី តិថី ។

តិថីឯណាថ្ងៃថ្ងាសោភ័ណ កបដោយដួងចន្ទរោញរាំសោភា
ត្រចះត្រចង់រុងរឿងខែខា អាកាសវេហាសៈនគាល័យ ។
គោចរដុំវិញផ្កាយបុក្ខរណ្ណជាក់ ឈ្មោះវិសាខៈសោភៈពេកក្រៃ
តិថីនោះឈ្មោះ "វិសាខបុណ្ណមី" ចន្ទពេញវង្សីនៃខែពិសាខ ។

ឯត្ថន្តរេ អភិសម្ពុទ្ធោ ឥសប្បរិយោ ច ឯត្ថន្តរេ
លោកស្សនុលោភចោ សត្ថា អមតំ បទមេសកោ ។

រីព្រះសម្ពុទ្ធមុជសាស្តា ជាដួងនេត្រានៃលោកពិភព
ព្រះអង្គប្រកាសត្រាស់ពន្យល់ប្រាប់ ខ្ទរខ្ទមិនស្ងាប់ឈ្មោះអមតៈ ។
ទ្រង់ជ្ញានប្រសូតបាតគតិមាតា, ត្រាស់ដឹងធម៌ញាណឥតទើសចំពាក់,
ទីឆ៍ចូលនិព្វានគាន់ស្ងាខសិវៈ, កុងតិថីលក្ខណ៍នោះតាំង ៣ ត្រា ។

សីលោភមនុភសព្វមិ ឥសប្ប វណ្ណោប្បភាសកំ
អប្បមញ្ញាយ រូបេន បសារេន តថាគតោ

ដោយបញ្ញាការេចនដ៏តិចពិត　　តែដោយទឹកចិត្តដ៏ច្រេចពេញខ្ចី

ក្នុងព្រះតថាគតបរមមុនី　　ខ្ញុំសូមវាទីពោលស្មោកប្រកាស ។

អំពីព្រះគុណអនន្តអនេក　　អនន្តព្រះពុទ្ធម្ចាស់

ដោយពាក្យនិពន្ធតាមធន្លូសាស្ត្រ　　លោកបានប្រកាសទុកពីបុពណ ។

ពុទ្ធោបិ ពុទ្ធស្ស កណោយ្យវណ្ណំ

កប្បម្បិ ចេ អញ្ញកាសមានោ

ខីយេថ កប្បោ ចីរទីឃមន្តរេ

វណ្ណោ ន ខីយេថ តថាគតស្ស ។

សូម្បីព្រះពុទ្ធម្ចាស់ក្តីតម្រិះ　　គប្បីពោលគុណព្រះពុទ្ធផងគ្នា

អស់កប្បវែងឆ្ងាយអន្លាយយូរយារ　　មិនពណ៌នាធម៌អាចដឹងទៃ ។

កប្បដ៏យូរលង់រាប់ឆ្ងាយ　　ក៏នឹងផុតអស់កន្លងសម័យ

ឯគុណព្រះពុទ្ធវិសុទ្ធិវិសិទ្ធ　　មិនហោចហ៊ានរៃអស់ទៅផងឡើយ ។

សមាសុសីសេ ปิ เต โธเสา

สีเส สีเส สตำ มุขา

มุเข มุเข สตำ ชิวหา

ชิวาสหสฺสา มหิทฺธิกา

ธ สกฺกาตำ จ วณฺณิตุ

ธิสฺสสำ สตฺถุโน กุลำ ฯ

ปุរิสมาตฺมานกฺปาลสหสฺสา กปาลมฺยา ๆ เนาะมานมาตฺมุยายย
มาตฺมุยา ๆ มานอณฺฑาตฺตชาบ์ชาย มุยายย ๆ ตฺรูบ์มาตฺเนาะฉัน ฯ
ปุริสเนาะมานอายุมุยกปฺป มานบุทฺธิสฺสา ฮาบ์, กมิ์นอาจโจฺง
พณินาตฺรัพระคุณตฺรัพระสาสฺดาสฺเดจ์ ฯ่ยอสฺรเลิงมิ์นสลฺบ์ฮานฯ่ยย ฯ

จตฺตาโร โลเกโก ปณฺโฑตา ปฏฺเมตฺถ ฉ วิชฺชติ
ติกา ตยติ อาทิโจฺจา รตฺติมาการติ จนฺทิมา
อฏ อกฺขิ ติกา รตฺติ ตตฺถ ตตฺถ ปกาสติ
สมฺพุทฺโธ ตยตำ เสเฏฺโ ฯสา อาคา อนุตฺตรา ฯ

พทฺธิกเงโลกมานโตร ๔ ตูต์ มิ์นมานกำณาตฺงฬ ๕ ปฺรการ
ตฺรัพอาจิตฺยบำกฺธิกเงวิก์ ฯ ตฺรัพจนฺโทกฺธิมาภตฺร์ ฯ
กเงโงบำกฺธิสพฺพกเงอ์เนาะ ๆ ตฺนุะกฺธิกำเงยบ์ตูบ์กำเงพลโจฺง
จำณูกตฺรัพพุทฺธมุนิกตาโตร ปฺรเสิรเงโงโกตพทฺธิกำเงอส์ ฯ
พทฺธิตฺรัพสมฺพุทฺธเยสนะ ปุเงร฿เงวิเสสวิสาลขเงฺงสฺ
เลิงสลุบเลิงสโลเงพทฺธิกำเงอส์ พทฺธิเนาะ ๆ ปฺรูบ์บตุำฮานฯ่ยย ฯ

วเกา เนาวเคตฺมิ เจาะเย อกฺขิลิมาลเกา
ฉนจาเล ภาภุเล จ สพฺพตฺถ สมมานสา ฯ

ตฺรัพพุทฺธจมตงฺคฺรัพงฺรัยมานเชาต ขสฺรเลิงสโลกชาเยมฺหาสฺองฺคเนาะ
เงเงมานตฺรัพเยมฺหาสฺตูตฺรูเสาะ สฺรุ๊ ๆ จำเนาะกเงพหูกสตฺว ฯ

គឺកង់ឥព្វកត្រែមនាយខ្នាន់ឆ្វេ កង់លោកគ្រែឈ្មោះព្រះទេវទត្ត
កង់មហាខោរវដែលសន្ធត ឈ្មោះគាត់ហៅថា អង្គុលិមាល ។
កង់ព្រះនុរសនាមអាហុល: ជាព្រះរាជបុត្រដ៏វិសាល
នឹងកង់ដំរីឈ្មោះធនបាល ដ៏សព្វៗ កាលតតមានរើសមុខ ។

តហ្វំ រត អត្តាយ មាយា ជនយិ គោតមំ
ព្យាធិ មរណាតុដ្ឋានំ ទុក្ខក្ខន្ធំ ព្យាថានុធិ ។

ព្រះនាងសិរីមហាមាយា ប្រសូតបុត្រានាមព្រះគោតម
ដើម្បីប្រយោជន៍សុខសាន្តដ៏ធំ ដល់ក្រុមនិកាយសត្វកង់ត្រៃវដ្ត ។
ព្រះអង្គទ្រង់បង្ហោះទុក្ខគោមនស្ស រៀបស់សព្វសត្វឲ្យបាត់សូន្យស្ងាត់
ដែលព្យាធិមរណៈគ្រប់សង្កត់ ឲ្យបានរលត់រលាយមិនសល់ ។

តោននេយ្យ៎ បមំ ទិស្វា សតសហស្សំ យោនន
ឧណោន ឧបគន្ត្វាន តោនេតំ តំ មហាមុនិ ។

ព្រះមហាមុនីមុនិន្ទ្រចមតង្ស ទ្រង់ឃើញជនណាដែលមានទិស្សយ
គួរត្រាស់ដឹងធម្មាភិសម័យ សម្បីផ្លូវឆ្ងាយចាំងវែនៈយោជន៍ណា ។
ក៏ស្តេចយាងទៅដល់ដោយរហ័ស ហើយទ្រង់ប្រកាសសំដែងធម៌អាថ៌
ញ៉ាំងជនទោះៗឲ្យកើតជ្រះថ្លា ឲ្យបានដល់ការត្រាស់ដឹងធម៌ថ្លៃ ។

លោកោ ទុក្ខេន សន្តប្តោ តណ្ហា ទុក្ខស្ស សម្ភវ
តណ្ហាយាតេន ទុក្ខេន តុម្ហោ ទេសេតិ ចាធនំ

សត្វលោកតែងរុំដោយសេចក្តីទុក្ខ តណ្ហាប្រមុខនាំកើតទុក្ខភ័យ
នឹងផុតចាកទុក្ខសោកទោសបង្រៃ ឃានព្រោះអាស្រ័យសម្លាប់តណ្ហា ។
ព្រះពុទ្ធជាម្ចាស់ទើបប្រកាសប្រាប់ នូវគន្ថធម្មប្រាប់សម្លាប់ "ប្រាថ្នា"
ដែលឲ្យលះផុតចាកទុក្ខា សម្រាប់ទេពតាមនុស្សសត្វទូទៅ ។

កាយកថាសុសីលេន អរោ ចិត្តំ សមាធិនា
ទិដ្ឋិ បញ្ញាយ សន្តេភិ វក្ខាមេតំ មហាមុនិ
ព្រះមហាមុនីឮពាក្យវប្បត្តម តែងនាំក្រមសត្វនិកាយទាំងឡាយ
ឲ្យថែរក្សាវាចានឹងកាយ ដោយសីលធោមធាយដ៏ស្អាតផូរផង់ ។
ឲ្យឃុំគ្រងចិត្តគំនិតនឹងនួន ដោយក្បួនសមាធិធម៌ទុក្ខ
ឲ្យពត់ទិដ្ឋិការយល់ត្រូវត្រង់ ដោយអង្គបញ្ញាពិចារណ៍ពិនិត្យ ។

យាវ អជ្ជតា សត្តា សេចេ លោកម្ហិ បស្សតិ
សព្ពោ លោកោ សុសព្ពោវ អហោធានិ សនិព្ពុតោ ។
ព្រះចមសាស្តាអាទិច្ចវង្ស បើព្រះអង្គទ្រង់គង់ព្រះជន្មនៅ
ក្នុងលោកហូតសព្វថ្ងៃតទៅ សត្វលោកទូទៅនឹងសូប់សែនសូប់ ។
តែអនិច្ចា ! តទៅទ្រង់ញាណ យាងចូលនិព្វានចាកលោកពិភព
ជាយូរយារហើយខ្ញុំសូមគោរព ! ខ្ញុំសូមគោរព ! អំពីចម្ងាយ ។

ឯម្មោ អិទ្ធយោ តស្ស សត្ថា ឧវ តិដ្ឋតិ
តស្មាសោ និព្ពុតោ កាមំ សាសនំ បន តិដ្ឋតិ

ធម៌ទឹងនិន័យរបស់ព្រះអង្គ ទៅតង់ដំនួសឆួសជាសាស្តា
នៃយើងតាំងឡាយតាំងមនុស្សទេព្តា ឲ្យទំសិក្សារៀនសូត្រតាវ: ។
ព្រោះហេតុដូច្នោះ សូម្បីព្រះអង្គ និព្វានយូរលង់ក៏មែនពិតជាក់
តែពាក្យប្រដៅពុទ្ធវចន: ថាវ: គង់វង់បិតថេរទៅទៀយ ។

កោ នុ ថោមយតិ សម្មា បដិបត្តិមនុត្តរំ
យោ សទ្ធោ สุ ចរេ ធម្មំ យត្ថេ កោវលវច្ចនំ ។

រីព្រះសាស្តាម្ចាស់អង្គណាហ្ន៎! ដែលទ្រង់សរសើរដំណើរចរិយា
កិច្ចប្រតិបត្តិប្រពៃថ្លៃថ្លា ថាប្រសើរជាងបូជាអាមិស ។
នរណាមានចិត្តជំនឿជឿពិត កំចូរប្រព្រឹត្តតាមគ្រឹត្យធម៌ប៉ុះ
ល្អតែក្រាបៗ សំពះៗ តើឃានអ្វីខ្លះ? ទឹងធ្វើអ្វីកើត? ។

កោ នុ សាសតិ អត្តស្ស តយំ ๙๘ អសាសិយំ
สទ្ធិ สម្បាទនេហេវ สเจ สោ น តថាគតោ

ព្រះចមសាស្តាម្ចាស់អង្គណាហ្ន៎! អាណិតអាសូរប្រដៅខ្ញុំខ្ញាន
ប្រយោជន៍តាំងពីរដែលមិនដែលមាន នរណាខ្ញុំខ្ញានក្នុងលោកនេះសោះ ។
តែមតាំងខ្ញប្រតិបត្តិច្រើនហាន ដែលនាំឲ្យឃានសម្បត្តិតាំងអស់
បើព្រះសាស្តាជាម្ចាស់អង្គនោះ មិនគឺចំពោះព្រះតថាគត! ។

ជនោ ជីវនជានន្តុ ភាសតំ
សក្កភោន្តោ បមជ្ជាតិ បុញ្ញាវិក្ខយភោ ចរេ ។

ជនណាបើបានធ្វើសក្ការៈ　　បូជាគារវៈតាមទន់ទពិត

ដែលព្រះសម្ពុទ្ធផ្សាពង្សវង្សវិទ្ធិ　　ដូចពង្សអោទិត្យសំដែងទុកមក ។

ជនខោះនឹងបានសុខសាន្តសែនសល់　　គឺនឹងបានដល់មគ្គផលផុតសោក

មានព្រះនិព្វានជាអារម្មណ៍យោគ　　កន្ទុងផុតលោកលែងជ្រកក្នុងកព ។

๗๘ គោត្តា ឯសាមេ ច　　សម្មាសម្ពុទ្ធសាសនំ

តតោ ឯ ច ឯតទគ្គេ ច　　បឋមេ អមតំ រសំ ។

មកចុះ លោកអ្នកចំរើនទាំងឡាយ !　　អញ្ជើញទូលាយពិនិត្យពិសោធ

ពាក្យប្រៀនប្រដៅនៃព្រះសម្ពោធ　　ពិនិត្យពិសោធឲ្យបានជាក់លាក់ ។

ដំណាងជាប់តអំពីខោះពិត　　អញ្ជើញប្រតិបត្តិតាមសាសនៈ

លោកក៏នឹងបានត្រេកបងំការៈ　　នៃអមតៈគឺព្រះនិព្វាន ។

๗ មាយ ភវិតព្វាយ　　មយា សទ្ធំ សុភាសិតំ

ចិរំ តិដ្ឋតុ សទ្ធម្មោ　　បជាយ អនុកម្បិតុំ ។

សច្ចៈវាចាដែលខ្ញុំម្ចាស់　　បានពោលប្រកាសយ៉ាងល្អប្រពៃ

ដោយគន្លងសាស្ត្រសំដួងភរ៍　　ទាំងខ្មែរបាលីទាំងអស់នេះណា ។

សូមព្រះសទ្ធម្មបូរគ្រាំបេះបិត　　គង់រង់នៅនិត្យអស់កាលយូរយា

ដើម្បីអនុគ្រោះចំពោះប្រជា　　ជនជាតិនានាក្នុងលោកនេះហោង ។

នេះជាទំនាយរឿងបញ្ហាខោះ, ឯមនុស្សទាំង ៦ នាក់ដែលយំសោកស្តាយថ្ម បិទមាត់ គឺសាស្តាចារ្យសំខាន់ទាំង ៦ នាក់ដែលព្រះពាជនុសេនីធ្វើឲ្យបាត់ដឹងខ្លួន ក្នុងអាការធ្លេសផ្តាសារបស់ខ្លួន ដោយព្រះបារមីដ៏ខ្លាំងក្លាំង នឹងព្រះធម្មទេសនាដែលមិនមានរឿងជាដែកបាន, ទ! ព្រះពាជាសូមទ្រង់ក្សេមក្សាន្តសម្បាន្តព្រះទ័យចុះ ព្រះគុណាសម្បត្តិរបស់ព្រះពាជនុសេមានដំឡៃលើសលែងពាជអាណាចក្រទាំងមូល, សំពត់ (ស្បង់ចីពរ) ជាចរយ៉ីរវើយមានដំឡៃក្រៃលែងសំពត់ដែលគេត្បាញដោយខ្សែមាស; ព្រះសុបិននិមិត្តរបស់ព្រះអង្គ ប្រែបានសេចក្តីត្រឹមប៉ុណ្ណេះឯង ហើយខាងក្នុង ៧ ទំព័រទៀត ៧ ក្តី, របស់ទាំងពួងនឹង១ប្បត្តិបង្កើតឡើង" កាលបុរសអស្ចារ្យនិយាយចប់ហើយក៏ក្រាបថ្វាយបង្គំ ៨ ដង ប៉ះពាល់ដល់ដី ៣ ដង ត្រឡប់ប្រែខ្នងហើយចេញទៅ តែកាលដែលព្រះពាជាទ្រង់តឲ្យរកខ្លួនមកនឹងព្រះពាជានាន្តាន់មានដំឡៃ, អាមាត្យដែលទទួលព្រះពាជឱង្ការត្រឡប់មកទូលថា "ទូលព្រះបង្គំតាមទៅរហូតដល់ព្រះវិហារចន្ទ្រា ដែលឃើញគាត់ដើរចូលទៅ តែកាលចូល

ទៅដល់ក្នុងទីនោះ កំស្រាប់តែឃើញទីពុយសំបុរប្រផេះ ១ ហើរចេញ ពីបង្គន់ទៅ" ។ (មានចួនកាលទេព្តាដំណែងមកឲ្យឃើញដូច្នេះដែរ) ។

ព្រះរាជាដែលទ្រង់ក្រែមក្នុងព្រះទ័យ កាលទ្រង់ព្រះសណ្តាប់ ពាក្យទំនាយសុបិននោះហើយ ទ្រង់សូតព្រះហឫទ័យ, ទ្រង់ចាត់ចែង ប្រលោមព្រះសិទ្ធត្ថដោយវិធីធ្វើឲ្យក្សេមក្សាន្តឡើងថ្មី ក្រៅអំពីនេះ ទ្រង់ បន្ថែមកងរក្សាព្រះគ្រាឲ្យមុឺងម៉ាត់ឡើងទៀត ។

ចុះនរណាអាចហាមឃាត់មិនឲ្យប្រព្រឹត្តទៅតាមជោគជតាវាស្នា របស់ខ្លួនបាន!

តាមដោយពិត ព្រះរាជបុត្រមានព្រះបំណងប៉ងចេញទៅទតព្រះ នេត្រហូងប្រជាជនជីងជំណើរនៃជីវិតមនុស្សទៀត ដែលជារបស់គួរឲ្យ ពិតពិលរមិលមើល ប្រសិនបើដំណើរបស់មនុស្សទាំងនោះ មិនបាន ទៅតាន់សេចក្តីវិបាកតឹមណា: ដែលជាបំផុតនៃកាលវេលា ទើបព្រះរាជ-ឫសគ្រាបទូលព្រះបាទសុទ្ធោទន:ថា "សូមព្រះអង្គទ្រង់ព្រះមេត្តា ប្រោសអនុញ្ញាត ឲ្យទូលព្រះបង្គំចេញទៅមើលរាជធានីរបស់យើងតាម សភាពធម្មតា, កាលគ្រាមុននោះ, ដោយអំណាចព្រះមហាករុណា-ធិគុណរបស់ព្រះអង្គ ទើបព្រះអង្គទ្រង់ហាមមិនឲ្យសត្វលោកដែលទល់ ទុក្ខវេទនា នឹងមិនឲ្យមានសភាពធម្មតាប្លែកដូច មានតែទ្រង់ឲ្យមនុស្ស គ្រប់រូបនឹងសភាពធម្មតាគ្រប់យ៉ាង ប្រកបដោយសេចក្តីក្សេមក្សាន្តរីករាយ

ដើម្បីឆាប់សុខសម្រាន្តនៃខ្ញុំព្រះបង្គំ ត្រមាំធ្វើឆ្នាល់គ្រប់អន្ទេះក៏ឲ្យ
មានតែការរីករាយក្សេមក្សាន្ត ទោះបីជួញប្រាះ ខ្ញុំបង្គំក៏ចាន់ដឹងច្បាស់ថា
របស់គាំងឡាយ មិនមែនប្រព្រឹត្តទៅតាមធម្មតាដែលមានទៅសត្វលែងទេ,
ដោយហេតុខ្ញុំព្រះបង្គំជាអ្នកខ្មោចតែត្រអក្ក នឹងព្រះរាជអាណាចក្រ
ក្រៃលែងជាងអ្នកឯទៀតៗ, ខ្ញុំព្រះបង្គំចង់ស្គាល់អាណាប្រជាជននឹង
ធ្វើឆ្នាល់គាំងឡាយ តាមសភាពធម្មតានៃរបស់អស់នោះ, កិច្ចការធម្មតា
សត្វៗលែង នឹងការចិញ្ចឹមដំរីតរបស់ប្រជាជនដែលមិនមែនព្រះរាជា,
បពិត្រព្រះអង្គដ៏ទ្រង់ព្រះគុណធម៌ដ៏ប្រសើរ, សូមទ្រង់អនុញ្ញាតឲ្យ
ខ្ញុំព្រះបង្គំចេញចាកព្រះរាជទ្រព្យដ៏សុខសម្រាន្តរបស់ខ្ញុំព្រះបង្គំទៅ
ដោយស្ងាត់ៗ ខ្ញុំព្រះបង្គំនឹងត្រឡប់ថ្កានមកវិញដោយជ័រតំរែកពុំខាន
ឬមិនរីកពាយទេ ក៏គង់ថ្កានសេចក្តីចេះដឹងមកតាន់ខ្ញុំនជាពុំខាន សូមទ្រង់
ព្រះមេត្តាបណ្តាយឲ្យខ្ញុំបង្គំចេញទៅតាន់ធ្វើឆ្នាល់នានា នៅវេលាព្រឹក
ស្អែកនេះ ជាមួយនឹងរាជបម្រើម្នាក់ប៉ុណ្ណោះចុះ ។ កាលព្រះរាជទ្រង់
ត្រាបបង្គំខ្ញុំជូរខ្មោះព្រះរាជទ្រង់ត្រាស់ក្នុងកណ្តាលសេនាមុខមន្ត្រីរបស់
ព្រះអង្គថា "ចូនកាលការចេញតំណើរទៅលើកនេះ អាចតែដោះគំនិត
កាលចេញទៅលើកមុននេះបានខ្លះ, ឃើញទេ នេះគឺសត្វទ្រង់ដែលដាប់
ចិត្តគំនិតនឹងរបស់គាំងឡាយដែលខ្ជិនបានឃើញខាងក្រោយ ដែលបាន
ផ្តុងរង្វើងកន្ត្រឹស្នេហា, ចូរបណ្តាយឲ្យកូនយើងបានឃើញបានយល់គ្រប់

យ៉ាងខ្លះទៀតផង, ហើយចូរនាំពត៌មានដែលក្នុងណៈអាការគំនិតរបស់គេមកបញ្ជាក់ដល់យើងផង ។

ហេតុដូច្នោះ ដល់ព្រឹកឡើង, លោកថ្លៃត្រង់ព្រះពាជបុត្រនឹងនាយធន្នក៏ចេញពីព្រះទ្វារ ដោយអ្នកយាមឃ្លាំនេះយើញព្រះពាជលញ្ជាករ ក៏បើកព្រះទ្វារឲ្យចេញទៅដោយស្រួល តែអ្នកបើកទ្វារមិនបានស្គាល់ថា អ្នកដែលតែងការយាយថា នាយតាណិជចេញពីទ្វារទៅនោះជា ព្រះពាជបុត្រទេ ទាំងនាយសារថីសោតទៀតក៏តែងខ្លួនជាមនុស្សសាមញ្ញដូចម្តាដែរ, ព្រះអង្គម្ចាស់នឹងនាយសារថីទាំងពីរនាក់ចេញដើរទៅតាមផ្លូវ ច្របូកច្របល់នឹងហ្វូងប្រជាជនច្រើនពួន ទ្រង់ទតព្រះនេត្រមើលនឹងអាការដែលសុខនឹងទុក្ខច្រើនពួនក្នុងព្រះនគរ បណ្តាផ្លូវថ្នល់ដ៏ល្អប្រពៃច្រើនពួន ក៏បានឮតែសំឡេងសំនៀងសៀរវែកវរខ្ចោក របស់ប្រជាជនដែលធ្វើការចិញ្ចឹមជីវិតជានិច្ចនិរន្តរ៍, ពួកឈ្មួញអង្គុយចោងហោងទៅកណ្តាលគ្រឿងទេសនឹងគ្រប់កន្លែងផ្សេងៗ, ពួកអ្នកទិញក៏មានច្រើនកកកាសទៅក្នុងដែលមាប់ទិញអីវ៉ាន់, ខ្លះក៏ដើរប្រកែកគ្នាក្នុងការទិញដូរ, ខ្លះក៏ស្រែកសុំផ្លូវឲ្យចេញពីកន្លែងទៅ, មានរទេះច្បាំងដ៏ធ្ងន់អូសទាញដោយគោដ៏មានកំឡាំងទៅយឺតៗ ផ្ទុករបស់ដែលមានទម្ងន់, មានមនុស្សសែងគ្រែស្នែងស្រែកច្រៀង, ពួកកុលីដញ្ជាន់អីវ៉ាន់មានកធំមាំ ដោកទៅដោយញើសក្អែលដោយកំដៅថ្ងៃស្ត្រីមេផ្ទះមានក្បាលខួលឆ្មាំងដី ឬឆ្មាំងស្ពាន់ដាក់ទឹកដែលបានដងយកមក

អំពីអណ្តាង ហើយតវកូនក្មែកខ្មៅៗ នៅទីឆ្ងាយឆ្ងាយ, រាល់ពាក្យណាដែលគាត់មានវុយវោមអ្វីពាសពេញ, ជាងគេមាញ់ក៏ធ្វើការរបស់ខ្លួនទីឆ្ងាយ, គ្មាល់កំនក៏វិលកំនស្រវាស្រី សុនខ៏តែពីសពាសស្វែងរកអាហារគោជន ជាងសាងអារុធកំពុងធ្វើការក្រោយដង្ហាប់ទឹកញញួរ, ជាងដែកកំពុងដុតខបទឹកលំពែងឲ្យនេះក្រហមច្រាលក្នុងឡ, នៅសាលារៀនពួកក្មេងសាកិយៈ ដែលជាសិស្សក៏អង្គុយរៀនសូត្រ នៅជុំវិញគ្រូរបស់ខ្លួន, ខ្លះអានមន្ត ខ្លះសិក្សាតម្រាព្រះជាម្ចាស់ ពួកជាងដែលក៏ទាំគ្នាដែលក់សំពត់ឲ្យមានសម្បុរខៀវ ពណ៌កុលាបទឹងពណ៌ស្វឹកឈើ ទើបលើកស្រង់ពីចាំងដែលក់កំពុងនៅសើមទឹក, ពួកគាហាន់កំពុងដើរលាន់ឮស្ងរជាវនឹងខែលប៉ះទង្គិចគ្នា, ពួកឃ្វាលសត្វអូដអង្គុយយោងលើពោងសត្វអូដ, ខ្ញុំបានឃើញស្គាល់ជាក់ច្បាស់ទាំងពួកព្រាហ្មណ៍ដែលកាន់សីលធម៌, ពួកខត្តិយៈអ្នកបម្រុងដ៏អង់អាច, ជនសាមញ្ញគឺពួកកម្មករ, នៅកន្លែងមួយនោះ មានពួកមនុស្សជ្រៀតជ្រៀតគ្នាទៅមើលហត្ថសន្ទិយាយបណ្តើរយកពស់រុំដៃធ្វើជាគ្រឿងអលង្ការមានដំរីត ប្តូរប្តូនការបង្ហាប់ឲ្យអស់រពិសសាហារនោះពាំអើតកងកពពារគាមចង្ការស្ករ ដែលប្រដាប់ដោយកំទេចតែរន្ទះ។, ប្តូនការឃើញមានក្បួនហែទីធ្លាក្នុងតែ មានសេះប្រដាប់គ្រឿងចងអានយ៉ាងរុងរឿង ទីឆ្ងាស់ព្រៃ ដើម្បីហែកូនក្រមុំទៅការនៅធ្លុះការ,ប្តូនការមានស្ត្រីច្បាយបូជាទំនឹងកម្រងផ្កាដល់ព្រះជាម្ចាស់

បន់ស្រន់សុំឲ្យស្វាមីរបស់នាងត្រឡប់ពីការធ្វើដំណើរ ឬមិនដូច្នោះទេ បន់សុំឲ្យបានកូនប្រុស ១ ក៏មាន, ឬតធ្វើយពីនោះទៀត មានពួកជាង ធ្វើកាជនៈខ្លួនឡើយ ដំទង់ដែងសូរពេងសម្រាប់ធ្វើជាចង្កើងនឹងឆ្នាំងឬក្អម, តពីនោះទៀត ព្រះរាជបុត្រនឹងនាយទន្ទ្រង់យាងសៀវភៅតាមកំពែង វិហារ នឹងដឹតូវធំក៏ចាន់ឆៅដល់ស្ទឹងនឹងស្ពាន ដែលខៅខាងក្រៅ កំពែងព្រះរាជធានី ។

ដល់ទ្រង់យាងទូលស្ពានខឹងកំដែងក្រុងឬតខៅ ដល់ខៅមាត់ឆ្នេរ ម្ខាង ស្រាប់តែទ្រង់ឮសូរសំឡេងស្រែកយំកន្ធក់កន្ធេញថា "ម្ចាស់ថ្លៃ អើយ ចូរលោកជួយខ្ញុំឆង សូមលោកជួយលើកខ្ញុំឆង ន! ម្ចាស់ថ្លៃ អើយ ជួយខ្ញុំឆង ខ្ញុំមុខជាស្លាប់មុនខៅដល់ឆ្នេរ!" ។ នេះជាសំឡេង មនុស្សខ្ទុគ៌តំម្នាក់ កំពុងវង់ក្រោះដោយជម្ងឺកាឡរោគ (ប៉ែស្ត៏) យ៉ាង សាហាវជិតនឹងស្លាប់ហើយ កំពុងបម្រះនទៀលលើផង់ធូលីដី ប្រឡាក់ ដោយខ្លុះនឹងឈាម មានដំណក់ញើសត្រជាក់ហូរចេញពីថ្ងាស, មាត់ញ័រ ចំប្រប់ ដោយសេចក្តីឈឺចាប់, ឯក្អែកក្រឡឹតក្រឡាប់ប្រាប់ការក្រលៀ ក្រពុយយ៉ាងខ្លាំង ។ គាត់ចំត្រងរយកដៃចាប់ស្មៅខៅផ្លូវ ដើម្បីក្រោក ខ្លឹង ហើយគាន់តែងើបក្បាលខ្លឹង ក៏ដួលស្រូសខៅវិញ ញ័រចំប្រប់ សព្វសរោងគ្រប់កាយ ហើយស្រែកគ្រលួចខ្លឹង គួរឲ្យតក់ស្លុតថា "ហ្អឺ! ឈឺចាប់អ្វីម្ល៉េះ! លោកសប្បុរស អាណិតជួយខ្ញុំឆង!" ។ (ខាងមុខ)

កិត្តិ សួន-សូន្ធ រ៉ៃវ៉ង្សា
(ពនក-ចប់)

លេចក្តីថ្លែងអាល័យ

អ្នកអាចារ្យ ! យើងមានសេចក្តីអាឡោះអាល័យសោកស្តាយអ្នកអាចារ្យឥតមានភ្លេច ដែលធ្លាប់មានឧបការៈដល់គ្នាទៅវិញទៅមក កាលយើងទើបមកបួសនៅវត្តនេះ ឥតមានស្គាល់នរណាសោះ មានតែអ្នកអាចារ្យនេះហើយឧបត្ថាកបំរើយើងដោយកិច្ចវត្តមិនមានជិនឆ្អន់ក្នុងគ្រាដែលទៅជានវកកិក្ខុ យើងស្គាល់កិរិយាមារយាទអ្នកពីតឹមនោះមកថាជាមនុស្សប្រដៅងាយ មនុស្សដូចអ្នកនេះដូចគ្រាប់ឈើល្អ បើបណ្តុះមុខជានឹងបានផល ។ កាលគ្រូអនិច្ចធម្មទៅ មាតាបិតាអ្នកកាត់ខោអាវមកធ្វើកអ្នកពីសាមណេរ ព្រោះគាត់ទៅរកទ្រួលទានឆ្ងាយ ក្រែងឈឺចាប់ពុំមាននរណាថែរក្សា យើងមានសង្ឃឹមថា វិជ្ជា ព្រះបរិយត្តិ-ធម៌ដែលអ្នកបានសិក្សាហើយ នឹងបានឆ្លងទៅអនាគត គ្រូអនិច្ចធម្មទៅ រូបអ្នកដូចគំពាំងស្នងឫស្សី ទើបយើងទ្រួលការៈពីមាតាបិតាអ្នកបកថែរក្សាដូចជាកូន អ្នកចង់ចេញទៅរៀនស្រុកក្រៅ ក៏ដឹកនាំឲ្យទៅរៀន លុះរៀនបានសំរេច ក៏ទ្រួលមកបង្ហាត់បង្ហាញជំនួសគ្រូដូចបំណង ។ រត្តញ្ញូពោធិ៍ឥតពីដើមស្តុកដោយពៃរីហារកុដិសាលាក៏ខ្វះគ្រែមានអស់ បានអ្នកជាកំឡាំងដៃស្តាំ គ្រូសុត្តអ៊ឹមជាកំឡាំងដៃឆ្វេង ព្រួតកំឡាំងគ្នា

ដោយសាមគ្គី ញើសហូរតាមខ្លួនអស់គ្នា គ្រូសូត្រអុំមអនិច្ចធម្មទៅ
យើងដូចជាកំបុតដៃឆ្វេង ទុនអ្នកពីដើមការៈខាងបង្ហាត់បង្ហាញ លុះអត់
អំពីគ្រូសូត្រអុំមទៅ អ្នកប៉ែងដំខ្លួសគ្រូសូត្រអុំម ទុនរកមួយដូចជាដៃស្តាំ
នឹងដៃឆ្វេងរបស់យើង អ្នកសឹកចេញចោលយើង អ្នកអង្វរសូមទុលធុរៈចា "បើសឹកទៅក៏ខោតែធ្វើខ្ញុំពុះ" តាមតែយើងហៅប្រើយប់ថ្ងៃតទាស់ អ្នកប្តេជ្ញាចា រកទុលទានឲ្យានឹងទំនុកបំរុងវត្ត ពុំចាអ្នកចាយ៉ាងណា ក៏ឃើញប្រពឹត្តរបស់អ្នកក៏ទៅយ៉ាងខោះ អ្នកសឹកទៅ ៣ ឆ្នាំ ទំរកត្បូងឃ្មុំបាន ដូចជាផញ្ជូនមកទុកជាសាសនសម្បត្តិតាំងអស់ ចែមតាំងដឹកនាំកឃើញអ្នកមកធ្វើជាឧបជ្ឈាយ៍តាមំរើសង្ឃក្នុងវត្តនេះទៀត យើងនឹកដល់សេចក្តីស្មោះសរសេចក្តីល្អរបស់អ្នក សូម្បីអ្នកអនិច្ចធម្ម ៤ ឆ្នាំហើយ ក៏ទៅចាំឥតក្លេច ។ សមដូចពុទ្ធភាសិតចា រូបំ ជីវកិ មច្ចានំ ជាមគោត្តំ ន ជីវតិ រូបរបស់សត្វតាំងឡាយ តែងខ្ចុះគ្រាមគ្រាំគ្រាទៅ, ឯនាមនឹងគោត្តមិនចេះគ្រាំគ្រាសាបសូន្យឡើយ ។

៥- ថ្ងៃ ៦ កើត ត្រង់នឹងថ្ងៃ ៤-៤-៤៩ វេលាព្រឹកប្រគេនយាគូ ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃ ២០០ រូប ។ ម៉ោង ១៨ ប្រជុំញាតិមិត្រសិស្សានុសិស្សនឹងមន្ត្រីភូមិឃុំតាមតាំងសម្តេចព្រះសង្ឃនាយកតាំងពីវគ្គណៈនឹងមន្ត្រីសង្ឃឯទៀត និមន្តអញ្ជើញទៅជាអធិបតី ក្នុងព្រះពន្ធាកំពូនឹងឃ្លាំ ។ មុននឹងបូជាសព គ្រូមសិស្សូ

ចាស់នៃសាលាបង្រៀនប្រចាំខែត្រចាត់ដំបង សំណែងកំឡាប្លែកៗ ទៅមុខ ជាវាំយ័ត ដូនលោកមន្ត្រីខ្មែរ - ឡាវ៉ាំងមើលកំសាន្តចំនួន ១ ម៉ោង រួចហើយទើបព្រះគេដ ព្រះគុណ ព្រះមុនីគោសលមេគណខែត្រចាត់ដំបង ថ្លែងសុន្ទរកថាជាភាសាខ្មែរដូចមានសេចក្តីតទៅនេះ ។

សុន្ទរកថា

ចំពោះមុខសព

សូមពិតពុទ្ធដីកាព្រះចេញពីមុខត្រង់ទាំងឡាយ !

សូមដំរាបលោកអ្នកសប្បុរសទាំងអស់

អ្នកអាចារ្យហ៊ិន - សុជ ដែលពុទ្ធបរិស័ទនឹងបូជារំលាយសពក្នុងខណៈនេះ ជាបុរសម្នាក់ប្រកបដោយសតិបញ្ញា ជាបណ្ឌិតឈ្លាសវាងវៃក្នុងផ្លូវលោកនឹងផ្លូវធម៌ មានសុចរិយានឹងបូតភាពខ្ជិលច្រអូសជាដើម គួរជាទីជ្រះថ្លាពេញចិត្តនៃពពួកពុទ្ធបរិស័ទជាប់ចាន់ដួយ : បគ្គម្ភដោយកំឡាំងកាយនឹងកំឡាំងប្រាជ្ញាក្នុងកិច្ចការសាងទីសេនាសន: មានគុដិសាលានឹងធម្មមន្ទីរជាដើម ហើយចាន់ដួយទំនុកបំរុងការសិក្សាក្នុងព្រះពុទ្ធសាសនាទាំងខាងផ្នែកគន្ថធុរៈ នឹងវិបស្សនាធុរៈដល់ភិក្ខុសាមណេរនឹងឧបាសកឧបាសិកាទាំងឡាយក្នុងវត្តពោធិវ័លនេះ ត្រាតែចាន់ចំរើនរុងរឿងៗមកដល់សព្វថ្ងៃនេះ ។

ព្រះតេជព្រះគុណ !

លោកអ្នកសប្បុរសទាំងឡាយ !

កាលពីថ្ងៃម្សិលមិញនេះ ខ្ញុំព្រះករុណា - អាត្មាភាពបានថ្វែងប្រវត្តិ អ្នកអាចារ្យ ហ៊ិន - សុជ ជាសង្ខេបរួចមកហើយ

ក្នុងឱកាសនេះ ខ្ញុំព្រះករុណា - អាត្មាភាពសូមថ្វែងគុណធម៌ ប្រការខ្លះ នឹងសេចក្តីអាឡោះអាល័យ ចំពោះសពអ្នកអាចារ្យ ហ៊ិន-សុជ យ៉ាងខ្លី ។ ដើម្បីទុកជាទិដ្ឋានុគតិនីធជាទីសណ្តាប់អស់លោកអ្នកសប្បុរស ទាំងឡាយ ។

កិត្តិគុណានិងគុណសម្បត្តិ

អ្នកអាចារ្យ ហ៊ិន-សុជនេះ កាលនៅពីកុមារកំពុងសិក្សាអក្សរសាស្ត្រ ក្នុងសំណាក់គ្រូបាអាចារ្យក្តី មានវ័យរឿងការបំរើនៅឡើងហើយ ឃាន បំពេញឆ្នូសជាសាមណេរក្តី ជាកិច្ចក្តី ដរាបដល់បានបង្ហាត់បង្ហាញសិស្ស គណៈទាំងឡាយក្តី ជាអ្នកមានសន្តានចិត្តធ្ងន់ធ្ងរ ប្រកបដោយខន្តីសោរច្ចៈ នឹងសច្ចៈ ដែលជាគុណធម៌របស់សប្បុរសជាអ្នកមានអាកប្បកិរិយាគួរ ឲ្យស្រឡាញ់គោរពចិត្តនៃគ្រូបាឧបជ្ឈាយាចារ្យ គួរឲ្យជាប់ចិត្តជ្រះថ្លានឹងជាទី គោរពនៃសិស្សានុសិស្សរបស់ខ្លួន ព្រមទាំងសាសនិកជនទាំងឡាយ ។ ដោយសារគុណធម៌ដ៏ប្រពៃថ្លៃថ្លាទាំងនេះហើយ ដែលជាបច្ច័យយ៉ាងសំ-ខាន់ បណ្តាលឲ្យកិត្តិគុណរបស់អ្នកអាចារ្យ ផ្សាយកូនក្រអូបឈ្ងុយឈ្ងប់

សព្វទីរួមទៀតក្រៃជាត់ដំបងតាំងមូល ក្រមាំងទៀតក្រៃជិតខាងខ្ទះឆង ។
ដោយកិត្តិគុណនឹងគុណសម្បត្តិនេះហើយដែលធ្វើកំឡាំងយ៉ាងធំរបស់ខ្ញុំ
ព្រះករុណា - អាត្មាភាព ក្នុងកាលដែលអ្នកអាចារ្យមានជីវិតរស់នៅឡើយ
ព្រោះអ្នកអាចារ្យ ឲ្យានជួយកំឡាំងខ្ញុំព្រះករុណា - អាត្មាភាពខាងផ្លូវសម្ភារៈ
តាំងខាងផ្លូវគំនិត ដួយបំពេញកិច្ចខាងគន្ថធុរៈនឹងវិបស្សនាធុរៈ ដរាប
ដល់កិច្ចការសាងផ្សេង ។ ឲ្យមានរបៀបរៀបរយល្អទៀង ទុកដូចជាដៃ
ស្តាំរបស់ខ្ញុំព្រះករុណាអាត្មាភាពយ៉ាងពិត ។ ។

សេចក្តីថ្វៃងអាល័យ

ព្រះតេជព្រះគុណ!

លោកអ្នកសប្បុរសទាំងឡាយ!

គួរឲ្យសោកស្តាយអ្ហីម្ល៉េះ! គួរឲ្យនឹកស្រណោះអ្ហីម្ល៉េះ! ចំពោះសព
អ្នកអាចារ្យ ហ៊ិន - សុជ នេះ ដែលត្រូវមច្ចុរាជដ៏មានអំណាចយោរយៅ
មកឆ្កាច់ផ្តួលអាយុសង្ខារ ក្នុងកំណត់អាយុ ៤៧ ឆ្នាំ ដែលឆាវំយកពុង
ចំរើនដោយប្រការគាំងពួង ។

តទ្បាវិនេះ យើងបានឃើញតែកើតដំណែលរបស់អ្នកអាចារ្យ មាន
កុដិសាលានឹងធម្មមន្ទីរឆាដើម តំាងរៀបចំតាមឲ្យមានរបៀបរៀបរយ
ល្អម៉ើលនេះគួរសរសើរដល់គំនិតនឹងស្នាដៃរបស់អ្នកអាចារ្យណាស់! ។

នែអ្នកអាចារ្យ ! ប្រសិនបើអ្នកនៅរស់ពានមានជីវិតមកដល់ឥឡូវ
នេះសមអ្នកមានបីតិរីករាយយ៉ាងក្រៃលែង នឹងស្ថានការណ៍បច្ចុប្បន្ន
ហើយមុខជានឹងចំដួយធ្វើការយើងជាកិច្ចការខ្លះខ្លែតពុំខាន ព្រោះ
អំពើដែលអ្នកបានសាបព្រោះមកហើយ ទើបតែនឹងចេញផ្លែផ្កាយើញ
ជាក់ស្តែង ក្នុងពេលនេះឯង ។

អ្នកអាចារ្យអើយ ! ប្លែបើយើងនឹករលឹកស្តាយអ្នក មិនចង់ឲ្យអ្នក
ត្រាត់ប្រាសចាកយើង ប៉ុន្តែដល់ពេលអ្នកត្រូវឈប់សំពាក ដោយអ្នក
បានធ្វើការខ្លាំយហត់ជាប្រយោជន៍ដល់ពុទ្ធសាសនាមកយូរហើយ ហាន
ស្មុគស្មាញត្រូវការឲ្យអ្នកឈប់សំពាក ឲ្យសមនឹងសេចក្តីខ្លាំយហត់របស់អ្នកនៅ
លោកខាងនាយឯណោះ ។ ឯយើងទាំងអស់គ្នានៅខាងអាយឯណោះ
ក៏មានចិត្តសោមនស្សណាស់ ចំពោះការឈប់សំពាកដ៏សុខក្សេមក្សាន្ត
ជានិច្ចនោះ ហើយនៅទុកាសនេះ យើងបានមកជួបជុំធ្វើបុណ្យហៅហាម
រំលាយសពអ្នកជាទីបំផុត ដើម្បីសំដែងឲ្យយើញព័ស្តុតាងនៃសេចក្តី
កតញ្ញូកតវេទី ចំពោះសពអ្នកនឹងគុណធម៌ដ៏ថ្លៃថ្លារបស់អ្នក ។ ហេតុ
ដូច្នេះ យើងសូមទូល សុសលកសីតាងអម្បាលម៉ានេះជូនអ្នកអាចារ្យ
សូមអ្នកអាចារ្យអនុមោទនាទទួលយកចំណែកកុសលនេះចុះ ហើយសូម
ជាបច្ច័យឲ្យបានសំរេចទូវតដ្ឋមនុញ្ញាណ តាមបំណងរបស់អ្នកអាចារ្យ
កុំបីឃ្លាត ។

អ្នកអាចារ្យ ! យើងសូមលាអ្នកហើយ

អ្នកអាចារ្យ ! ក្រុមញាតិមិត្តអ្នកសូមលាអ្នកហើយ

អ្នកអាចារ្យ ! ក្រុមសិស្សានុសិស្សត្រមាំងកវិយា

អ្នក សូមគោរពលាអ្នក លែងបានជួបមុខទៀតហើយ !

ក្នុងទីបំផុតនេះ ខ្ញុំព្រះករុណាគង្វាភាពសូមថ្វែងអំណរអរគុណដោយគោរពចំពោះព្រះថេរានុត្ថេរៈទាំងអស់ មានសម្តេចព្រះសង្ឃនាយកទាំង-ពីរគណៈផងដើម នឹងអស់លោកអ្នកសប្បុរសទាំងឡាយ ដែលបានមិមន្ត - អញ្ជើញមកជួបជុំក្នុងពិធីបុណ្យឈាបនកិច្ចសពអ្នកអាចារ្យ ហ៊ុន-សុជនេះ ហើយសូមអានុភាពនៃកុសលបុញ្ញារាសីនេះ ផ្តល់ន្ធូវតដួងមនុញ្ញា-ផលតាមបំណងគ្រប់ៗ រត្តិន្ទិពាកុំបីឃ្លាតឡើយ ។

លំដាប់អំពីសុន្ធរកថានេះទៅ លោកគ្នន - ង៉ានថ្វែងវិបាកសាសា ជាកំង លុះចប់លោក•កញ្ញាដំនិតព្រះស្តេច (ជ្រាក់ - ជ្រាន) នាំទៀនទៅសូមភ្លើងអំពីសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ ទៅដំកល់លើជ្រាំយ៉ាត ហើយអស់លោកមន្ត្រីខ្មែរ - ជ្រាំងយកធ្លាន់ទឹងទៀនជូបទៅបូជាសព ។ ព្រះសង្ឃ ៤ រូបគង់ចាំទិសទាំង ៤ ហើយចំរើនអសុភកម្មដ្ឋាន ព្រះជាឡាត់ ធម្មមុនី (លី) វត្តបទុមវតីសំដែងធម៌ទេសនាមុខសព ។ តពីនោះ អស់លោកមន្ត្រីខ្មែរ - ជ្រាំងក៏អញ្ជើញត្រឡប់ទៅគេហដ្ឋាន

រៀងៗខ្លួនវិញ ទើបក្រុមញាតិមិត្តនឹងសិស្សានុសិស្ស ព្រមទាំងភរិយាបុត្រលើសអដ្ឋធាតុ ហើយលាងដាក់កងពានប្រាក់យកទៅដំកល់លើតុទៅមុខធម្មាសនា ទើបនិមន្តព្រះសង្ឃចំរើនព្រះបរិត្តលុះចប់និមន្តព្រះតេជព្រះគុណ ព្រះពុទ្ធវង្ស នឹង ព្រះតេជព្រះគុណ ព្រះពោធិវង្ស សំដែងធម្មទេសនាសង្ក្រាយនា ។

៦ – ថ្ងៃ ៧ កើត ត្រង់នឹងថ្ងៃ ៥ - ៨ - ៨៩ វេលាព្រឹកប្រគេនយាគូ ថ្ងៃត្រង់ប្រគេនចង្ហាន់បិណ្ឌបាតដល់ព្រះសង្ឃ ២០០ រូប ហើយដារវៃធូបណ្យជាការស្រេច ។

អំពីតាំងចៅអធិការ

(តមក)

សញ្ញាប័ត្រលេខ ២៥០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
ធឹង - មៅ នាមឆាយា ធម្មត្ថេរ កើតឆ្នាំកុរ អាយុ ៣៨ វស្សា ១៧ ជា
ចៅអធិការ វត្តត្រពាំងគង ឃុំត្រពាំងគង ស្រុកសំរោងទង ខែត្រ
កំពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៥១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
សូរ - មៃ នាមឆាយា ធម្មជោត កើតឆ្នាំមមែ អាយុ ៣០ វស្សា ១០ ជា
គ្រូសូត្រស្តាំវត្តត្រពាំងគង ឃុំត្រពាំងគង ស្រុកសំរោងទង ខែត្រកំ-
ពង់ស្ពឺ ។

សញ្ញាប័ត្រលេខ ២៥២ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
វង់ - ភ័ត . នាមឆាយា បញ្ញាជោត កើតឆ្នាំវក អាយុ ២៩ វស្សា ៩ ជា
គ្រូសូត្រឆ្វេងខេវវត្ត - ឃុំ - ស្រុក - ខែត្រដដែល ។

សញ្ញាប័ត្រលេខ ២៥៣ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ
គាំ - ខៅ នាមឆាយា មុនិយត្ថេរ កើតឆ្នាំចោរ អាយុ ៤៦ វស្សា ២៥
ជាចៅអធិការវត្តបទុមសាគរ ឃុំធ្លកណ្តាល ស្រុកស្រីសន្ធរ ខេត្ត
កំពង់ចាម ។

សញ្ញាប័ត្រលេខ ៨ ចុះថ្ងៃ ៩-៩-៤៨ តាំងលោកគ្រូចាន់-ស៊ី នាមធាយា ខេមរកោ អាយុ ៥៣ វស្សា ៣៣ ជាចៅអធិការវត្តកោះសុខ ឃុំត្រាស្រុកកណ្តាលស្ទឹងខេត្តកណ្តាល ។

សញ្ញាប័ត្រលេខ ៩ ចុះកាលបរិច្ឆេទដដែលតាំងលោកគ្រូ អ៊ុក-អ៊ុម នាមធាយា អគ្គសិរី អាយុ ៦០ វស្សា ៣១ ជាចៅអធិការវត្តធម្មនិយាមឃុំស្នោស្រុកកៃពកប្បាស ខេត្តតាកែវ ។

សញ្ញាប័ត្រលេខ ២៥៤ ចុះថ្ងៃ ព្រហស្បតិ៍ ប្តាំមួយកើតខែកត្តិក ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ង៉ោ-កត់ នាមធាយា តន្ទូជោត កើតឆ្នាំច អាយុ ៣៩ វស្សា ១៦ ជាចៅអធិការវត្តព្រះពុទ្ធឯកភាជ ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ២៥៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ព្រាប-សុប នាមធាយា តន្ទូត្នេរ កើតឆ្នាំជូត អាយុ ៤៨ វស្សា ២៨ ជាគ្រូសូត្រស្តាំវត្តកំពង់ឃ្លាំង ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្តសៀមរាប ។

សញ្ញាប័ត្រលេខ ២៥៦ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ កុយ-ឆួន នាមធាយា បន្ទូសុវណ្ណ កើតឆ្នាំវក អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រឆ្វេងខេវត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៥៧ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ គួ-ជា នាមធាយា ព្រហ្មសារ កើតឆ្នាំច អាយុ ៥១ វស្សា ៣០ ជា

គ្រូសូត្រស្តាំវត្តល្វា ឃុំ កំពង់ឃ្លាំង ស្រុកដំណែក ខេត្តសៀមរាប ។ បេ ។

សញ្ញាប័ត្រលេខ ២៥៨ ចុះថ្ងៃព្រហស្បតិ៍ ៦ កើតខែកត្តិក ឆ្នាំជូតសំរឹទ្ធិស័ក តាំងលោកគ្រូ ហែម - ស៊ូ នាមនាយា សន្តម្មប្បញ្ញោ កើតឆ្នាំច អាយុ ៣៩ វស្សា ១៨ ជាចៅអធិការវត្តព្រៃស្នែត ឃុំព្រៃស្នែត ស្រុកពាមឆ្កឹងខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៥៩ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ញ៉ែម - ណាំ នាមនាយា ផោតប្បញ្ញោ កើតឆ្នាំកុរ អាយុ ៥០ វស្សា ១៥ ជាគ្រូសូត្រស្តាំ នៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦០ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ម៉ប - ខូច នាមនាយា មុនីបញ្ញាផោត កើតឆ្នាំជូត អាយុ ៣៧ វស្សា ១៥ ជាគ្រូសូត្រឆ្វេងនៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។

សញ្ញាប័ត្រលេខ ២៦១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ចាន់ - ណាក នាមនាយា ធម្មសរ កើតឆ្នាំរកា អាយុ ២៨ វស្សា ៨ ជាគ្រូសូត្រស្តាំ វត្តមេលោង ឃុំ ព្រៃស្នែត ស្រុកពាមឆ្កឹង ខេត្តព្រៃវែង ។

សញ្ញាប័ត្រលេខ ២៦២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ មាស - អៃ នាមនាយា សន្តម្មប្បញ្ញោ កើតឆ្នាំមមែ អាយុ ៣០ វស្សា ៧ ជាគ្រូសូត្រឆ្វេងនៅវត្ត - ឃុំ - ស្រុក - ខេត្តដដែល ។ (មានត)

សូមថ្វាយដំណឹង

ការផ្សាយពេលស៍ក្រុមពុទ្ធសាសនបណ្ឌិត្យ ដែលអក់ខានចោះពុម្ព
មកយូរហើយ ដោយខ្វះអក្សរ ទីដ៏ក្រជាស ឥឡូវនេះ ចាប់ផ្តើមចោះ
ពុម្ពបានឡើងវិញហើយ មានសៀវភៅការណាវ: ចាល័, សម្ពន្ធមាលា,
ចាដិមោក្ខសង្ខេប, ពិធីភ្ជុំសមាសសង្ខេបជាភាសាចាក់ងនីងរឿងមួយ
ភាគមួយយប់ជាដើម ដែលគេបានីងចេញពីពេលពុម្ពកន្លងមកនេះ
ហេតុនេះ បើអស់លោកអ្នកប្រាថ្នាចង់បានសៀវភៅដូចមានឈ្មោះខាងលើសូមអញ្ជើញចូលទៅជាវនៅក្រុមពុទ្ធសាសនបណ្ឌិត្យតាមត្រូវការ ។

ក្រុមពុទ្ធសាសនបណ្ឌិត្យ


IMPRIMERIE ROYALE